# រឿង

# ទារុណជួងចិត្ត

## ប្រលោមលោកជីវិត

**និពន្ធ គូរគំនូរ និង រចនាក្របដោយ**

*អ្នកស្រី កែវ ចន្ទ័បូរណ៍*

khmervissal @ yahoo.com

ទាក់ទងទូទៅ

016-318-023

012-774-751

ខែសីហា១៩៩៨

រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO.COM

## ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៌

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្មឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង ស្នេកចាកផុតទៅ
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណាដួងចិត្ត
១៥- រឿង បើសិននៅមានថ្ងៃស្នេក
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្ញើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង សីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីសួនសុបិន
២៦- រឿង ម្លប់អសោក
២៧- រឿង ពិជេន្ទភានុមា
២៨- រឿង ផ្ការីកក្រៅសួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភ្នួងមាលា
៣៦- រឿង វាយោដួងចិត្ត

CHAMBOKEO.COM

ISBN: 99950-79-04-6
9 789995 079048

# វាចាអ្នកនិពន្ធ

អ្នកនិពន្ធបានប្រតិស្ឋរឿង ទារុណដួងចិត្ត នេះឡើង ក្នុងគោលបំណងផ្សព្វផ្សាយនូវវិន័យនិងគំនិតអប់រំល្អប្រពៃ សំរាប់ជូនទៅមិត្ត អ្នកអានដែលជាឪពុកម្តាយ ដើម្បីទទួលយកជាគោលគំនិតណែនាំ កូនចៅ អោយឈោងចាប់យកតម្រេះវិជ្ជាខ្ពង់ខ្ពស់ឧត្តុង្គឧត្តម និង អនាគតរុងរឿងល្អប្រសើរ ។

អ្នកនិពន្ធសូមទទួលយកនូវយោបល់និងមតិរិះគន់ដើម្បីស្ថាបនា និងអភិវឌ្ឍន៍ តាមរយៈអសយដ្ឋានខាងក្រោមនេះ ៖


Pannalai Khmer Vissal
P.O.Box 600279
Saint Paul, MN 55119, USA
Khmervissal@yahoo.com


សូមប្រិយមិត្តអ្នកអានបានទទួលនូវភាពក្សេមក្សាន្តក្នុងដួងចិត្ត វឌ្ឍនសុខ និងសុវត្ថិភាពរៀងរាល់ទិវារាត្រី ។




អ្នកស្រី កែវ ចន្ទ័បូរណ៌
រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

ជូនចំពោះលោកឪពុកជាទីគោរព



សាស្ត្រាចារ្យ **ប៊ុន ថង**

១៩៣២-១៩៧៧

អតីតអគ្គានុរក្ស វិទ្យាល័យអាបយុត បាត់ដំបង

ជូនចំពោះអ្នកម្ដាយជាទីស្រឡាញ់



# អ្នកស្រី កែវ យឿង

អតីតគ្រូបង្រៀន សាលាបឋមសិក្សាវត្តបាឡាត់ បាត់ដំបង
ថតនៅខែ១៣មិនា១៩៩៨ ក្នុងព្រះជន្ម ៦៨ឆ្នាំ

# ជូនចំពោះ

- លោក មេងស្នួងសុវណ្ណធី ជាស្វាមី
- កុមារី សុវណ្ណធីធម្មិកាបារមីបុណ្យ ជាបុត្រី
- លោកឪពុក ប៊ុនថង អ្នកម្តាយ កែវយឿង ប្អូនទាំងបួន ព្រមទាំងក្រុមគ្រួសារ
- លោកឪពុកក្មេក មេងស្នួង និងអ្នកម្តាយក្មេក កូវសាវ៉ាន់ ព្រមទាំងកូនចៅ
- លោកនូសារិទ្ធ និងអ្នកស្រីមេងសុមាលី
- លោកគ្រូ ប៊ុន ឈុននាម និងភរិយា
- លោកគ្រូ ប៊ុនណាំ និងភរិយា
- អ្នកស្រីនៅសារិម វិទ្យុសម្លេងសហរដ្ឋអាមេរិ VOA និងបណ្ឌិតយូគិមទូយ
- សាស្ត្រាចារ្យគិមមាសកូយ រស់សាន់ អួន នឿង និង ចាន់សុខា ។
- លោកគ្រូ លីតាយហុង អ្នកគ្រូ ទូចសារៀង អ្នកគ្រូ កែវសុផុន លោកវើនរស់ អ្នកស្រីប៉ក់ដារិនី
- អ្នកគ្រូមៀចសុខារី វិទ្យាល័យនេតយ៉ង់ បាត់ដំបង
- អ្នកស្រី ប៉ិចសង្វាវវ៉ាន វិទ្យុបារាំងអន្តរជាតិ RFI
- លោកអ៊ិមសុនាថ លោកជិនសៅរិន លោកជាសយនា កាសែតកោះសន្តិភាព
- លោកខូតារាឫទ្ធិ  នាយកកម្មវិធីសម្ធហកម្មអក្សរសិល្ប៍នូហាច ភ្នំពេញ
- សាស្ត្រាចារ្យ យូសុភា មជ្ឈមណ្ឌលគរុកោសល្យខេត្តកំពង់ចាម
- លោកពៅធនវឌ្ឍ លោកឈួនមណី បណ្ណាល័យជាតិកម្ពុជា
- លោកសេនសេង នាយកបណ្ណាល័យមហាវិទ្យាល័យភូមិន្ទភ្នំពេញ
- អ្នកគ្រូស៊ិមចាន់យ៉ា អតិតសាស្ត្រាចារ្យវិទ្យាល័យអ៊ាបឃុត បាត់ដំបង
- លោកសេកសុភា សាស្ត្រាចារ្យសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- អ្នកស្រី ប៉ាល់វណ្ណារីរក្ស អ្នកនិពន្ធ
- លោកពេជ្រ ប៊ុននិន ពុទ្ធិកមហាវិទ្យាល័យភ្នំពេញ
- សាស្ត្រាចារ្យ គ្រូបង្រៀន និងអ្នកនិពន្ធទាំងឡាយ
- និងក្រុមគ្រួសារដែលរងគ្រោះដោយរបបផ្តាច់ការខ្មែរក្រហម ។

CHANBOKEO.COM

# កំណាព្យ

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

# គ្រួសារក្រោមម្លប់ពុកម៉ែ

គ្មានអ្វីកក់ក្តៅជាងជុំគ្រួសារ មាតាបិតានិងបុត្រគ្រប់កាយ
ទោះបីក្រខ្សត់ក៏រស់សប្បាយ ចាកប្រទុស្តរាយទោសៈមោហៈ ។
គ្មានអ្វីត្រជាក់ជាងរស់ក្រោមម្លប់ ម៉ែពុកដណ្តប់រក្សាថ្នមថ្នាក់
ថៃទាំបុត្រស្ងួនធ្លួនមិនឲ្យអាក់ រស់សុខត្រជាក់ភ្ញាក់ម្លប់ពុកម៉ែ ។
គ្មានអ្វីឧត្តមសមស្មើគុណលោក គ្រងកូនពន្លកពុំមានត្អូញត្អែ
ស៊ូលំបាកខ្លួនចិញ្ចឹមហូរហែ កូនចៅផងដែរសុខគ្រប់ៗគ្នា ។
គ្មានអ្វីតម្លៃខ្ពស់ស្មើទឹកចិត្ត ម៉ែឪនៃបនិត្យអស់បុត្រស្ងួនភ្ជា
មិនថាកូនឈឺខិលខូចឬជា ម៉ែពុកអធ្យាស្រ័យអោយជានិច្ច ។
គ្មានអ្វីសុខសាន្តជាងមានម៉ែពុក រស់មង្គលសុខផុតអស់លង់លិច
ឃើញកូនខ្វះខាតម៉ែពុកមិនធ្មេច ជួយកូនជានិច្ចមិនមើលបំណាំ ។
គ្មានអ្វីប្រសើរជាងពាក្យទូន្មាន ពុកម៉ែលោកប្រៀនឲ្យកូនចងចាំ
ប្រព្រឹត្តត្រឹមត្រូវដើរផ្លូវចាកកម្ម ពាក្យលោកផ្តែផ្តាំនាំកូនសុខអើយ ។

CHANBOKEO.COM

# ដើមអំពិល

នឹងថាគេបោចពេលខ្លួនលាស់ត្រួយ ចេញក្តិបមួយរយផ្លែទំមួយពាន់
អ្នកភូមិឡើងបេះធ្វើអាហារលាន់ អំពិលមិនទ្រាន់លាស់ត្រួយថែមទៀត ។
ជាដើមអំពិលមិនខ្ជិលផ្លែផ្កា ទាំងប្រាំងវស្សាបំរើផៅញាតិ
ស្លឹកខ្ចីបួតស្ល ស្លឹកចាស់បុកទៀត ធ្វើថ្នាំអស់ស្ទៀតថ្នមអ្នកកូនខ្ចី ។
បោចណាស់លាស់ណាស់អំពិលដីស្រែ បំរើហូរហែជាតិខ្មែរប្រុសស្រី
មិនខុសអ្នកប្រាជ្ញបំរើតិចអី លាស់ចំណេះថ្មីចែកចាយមិនភ្លាត់ ។
បេះណាស់លាស់ណាស់អ្នកប្រាជ្ញបញ្ចេញ គ្មានថ្ងៃទោម្ទេញទ្រោមដើមប្រាកង
សិស្សតាមបេះបោចគំនិតមរកង ចែកមួយមិនភ្លាត់លាស់ទៀតរយពាន់ ។
គំនិតអ្នកប្រាជ្ញមិនខុសអំពិល រាល់ថ្ងៃមិនខ្ជិលបញ្ចេញសម្ពន្ធ័
លាស់គំនិតថ្មីចែកចាយរួសរាន់ ជាតិខ្មែរលែងភន្ត័ត្បិតពលរដ្ឋប្រាជ្ញ ។

CHANBOKEO . COM

# ទឹកសមុទ្ទនិងទឹកត្រពាំង

សមុទ្ទធំធេងទឹកថ្លាក្រៃ ស្រណោះវិស័យពឹងមិនបាន
ពេលឃ្លានពេលស្រេកបែរអាក់ខាន សមុទ្ទប្រែខានផឹកសម្រន់ ។
ត្រពាំងតូចក្តាត់ទឹកល្អក់ខ្វល់ បែរជានិមលគួរអោយភន្ត័
អ្នកស្រុកដងប្រើពេញភូមិលាន់ រស់រានឃ្លានស្រន់ត្បិតទឹកជា ។
សមុទ្ទដូចមនុស្សអស្សុរស មានបុណ្យសក្តិយសមានទ្រព្យា
ចិត្តវិញជាកំណាញ់មិនធូរធារ នឹងមនុស្សដូចគ្នាសូម្បីមិត្ត ។
រីទឹកត្រពាំងដូចអ្នកបុណ្យ តិចតួចចែកគ្រាន់លៀងជីវិត
មិនមើលបំណាំស្តាំវិបរិត ញាតិផៅឆ្ងាយជិតពឹងពាក់បាន ។
ច្នេះធ្វើសមុទ្ទប្រយោជន៍អ្វី ធំធេងពេកក្រៃតែសាមាន្យ
សូវធ្វើត្រពាំងទឹកកល្យាណ សន្តានរំភើបត្បិតសប្បុរស ។

CHANBOKEO . COM

# រស់គាប់រាប់គួរ

កើតជាទារកចេះត្រឹមយំបៅ ជុះនោមលើភ្លៅក្នុងដៃធ្លួនថៃ
ស្គាល់ត្រឹមជីវិតសុខក្នុងដៃម៉ែ កន្លងហួសខែចូលវ័យកុមារ ។
ចេះដើរចេះរត់ស្រដីឆ្លើយឆ្លង ស្គាល់អស់ប្អូនបងមាតាបិតា
ស្គាល់ផ្លូវទៅរៀនសន្សំសិក្សា ស្តាប់ក្បួនតម្រាម៉ែឪគ្រូប្រៀន ។
លុះចូលយុវវ័យដៃជើងធំធាត់ កម្លាំងធាក់ទាត់ធ្វើការក្លាហាន
សំដីហំហួនប្រាជ្ញក៏បាន ជួនខ្លាំងដល់ហ៊ានតមាត់ចាស់ៗ ។
ក្រោយមកពេញវ័យទទួលខុសត្រូវ ក្លាយជាម៉ែឪកូនចៅពេញផ្ទះ
បែរសម្លឹងក្រោយរអើលខ្លួនណាស់ ធ្វើអ្វីល្អខ្លះគំរូបុត្រផៅ ។
កាលនៅពីក្មេងប្រព្រឹត្តភ្លើតភ្លើន មិនរវល់ច្រើននឹងគិតសខ្មៅ
ក្លាយមេគ្រួសារទើបគិតខុសត្រូវ ភ័យក្រោយពេកកូវផ្លូវអ្វីគួរដើរ ។
ហៅកូនមកប្រៀនអៀនខ្លាចវាដឹង អតីតកាលហ្នឹងយើងខូចមិនស្មើរ
ពិបាកនឹងហារប្រាប់កូនអោយដើរ លាក់ក៏ស្ទាក់ស្ទើរប្រាប់ក៏អាមាស ។
ច្នេះទាន់មានពេលគប្បីគិតគូរ មិនទាន់មានគ្រួកូនច្រើនពោរពាស
ប្រព្រឹត្តផ្លូវល្អគន្លងធម៌ព្រះ ផ្លូវនាំវិនាសចៀសអោយបានឆ្ងាយ ។
ចាកភពទុច្ចរិតស្រីស្រាគ្រឿងញៀន ចៀសវាងរំខានញាតិមិត្តទាំងឡាយ
ឱនកាយវាចាចិត្តប្រព្រឹត្តថ្លៃ ពោលពាក្យប្រពៃនាំក្តីភិរម្យ ។
លុះបែរប្រៀនកូនស្ងួនអស់ផងចៅ កត្តិយសខ្ពស់នៅឧត្តុង្គឧត្តម
ឆ្លងបឋមវ័យយុវវ័យស្ងួនសម ឈានដល់ចាស់ទុំរស់គាប់រាប់គួរ ។

អ្នកស្រី កែវ ចន្ទ័បូរណ៍

CHANBOKEO.COM

# វគ្គទី១

## សញ្ញាបត្រ

ក្រុងសេនផល រដ្ឋមិនិសូតា សហរដ្ឋអាមេរិក ឆ្នាំ១៩៨៨...

ក្រោមស្ទូរទះដែលលាន់រំពង ព្រមទាំងការក្រោកឈរគោរពពីសំណាក់មាតាបិតាសាច់ញាតិនិងភ្ញៀវជាងពីរពាន់នាក់ ក្នុងសាលប្រជុំយ៉ាងមហាសាលមួយនៃមហាវិទ្យាល័យមិនីសូតា និស្សិតបណ្ឌិតនិងអនុបណ្ឌិតកំពុងតែដើរម្តងមួយៗ ឡើងលើវេទិកាតាមលេខ រៀងនិងតាមឈ្មោះដែលសាស្ត្រាចារ្យបានប្រកាស ។ នៅក្នុង ចំណោមនោះមាននិស្សិតនារីជាតិខ្មែរម្នាក់ អាយុជាងសាមសិប កំពុងដើរឡើងលើវេទិកាបណ្តើរជូតទឹកភ្នែកបណ្តើរ ដើម្បីទៅ ទទួលយកសញ្ញាបត្រអនុបណ្ឌិតផ្នែកចិត្តវិទ្យាគ្រួសារ ។

នៅទីធ្លាខាងក្រៅអាគារ ក្រោយពីបញ្ចប់កម្មវិធី...

- នាងយំធ្វើអី និមល ? នេះជាសញ្ញាបត្រអនុបណ្ឌិត សន្លឹកទីពីរ របស់ក្មួយហើយ! គួរណាស់តែក្មួយត្រេកអរ ហេតុអ្វីបែរជាមក អង្គុយយំខ្សឹកខ្សួលដូច្នេះទៅវិញ ?

ស្ត្រីមួយរូបក្នុងវ័យប្រហែលហាសិបប្លាយ មានប្រសាសន៍ទៅរកខេមរនារីដែលទើបទទួលសញ្ញាបត្រអំបាញមិញនេះ ។

- គឺខ្ញុំនឹកទៅដល់ឪពុកម្តាយខ្ញុំណាមីង!

អ្នកស្រីនោះឈ្មោះនៅ ជាអតីតគ្រូបង្រៀនដែលបានឆ្លងកាត់ សម័យខ្មែរក្រហមដែរ ។ អ្នកស្រីរាប់អាននិមលដូចកូនដូនចៅ អញ្ចឹង ។ ថ្ងៃនេះ អ្នកស្រីនៅមួយជួយលើកទឹកចិត្តនិមលដែលបាន ទទួលបរិញ្ញាបត្រជាអនុបណ្ឌិត ជាលើកទីពីរ បន្ទាប់ពីទទួលលើកទី មួយ កាលពីឆ្នាំទៅមិញខាង សង្គមវិទ្យា ។

- ក្រែងម៉ាក់ក្មួយនៅសេនផលនេះតើហ៎ មែនទេ ? ហេតុអ្វីមិន ឃើញគាត់អញ្ជើញមក ?
- ចា៎ស! គាត់មានជម្ងឺត្រូវសម្រាន្តពេទ្យ មិនអាចមកបាន ។ ម្យ៉ាងទៀត អ្នកដែលគួរបានសញ្ញាបត្រមួយនេះគឺឪពុករបស់ខ្ញុំឯ នោះទេ...

CHANBOKEO.COM

- ហ្អ៊ក ? ម៉េចអញ្ចឹង ? ចុះក្រែងឯង ឪពុករបស់ក្មួយបាត់ខ្លួនទៅ
កាលពីសម័យអង្គការខ្មែរក្រហមទៅហើយ មិនមែនទេ ?
- ចាំសមែនហើយ ។ ប៉ុន្តែ ចម្លើយក្នុងសំណៅស្រាវជ្រាវបញ្ចប់
ការសិក្សានោះគឺភាគច្រើនជាគំនិតទាំងឡាយដែលឪពុកខ្ញុំធ្លាប់ ប្រដៅប្រដៅងាស់តឿន
តាំងពីខ្ញុំនៅក្មេង ដូចជាការដោះស្រាយ បញ្ហាដោយមិនប្រើហឹង្សា ក្នុងគ្រួសារឬក្នុងសង្គម...
ការរៀនពន្លត់ កំហឹង... ការរំសាយវិបត្តិក្នុងដួងចិត្ត ការមានអាធ្យាស្រ័យចំពោះគ្នា
ការរក្សាសន្តិសុខសង្គម ដោយរក្សាសន្តិសុខក្នុងគ្រួសារ... ការរក្សា សន្តិសុខគ្រួសារ
ដោយរក្សាលំនឹងក្នុងចិត្តបុគ្គល...

នាងនិយាយផង ស្រក់ទឹកភ្នែកផង ។ អ្នកស្រីនៅក៏យកដៃ
អង្អែលស្មានិមលហើយមានប្រសាសន៍ថា ៖
- នេះល្អហើយដែលក្មួយនៅចាំពាក្យទូន្មានរបស់លោកបាន ហើយ
អាចយកមកប្រើក្នុងសំណៅសិក្សាទៀត មិនដូចកូនចៅខ្លះដែល
មិនព្រមអើពើនឹងឮឬចងចាំពាក្យឪពុកម្តាយប្រដៅនោះទេ.. ដូច្នេះ
សញ្ញាបត្រជាអនុបណ្ឌិតមួយសន្លឹកនេះ ត្រូវបានទៅមនុស្សពីរនាក់ គឺ
ឪពុកនាងបានរង្វាន់មោទនភាពយ៉ាងឧត្តម ចំណែកនិមលជា កូននឹងបានរង្វាន់កត្តិយស
ដោយបានទទួលជោគជ័យប្រសើរក្នុង ការសិក្សា ។

និមលក៏ញញឹមឡើង កាលបើនាងបានទទួលការលើកកម្លាំងចិត្ត
ពីអ្នកស្រីនៅដែលជាភ្ញៀវកិត្តិយសតែម្នាក់គត់ ដែលមកជួយទះដៃ
អបអរសាទរជោគជ័យរបស់នាង ។ ការពិត នាងមានប្អូនៗប្អូន នាក់ និងប្អូនថ្លៃម្នាក់ ។ ប៉ុន្តែ
ជីវិតគ្រួសាររបស់នាងអត្តខាត់ណាស់ ព្រោះពួកគេទាំងនោះ ទើបតែមកដល់អាមេរិកថ្មីៗ ។
ម្នាក់សុទ្ធតែ រៀនផងធ្វើការផង មិនអាចឆ្លៀតឈប់បានងាយៗទេ ។ ហើយបើ ឈប់វិញនោះ
ពួកនាងនឹងអត់ប្រាក់រៀន អត់ប្រាក់រស់ ។ ម្យ៉ាង ទៀត ម្តាយនាងកំពុងសម្រាន្តពេទ្យផង
ម្លោះហើយ និសាជាប្អូន របស់នាងដែលទំនេរមិនបានទៅរៀន ក៏ទៅនៅកំដរបំរើគាត់ មិន
អាចមកចូលរួមពិធីទទួលសញ្ញាបត្ររបស់នាងបាន ។
- និមលអរគុណអ្នកមីងណាស់ ដែលទទួលនាទីជំនួសម្តាយរបស់ខ្ញុំ
មកជួយលើកទឹកចិត្តក្មួយនៅពេលនេះ ។

CHANBOKEO.COM

- មិនអីទេ និមល ។ ឯងជាស្ត្រីគម្រូម្នាក់នៅមិនីសូតាដែលមាន សញ្ញាបត្រខ្ពស់ជាងខ្មែរដទៃជាច្រើន ដែលរត់ពីរបបខ្មែរក្រហមដូច គ្នា ។ មីឯពិតជាមានមោទនភាពណាស់ ដោយបានមកចូលរួមពិធី ចែកសញ្ញាបត្ររបស់ក្មួយ ថ្ងៃនេះ ។

បន្តិចមក អ្នកស្រីនៅក៏លានិមលត្រឡប់ទៅធ្វើការវិញ ។ រីឯ មាណវីយើង ក៏ដើរឆ្លងថ្នល់ ទៅជិះឡានក្រុងដើម្បីទៅមើលម្តាយ នៅមន្ទីរពេទ្យ ។

- ម៉ាក់ បានគ្រាន់បើទេ ថ្ងៃនេះ ?

និមលសួរនិសាដែលជាប្អូនស្រីនៅអង្គុយយាមកំដរម្តាយ ។

- ផ្លូវកាយគ្រាន់បើហើយ តែផ្លូវចិត្តត្រូវការពេលយូរតទៅទៀត ។

រំពេចនោះ យាយមណីជាម្តាយ ក្នុងវ័យក្បែរហុកសិប ក៏បើក ភ្នែកឡើង ស្រដីថា ៖

- ម៉ាក់មិនអីទេ កូន! ពីរបីថ្ងៃនេះទៀត ជាវិញហើយ ។

ការពិត លោកយាយមណី ឈឺរ៉ាំរ៉ៃយូរហើយ ក៏ចូលពេទ្យជា ប្រចាំដែរ ។ ប៉ុន្តែ ជម្ងឺអ្វីក៏ពេទ្យនៅអាមេរិកអាចមានសមត្ថភាព ជួយគាត់បានដែរ វៀរលែងជម្ងឺចិត្តរបស់គាត់ដែលមានសភាពធ្ងន់ ធ្ងរ ពិបាកនឹងព្យាបាល ។ លោកបណ្ឌិតសតិវិទូ បានប្រាប់និមលនិង និសាថា ជម្ងឺរបស់គាត់មិនងាយធូរស្រាលទេ គឺត្រូវប្រើពេលយូរឆ្នាំ ណាស់ ។ ការពិត លោកយាយមណីមានវិបត្តិតាំងពីលោកគ្រូសុធីជា ស្វាមី បានត្រូវអង្គការខ្មែរក្រហមចាប់បំបែកយកពីគ្រួសារទៅតាំង ពីឆ្នាំ១៩៧៥នោះមកម្ល៉េះ ។

នៅឆ្នាំ១៩៧៨ និមលបានរត់មកដល់ជំរំហើយបានចេញមករស់ នៅអាមេរិកមុនគេ ក្រោយមកក៏បានធានាយកម្តាយនិងប្អូនៗពីជំរំ មកអាមេរិកម្តងមួយៗ ទាល់តែជួបជុំគ្នាវិញអស់នៅរវាងឆ្នាំ១៩៨៤ បាត់តែលោកគ្រូសុធីជាឪពុកតែម្នាក់ប៉ុណ្ណោះ ។ ចំណែកប្អូនចិញ្ចឹម របស់និមល ដែលបានចូលបំរើជាកងយុវនារីខ្មែរក្រហមបដិវត្តន៍ ភូមិភាគពាយ័ព្យនោះក៏បានបាត់ខ្លួនទៅ ដោយគ្មាននរណាម្នាក់ ទទួលដំណឹងថានាងសុខទុក្ខយ៉ាងណាទេ ។

និមលនៅលេងជាមួយម្តាយមួយសន្ទុះ ក៏វិលត្រឡប់ទៅធ្វើការ វិញ ។ ការពិត និមលមានអាយុជាងសាបសិបហើយ តែនាងនៅ លីវមិនទាន់មានគ្រួសារនៅឡើយ ។ ចៃដន្យនាងបានក្លាយជាម្តាយ របស់ក្មេងកំព្រាចំនួន៦នាក់ ដែលនាងធានាមកពីជំរំខាវអីដាង ។

- ស្តាយណាស់ដែលខ្ញុំអាល័យជាប់រៀនដែរ កុំអីខ្ញុំទៅមើលម៉ាក់ ទទួលសញ្ញាបត្រដែរហើយ ។

CHANBOKEO.COM

និដាជាកូនស្រីច្បងអាយុ១៦ឆ្នាំស្រដីឡើង ។ ក្នុងចំណោមកូន ទាំង៦នាក់ មានតែម្នាក់ទេជាក្មេងប្រុស ។ គេរត់មកចោមនិមលសុំ មើលសញ្ញាបត្ររបស់នាង ។ និមលក៏និយាយទៅកាន់កូនៗថា ៖

- ឃើញទេ សូម្បីតែម៉ាក់អាយុជាងសាមសិបទៅហើយហើយថែម ទាំងធ្វើការរាល់ថ្ងៃចិញ្ចឹមកូនៗទៀតផង ម៉ាក់នៅតែអាចរៀនបាន រហូតដល់ថ្នាក់អនុបណ្ឌិត ដូច្នេះ កូនទាំងអស់គ្នាត្រូវខំឡើង ព្រោះ កូនមិនមានភារៈត្រូវចិញ្ចឹមនរណាទេ ក្រៅតែពីខ្លួនកូនម្នាក់ ។ កូន ត្រូវតែដើរអោយបានឆ្ងាយជាងម៉ាក់ ។ ឪពុករបស់ម៉ាក់បានដាស់ តឿនម៉ាក់តាំងពីក្មេង ដូចដែលម៉ាក់ដាស់តឿនកូននៅពេលនេះ ។ សូមកូនយកពាក្យម្ដាយទៅគិត ហើយស្រង់យកគតិណាដែលល្អ សំរាប់ខ្លួនកុំបីខាន ។ កូននឹងឃើញសារប្រយោជន៍របស់គំនិតទាំង នោះ នៅពេលកូនធំឡើង...

កូនចិញ្ចឹមរបស់និមល ភាគច្រើនជាក្មេងដែលវង្វេងបាត់ឪពុក ម្ដាយ នៅសម័យខ្មែរក្រហមបដិវត្តន៍ ឬក៏បាត់នៅពេលរត់មកជំរំ ទល់ដែន ។ ពួកគេសុទ្ធតែជាមនុស្សមានជម្ងឺកាយផង ជម្ងឺចិត្តផង ដោយការព្រាត់ប្រាសគ្រួសារ ប៉ុន្តែគេបានមករស់នៅជាមួយនាង យ៉ាងសុខរមនា ។

នៅចំពោះរូបថតរបស់លោកគ្រូសុធី ដែលដាក់តាំងនៅលើ ជញ្ជាំង ក្នុងបន្ទប់ទទួលភ្ញៀវ និមលអង្គុយស្ងៀមស្ងាត់ ដើម្បីរំលឹក ដល់ឪពុកនាងដែលមិនដឹងថាស្លាប់ឬរស់យ៉ាងណា ។ នៅក្នុងជំរៅ ចិត្ត និមិលតែងតែគិតថា លោកគ្រូសុធីប្រហែលជាបានលាចាក លោកនេះទៅហើយ ប៉ុន្តែចិត្តមួយមិនព្រមទទួលស្គាល់ទេ ថាលោក បានលាក្រុមគ្រួសារទៅ ព្រោះរូបលោក សំដីលោក គំនិតអប់រំ របស់លោកស្ថិតនៅរស់រវើកក្នុងបេះដូងនិមលនិងក្នុងបេះដូងរបស់ គ្រប់ៗគ្នាក្នុងគួសាររបស់នាង រួមទាំងម្ដាយរបស់នាងផង ។

- ប៉ា! កូនបានខំរៀនរហូតដល់បានបរិញ្ញាបត្រជាអនុបណ្ឌិតដល់ ទៅពីរសន្លឹក... នោះគឺដោយសារកូនមានបំណងយកមកចែកគ្នាពីរ នាក់ប៉ាម្នាក់មួយ ព្រោះជោគជ័យដែលកូនទទួលបានថ្ងៃនេះ សុទ្ធតែ បណ្ដាលមកពីគ្រឹះដ៏មាំ ដែលប៉ាបានខំសាងរូបកូនមកទាំងចិត្តគំនិត ទាំងប្រាជ្ញស្មារតី ទាំងមារយាទ និងការប្រព្រឹត្តរបស់កូន ។ សូម លោកប៉ាទទួលយកសញ្ញាបត្រមួយសន្លឹកនេះ ពីកូនផង ។

និមលបានយកសញ្ញាបត្រមួយសន្លឹក មកសរសេរឈ្មោះឪពុក នាងពីលើ ហើយក៏យកទៅបិទខ្ទាស់នឹងរូបថតរបស់លោក បន្ទាប់ មកក៏ស្រដីបន្តថា ៖

CHANBOKEO.COM

- មួយសន្លឹកនេះជារបស់ប៉ាហើយ ។ កូនតែងតែឮប៉ាធ្លាប់ពោល
សោកស្តាយដែលប៉ាពុំមានលទ្ធភាពរៀនសូត្រ បានដល់កម្រិតនោះ ព្រោះកាលនោះ
ប៉ាមានជីវិតក្រីក្រផង ហើយមានបន្ទុកច្រើនផង ប៉ុន្តែ ឥឡូវនេះប៉ាក៏បានទទួលហើយ ។
ថ្វីបើប៉ាមិនបានទទួល សញ្ញាបត្រនេះដោយផ្ទាល់ក៏ដោយ ក៏កម្រឹតវិជ្ជារបស់ប៉ា ការចេះ
ដឹងរបស់ប៉ាដែលបានប្រគល់មកអោយកូន កូនក៏យកវាមកប្រើក្នុង
សាលារហូតដល់បានទទួលអនុបណ្ឌិតបរិញ្ញា ដូច្នេះកូនសូមប្រគល់
មួយសន្លឹកនេះជូនប៉ាដោយមោទនភាពយ៉ាងឧត្តុង្គឧត្តមបំផុត ។

និមលពោលខ្សឹបៗ ទាំងទឹកភ្នែករលីងរលោង ។ មែនហើយ !
កត្តាទាំងឡាយដែលជំរុញអោយនាងមានកម្លាំងចិត្តខ្លាំងក្លារហូតសព្វ ថ្ងៃនេះ
គឺសុទ្ធតែជាគំនិតអប់រំទាំងឡាយដែលឪពុកនាងធ្លាប់ផ្តល់ មកឲ្យនាងតាំងពីក្មេងៗមក ។
នាងមិនដែលភ្លេចពាក្យអប់រំទាំង ឡាយដែលឪពុកនាងធ្លាប់ណែនាំទេ ។
នាងធ្លាប់ទាំងបានសរសេរ នូវគំនិតអប់រំល្អៗទាំងនោះទុកទៀតផង ។ ថ្ងៃនេះ នាងបានក្លាយ
ជាបុគ្គលិកយ៉ាងជំនាញម្នាក់ ក្នុងក្រសួងតុលាការមួយនៃរដ្ឋមិនីសូតា សហរដ្ឋអាមេរិក
នាងពិតជាមិនភ្លេចកាំជណ្តើរដំបូង ដែលឪពុក
នាងបានសង់អោយនាងតោងឡើងមកនោះឡើយ ។

ថ្មីៗនេះ អ្នកគ្រូនិមលក៏ចាប់សរសេរចងក្រងនូវអ្វីដែលឪពុក របស់អ្នកគ្រូ ធ្លាប់បានទូន្មាន
ដើម្បីផ្សព្វផ្សាយទៅដល់កូនខ្មែរទាំង ឡាយនៅកម្ពុជាអោយបានទទួលនូវគោលគំនិតរឹងមាំ
និងការលើក កម្លាំងចិត្ត ក្នុងការឈោងចាប់ចំណេះវិជ្ជា សំរាប់អនាគតរុងរឿង ។

នៅឆ្នាំបន្តបន្ទាប់មក អ្នកគ្រូនិមលក៏បាននិពន្ធបោះពុម្ពផ្សាយ សំណេរសិក្សាជាភាសាអង់គ្លេស
សំរាប់មហាវិទ្យាល័យនៅអាមេរិក ផង ផ្សាយសំណេរសំរាប់សហគមន៍ខ្មែរនៅក្នុងរដ្ឋផង
សំរាប់វិទ្យុ សម្លេងខ្មែរផង និងបោះសំណេរសិក្សាជាភាសាខ្មែរ ដូចជាអត្ថបទ សិក្សា
សៀវភៅកំណាព្យនិង ប្រលោកលោកអប់រំ ជាភាសាខ្មែរ
សំរាប់បោះពុម្ពចែកចាយនៅកម្ពុជាផង ។

oooooooooooooooooooo

oooooo

o

# វគ្គទី២
# ពាក្យទូន្មាន

ជំនាន់សង្គមរាស្ត្រនិយម...

ភូមិក្រោយភាស៊ី ផ្សារលើ ក្រុងបាត់ដំបង ...

ត្រុងត្រាំងៗ ! ឈូ !

សូរសៀងប៉ោតទង្គិចមាត់ពាងនិងសម្លេងទឹកធ្លាក់ចូលពាងបាន ធ្វើអោយកុមារីនិមលភ្ញាក់ទាំងព្រហាមតែម្តង ។ នាងស្ទុះងើបមើល នាឡិកាឃើញម៉ោង៦ភ្លឺស្រាងៗ ក៏លាត់មុងចេញមកបើកបង្អួច មើលទៅខាងក្រៅ ឃើញឪពុកនាងឈ្មោះសុធីកំពុងយោងប៉ោត ចាក់ទឹកចូលពាង ។ កុមារីក៏ប្រញិបប្រញាប់ដើបចុះដើរមកដី ។

- ភ្ញាក់ហើយហ្ន៎ស កូន ? (សុធីសួរកូនស្រី)
- ចា៎ស ប៉ា !
- អញ្ចឹងកូនលាងអង្ករដាំបបរទៅ ចាំប៉ាបង្កាត់ភ្លើងអោយ ។

សុធីក៏ដាក់ប៉ោតចុះ ស្ទុះទៅចាប់អុសច្រៀកតូចៗ ដាក់បង្កាត់ ភ្លើងភ្លាម ព្រមទាំងវាចាបន្តថា ៖

- ព្រឹកនេះ និមលភ្ញាក់ខ្លួនឯង ឬក៏ភ្ញាក់ដោយនាឡិកាដាស់ ?
- ចា៎ស ប៉ា ! ថ្ងៃនេះជាថ្ងៃអាទិត្យ កូនមិនបានដាក់នាឡិកាឲ្យរោទិ៍ ដាស់កូនទេ ។
- មានន័យថា កូនភ្ញាក់ដោយខ្លួនឯងមែនទេ ? នោះ ល្អហើយណា៎ កូន ដែលចេះភ្ញាក់ងើបឡើងពីព្រឹកដោយខ្លួនឯង មិនបាច់ចាំអោយ នាឡិកាដាស់ ព្រោះគឺជាសញ្ញាដែលប្រាប់ថា កូនមានទម្លាប់ល្អ គេងទៀងពេល ងើបទៀងពេល ។ ចេះភ្ញាក់រលឹកងើបដោយខ្លួន ឯងនូច្នេះ ជាជំហានដំបូងដែលនឹងជួយអោយរូបកូនក្លាយជាមនុស្ស ឧស្សាហ៍ ហើយចេះទទួលខុសត្រូវក្នុងជីវិតបានល្អ ជាពិសេស បំផុតនោះ គឺធ្វើអ្វីដោយមិនបាច់នរណាដាស់តឿនក្រើនរំលឹក !

និមលញញឹម មិនហ៊ានតបអ្វីទៅឪពុកនាងវិញទេ ព្រោះឆវី មិនបានភ្ញាក់ដោយខ្លួនឯងឯណា ។ ការពិត គឺសម្លេងប៉ោតដែល ឪពុកនាងយោងទឹកនោះទេតើ ដែលដាស់នាងនោះ ។ កុមារីទើប តែចូលវ័យ៨ឆ្នាំទេ ធ្វើម៉េចនឹងមានវិន័យ រហូតចេះដើបពីព្រឹក ព្រហាមខ្លួនឯង ដោយមិនបាច់នាឡិកាដាស់នោះ ?

កុមារីលាងអង្ករបណ្ដើរ លួចមើលឪពុកបណ្ដើរ ។ មើលចុះ ! មិននឹងថា សុធីដើបពីម៉ោងប៉ុន្មានទេ យោងទឹកចាក់ពាងធំៗបួន ប្រាំនោះពេញអស់ទៅហើយ ថែមទាំងបោសផ្ទះ ជូតយ៉ាងស្អាត រួចហើយអស់ទៀតផង ។ ផ្ទះរបស់សុធី មានគ្នាច្រើននាក់ណាស់ មានសុធី និងភរិយាឈ្មោះ មណី និងកូនបួននាក់ ព្រមទាំងក្មេងៗ ជាកូនចៅសាច់ញាតិរបស់សុធីនិងមណីទាំងសងខាង ។ នៅក្នុង ចំណោមនោះ សុធីចូលចិត្តហៅនាងតូចនិមលមកប្រើច្រើនជាងគេ ទើបនិមលទទួលនូវការទូន្មានពន្យល់ពីឪពុកបានច្រើនជាងអ្នកដទៃ ទៀតទាំងអស់ក្នុងផ្ទះ ។ ថ្វីបើសាច់ញាតិខ្លះដែលរស់នៅជាមួយ គ្រួសាររបស់និមលនោះ មានវ័យចាស់ជាងនាង ច្រើនក៏ដោយ ក៏ សុធីមិនសូវហៅមកប្រើញឹកញាប់ដូចប្រើនាងនិមលជាកូនឡើយ ។ នោះប្រហែលមកពីកុមារីជាកូនស្រីច្បងគេក្នុងផ្ទះទេដឹង ទើបសុធី ចង់ណែនាំបង្រៀនឲ្យនាងឆុសដាលរឹងប៉ឹងជាងគេ ។

ឃើញនិមលលើកឆ្នាំងធំដាក់ទឹកពេញដល់មាត់ ដើរតតេះតតះ ទៅដាក់នៅលើជើងក្រាន សុធីញញឹមហើយប្រាប់កូនស្រីថា ៖

- ឆ្នាំងនេះវាធំខុសមាឌកូនហើយ ។ កូនចាក់ទឹកចេញសិនទៅ ទើបឆ្នាំងវាស្រាល ស្រួលលើកដាក់លើជើងក្រាន រួចហើយសឹមដងទឹកចាក់បន្ថែមតាមក្រោយ ។

និមលភ្ញាក់ព្រើត ធ្វើតាមភ្លាម ឃើញថាងាយដូចប្រសាសន៍ របស់ឪពុកនាងមែន ។ ធិតាក៏នឹកគិតក្នុងចិត្តថា ៖

- សំណាងហើយដែលបានប៉ាជួយប្រាប់ កុំអីតតេះតតះដួលកំពប់ លើចង្ក្រានរលាកដៃជើងអស់ !

បន្តិចមក សុធីក៏ស្រដីបន្តថា ៖

- និមល ! លើកឆ្នាំងអំបាញ់មិញធ្ងន់ណាស់មែនទេ កូន ?

- ចា៎ស ប៉ា !

CHANBOKEO.COM

- នោះត្រឹមតែមួយឆ្នាំងទេ ។ ចុះបើកូនយោងប៉ោតទឹករែកចាក់ ពាងរាប់ពាងទៀត តើធ្ងន់ប៉ុនណាទៅ ?
- ពិតជាធ្ងន់ជាងឆ្ងាយណាស់ ចាស!
- ហ្នឹងហើយ! ចុះបើសិនជាយើងធ្វើកម្មករលីសែង ធ្វើការរោង ចក្រ ទូលនំលក់ រែកត្រីលក់ រាល់ព្រឹករាល់ថ្ងៃវិញនោះ តើធ្ងន់ យ៉ាងណាថែមទៀតទៅ កូនដឹងទេ ?
- ចាស ពិតជាធ្ងន់ហើយនឿយហត់រកគ្មានទេ!
- អញ្ជឹង កូនត្រូវខំរៀនណា! បើសិនជាកូនមិនខំរៀនទេ កូន ច្បាស់ជាល្វិតល្វង់ ក្រីក្រ ធ្វើការនឹងកម្លាំងធ្ងន់ៗដូចកូនយោងឆ្នាំងធំ ដូចប៉ាយោងទឹកចាក់ពាងអញ្ជឹង ។ វិជ្ជានឹងនាំអោយកូនមានវាសនា អនាគតភ្លឺស្វាង មិនបាច់មកប្រើកម្លាំងធ្វើការធ្ងន់ៗយ៉ាងហត់នឿយ រាល់ព្រឹករាល់ល្ងាច ដើម្បីចិញ្ចឹមជីវិតឡើយ ។

ពេលនោះ និមលយល់តិចៗដែលឪពុកមានប្រសាសន៍ប្រាប់ តែក៏ឆ្ងល់ណាស់ដែរ ថាហេតុអ្វីឪពុករបស់នាងមានវិជ្ជាខ្ពស់ បានធ្វើ ការជាគ្រូបង្រៀន បែរជានៅយោងទឹក ដូតផ្ទះ បោកខោអាវ ដោយខ្លួនឯងអោយហត់នឿយដដែលអញ្ជឹង ? គ្រាន់តែបែរឃើញ ក្រសែភ្នែករបស់កូនស្រី សុធីយល់ជំរៅចិត្តនាងភ្លាម រួចមាន វាចាបន្ថែម ពន្យល់នាងតូចថា ៖
- ប៉ាធ្វើការនឿយហត់ក្នុងផ្ទះយើង ក៏ព្រោះម៉ាក់កូនទើបសម្រាល កូនខ្ចីហើយ មិនអាចធ្វើកិច្ចការអ្វីបានទេ ។ ឯប៉ាចិញ្ចឹមកូននិងញាតិ ច្រើននាក់នៅក្នុងបន្ទុក ដូច្នេះប៉ាត្រូវតែសន្សំសំចៃ គ្មានកម្រៃសល់ សំរាប់ជួលគេឲ្យមកធ្វើការបំរើផ្ទះយើងបានទេ ។ ណាមួយ ប៉ាចង់ សន្សំលុយជួយកូនអោយបានទៅរៀននៅមហាវិទ្យាល័យផង ។ បើ សិនប៉ាគិតត្រឹមតែខ្លួនប៉ានិងជីវិតបច្ចុប្បន្ន ប៉ាអាចរស់ស្រណុកសុខ ស្រួលទៅហើយ ។ តែពេលនេះ ប៉ានៅតែនឿយហត់ ព្រោះប៉ាមិន ចង់អោយកូនៗឆ្លងកាត់ជីវិតអត្តខាត់ខ្វះមុខខ្វះក្រោយដូចរូបប៉ាកាល នៅពីក្មេងនោះឡើយ ។

ពុទ្ធោ! និមលទើបអាយុនឆ្នាំ ទៅចេះគិតឯណាវែងឆ្ងាយដល់ ម្លឹងនោះ ? កុមារីហាក់ដូចជាយល់អត្ថន័យតិចណាស់អំពីអ្វីដែល ឪពុកស្រដីពន្យល់ទាំងឡាយ ។ ប៉ុន្តែ ធិតាស្តាប់ហើយនៅស្ងៀម មិនហ៊ានវាចាសួរអ្វីតទៅទៀតទេ ព្រោះនាងឃើញឪពុកដើបធ្វើ ការហត់ទាំងព្រឹកព្រហាម មិនហ៊ានរំខានអារម្មណ៍របស់ឪពុកអោយ ហ្មូហ្មងទេ ។

CHANBOKEO.COM

រាល់ថ្ងៃអាទិត្យ មួយថ្ងៃបីវេន ម៉ោង៨ ម៉ោង១០ និងម៉ោង២ រសៀល សុធីតែងបង្រៀនសិស្សបីថ្នាក់ផ្សេងគ្នា ដើម្បីយកកម្រៃ ជួយគ្រួសារ ។ ផ្ទះរបស់សុធីជាផ្ទះឈើសង់ខ្ពស់ពីដី ។ នៅខាង ក្រោមផ្ទះ មានដាក់តុរៀនប្រហែល៤០និងក្តារខៀនមួយ សំរាប់បង្រៀនឈ្នួលដល់សិស្សនៅអនុវិទ្យាល័យ ។ រីឯនិមលនៅតូច រៀននៅបឋមសិក្សា ស្តាប់ការបង្រៀនរបស់ឪពុក មិនយល់ឡើយ
ប៉ុន្តែសុធីតែងតែហៅនិមលឲ្យទៅអង្គុយកៀនខាងក្បែរៗ ក្នុងថ្នាក់ជានិច្ចពេលសុធីបង្រៀនសិស្ស ។ កិច្ចការដែលនាងតូចត្រូវធ្វើនៅ ពេលនោះ គឺចម្លងអ្វីសព្វយ៉ាងទាំងអស់នៅលើក្តារខៀន ទុកក្នុង សៀវភៅ ថ្វីបើនិមលមិនយល់ពាក្យទាំងឡាយថាជាអ្វីក៏ដោយ ។ យូរឆ្នាំក្រោយមកទើបនិមលដឹងថា នាងហាក់ដូចមានការយល់ដឹង ចេះចាំអ្វីៗជាច្រើនដោយមិនដឹងខ្លួន ។ លុះនាងប្រឡងចូលរៀននៅអនុវិទ្យាល័យ និមលក៏ចាប់អារម្មណ៍ថា នាងយល់កិច្ចការសាលាអាចធ្វើបានល្អបានរហ័សជាងក្មេងដទៃទៀត រហូតដល់ធ្វើឲ្យធិតាយើងក្លាយទៅជាសិស្សនិស្សិតដ៏ពូកែល្បីឈ្មោះម្នាក់ តាំងពីប្រឡងជាប់ចូលអនុវិទ្យាល័យរហូតរៀងមក ។ ពេលនេះហើយទើបនាងយល់នូវជំរៅចិត្តរបស់ឪពុកនាង ថាហេតុអ្វីលោកអោយនាងនៅអង្គុយស្តាប់លេងៗបណ្តើរពីចម្ងាយ ។

ថ្ងៃបុណ្យចូលឆ្នាំខ្មែរមួយ...

- មើល៎! ទាំងអស់គ្នា! ថ្ងៃនេះ មាននរណាចង់ទៅលេងវត្តខ្លះ ជាមួយចាស់ៗទេ?

សុធីសួរកូនទាំងអស់គ្នា ប៉ុន្តែ គ្មាននរណាហ៊ានលើកដៃទេ មានតែនិមលម្នាក់ឯង ។

- ហ៊្វាក! ហេតុអីគ្មាននរណាចង់ទៅអញ្ចឹង? (សុធីលាន់មាត់)

ការពិត ទាំងអស់គ្នា ទាំងមាមីងក្រមុំកម្លោះរបស់និមល ទាំង ប្អូនៗបង្កើត និងប្អូនៗជីដូនមួយ សុទ្ធតែកំពុងជ្រួលរសើបជើងចង់ទៅលេងបុណ្យនៅវត្តដេកមិនលក់ទៅហើយ តែគ្មាននរណាហ៊ាន វាចាមកក្រៅសោះ ត្បិតខ្លាចប៉ាម៉ាក់បន្ទោស ថាជាក្មេងព្រើលចង់តែដើរលេង ។

- អើ! ក្លាហានណាស់តើហ៎ និមល! បើលើកដៃម្នាក់ឯង ដូច្នេះ បានទៅវត្តជាមួយម៉ាក់ប៉ាហើយ ។ សល់ប៉ុន្មាន ចាំផ្ទះចុះ!

សុធីស្រដីទាំងមុខស្មើ ទំនងចង់សាកចិត្តកូនចៅ ។ ថាហើយ នរៈក្រពាត់ដៃដើរចេញទៅ ។ មាមីងនិងប្អូនៗរបស់និមលក៏នាំគ្នា ធ្វើមុខស្មឿក អន់ចង់ ។ ឪពុកមារបស់និមលម្នាក់រអ៊ូរថា ៖

- ហេតុតែនាងនិមលជាកូនសម្លាញ់របស់ឪពុក ទើបបានចេញដើរ ក្រៅ ឲ្យរាល់តែដង ។

និមលមិនហ៊ានឆ្លើយតបមាមីងរបស់នាងទេ ថ្វីបើអ្វីដែលគេ និយាយដាក់នោះ មិនត្រឹមត្រូវក៏ដោយ ។ ការពិត សុធីអនុញ្ញាតឲ្យ នាងទៅវត្ត ព្រោះនិមលមានសេចក្តីក្លាហានលើកដៃប្រាប់ ថាឆរី កំពុងចង់ទៅវត្តពិតមែន តែអ្នកដទៃខ្វេញកង្វចអណ្តើកមិនហ៊ានវាថា ដូច្នេះអ្វីដែលគេទទួល គឺរួញដីដើរលេងនៅត្រឹមរង្វង់ដីផ្ទះ ។

បន្តិចមក សុធីក៏ត្រឡប់មកវិញ សួរម្តងទៀតថា ៖

- ឥឡូវ ប៉ាសួរម្តងទៀត! តើនរណាចង់ទៅវត្តទេ ?

ម្តងនេះ សាច់ញាតិរបស់មណីម្នាក់ ចាស់ជាងនិមល៦ឆ្នាំ លើក ដៃឡើង តែអ្នកដទៃនៅស្ងៀមដដែល ។ សុធីឃើញហើយ ក៏ ញញឹម តបថា ៖

- ការនៅស្ងៀមចំពោះចាស់ជាការប្រសើរហើយ ព្រោះបង្ហាញថា អ្នករាល់គ្នាគោរពការសំរេចចិត្តរបស់មនុស្សចាស់ ។ ប៉ុន្តែ ពេល ចាស់ៗសួរយោបល់ដល់ទៅពីរដងហើយ មិនព្រមឆ្លើយ មានន័យ ថា នោះមិនមែនជាការគោរពចាស់ទេ តែក៏គឺជាការខ្វះសេចក្តី ក្លាហាននឹងសំរេចចិត្តដោយខ្លួនឯងសំរាប់ខ្លួនឯង និងការខ្វះសេចក្តី ក្លាហាននឹងបង្ហាញនូវអារម្មណ៍ពិតក្នុងចិត្តឲ្យចាស់ទុំដឹង ។ ពេល នេះ ចាស់ទុំគេបានអនុញ្ញាត្តិអោយគិត អោយឆ្លើយដល់ទៅពីរដង អ្នករាល់គ្នានៅមិនព្រមគិត មិនព្រមឆ្លើយទាំងពីរដងដែរ ។ ចុះទំរាំ ដល់អ្នករាល់គ្នាប្រឈមមុខនឹងកិច្ចការធំៗ ឬកិច្ចការបន្ទាន់អាសន្ន វិញ តើអ្នករាល់គ្នានឹងគិតយ៉ាងណា សំរេចចិត្តយ៉ាងណា បើសិនជា គិតយឺត ឆ្លើយយឺត យ៉ាងហ្នឹង ?

រំពេចនោះ ឪពុកមាសាច់ឆ្ងាយរបស់និមលម្នាក់ទៀត អាយុ ច្រើនជាងនិមល ៨ឆ្នាំ ស្រដីឡើងថា ៖

- ជំរាបប្រសាសន៍បាទ! គឺថាខ្ញុំមិនហ៊ានព្រោះខ្លាចបងស្តីអោយ ថា ពួកខ្ញុំជាក្មេងព្រើល មមើល ចង់តែដើរលេង ។

CHANBOKEO.COM

- ហើយចុះក្មេងណាមួយទៅ ដែលមិនចង់ដើរលេងនោះ ? (សុធីស្រដីតប) ថ្ងៃនេះជាថ្ងៃចូលឆ្នាំ ជាពេលដើរលេងសប្បាយ បើអ្នករាល់គ្នាធ្វើកិរិយាអេះអុញ មិនចង់ទៅវត្តដើរលេងនឹងគេ នោះទើបវាគួរអោយឆ្ងល់ !

- ចុះឧបមាថា ពួកយើងឆ្លើយហើយ ស្រាប់តែចាស់ទុំបែរជាស្តី អោយថាពួកខ្ញុំព្រើលវិញនោះ តើគិតយ៉ាងម៉េចវិញ បង ?

- តើចាស់ទុំមួយណាទៅ ដែលថា ការទៅធ្វើបុណ្យនៅវត្តជាភាព ព្រើល ជាពិសេស ពេលចាស់ៗបបួលអោយទៅជាមួយលោក ?

ទាំងអស់គ្នា ឈ្ងោកមុខនៅស្ងៀម ។ និមលបានស្តាប់ការ ពន្យល់របស់ឪពុកឥតចន្លោះ ។ ការពិត សុធីមិនដែលនិយាយអ្វី ប្រដៅអ្វីដោយត្រង់ៗនោះទេ ។ នរៈតែងតែធ្វើជាសំនួរឲ្យត្រិះរិះ ឲ្យពិចារណា រួចហើយកូនត្រូវឆ្លើយបញ្ចេញយោបល់ ។ គេមិន ចូលចិត្តអោយកូនធ្វើតាមទូន្មាន១០០ភាគរយ ដោយមិនយកសតិ ប្រាជ្ញរបស់ខ្លួនមកប្រើនោះឡើយ ។ សុធីចង់អោយកូនរៀនគិត គិតហើយពិគ្រោះជាមួយនឹងនរៈវិញ ដើម្បីនឹងបានដឹងថាតើកូនចៅ យល់ដឹងអត្ថន័យនៃការទូន្មានទាំងឡាយបានកម្រិតណាហើយ...

នៅឯវត្ត...

ទាំងអស់គ្នារត់លេងឈូង លេងអង្គុញ លេងពួន លេងស្តេច ចង់ លេងស្វាងណ្តើមស្លឹកឈើ ចាប់កូនខ្លែង ជាដើមជាមួយអ្នក ភូមិអ្នកស្រុកអ៊ូអរ ។ ស្រាប់តែ សុធីកេះនិមល ខ្សឹបប្រាប់ថា ៖

- បើកូនចង់លេងអោយឈ្នះ កូនស្តាប់តាមប៉ាណ៎! ចូរកូនអង្គុយ សង្កេតមើលគេលេងសិន តើអ្នកដែលលេងឈ្នះនោះ ប្រើទេព កោសល្យយ៉ាងម៉េច ទើបគេលេងឈ្នះ ? ហើយសង្កេតអ្នកចាញ់ ម្តង ថាតើគេភ្លាត់ស្នៀតអ្វីខ្លះទើបគេចេះតែចាញ់ញឹកញយ ? ពេល កូនសង្កេតឃើញហើយ មិនបាច់នាំចម្លើយអោយប៉ាទេ ។ កូនទៅ លេងនឹងគេសិនចុះ ។ ក្រោយពេលបុណ្យចូលឆ្នាំ ចាំយើងពិគ្រោះ គ្នាណ៎កូន! អូហ៍! ប៉ាសូមផ្តាំមួយថា ថ្ងៃនេះជាថ្ងៃចូលឆ្នាំ លេងអី សប្បាយ ក៏លេងទៅ ឈ្នះក៏សប្បាយ ចាញ់ក៏សប្បាយដែរ ព្រោះ ពេលនេះ មិនមែនជាពេលប្រកួតយកពានរង្វាន់ទេ ឮហើយនៅ ?

- ចា៎ស ប៉ា!

មិនថា នៅទីណាកន្លែងណាទេ បើសិនជានិមលនៅក្បែរៗ សុធីតែងតែមានសំនួរ ឲ្យកូនស្រីវិភាគតាមដានរកចម្លើយឲ្យវិញ ជានិច្ច ។ ដំបូង និមលឆ្ងល់ណាស់

CHANBOKEO.COM

ហេតុអ្វីឪពុកនាងចង់ដឹងអ្វីច្រើន ម្ល៉េះ ។ លុះដល់នាងធំពេញវ័យទៅទើបដឹងថា សុធីកំពុងបង្រៀន អោយនាងចេះសង្កេតខុសត្រូវល្អអាក្រក់ និងសង្កេតរកមធ្យោបាយ ដែលអាចនាំរូបនាងស្វែងរកជីវិតជោគជ័យ ។ ឪពុករបស់និមល តែងតែធ្វើដូច្នេះចំពោះកូនគ្រប់ៗគ្នា ខុសគ្នាតែត្រង់ថា តើកូនណា មួយ ហ៊ានយកខ្លួនទៅជិតសុធីញឹកជាងគេ ។ កូនខ្លះមិនសូវ ហ៊ានទៅជិតនរៈញឹកញាប់ទេ ព្រោះខ្លាចខ្លួនឯងរកចម្លើយជូនសំនួរ ឪពុកមិនបាន ណាខ្ជិលតាមដានវិភាគសង្កេតអ្វីៗ ដើម្បីសរសេរ រាយការណ៍ជូនសុធីវិញផង ។

ការពិតនិមលជាក្មេងឈ្លាសវៃ ចូលចិត្តចង់ដឹងអ្វីៗ សព្វយ៉ាង ហើយចូលចិត្តចង់ជំនះនូវពាក្យថា ស្រី...វិលមិនជុំចង្ក្រាន ។ នាង បានប្តេជ្ញចិត្តថា នាងនឹងត្រងត្រាប់ពាក្យឪពុកជាគោល តែនាងនឹង ជ្រើសរើសផ្លូវដើរក្នុងជីវិតដោយខ្លួនឯង ដើម្បីបង្ហាញថា ស្ត្រីក៏ អាចមានសមត្ថភាពមិនចាញ់បុរសទេ ជាពិសេសគឺសមត្ថភាពខាង ប្រាជ្ញនិងគំនិត ។ កាលបើឃើញកូនមានការព្យាយាម សុធីបាន ជំរុញបណ្តុះបណ្តាលកូនស្រីច្បងយ៉ាងអស់ពីសមត្ថភាពរបស់ខ្លួន ។

នៅថ្ងៃមួយ...

នាងតូចនិមលបានលួចទៅសួរឪពុកនាងស្ងាត់ៗនៅពេលដែល សុធីបង្រៀន អំពីរបៀបបោកអ៊ុតខោអាវ ទៅតាមសាច់ក្រណាត់ របៀបហាល របៀបបត់ខោអាវ និងរបៀបព្យួរខោអាវល្អៗ ទុក ក្នុងទូ កុំអោយបាក់ព្លី ។

- ប៉ា! ចុះហេតុអ្វីក៏ប៉ាដឹងអំពីរបៀបបោកអ៊ុត ហ្មត់ចត់ម្ល៉េះ ?
- មកពីប៉ាធ្លាប់ធ្វើអ្នកបំរើហាងបោកអ៊ុតនោះអី ។
- តែខ្ញុំមិនដែលឮប៉ាមានប្រសាសន៍អំពីប្រវត្តិប៉ាសោះ ។
- ចង់ដឹងមែនទេ កូន ?
- ចា៎ស ប៉ា!
- អញ្ចឹង យើងអ៊ុតខោអាវ បត់ខោអាវផង យើងជជែកគ្នាផង ។

តាមពិត ជីវិតប៉ាមិនមែនធ្វើការត្រឹមតែជាគូលីបោកអ៊ុតទេណា៎! នៅមានអ្វីច្រើនយ៉ាងទៀត ដែលប៉ាមិនទាន់បាននិយាយប្រាប់កូន អោយបានដឹងនៅឡើយ ។

- ចា៎ស! ខ្ញុំក៏ចង់ដឹងណាស់! ជាពិសេសទៅទៀត ប៉ាពូកែដុត មាន់ប៉ោតដាក់ទឹកប៊ិបស៊ី ។

CHANBOKEO . COM

- អូហ៍ ព្រោះប៉ាធ្លាប់ធ្វើការ ជួយដាំបាយធ្វើម្ហូបនោះអី ។
- គិតទៅ ប៉ាធ្វើការច្រើនយ៉ាងណាស់ ដល់ទៅបីបួនមុខ...!
- ច្រើនជាងហ្នឹងទៅទៀត មានទាំងកន្លែងល្អ ទាំងកន្លែងមិនល្អ ។
- ម៉េចអញ្ចឹងប៉ា ?
- ព្រោះប៉ាជាកូនកំព្រានោះអី ម្ល៉ោះហើយចេះតែរស់រសាត់អណ្តែត តាមតែដំណើរទៅ ទំរាំរកផ្លូវល្អឃើញ ។
- មានន័យថា ប៉ាធ្លាប់ចូលហ្វូងមនុស្សមិនល្អ ?
- មែនហើយ! តែកាលនោះវាជារឿងដោះទ័លក្នុងជីវិតទេ ។ ការ ពិត មិនមែនប៉ាចង់ក្លាយខ្លួនជាក្មេងមិនល្អទេ ប៉ុន្តែប៉ាគ្មានផ្លូវជីវិត សម្រាប់អោយប៉ាជ្រើសរើសទាល់តែសោះ ។ កាលនោះ អ្នកដែល ចិញ្ចឹមប៉ា គេចង់អោយប៉ាស្ថិតនៅក្នុងភាពល្ងង់ខ្លៅរហូត ដើម្បីឲ្យ គេបានកេងប្រវញ្ច័កម្លាំងរបស់ប៉ា យកជាប្រយោជន៍ធ្វើការអោយ គេដោយឥតកម្រៃឈ្នួល ។
- កូនដូចជា...មិនយល់ទេប៉ា!
- អញ្ចឹងកូនចាំស្តាប់ទៅ ។ ពេលប្អូនៗធំឡើង កូនអាចនិយាយ ប្រាប់គេបាន ថាប៉ារបស់កូនជាមនុស្សមានអតីតកាលយ៉ាងណា ជា ពិសេស រៀនពិចារណាថា តើហេតុអ្វីមនុស្សម្នាក់ត្រូវការរៀនសូត្រ ចេះដឹងអោយបានច្រើនបំផុត ?

នាងតូចនិមលជ្រួញចិញ្ចើម នឹកភ័យផ្ទួចៗក្នុងពោះ មិនដឹងថា ឪពុករបស់នាងមានអតីតកាលអាក្រក់ ឬក៏អភព្វ ឬយ៉ាងណាវិញ ។ តរុណីក៏នៅស្ងៀម ទាញអាវបត់បណ្តើរ ស្តាប់សុធីជាឪពុកនិទាន ប្រវត្តិរបស់លោកប្រាប់នាងបណ្តើរ ។ នោះជាប្រវត្តិដែលនាងបាន ទទួលជាលើកដំបូងពីមាត់របស់ឪពុកនាងផ្ទាល់ ។

មើលទៅ រង្វង់មុខរបស់សុធី ហាក់ដូចជានៅស្តាយពេល វេលាពីអតីតកាល ដែលលោកបាត់បង់ទៅឥតប្រយោជន៍ ដោយ សារមូលហេតុអ្វីម្យ៉ាង ។ ប៉ុន្តែ ភាពញញឹមមួយនៅលើផ្ទៃមុខសុធី ក៏មាននាំមកនូវសេចក្តីសប្បាយរីករាយ ចំពោះមោទនភាពរបស់ ខ្លួនគេដែរ ដែលមាណពបានរកច្រកត្រឡប់មករកជីវិតភ្លឺថ្លា សាជាថ្មីបាននឹងគេវិញ ។

CHANBOKEO.COM

ភ្លាមនោះ និមលក៏ទាញប៉ាកកានិងសៀវភៅមួយក្បាលចេញ មកកត់សរសេរយ៉ាងញាប់ដៃ ពេលឪពុកនាងបរិយាយរឿងរបស់ ខ្លួន ប្រាប់ដល់នាងតូចជាកូន... ធិតាស្ដាប់បណ្ដើរ សរសើរបណ្ដើរ មានកាលក៏លួចយកដៃជូតភ្នែករបស់នាង ម្ដងៗ...

*oooooooooooooooooooo*

*ooooo*

*o*

CHANBOKEO .COM

# វគ្គទី៣
## បណ្ណាសាព្រហ្មលិខិត

មង្គលបុរី បាត់ដំបង ឆ្នាំ ១៨៣០...

ក្នុងចំណោមបងប្អូនប្រុសបួននាក់ កុមារសុធីជាកូនពៅរបស់ ប្ដីប្រពន្ធជាតិចិនកន្ដាំងមកពីក្វាងទុង រត់ភៀសខ្លួនចូលមកស្រុក ខ្មែរ ដោយសារគេចឃ្មៀបសង្គមសាហាវរបស់ចិនដីគោក ។ ម្ដាយ របស់សុធីបានអនិច្ចកម្មទៅ តាំងពីកុមារយើងមានអាយុប្រហែល ពីរខួបប៉ុណ្ណោះ ។ ចំណែក ឪពុករបស់សុធីវិញបានធ្វើមរណកាល ទៅ ពេលសុធីចំរើនចូលវ័យប្រហែលបួនឆ្នាំ ។

កូនប្រុសច្បងបង្អស់ឈ្មោះយីង មានអាយុច្រើនជាងកុមារសុធី ជិត៣០ឆ្នាំ កើតនៅប្រទេសចិន មានប្រពន្ធកាត់ចិនយួន មានកូន ស្រីមួយដែលមានវ័យក្មេងជាងសុធីប្រហែលជា២ឆ្នាំ ។ ចំណែកបង ប្រុសទីពីរឈ្មោះ យ៉ាង កើតនៅស្រុកខ្មែរ មានវ័យចំណាស់ជាង សុធីប្រហែល១៨ឆ្នាំ ធ្លាប់បានរៀនសូត្របន្តិចបន្តួច រួចក៏ស្មគ្រ័ ចូលធ្វើទាហានរាជការខ្មែរតូចតាច ។ ។ បងប្រុសទីបីមានឈ្មោះថា យេង មានមុខរបរជាអ្នកលេងភ្លេងល្ខោនបាសក់ ។

រីឯកុមារសុធីវិញមានឈ្មោះកំណើតថា ហ្វាងយូ ហៅធី(ទ្វី) ។ តាំងពីម្ដាយឪពុកស្លាប់ទៅ កុមារសុធីក៏រស់បានមករស់នៅជាមួយ បងប្រុសច្បងនិងបងថ្លៃស្រី ដែលរកស៊ីបើកកុងស៊ីបញ្ជាំផង បើក ហាងបោកអ៊ុតផង ហើយមានបើកហាងលក់បាយ នៅផ្សារមង្គល បុរីបាត់ដំបងផង ។ ទាំងអស់នោះសុទ្ធតែជាទ្រព្យកេរ្ដិ៍បន្សល់ពី ឪពុកម្ដាយ នៅមុនពេលលោកចែកឋានទៅ ។ ប៉ុន្ដែ បងទាំងពីរ ជាមនុស្សកំណាញ់ម៉ៅស្និត អាត្មានិយមណាស់ ជាពិសេសប្រពន្ធ របស់បងប្រុសច្បងតែម្ដង ។ កុមារសុធីមិនដែលបានទៅរៀនសូត្រ ឯណាទេ គ្រាន់តែបានរៀន ចេះអក្សរចិនបន្តិចបន្តួច ហើយចេះ វាយក្បាច់ប្វូកលេខប៉ុនហ្នឹង បងប្រុសនិងបងថ្លៃក៏ឈប់អោយរៀន ដើម្បីទុកកម្លាំងឲ្យមកធ្វើការបំរើក្នុងហាងបោកអ៊ុតរបស់គាត់វិញ ។ បងប្រុសទីពីរទ្រាំនឹងការងារបោកអ៊ុតមិនបាន ក៏រត់គេចពីផ្ទះទៅ ធ្វើទាហានបាត់ ។

CHANBOKEO.COM

រីឯបងប្រុសទីបីវិញ ពូកែលេងភ្លេងគ្រប់ប្រភេទ តាំងពីខ្លុយ ទ្រ ឃឹម គង វាយស្គរម៉ុងសាយជាដើម ។ ប៉ុន្តែ គាត់ ក៏ទ្រាំនឹងជីវភាពកៀបសង្កត់ពីបងប្រុសនិងបងថ្លៃ មិនបានដូចគ្នា ក៏រត់តាមឡានល្ខោនបាសាក់ ដែលដើរសម្តែងតាមភូមិតាមខេត្ត នោះបាត់ម្នាក់ទៀតទៅ នៅសល់តែកុមារសុធីម្នាក់ឯងដែលនៅ តូចជាងគេ មិននឹងជារត់ទៅខាងណា ។

លុះកុមារសុធីចូលវ័យប្រហែល៦ឆ្នាំ បងថ្លៃក៏ប្រសូត្របានកូន ស្រីម្នាក់ ។ ចាប់តាំងពីថ្ងៃនោះមក គេក៏ក្លាយជាឆ្កែកំបែកក្បាល រស់នៅពំនាក់នឹងបងប្រុស ក្នុងឋានៈជាខ្ញុំបំរើដាច់ថ្លៃ ។ រាល់ថ្ងៃ កុមារក្រោកពីព្រហាម យោងទឹកស្ទឹង បោកគក់ខោអាវ កំរាលពូក វាំងនន ដែលភ្ញៀវយកមកបោះឲ្យបោកអ៊ុត នៅហាងហ្វាងយិង ។ គេធ្វើការជាមួយឈ្នួលបំរើប្រុសៗពីរបីនាក់ទៀត មកពីស្រុកស្រែ មិនសូវបានសំរាកទេ ។ ជួនកាល គេក៏ត្រូវរំពាត់បងៗដាំពេញខ្លួន ព្រោះបោកគក់ឥវ៉ាន់មិនបានស្អាត ឬធ្វើការយឺតយ៉ាវជាដើម ជួន កាល គេក៏ត្រូវបងថ្លៃបង្អត់បាយពេញមួយថ្ងៃ ។ ដោយសារភាពចង្អៀតចង្អល់តឹងតែងក្នុងផ្ទះពេក កុមារសុធីក៏បែកប្រាជ្ញដេកនឹក រកមធ្យោបាយជួយខ្លួនឯង ដើម្បីអោយបានចៀសផុតពីការវាយដំ ទាត់ធាក់បង្អត់បាយ ពីបងប្រុសនិងបងថ្លៃ ។

នៅម្តុំជិតខាងផ្ទះ មានបនល្បែងពីរបីកន្លែង ដូចជាបនបាញ់ អាប៉ោង បនសាប់សាម បនចាក់ភ្លៀង និងបនស៊ីសឹក ។ កាល នោះ ផ្ទះបងប្រុសរបស់កុមារសុធី សង់បែរខ្នងចុះទៅក្នុងស្ទឹង ដែលជាហេតុធ្វើឲ្យកុមារយើងចូលគេងពីព្រលប់ រួចភ្ញាក់យប់ជ្រៅ លួចចុះតាមបង្អួចហែលទឹកទៅមើលគេលេងល្បែងជាញឹកញយ ។ គេជាមនុស្សមានប្រាជ្ញមានសំដីរួសរាយ ហើយមានអំណោយទាន ណាស់ ជាពិសេសគឺគេចេះកំប្លុកកំប្លែង ធ្វើឲ្យចាស់ៗសើចក្អាក ក្អួយខ្វាយទឹកមាត់ពេញភូមិ ។ រាល់ឆ្នាំ គេតែងតែទៅលេងរាំប៉ាហ៊ី វាយស្គរម៉ុងសាយ ពេលចូលឆ្នាំចិន ឬ បបួលក្មេងៗដូចគ្នា វាយស្គរឡាំចូន ច្រៀងផង រាំផង ពេលណាមានបុណ្យទានក្នុងភូមិ កំដរចាស់ៗម្តុំៗនោះ បានលុយចាយ បានបាយឆ្អែត ឯលិចឯកើត តែអញ្ជឹងទៅ ។ ជួនកាល ទំនេរៗ គេក៏ជួយរត់ទិញបារីស្រា ទិញ បាយទឹកអោយពួកអ្នកលេងល្បែង ។ ពេលបានលុយតុងកាលណា គេក៏យកមកសូកចិត្តអ្នកបំរើឯផ្ទះប៉ុន្មាននាក់ទៀត ដើម្បីអោយពួក បងៗនោះជួយបោកគក់ឥវ៉ាន់ចំណែករបស់នាយ អោយស្អាតហើយ ទាន់ពេលអ៊ុតផង ។ យូរៗទៅ គេក៏រៀនចេះបាញ់អាប៉ោង ចេះ ចាប់តម្រៀបបៀរសាប់សាម ចេះវាយស៊ីសឹក

CHANBOKEO.COM

ចេះឡើងដំបូលផ្ទះ មើលមេឃទាយដំណើរភ្លៀងឲ្យអ្នកស្រុកចាក់ភ្នាល់ ។ ក្រោយមក គេក៏ក្លាយជាកូនជីងបាញ់អាប៉ោងយ៉ាងស្ទាត់ជំនាញឲ្យថៅកែអាប៉ោង ម្នាក់ ។ ថៅកែចាស់នោះស្រឡាញ់រាប់អានរូបគេណាស់ ហើយតែង តែឲ្យលុយគេចាយទាំងដៃៗ ពេលគេបាញ់អាប៉ោងឲ្យថៅកែធ្វើមេ ឈ្នះម្ដងៗ ។

ពេលនេះ សុធីចំរើនវ័យបានប្រហែល១២ឆ្នាំហើយ...

ថ្ងៃមួយ...

- អាធី! (បងយិងហៅ)
- បាទ! (កុមារសុធីឆ្លើយ)
- មកនេះ!

កុមារដើរត្រុនៗទៅជិតបងប្រុសដែលធ្វើមុខមាំ ហើយដែល មានបងថ្លៃស្រីឈរទន្ទឹមនោះ ធ្វើមុខកាច ហាក់ចង់ស៊ីសាច់នាយ ទាំងរស់ ។ ផាំង! បងប្រុសយារដៃទះកំភ្លៀងកុមារយើងយ៉ាង អស់ទំហឹង ធ្វើអោយកុមារវិលខ្លួនខ្វាល់ដួលប្រូសទៅលើក្ដារផ្ទះ ចេញឈាមពីច្រមុះមួយរំពេច ។

- ឥឡូវនេះ ឯងចេះលួចលុយអញយកលាក់ទុកផងហ្អែស?

បងយីងសម្លុត ។

- បាទ! អត់ទេ បង! ខ្ញុំមិនដែលលួចលុយបងទេ (កុមារឆ្លើយ)
- បើឯងមិនបានលួចទេ ចុះលុយមួយរម្ងរធំក្នុងហិបខោអាវរបស់ ឯងនេះ បានមកពីណាដែរ?

ថាហើយ គាត់ក៏បោកដុំលុយមួយដុំដែលចងនឹងកៅស៊ូកងទៅ លើក្ដារផ្ទះភូស ។ កុមារសុធីក្រឡេកឃើញហើយ ក៏ចំណាំបានថាជា លុយរបស់នាយមែន តែគេបេះជាអេះអុញមិនហ៊ានប្រាប់បងប្រុស ទេ ថាលុយនោះគេបានលុយនេះពីវង់ល្បែង លួចសន្សំទុកជាយូរ មកហើយ ។ ឃើញប្អូននៅស្ងៀមមិនឆ្លើយ បងយីញកាន់តែ បានចិត្តតែម្ដង ក៏យកជើងទាត់ធាក់ប្អូនប្រុសពីរបីជើងទៀត យ៉ាង ដំណាំ ៖

- ឯងមិនហ៊ាននិយាយ បានន័យថា ឯងពិតជាលួចលុយអញពិត មែន ។ ពីដើម បងថ្លៃឯងប្រាប់អញ អញមិនដែលជឿទេ ប៉ុន្តែ ពេលនេះអញជឿហើយថាប្អូនរបស់អញមានដៃមានជើងពិតមែន!

ផាំង! ផាំង! កុមារក៏ត្រូវពីរបីកំភ្លៀងទៀតយ៉ាងធ្ងន់ពីបង ប្រុសរបស់ខ្លួន ធ្វើអោយគេវិលខ្វាល់ដួលលើក្ដារផ្ទះជាលើកទីពីរ ។ ដោយទ្រាំទ្រនឹងកម្លាំងដៃបងប្រុសមិនបាន គេក៏សន្លប់បាត់ស្មារតី ទៅ ។ មិនដឹងអស់ប៉ុន្មានម៉ោងទេ ពេលកុមារភ្ញាក់ឡើង ឃើញ

CHIANBOKEO.COM

យប់ងងឹតឈឹង ។ គេដើបទៅរោងបាយ រាវដៃកកេះអុជចង្កៀង ឡើង
រកបាយឃើញមានតែឆ្នាំងដែលលាងស្អាតផ្កាប់ទុកក្នុងរៀវ ។
សុធីត្រូវបង្ខំចិត្តចូលទទួលទានដំណេក ទាំងឃ្លានល្ហេចពោះ ។
យប់នោះ គេគ្រុនក្តៅខ្លាំងណាស់ តែមិនហ៊ានថ្ងូរសូម្បីមួយម៉ាត់
ព្រោះគេខ្លាចមានជើងហោះដៃហើរ មករកខ្លួនគេជាលើកទីពីរ ។ នៅក្នុងមុងកណ្តាច
លើកន្ទេលកក់កញ្ជាស់ សុធីមានអារម្មណ៍ថា ខ្លួនគេកណ្តោចកណ្តែងអ្វីម្ល៉េះ កំព្រាវងាអ្វីម្ល៉េះ
ឈឺចាប់អ្វីម្ល៉េះ រកអ្វី មកប្រៀបស្មើមិនបានឡើយ ។ គេនឹកម្តាយ នឹកឪពុក នឹកដល់គ្រា
ដែលលោកធ្លាប់ថ្នាក់ថ្នម... ថៃដន្យ ជីវិតរបស់គេមិនបានទទួល
ការថ្នាក់ថ្នមពីឪពុកម្តាយបានដល់ត្រើយផង លោកទាំងពីរក៏លាចាក រូបគេទៅ...
- ពុកអើយ! ម៉ែអើយ! ហេតុម្តេចជីវិតកូនវងាម្ល៉េះ ? តើថ្ងៃណា កូននឹងយល់រស្មីជីវិត
ទទួលភាពកក់ក្តៅក្នុងចិត្ត ដូចក្មេងដទៃទៀត ទូទៅក្នុងលោក ? សូមពុកម៉ែជួយប្រាប់កូនផង...!
កុមារសុធីគេងកើយដៃក្នុងមុងតែម្នាក់ឯង ស្វែងរកការយាង
ប្រោសពីព្រះនិងពីវិញ្ញាណក្ខន្ធ័របស់ឪពុកម្តាយ តាមរយៈដំណក់ទឹក ភ្នែករបស់កុមារ
ដែលកំពុងស្រក់មកលួងលោមដួងចិត្តដ៏សែនវងា ក្រៃលែង... កុមារគេងគិតមិនអស់មិនហើយថា
ហេតុអ្វីក៏បង ប្រុសរបស់គេមានចិត្តអន្តរិយ៍ចំពោះប្អូនប្រុសដល់ម្លឹង ? មើលចុះ
គេធ្វើការតាំងពីតូច រហូតវ័យជំទង់ មិនដែលបានចូលរៀនសូត្រ អ្វីនឹងគេទេ...
រីបាយវិញក៏មិនដែលបានបរិភោគពេញពោះ... ម្ល៉ៅៗ គេខំធ្វើការព្រឹកល្ងាចៗយ៉ាងពេញទំហឹង
គ្រាន់តែដួរបាយពីរពេល ក៏បងយឺងហុចអោយទាំងប្រមាថជេរស្តី ត្រូវវាយ ត្រូវទះ ក៏ទះ
ស្រេចតែចិត្តរបស់គេ ។ ទាំងពីរនាក់បងប្រុសនិងបងថ្លៃនាំគ្នាពួន សង្វាតរកសន្សំតែលុយ
ចង់មានចង់បាន រហូតដល់ភ្លេចគិតពីសាច់ ឈាមរបស់ខ្លួនឯងក្នុងផ្ទះ
ដែលនៅសល់តែមួយគ្រាប់...
ព្រហាមឡើង...
កុមារហៅលឆ្លងទឹកស្ទឹងទៅត្រើយម្ខាង ឡើងដើររហូតដល់វត្ត ឫស្សីក្រោក
ទៅថ្វាយបង្គំចៅអធិការនៅទីនោះ យំសម្រក់ទឹក ភ្នែកពេញមួយថ្ងៃ
ដើម្បីទម្លាយនូវការឈឺចាប់នឹងភាពហ្មួហ្មងក្នុង ចិត្តឲ្យធូរស្រាល ។
- អានាងអើយ! ឈប់យំទៅចៅ (ព្រះគ្រូលួងលោម) តាំងចិត្ត តាំងស្មារតីឡើង
កុំអោយចុះចាញ់ជីវិតអោយសោះ ។

CHANBOKEO.COM

កាលបើឃើញកុមារមានទុក្ខគ្រាំគ្រាយ៉ាងទារុណបំផុត ព្រះគ្រូក៏ហុចបាយបាត្រឲ្យឆីសម្រន់គម្លាន ហើយក៏ទូន្មានណែនាំផង លួងលោមផងរហូតកុមារបានធូរស្រាលក្នុងចិត្តមកវិញ ។ រសៀលបន្តិច លោកគ្រូចៅអធិការក៏ចែវទូកនាំកុមារសុធីត្រឡប់ទៅផ្ទះវិញ ព្រោះលោកបារម្ភក្រែងបងប្រុសបងស្រីរបស់កុមារ វាយដំនាយទៀតសា ជាថ្មី ព្រោះគេរត់គេចមិនបានធ្វើការព្រឹកមិញនេះ ។ លុះឃើញ វត្តមានរបស់ព្រះចៅអធិការ បងយើងនិងប្រពន្ធក៏មិនហ៊ានមាត់អ្វី ឡើយ គ្រាន់តែនាំគ្នាឈរសម្លក់កុមារយើង
ដោយក្រសែភ្នែកលៀន
ខ្មៃរតែម្យ៉ាងប៉ុណ្ណោះ ។

ថ្ងៃដន្យ ការវាយដំដាក់ទណ្ឌកម្មរបស់បងប្រុសមិនបានធ្វើឲ្យកុមារយើងបញ្ឈប់សកម្មភាពពីបនល្បែងទេ ត្បិតមានតែទីនោះទេ ដែលគេអាចទទួលសេចក្តីសុខខ្លះៗ ដែលចៅកែចាស់មេអាប៉ោង ម្នាក់នោះស្រឡាញ់សុធី ហើយហុចលុយអោយចាយ ហុចបាយ អោយបរិភោគឆ្អែតៗជានិច្ចជាកាល ។ ជាពិសេស ពេលណាគេ ជួយបាញ់អាប៉ោងអោយគាត់ឈ្នះបានលុយទាំងក្តាប់ៗ គាត់បោះលុយអោយសុធីចាយមិនស្តាយឡើយ មិនដូចបងប្រុសបងស្រីរបស់សុធីទេដែលរិះគំណាញ់ម៉ៅស្វិតហួសហេតុ ។ សូម្បីតែជាមួយ ប្អូនប្រុសរបស់ខ្លួនឯង ក៏គេមិនហ៊ានអោយបរិភោគបរិបូណ៌ដែរ ។

រៀងរាល់យប់ជ្រៅ សុធីនៅតែលួចដើបហែលទឹកទៅបន ល្បែង ជួយបាញ់អាប៉ោង ឬរត់នាំបាយ ចាប់មាន់ពីទ្រុង មកបោច ដុត អាំង ស្ងោរទាំងយប់អាធ្រាតតាមដែលចាស់ៗប្រើ ដូចពីមុនៗ អញ្ចឹង ។ លុះចាស់ៗហុចប្រាក់ឲ្យចាយ គេមិនហ៊ានយកទៅផ្ញើ លោកគ្រូចៅអធិការទេ ព្រោះខ្លាចលោកស្តីបន្ទោសពីរឿងប្រាក់ ដែលរកបានពីបនល្បែង ។ គេក៏សំរេចចិត្តយកប្រាក់ទាំងនោះ រុំ នឹងថង់ប្លាស្ទិក រួចឡើងយកទៅលាក់នៅចុងដូងមួយដែលដុះកៀន ផ្ទះ ។ គេធ្វើដូច្នេះតរៀងៗមក មិនដែលបានជាប់ពិរុទ្ធទៀតឡើយ ព្រោះគេចេះល្បិចឆ្លាតជាងមុន មិនអោយបងប្រុសនិងបងថ្លៃជាន់ កែងចាប់ថ្នាក់បានដូចពីមុនទៀតឡើយ ។

នៅពេលខ្លះដែលសុធីហាក់ដូចជាចាប់ភ្លឹកថា បងប្រុសនិងបងថ្លៃលួចតាមដានសកម្មភាពរបស់ខ្លួន គេក៏បង្អាក់មិនហ៊ានលួចទៅ បនល្បែងឡើយ

CHANBOKEO.COM

ប៉ុន្តែគេយកពេលទៅថ្វាយបង្គំលោកគ្រូព្រះចៅ អធិការវិញ ដើម្បីទទួលបាយបាត្រលោកចំអែតគម្លានជាជំនួស ។ ជួនកាលគេអង្គុយនៅក្នុងវិហារ មុខព្រះពុទ្ធបដិមារ នឹកសង្វេគទៅ ដល់ទឹកចិត្តរបស់បងប្រុសខ្លួនឯងដែលកំណាញ់ទ្រឹស្នូរ កំណាញ់ សែនមហាកំណាញ់! សូម្បីតែសេចក្តីស្រឡាញ់ និងការកក់ក្តៅ ចំពោះប្អូនកំព្រា ក៏គេមិនហ៊ានផ្តល់ឲ្យដែរ កុំថាដល់ទៅអ្វីៗផ្សេង ទៀត ។ ក្នុងមួយជីវិតរបស់គេនោះ កុមារសុធីមានខោអាវតែពីរ បន្លាស់គត់សំរាប់ផ្លាស់ប្តូរ ។ គេពាក់ខោអាវនោះទាល់តែដាចរយ៉ៃ នឹងខ្លួន ទើបបងប្រុសទិញថ្មីយកមកហុចអោយប្តូរ ហើយគាត់ធ្វើ ដូច្នេះរហូតដល់សុធីចំរើនវ័យគម្រប់១៦ឆ្នាំ ។

ថ្ងៃណាក៏សុធីអង្គុយបន់ព្រះ ថ្ងៃណាក៏នាយបន់អង្វរវិញ្ញាណក្ខន្ធ ឪពុកម្តាយ សូមអោយលោកជួយតម្រែតម្រង់ផ្លូវជីវិត អោយគេ បានស្គាល់សេចក្តីសុខ និងការមានអាហារបរិភោគពេញពោះមក វិញ ។ គេបន់សូមអោយគេមានជីវិតរស់នៅក្នុងគ្រួសារដ៏កក់ក្តៅ ហើយមានសេចក្តីស្រឡាញ់ជុំជិត មានញាតិសន្តានទៅមក កុំអោយ ដូចជីវិតសព្វថ្ងៃដែលកណ្តោចកណ្តែង ឥតមានញាតិម្នាក់រាប់នឹងគេ ឥតទីងតទៅទៀតឡើយ ។

ក្រោយមក សុធីបានស្គាល់កូនក្រមុំខ្មែរម្នាក់មានរូបស្អាតបាត សំដីរួសរាយឈ្មោះ ណាលី ។ ដំបូងក្រុមគ្រួសាររបស់ណាលីរស់ នៅក្នុងខ្ទមតូចមួយ ។ ក្រោយមក គេរកស៊ីធូធារ ក៏ទិញដីសង់ផ្ទះ នៅឆ្ងាយពីផ្ទះរបស់បងយីប្រហែលជាមួយគីឡូម៉ែត្រ ។ ឯយុវជន សុធីយើងវិញ តែងតែលួចទៅលេងផ្ទះ ណាលី ជាញឹកញាប់ ត្បិត គេលបប្រតិពទ្ធ័ នាងក្រមុំកូនស្រីរបស់ម្ចាស់ផ្ទះនោះ ។ កាលនោះ ណាលីក៏មានវ័យដំណាលគ្នានឹង នាយសុធីរបស់យើងដែរ ។

ក្រុមគ្រួសាររបស់ណាលីក៏រាប់អានសុធី ហាក់បីដូចជាកូនចៅ ម្នាក់របស់គេដែរ ព្រោះនាយជាមនុស្សឧស្សាហ៍ មានសមានចិត្ត ទូលំទូលាយ ហើយឆ្លាតវៀងវៃ ។ ប៉ុន្តែគ្មាននរណាចាប់ភ្លឹកថា យុវជនយើងលួចពេញចិត្តពេញថ្លើម នឹងកូនក្រមុំម្ចាស់ផ្ទះឡើយ រហូតទាល់តែថ្ងៃមួយ សុធីចូលខ្លួនទៅជំរាបប្រាប់គាត់ដោយត្រង់ៗ តែម្តង ។ បុរសជាឪពុករបស់ណាលីក៏យកដៃរឹតដើមទ្រូង ហួសចិត្ត ព្រោះឃើញនាយនៅក្មេងពេក ៖

- អាធីអើយ! ឯងមានអីមកដាក់ដៃកូនអញ កាលបើឯងត្រឹមជា ក្មេងបំរើក្នុងផ្ទះគេយ៉ាងនេះ ?
(ឪពុកណាលីសួរ)

- បាទ! ពូ! ខ្ញុំនឹងប្រឹងរកជូន អោយតែពូតម្រូវ (សុធី ឆ្លើយតប)
- ហើយចុះចាស់ទុំរបស់ឯងជានរណាដែរ ?
- គឺ ពុកម៉ែខ្ញុំស្លាប់អស់ហើយ សព្វថ្ងៃនៅជាមួយបង បើកកុងស៊ី បញ្ជាំនិងហាងបោកអ៊ុត នៅប្រឡាយហ្លួង ។
- អូហ៍! ឯងត្រូវជាយ៉ាងម៉េច ជាមួយថឹកយីង ?
- បាទ! ជាប្អូនពៅ ។
- បើអញ្ចឹងល្អហើយ! ឯងទៅប្រាប់ចាស់ៗឲ្យមកនិយាយជាមួយ អញសិនមក៉ ចាំអញគិតតទៅទៀត ។

ថៃដន្យ បងប្រុសនិងបងថ្លៃរបស់នាយសុធីនោះមិនមានចិត្ត ទូលាយដល់ម្លឹងទេ ។ ពួកគាត់បែរជាខឹងច្រឡោតនឹងសុធីជាខ្លាំង ពេលឮនាយមកសារភាពសុំអោយទៅជួយដណ្ដឹងកូនក្រមុំគេ ព្រោះ គាត់នឹងត្រូវបាត់បង់អ្នកបំរើដាច់ថ្លៃដូចសុធីម្នាក់នេះ ចេញពីផ្ទះ ទៅ ។ ណាមួយ បើនឹងរើសរកឈ្នួលថ្មីទៀត គាត់ក៏ត្រូវខាតបង់ ប្រាក់ខែថែមទៀតផង ។ ពេលនោះ បងយីងក៏ទាញរំពាត់រកវ៉ាត់ នាយសុធីសាជាថ្មីទៀត ដោយសំអាងថា នាយកំពុងតែភ្លើតភ្លើន វាយមាយនឹងស្នេហា ប្រាថ្នាចង់រត់គេចមិនចង់ជួយការងារនៅហាង បោកអ៊ុតរបស់គាត់ ។

ដោយការភិតភ័យ យុវជនសុធីក៏រត់ទៅរកមេឃុំឬស្សីក្រោកឲ្យ ជួយធ្វើអន្តរាគមន៍ ។ កាលបើកើតមានក្ដីអាណិតចំពោះយុវជន យើងដែលតែងតែជួយមេឃុំដុតដៃដុតជើង ពេលមានបុណ្យទាន ក្នុងភូមិម្ដងៗ មេឃុំនោះក៏ចេញមុខទៅដណ្ដឹងនាងណាលី ជំនួស បងយីងរបស់មាណពយើងទៅ ។ លុះដល់ឪពុកខាងស្រីហារទាម ទារថ្លៃបណ្ណាការ សុធីបានឡើងដើមដូង យកប្រាក់ដែលសន្សំទុក ជាយូរឆ្នាំហើយនោះ មកចាក់អោយខាងស្រីរាប់យកទាំងអស់ ។ ថៃដន្យ ព្រមពេលជាមួយគ្នានោះដែរ ស្រាប់តែមានចាស់ៗមកពី ភូមិផ្សេងទៀតនាំគ្នាចូលមកស៊ើបសួរនាងណាលី អោយទៅកម្លោះ ផ្សេងៗទៀត ។ ពេលនោះ ឪពុកណាលីរីកមុខប៉ុនជញ្ជាំងព្រះវិហារ ដែលដឹងថា កូនស្រីរបស់គាត់មានរូបសម្ផស្សទាក់ទាញកម្លោះៗ អោយមកស៊ើបសួរគ្រប់ទិស ។ គាត់ក៏តម្លើងថ្លៃបណ្ណាការ ដោយ ជ្រើសរើសយកកូន

CHANBOKEO.COM

កម្លោះណាដែលមានលុយដាក់ដៃច្រើនជាងគេ មានវិជ្ជាច្រើនជាង គេមានប្រវត្តិគ្រួសារល្អជាងគេ ហើយក៏មានការ ងារធ្វើត្រឹមត្រូវ កក់ក្តៅចិត្តគាត់ច្រើនជាងគេ ។

ពេលនោះ ពិន្ទុយុវជនសុធីក៏ធ្លាក់ក្នុកមកនៅលេចចុងប៉ូចគេ បង្អស់ ព្រោះនរៈមិនមានតម្រេះវិជ្ជាអ្វីទាំងអស់ ក្រៅពីចេះអក្សរ ចិនបន្តិចបន្តួច ។ ចំណែកលុយសំរាប់ដាក់ដៃខាងស្រីវិញ គេអាច មានល្មមគ្រប់គ្រាន់នឹងបំពេញចិត្តខាងស្រីបាននាគ្រានោះដែរ ខុស ត្រង់តែគេគ្មានមុខរបរអ្វីនឹងអាចចិញ្ចឹមនាងណាលីបាន ពេលរៀប ការរួច ។ ណាមួយទៀត ក្រុមគ្រួសាររបស់ថៅកែយីញ ក៏មិនជួយ ជ្រោមជ្រែងនាយអ្វីបន្តិចសោះឡើយ មិននឹងថានាយត្រូវធ្វើយ៉ាង ណាអោយខាងស្រីគេធ្វន់ចិត្តបាន ។ សុធីនឹកអស់សង្ឃឹមក្នុងចិត្ត ក៏ ដើរទៅអង្គុយសំកុកនៅមាត់ស្ទឹង ដែលគេធ្លាប់ទៅជួយណាលី ដង ត្រី ។ ពេលនោះ ម្តាយណាលីជាតិខ្មែរបានដើរមកជិតសុធីហើយ លួចនិយាយខ្សិបសួរយុវជនយើងថា ៖

- ឯងចង់ធ្វើកូនប្រសារយើងមែនហ្ស៎ស អាធី ?
- ពិតណាស់ មីង!
- បើដូច្នេះ ឯងត្រឡប់ទៅរៀនសូត្រវិញសិនទៅ ។ បើសិនឯង បានធ្វើគ្រូបង្រៀន មានប្រាក់ខែត្រឹមត្រូវ នោះយើងនឹងលើក ណាលីអោយឯងហើយ ។ ពេលនេះ យើងមិនអាចយល់ព្រមបាន ទេ ព្រោះឯងគ្មានអ្វីឲ្យយើងជាឪពុកម្តាយមានការកក់ក្តៅក្នុងចិត្ត សោះ ។ យើងនឹងហើយថាឯងមានចិត្តល្អ មានសេចក្តីព្យាយាម ហើយជាក្មេងឧស្សាហ៍ម្នាក់ ប៉ុន្តែគុណសម្បត្តិប៉ុនហ្នឹង មិនទាន់គ្រប់ គ្រាន់ទេ សំរាប់ឲ្យយើងលើកកូនស្រីអោយ ។ ឯងត្រូវតែមាន ចំណេះវិជ្ជាខ្លះ ហើយត្រូវមានការធ្វើផង ទើបអាចសមរម្យនឹងធ្វើ ជាប្តីរបស់គេបាន ។ ពេលនេះ ឯងទៅដេកគិតវិញសិនទៅ ថាឯង នឹងជួយខ្លួនយ៉ាងណា ដើម្បីអោយខ្លួនឯងមានលំនឹង មុននឹងទទួល យកបន្ទុកប្រពន្ធកូនបាន ? បើជួយខ្លួនមិនទាន់រួចទេ កុំគិតរឿង យកប្រពន្ធមកអោយគេរស់នៅវេទនាតាមឯងធ្វើអី ។

សុធីឮសំដីរបស់គាត់ភ្លាម ស្រាប់តែមានកម្លាំងចិត្តប្រឹស លើក ដៃសំពះលាគាត់ហើយក៏ហាក់ហែលឆ្លងស្ទឹងទៅផ្ទះវិញ ដោយក្តីរីក រាយក្នុងចិត្ត ព្រោះគិតថា គាត់កំពុងតែបើកផ្លូវអោយនាយហើយ ។

CHANBOKEO.COM

ស្នែកឡើង គេក៏រត់ទៅចុះឈ្មោះរៀននៅសាលាបឋមសិក្សាមង្គល ប៉ុន្តែ
ស្រាប់តែលោកគ្រូចាងហ្វាងញញឹមសួរថា ៖

- ហេតុអ្វី ទើបឯងមកចុះឈ្មោះចូលរៀន នៅពេលខ្លួនពេញ កម្លោះដូច្នេះទៅវិញ ?

សុធីសើចញញឹម ហើយឆ្លើយតបលោកគ្រូថា ៖

- ព្រោះខ្ញុំទើបតែភ្ញាក់ពីដេក គឺ..មានន័យថា សុធីធ្លាប់មានគេ
សង្កត់ឲ្យសុធីដេកលក់ក្នុងភាពកម្លៅយូរអើយសែនយូរ ទើបតែ
មានមនុស្សចាស់ម្នាក់មកដាស់ប្រាប់អោយទៅរៀនកាលពីម្សិលមិញ នេះឯង ។
ខ្ញុំដេកគិតមួយយប់ ចង់ដឹងថា តើខ្ញុំត្រូវទ្រាំទ្រទម្ងន់នៃ ភាពល្ងង់ខ្លៅតទៅទៀតឬក៏យ៉ាងណា ?
ឬក៏ខ្ញុំត្រូវរើបម្រះរកផ្លូវ ដែលធ្វើអោយភ្នែកខ្ញុំភ្លឺ លែងខ្វាក់ល្ងិតល្ងង់តទៅទៀត ? ព្រឹកនេះ
ខ្ញុំគិតថា ខ្ញុំភ្ញាក់រលឹករហូតហើយ មិនព្រមអោយនរណាសង្កត់
រូបខ្ញុំអោយដេកលក់ក្នុងភាពល្ងិតល្ងង់កម្លៅ ដូចគ្រាមុនតទៅទៀត ឡើយ ។
ខ្ញុំត្រូវតែស្វែងរកអនាគតភ្លឺស្វាង មិនឲ្យមនុស្សចាស់ មនុស្សក្មេង ណាមួយ
ខកចិត្តនឹងសុធីទៀតទេ ។

មនុស្សចាស់មនុស្សក្មេងដែលសុធីនិយាយពេលនោះ គឺសំដៅ
ទៅលើឪពុកម្តាយណាលីនិងណាលីតែម្តង ។ រំពេចនោះ លោកគ្រូ សួរបញ្ជាក់ទៀតថា ៖

- នេះឯងអាយុ១៦ឆ្នាំហើយ បើចូលរៀនមែននោះ ឯងច្បាស់ជា
ត្រូវអង្គុយក្នុងថ្នាក់ជាមួយក្មេងតូចៗ ដែលមានអាយុតិចជាងឯង ច្រើនឆ្នាំ ។
តើឯងមិនខ្មាសពួកវាទេ ហ្ន៎ស ?

- លោកគ្រូកុំមានប្រសាសន៍បំបាក់ទឹកចិត្តសុធីអី (យុវជនយើង ឆ្លើយតបវិញ) សុធីមិនខ្មាសទេ
ព្រោះសុធីកំពុងតែដើរផ្លូវត្រូវ ។

លោកគ្រូចាងហ្វាងឮវាចារបស់យុវជនដូច្នោះ ក៏ញញឹមឡើង រួចហើយក៏សួរឈ្មោះនាយ ។

- ឈ្មោះ ហ្វាងយូ បាទ! (សុធីឆ្លើយ)

- ឯងនៅកាន់កាតជាជាតិចិននៅឡើយ មែនទេ ?

- បាទ! មែនហើយ!

- អញ្ចឹងទៅចុះឈ្មោះធ្វើកាតខ្មែរសិនទៅ ចាំមកចុះឈ្មោះរៀនម្តង ទៀត
ព្រោះសាលាមិនអាចទទួលសិស្សកាន់កាតបរទេសបានទេ ។

CHANBOKEO.COM

សុធីអន់ចិត្តស្រឡេតតែម្តង ដែលសាលាមិនអនុញ្ញាត្តិអោយ ខ្លួនចូលរៀន ។ គេក៏រត់ទៅរកមេឃុំឫស្សីក្រោកអោយជួយធ្វើកាត ថ្មី ។ ទទួលថៃដន្យ មេឃុំនោះមានត្រកូល សុទ្ធ ។ នាយសុធី ក៏សុំយកត្រកូលមេឃុំជានាមត្រកូលរបស់ខ្លួន ហើយក៏ចុះឈ្មោះ ចូលរៀនជាកុមារ សុទ្ធ សុធី ចាប់តាំងពីពេលនោះមក ។

ដោយហេតុថា នាយចូលរៀនសាលាពេញមួយថ្ងៃ មិនសូវបាន នៅផ្ទះជួយធ្វើកិច្ចការបោកអ៊ុតនៅហាងបងយីញ នាយសុធីបានត្រូវ បងប្រុសបងថ្លៃ បង្អត់បាយញឹកញាប់ ដោយសំអាងថា នាយមកផ្ទះ មិនទៀងពេល ទើបកម្មករបរិភោគបាយចោលអស់ ។ ប៉ុន្តែ ដោយការអាណិតស្រណោះរបស់លោកគ្រូចៅអធិការវត្តឫស្សីក្រោក សុធីតែងតែបានទទួលអាហារសំណល់បាយបាត្រ ទ្រាប់ក្រពះរាល់ ថ្ងៃជាជំនួសវិញ ។ សុធីខំរៀនណាស់ ហើយក៏បានលះបង់សព្វ យ៉ាងដែលគេធ្លាប់ប្រព្រឹត្តកាលពីក្មេងអស់រលីង ត្បិតមិនចង់អោយ មានប្រវត្តិមិនល្អជាប់ខ្លួនគេតទៅទៀត ។ ពេលនោះ សុធីលែង ត្រឡប់ទៅរកបនល្បែងទៀតហើយ ថ្វីបើគេនៅស្តាយប្រាក់ដែល ធ្លាប់រកបានពីបនល្បែងនោះយ៉ាងណាក៏ដោយ ។

ដោយការសង្វាតព្យាយាមយ៉ាងមោះមុត សុធីរៀនបឋមសិក្សា បានប្រាំឆ្នាំ ក៏បានប្រឡងជាប់សញ្ញាបត្រ័ បញ្ចប់បឋមសិក្សា ក្នុង រង្វាន់កត្តិយសផង ។ ដំណឹងនេះបានធ្វើឲ្យអ្នកភូមិប្រឡាយហ្លួង និងព្រះគ្រូនៅវត្តឫស្សីក្រោក មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងមហិមា ត្បិតគេទាំងអស់គ្នាមិនដែលគិតពីមុនមកថា នាយសុធីអាចមាន ប្រាជ្ញ រៀនបានជោគជ័យយ៉ាងឆាប់រហ័សដល់ថ្នាក់ហ្នឹងឡើយ ។

កាលនោះ គេអាល័យតែផ្ចង់ស្មារតីនឹងការរៀនសូត្រ គេមិន សូវបានទៅមកផ្ទះណាលីប៉ុន្មានទេ ។ បន្ទាប់ពីប្រឡងជាប់មក សុធី ក៏យកដំណឹងសប្បាយរីករាយនេះ ទៅជំរាបចាស់ៗនៅផ្ទះណាលី ។ ស្រាប់តែឪពុកម្តាយណាលីបែរជាសំដែងទឹកមុខស្មើៗ មិនឃើញ សម្តែងសេចក្តីត្រេកអរចំពោះជោគជ័យរបស់សុធីយើង អ្វីបន្តិច សោះ ។ កំពុងតែជជែកគ្នានោះ មានបុរសសង្ហាម្នាក់ជិះកង់ថ្មី ស្រឡាងមួយឌុបណាលីមកដល់ ។ គ្រាន់តែប្រទះឃើញវត្តមាននរៈ យើងនៅទីនោះភ្លាម ណាលីក៏ថ្លោះទឹកមុខរួចហើយឈ្ងោកមុខដើរ គេចទៅខាងក្រោយផ្ទះបាត់ ដោយមិនមានវាចាអ្វីមួយម៉ាត់រាក់ទាក់ ជាមួយនរៈយើងដូចពីដើមទេ ។

CHANBOKEO.COM

ឯបុរសនោះវិញក៏មិនមានស្រដី សួរអ្វីជាមួយសុធីដែរ ។ គេក៏ចតកង់ទុកកៀនផ្ទះ ហើយក៏ដើរចេញ ទៅតាមពីក្រោយណាលីបាត់ដែរទៅ ។ ភ្លាមនោះ ស្រាប់តែម្ដាយណាលីកេះមាណពយើង ហើយមានប្រសាសន៍ប្រាប់ថា ៖

- សុធីអើយ! អារអន្ទិតហ្នឹងជាកូនប្រសារមីង ប្ដីរបស់ណាលី ។ ការពិតពូមីងមិនបានបង្ខំកូនស្រីទេ តែណាលីវាយល់ព្រមខ្លួនឯង ព្រោះវាថា ឯងទៅរៀនយូរឆ្នាំ មិនដឹងអង្កាល់បានចេញពីសាលា ឡើយ ។ ម្យ៉ាងទៀត វាមិនទុកចិត្តថា ឯងនឹងវិលត្រឡប់មករកវាវិញទេ ពេលឯងរៀនមានសញ្ញាបត្រខ្ពស់ ។ វាបារម្ភថា បើថ្ងៃ ក្រោយ ឯងនូវចិត្តទៅស្វែងរកនារីដែលសក្ដិសមនឹងឯង ជាងវា ពេលនោះវាច្បាស់ជាត្រូវខកចិត្ត ដោយសារការរង់ចាំឯងហើយ ។

ដំណឹងនេះ ប្រៀបហាក់ដូចជារន្ទះបាញ់កណ្ដាលមុខនរៈអញ្ចឹង! ភាពសប្បាយរីករាយកន្លងមកក៏រលាយបាត់ពីបេះដូងរបស់នាយ យើងភ្លាមមួយរំពេច ។ គេភ្ញាក់ស្រឡាំងកាំង និយាយមិនចេញអ្វីមួយម៉ាត់តទៅទៀតឡើយ ។ បន្តិចមក គេក៏សំពះលាម្ដាយរបស់ ណាលី ត្រឡប់គេចចេញមកវិញទាំងរសេះរសោះដៃជើង ។ គេក៏ ត្រឡប់ទៅវត្តឫស្សីក្រោក ស្នាក់នៅកុដិព្រះគ្រូអធិការមួយពេល ។

នៅក្នុងមុងកញ្ចាស់ ក្នុងកុដិព្រះគ្រូ...

សុធីគេងគងថ្ងាសសួរខ្លួនឯងដដែលៗថា ៖

- ហេតុអ្វីជីវិតខ្ញុំ មិនដែលមានថ្ងៃណាជួបភាពគាប់ប្រសើរម្ដងណា សោះ ? អ្វីៗទាំងឡាយក្នុងជីវិតរបស់ខ្ញុំ តែងតែបានមកដោយ លំបាកបំផុតសូម្បីតែការសិក្សា ។ មួយជីវិតនេះ ខ្ញុំប្រឹងតស៊ូណាស់ ប៉ុន្តែ ម្ដេចក៏រូបខ្ញុំជួបប្រទះតែការខកចិត្តយ៉ាងដូច្នេះទៅវិញ ?

ថៃដន្យ គេមិនបានខឹងនឹងឪពុកម្ដាយណាលីទេ ម្យ៉ាងព្រោះ គាត់មានសិទ្ធិលើកកូនអោយទៅបុរសណាក៏បាន អោយតែគាត់ជឿ ជាក់ថា បុរសម្នាក់នោះជាពំនាក់មាំមួនរបស់ណាលី ទៅអនាគត ។ ទីពីរ នរៈមិនបានខឹងនឹងគាត់ដែរ ព្រោះហោចណាស់ គាត់បាន រំលឹកដាស់តឿនអោយនាយវិលត្រឡប់ទៅរៀនសូត្រ សាងអនាគតល្អសំរាប់ខ្លួននាយផ្ទាល់ ។ ទីបី មាណពអាល័យតែរៀនជាប់រហូត មិនសូវបានទាក់ទងនឹងគ្រួសាររបស់ណាលីឡើយ ម៉្លោះហើយ គេ អាចយល់ច្រឡំអំពីរូបនាយខាងផ្នែកណាមិនល្អក៏បានដែរ ។

CHANBOKEO.COM

ថ្វីបើ ពេលនោះសុធីនៅនឹកស្តាយនាងណាលី ប៉ុន្តែក៏ឈប់ស្តាយទៅវិញព្រមជាមួយគ្នាយ៉ាងរហ័សដែរ ព្រោះគេបានគិត ឃើញថា ៖

- នែ៎ សុធីអើយ! ទោះបីជាណាលីរបូតពីដៃរបស់នាយទៅមែន តែឯងនៅមានផ្លូវ មានសំណាងអាចជួបនារីល្អៗនៅនាអនាគត ដែលឯងអាចជ្រើសរើសយកមកជាគូជីវិតបានយ៉ាងសក្តិសមពេល ឯងបញ្ចប់ការសិក្សាជាន់ខ្ពស់នោះទៅ ។ ប៉ុន្តែ បើសិនណាជាឯងបណ្តោយអោយបាត់បង់ការសិក្សាពេលនេះវិញ នោះទើបវាជារឿងដែលគួរសោកស្តាយស្រណោះបំផុត ព្រោះឯងពិបាកនឹងតាមចាប់ យកវិជ្ជាមកវិញណាស់បើសិនឯងបាត់បង់ឱកាសនេះ ។

ភ្លាមនោះ យុវជនយើងក៏ងើបលូនចេញពីមុង ស្រវាដៃកកេះ អុជចង្កៀងរួចទាញប៉ាកកាមួយមកចារ លើក្រដាសមួយសន្លឹកមានសេចក្តីថា "សុធីនឹងមានអនាគតភ្លឺស្វាង!" រួចហើយគេក៏យក ក្រដាសនោះទៅបិទនៅជញ្ជាំងគេងសម្លឹងមើលមិនពព្រិចភ្នែក បន្តិចឡើយ ហើយថែមទាំងលួចញញឹមតែម្នាក់ឯងទៀតផងទំនង រីករាយសប្បាយចិត្តណាស់ ដែលគេនៅមានការសិក្សានិងអនាគតល្អកំពុងរង់ចាំរូបគេនៅខាងមុខ ។ ពេលនោះ គេកាត់ចិត្តពីណាលីបានយ៉ាងជ្រះស្រឡះពីអារម្មណ៍តែម្តង ។

ដោយសារភាពឆ្លៀវឆ្លាតរបស់គេ នាយសុធីក៏បានទទួលរង្វាន់ អាហារូបករណ៍ទៅរៀនបន្តនៅវិទ្យាល័យមុនីវង្សក្រុងបាត់ដំបង ។ គេក៏ត្រូវឃ្លាតមង្គលបុរីមួយពេល ។ សុធីយើងក៏បានទទួលនូវការ លើកទឹកចិត្តយ៉ាងពេញទំហឹងពីព្រះគ្រូចៅអធិការ តាមេឃុំ និងអ្នកស្រុកអ្នកភូមិនៅប្រឡាយហ្លួង វៀរលែងតែក្រុមគ្រួសារបង យីញចេញមួយប៉ុណ្ណោះដែលបែរជាខឹងកាត់កាល់រូបនាយយ៉ាងដាច់ អហង្ការយ៉ាងចម្លែកទៅវិញ ។

មិនយូរប៉ុន្មាន សុធីក៏ឃ្លាតពីមង្គលបុរី ទៅបន្តការសិក្សានៅ វិទ្យាល័យមុនីវង្សបាត់ដំបងផ្សងព្រេងក្នុងពិភពដែលខ្លួនមិនដែល ស្គាល់ តែម្នាក់ឯង ។ រៀងរាល់ថ្ងៃគេតែងតែសរសេរក្រដាស ទូន្មានខ្លួនគេ រាល់ៗព្រឹកថា ៖

- យើងជាកូនកំព្រា មិនមានចាស់ទុំថែរក្សា អប់រំ ណែនាំរូបយើង ទេ ដូច្នេះយើងត្រូវតែរៀនណែនាំខ្លួនឯង ត្រូវតែរៀនស្តាប់ ចាស់ៗដែលមានបំណងល្អលើយើងដើម្បីត្រងយកគំនិតរបស់គាត់ មកបណ្តុះបណ្តាលខ្លួនយើងអោយប្រសើរ ។ បើយើងរៀនស្តាប់កាន់តែច្រើន យើងនឹងបានទទួលគំនិតប្លែកៗក៏កាន់តែច្រើនហើយ

CHANBOKEO.COM

យើងយកមកអនុវត្តន៍នូវគោលគំនិតណា ដែលជំរុញអោយយើង
ឈានទៅរកអនាគតរុងរឿងជោគជ័យឆាប់រហ័ស តាមផ្លូវសុចរិត បំផុតផង ។
យើងនឹងធ្វើអោយពិភពលោកដឹងថា ថ្វីបើយើងជា កូនកំព្រា
តែយើងមិនបណ្តោយជីវិតខ្លួនអោយរស់តាមយថាកម្ម ទេ ។ សំណាងពិតជាមិនរត់រកយើងឡើយ
បើសិនណាយើងមិន ចេញតាមស្វែងរកចាប់វា ។ ពេលនេះ យើងនឹងចេញតាមចាប់
ព្រេងសំណាងនោះ ។ យើងនឹងបង្ហាញអោយអ្នកទាំងឡាយឃើញ ថា
យើងពិតជាទទួលជោគជ័យក្នុងជីវិតដោយស្នាដៃនិងសមត្ថភាព របស់សុធីដោយផ្ទាល់ ! !

*ooooooooooooooooo*

*ooooo*

*o*

CHANBOKEO . COM

# វគ្គទី៤
# ប្រៀន

ឃើញនិមលយកដៃជូតទឹកភ្នែក ឪពុកនាងក៏សួរថា ៖
- រឿងប៉ាកំសត់ណាស់មែនទេ កូន ?
នាងតូចឈ្ងោកមុខមិនហ៊ានតបទេ ប៉ុន្តែការពិតវិញនោះ នាងកំពុងតែញាប់ញ័រក្នុងចិត្តក្រៃលែង ដែលបានដឹងប្រវត្តិដ៏ល្វីងជូរចត់ របស់សុធីជាឪពុក ។ គិតទៅ ឪពុកនាងបានពុះពារច្រើណាស់ ទើបអាចសំរេចភាពជោគជ័យនៅថ្ងៃនេះបាន ។ បើសិនជារូបនាង ជាក្មេងកំព្រាម្នាក់នោះវិញ តើនិមលត្រូវគិតយ៉ាងណា ធ្វើយ៉ាងណា ឲ្យផុតជីវិតទារុណដូចឪពកនាងធ្លាប់បានទទួលនោះ ? ភ្លាមនោះ សុធីក៏មានវាចាបន្តទៅកូនស្រីទៀតថា ៖
- ការពិត កូនមិនគួរស្រក់ទឹកភ្នែកទេ និមល ! កូនគួរណាស់តែញញឹមដែលកូនមិនបានហែលឆ្លងកាត់រំពាត់ផ្តៅ នឹងការវាយដំច្រំ ធាក់របស់មនុស្សចាស់ ហើយមិនបានត្រូវគេបង្អត់បាយ ។ ផ្ទុយទៅ វិញ កូនប៉ាមានសំណាង ដែលបានចូលរៀនសាលាតាំងពីវ័យក្មេង មានបាយបរិភោគឆ្អែតៗ មានដំណេកគ្រប់គ្រាន់ មិនពិបាកក្រោក ធ្វើការនឿយហត់ទាំងក្មេង ដូចកាលប៉ានៅពីតូច...
ថ្វីបើនិមលមិនដឹងថា កាលនោះ ឪពុកនឿយហត់យ៉ាងណាទេ ប៉ុន្តែស្រីតូចអាចយល់បានខ្លះៗ ថាសព្វថ្ងៃ ឪពុកកំពុងបង្រៀន នាងឲ្យក្រោកធ្វើការផ្ទះពីព្រឹកព្រហាម សូម្បីតែថ្ងៃឈប់សម្រាក ថ្វី បើគាត់មិនដែលទះតប់ឬវាយដំកូនស្រីអ្វីបន្តិចឡើយ ។ ជាក្មេងស្រី អាយុត្រឹម១១ឆ្នាំនេះ និមលធ្លាប់ក្រោកពីព្រឹក យោងទឹកបោកខោ អាវប្អូនៗ បោកខោអាវប៉ាម៉ាក់ ទាំងធុង ទាំងកញ្ច្រែង នៅរាល់ចុង សប្តាហ៍ ។ ពេលនោះស្រីតូចដឹងថា វាហត់នឿយប៉ុនណាទៅហើយ ចុះទម្រាំធ្វើរាល់ថ្ងៃ មួយថ្ងៃវាស់ល្ងាច គ្មានឥតសំរាកសោះ តើវា ហត់យ៉ាងណាទៅទៀត ? និមលលួចបែរក្រោយគិតប្រៀបធៀបតែ ម្នាក់ឯង ។ ភ្លាមនោះ នាងឃើញឪពុកញញឹមដាក់ហើយស្រដីថា ៖

CHANBOKEO . COM

- កុំគិតច្រើនអីកូន! យើងកែអតិតកាលមិនបានទេ តែយើងអាច កែអនាគតបាន ។ បើកូនឃើញឧទាហរណ៍ក្នុងជីវិតអតិតកាលរបស់ ប៉ារួចហើយ ចូរកូនរៀបចំផ្លូវជីវិតរបស់កូនទៅ កុំអោយដើរពារ ប៉ះជីវិតវេទនាដូច្នេះឡើយ ។ ដឹងទេ កូនចាប់ផ្ដើមពីចំណុចដែល ប្រសើរជាងប៉ាឆ្ងាយណាស់ ព្រោះកូននៅមានប៉ាជាបង្គោល នាំ បង្ហាញបំភ្លឺផ្លូវ ដូច្នេះ កូនត្រូវតែប្រឹងបោះជំហានដើរអោយបាន ឆ្ងាយ ហើយខ្ពស់ជាងប៉ាទៅទៀត ឮហើយនៅ កូនស្រី ?

ធិតាញញឹមតបវិញ ហើយឆ្លើយជំរាបថា ៖

- ចា៎ស! កូននឹងប្រឹងដើរអោយបានឆ្ងាយហើយអោយបានខ្ពស់ បំផុត តែមិនកូនធានាថា កូននឹងដើរផ្លូវដែលប៉ាដើររួចហើយទេ ព្រោះខ្ញុំជាស្រី ប្រហែលជាដើរផ្លូវប្លែកពីបុរសបន្តិចហើយ ។
- នោះល្អហើយ ដែលកូនចេះស្វែងរកផ្លូវដើរដោយខ្លួនឯង ។ ប៉ា មិនថាអីទេ អោយតែផ្លូវមួយនោះ មិននាំកូនធ្លាក់រណ្ដៅ តែនាំកូន អោយទៅដល់ទីដៅ ដែលប៉ាចង់ឃើញកូនទៅដល់ ។
- ចុះបើកូន មិនត្រឹមតែទៅដល់ទេ តែទៅហួសឆ្ងាយពីអ្វីដែលប៉ា គិតទុក តើប៉ាមានរង្វាន់អោយកូនទេ ?
- ថីមិនមាន! អោយតែប៉ារកបាន ប៉ាអោយទាំងអស់ ។
- ខ្ញុំថា ប៉ាងាយរកទេ ។
- គឺ អ្វីទៅកូន ?
- ព្រោះខ្ញុំសុំអោយប៉ាដុតមាន់ប៉ោតចែកកូនញ៉ាំទៀត ។

ភ្លាមនោះ ឪពុកនាងសើចខឹកៗឡើង យកដៃអង្អែលក្បាល និមល ដោយក្ដីអាណិតស្រឡាញ់ រួចក៏ស្រដីបន្ថែមថា ៖

- អឺ! ចាំប៉ាដុតអោយ អោយតែកូនរៀនពូកែប្រឡងជាប់រហូតទៅ
- តែ ប៉ាត្រូវនិយាយរឿងចែកកូនស្ដាប់តទៅទៀត ព្រោះប៉ាមិន ទាន់និយាយប្រាប់កូនទេ ថា ប៉ាជួបម៉ាក់យ៉ាងម៉េច ?
- យី! ចង់ដឹងម្ល៉េះ កូននេះ ?
- ដឹងដើម្បីអោយកូនបានយកធ្វើជាគំរូក្នុងជីវិតនោះអី ប៉ា!
- អីយ៉ា! រៀនឆាប់ចេះម្ល៉េះកូន ? ដូចជាលឿនពេកទេហ្អី ?

CHANBOKEO.COM

- មិនជឿនទេ ប៉ាប្រាប់កូនយឺតពេកណាស់ ការពិត ខ្ញុំចង់ដឹង ថែមទៀតអោយបានឆាប់ៗ !
- អើ បើអញ្ចឹង យើងរៀបកាលវិភាគវិញ ។ រាល់ថ្ងៃអាទិត្យ ពេល កូនក្រោកពីព្រហាមមកបោកគក់ខោអាវជាមួយប៉ា ចាំប៉ានិទានឲ្យ កូនស្តាប់ យ៉ាងម៉េចដែរ ?
- ចាស! យល់ព្រម ។

និមលជាកូនស្រីច្បងក្នុងចំណោមកូនទាំងប្រាំនាក់ ។ ឪពុកនាង ធ្លាប់យកនាងដើរតាមលោកទៅក្រៅ ពេលមានការអ្វីនានា តាំងពី រឿងទៅបង្រៀនឈ្នួលតាមផ្ទះអភិជន ទៅបង្រៀននៅសាលា ឯកជន ទៅប្រជុំ ទៅជួបសាច់ញាតិ ឬក៏ជួបសូម្បីតែទៅជួបមិត្ត ភក្តិរបស់គាត់ មិនខុសឡើយពីកូនមាន់ដែលដើរតាមមេ អោយ តត្រុកនោះឡើយ ។ នាងតូចបានឃើញអ្វីៗអំពីជីវិតក្រៅផ្ទះច្រើន ជាងប្អូនស្រីបន្ទាប់របស់នាង ព្រោះបានដើរជាមួយឪពុកញឹកញាប់ ទៅឃើញសង្គមក្រៅច្រើនកន្លែង តាំងពីអ្នកក្រតូចតាច សិស្ស សាលា គ្រូបង្រៀន រហូតដល់អ្នកធំជាឧត្តមសេនិយ ចៅហ្វាយ ស្រុក ចៅហ្វាយខែត្រ ព្រមទាំងនាយកធំៗក្នុងក្រសួងផ្សេងៗ ម្ល៉ោះហើយ នាងក៏ក្លាយទៅជាក្មេងក្លាហានដោយឯកឯង មិនរួញរា មិនឈ្លោកមុខ មិនអៀនប្រៀនដូចក្មេងស្រីទូទៅឡើយ ។ ការពិត ពេលនោះសុធីកំពុងតែណែនាំបង្ហាត់បង្រៀនកូនស្រីច្បងគេនោះឲ្យ សម្លឹងមើលផ្លូវជីវិតអោយបានច្រើនប្លែកៗ ហើយរៀនប្រៀបធៀប ថាតើជីវិតបែបណាមានន័យ មានសារប្រយោជន៍សំរាប់អនាគត របស់នាងជាងគេ ដើម្បីនាងអាចបណ្តុះគំនិតល្អៗ ជ្រើសរើសផ្លូវ ជីវិតសមរម្យសំរាប់ខ្លួននាងទៅថ្ងៃក្រោយបាន ។ ម្យ៉ាងទៀតលោក យល់ថានិមលជាកូនស្រីច្បង ជាគំរូ និងជាបង្អែករបស់ប្អូនៗ ។ បើសិននិមលមានការចេះដឹងច្រើន នោះប្អូនៗប្រហែលប្រឹងចម្លង គំរូតាមខ្លះៗ មិនលែងឡើយ ។

នៅក្នុងផ្ទះ និមលមានភាពស្និទ្ធស្នាលនឹងឪពុកជាងម្តាយ ។ តែនិសាប្អូនស្រីបន្ទាប់របស់នាង មានភាពស្និទ្ធស្នាលជាមួយម្តាយ ជាងឪពុក ។ និសាចូលចិត្តមើលប្អូន ហើយប៉ិនលួងលោមក្មេង ណាស់ ។ គេចេះនិយាយរឿងប្លែកៗហើយកំប្លែងៗ ដែលប្រឌិត ភ្លាមៗយកមកលួងប្អូនអោយគេងឬអោយបាត់យំ ។ ចំណែកនិមល វិញកាន់កិច្ចការខាងប្រើកម្លាំង ដូចជាបោសផ្ទះ ជូតផ្ទះ បោកខោ អាវ ដាំបាយ ធ្វើម្ហូបអាហារជាដើម ជួនទំនេរក៏ជំរះស្មៅជុំវិញ ផ្ទះ ។ បើសិនចេញក្រៅញឹកញាប់ជាមួយឪពុក និមលត្រូវក្រោក ពីព្រឹក ជូតផ្ទះនឹងដណ្តាំបបរ

រួចលាងចាន ។ ក្រៅពីនោះ ម្ដាយ នាងធ្វើជំនួសទាំងអស់ ។ ប៉ុន្តែ នៅថ្ងៃឈប់សំរាក និមលទទួល បន្ទុកពេញដៃពេញជើង ទាំងស្រុង ។

ឯសុធីវិញតែងលួចគន់មើលគ្រប់កូនទាំងអស់ ហើយក៏អប់រំ ប្រដៅកូនខុសៗគ្នា មិនដូចគ្នាឡើយ ព្រោះមាណពអប់រំទៅតាម អាយុ តាមភេទ តាមសម្បទា និងតាមនិស្ស័យរបស់កូន ។ សុធី អោយនិមលរៀនធ្វើកិច្ចការអ្វីទាំងនោះ ព្រោះគេដឹងថា និមលមិន សូវចេះលួងប្អូន ព្រោះនាងជាមនុស្សម៉ឺងម៉ាត់ ហើយធ្វើអ្វីមធ្យ័ត ខ្លាចខុសណាស់ ។ ម្យ៉ាងទៀត ពិតមែនតែនិមលប៉ិនខាងសរសេរ និពន្ធអ្វីៗ តែនាងមិនពូកែនិយាយរឿងកំប្លុកកំប្លែងសើចសប្បាយ អោយប្អូនៗស្ដាប់ដូចជានិសាប្អូនស្រីរបស់នាងទេ ។ ឯការដែល សុធីចូលចិត្តនាំកូនស្រីច្បងចេញទៅក្រៅ តាមខ្លួនញឹកញាប់នោះ ព្រោះនិមលមិនសូវចេះខ្លាចគេ ហើយនាងពូកែសរសេរលឿន មានប្រាជ្ញអាចចាប់សំដីរបស់គេបានឆាប់រហ័ស រួចចម្លងពាក្យគេ ទុកក្នុងក្រាំងបានទាន់ចិត្តទៀតផង ។

សុធីជាមនុស្សចូលចិត្តអានសៀវភៅ ហើយចូលចិត្តសរសេរ ណាស់ ។ គេជាមនុស្សម៉ត់ចត់ល្អិតល្អន់ ។ សៀវភៅមួយក្បាលៗ មាណពចាប់អានខ្ចេចតាំងពីក្របមុខរហូតដល់ទំព័រក្រោយ អក្សរធំ អក្សរតូច មិនឲ្យមានរំលងទំព័រ ឬរំលងពាក្យណាមួយទេ ។ លុះ និមលលួចរៀនធ្វើតាមឪពុកម្ដងមួយយាម ទើបដឹងថាតួអក្សរតូចៗ ល្អិតៗជាងគេនៅក្នុងសំណៅសៀវភៅមួយៗសុទ្ធតែបង្កប់អត្ថន័យ ដែលអ្នកអានទាំងឡាយគួរដឹង ហើយមិនគួររំលងពាក្យចោលសោះ ឡើយ ។ កាលបើឃើញកូនស្រីចូលចិត្តលួចអានសៀវភៅរបស់ គេញឹកញាប់ពេក សុធីក៏ហៅនិមលទៅប្រាប់ថា ៖

- និមលមិនបាច់លួចអានទេ ។ បើចង់អាន កូនមកសុំពីប៉ាទៅ ចាំ ប៉ាប្រាប់ថា តើសៀវភៅណាមួយ កូនគួរអាន សៀវភៅណាកូនមិន គួរអាន ព្រោះថា គេបោះពុម្ពសៀវភៅមានលក្ខណៈផ្សេងៗគ្នា ។ ជួនកាលសៀវភៅខ្លះ គេសរសេរសំរាប់មនុស្សធំ ព្រោះអ្នកនិពន្ធ សរសេរអោយរួចតែពីដៃ ដោយមិនគិតតម្លៃសីលធម៌និងវិន័យ សំរាប់អ្នកអានវ័យក្មេងដូចកូននោះទេ ។ ឯគ្រួសារយើងក៏មិនមាន លុយកាក់សំរាប់ទិញសៀវភៅអោយកូនបានអានច្រើនឡើយ តែប៉ា

អាចនាំកូនទៅខ្ចីពីបណ្ណាល័យសាលា អោយកូនអានបានម៉ាសប្បាយ អោយតែកូនចូលចិត្តអានពិតមែន ។

ការពិត និមលមិនសូវជាចូលចិត្តអានប៉ុន្មានទេ តែចូលចិត្ត សរសេរជាជាង ។ ថៃដន្យ ពេលសរសេរដោយមិនបានអាន មិន មិនបានសង្កេតអ្វីៗថែមទៀត នាងតូចតែងតែសរសេរសាច់រឿង ដដែលៗ មិនប្លែកសោះ គឺកុមារីទាល់គំនិត គិតអ្វីយកមក ជាពិសេសមិនអាចវែកញែកគំនិតឲ្យពិរោះអត្ថន័យ ។ ដូច្នេះហើយ នាងតូចត្រូវតែប្រឹងអានសៀវភៅរបស់អ្នកដទៃអោយបានច្រើន ឬ ហោចណាស់ក៏ប្រឹងស្តាប់យោបល់របស់អ្នកដទៃ ដើម្បីទទួលគំនិតល្អៗប្លែកៗយកមកសរសេរដែរ ។ ពេលនោះ កុមារីនិមលនៅ តូចនៅឡើយ អាយុទើបតែ១១ឆ្នាំមែន ប៉ុន្តែ នាងអាចសរសេរ មួយថ្ងៃបានពីរសន្លឹកពេញ ជួនជាកំណាព្យ ជួនជាពាក្យរាយធម្មតា ទោះបីជាសរសេរ ខុសខ្លះ ត្រូវខ្លះ ក៏ដោយ ។

មានកាលខ្លះ សុធីបានហៅនិមលទៅបង្ហាញ អំពីរបៀបអាន សៀវភៅ លឿនហើយយល់ន័យពិស្តារ មិនខាតពេលចោលអាន សៀវភៅយូរឥតប្រយោជន៍ ព្រមទាំងបង្គាប់ឲ្យនាងរៀនសង្កេត អក្សរតូចៗទាំងទំព័រមុខទាំងទំព័រក្រោយ ។ សុធីតែងនិយាយថា ពេលដែលប្រសើរបំផុតសំរាប់អានសៀវភៅនោះ គឺមុនពេលចូល ដំណេក ។ មាតាពន្យល់កូនបន្ថែមទៀតថា៖

- ការអានសៀវភៅធ្វើឲ្យអារម្មណ៍យើងស្ងប់ ចេះគិតវែងឆ្ងាយ ចេះវិភាគពិចារណាហេតុផលផ្សេងៗ ជាពិសេស សៀវភៅដែល អ្នកនិពន្ធផ្តោតសារន័យ និងសារប្រយោជន៍ទៅលើសង្គមធម៌ សីលធម៌ វប្បធម៌ វិទ្យាសាស្ត្រ ទស្សនវិជ្ជា ជាដើម ។ល ។

សាច់ញាតិរបស់និមលខ្លះដែលរស់នៅជាមួយគ្នានោះ មិនចូល ចិត្តរៀនទេ ។ ខ្លះទៀតខំណាស់ពេលរៀនម្តងៗ ទន្ទេញរ៉ូងរ៉ាំង ឮខ្ទរខ្ទារពេញផ្ទះ ។ ខ្លះទៀត ជិតដល់ថ្ងៃប្រឡង ទើបស្រវាទាញសៀវភៅយកមកបើកមើល ។ ខ្លះគិតថារៀន គ្រាន់តែចេះបន្តិច បន្តួចក៏ត្រឡប់ទៅធ្វើការរកស៊ីនៅស្រុកជាមួយម៉ែឪវិញ ។

រាល់យប់មុនចូលដំណេក តាំងពីនិមលរៀនកុមារដ្ឋានរហូតដល់ ពេលប្រឡងចូលអនុវិទ្យាល័យ ឪពុកនាងតែងតែនិទានរឿងឲ្យកូន ចៅក្នុងផ្ទះស្តាប់ចំនួនមួយម៉ោង ជួនកាលជារឿងនិទានពីសៀវភៅ គតិលោក ជួនមកពីស្រីហិតោបទេស ខ្លះមកពីសំណៅប្រជុំរឿង ព្រេងខ្មែរជាដើម ។ កាលខ្លះទៀត សុធីនិទានរឿងបរទេស ឬក៏

CHANBOKEO.COM

ជារឿងដែលមាណពនិពន្ធខ្លួនឯងមកនិយាយឲ្យកូនៗស្តាប់ ។ រីឯ រឿងដែលសុធីប្រឌិតខ្លួនឯង ភាគច្រើនជារឿងកំប្លែងៗ តែប្រកប ដោយគតិល្អៗសំរាប់ក្មេងៗត្រងត្រាប់ ។ លុះស្តាប់រឿងរួចហើយ សុធីក៏ទុកពេលអោយកូនគេងគិតមួយយប់ លុះយប់ស្អែកឡើង គេហៅក្មេងៗមកជួបជុំ ដើម្បីឆ្លើយសំនួរប្រាជ្ញផ្សេងៗដែលទាក់ ទងទៅនឹងសាច់រឿងដែលនិទានរួចហើយ ។ នៅថ្ងៃបន្ទាប់ៗមក ទៀត សុធីបង្គាប់អោយកូនសរសេររឿងនោះមកវិញ តាមដែល គេចងចាំសាច់រឿងបាន យ៉ាងហោចណាស់ឲ្យបានមួយទំព័រដែរ ។ លុះធ្វើដូច្នេះដដែលៗយូរទៅ ទើបនិមលដឹងថាសុធីកំពុងបង្រៀន កូនឲ្យចេះស្តាប់អ្នកដទៃ ចេះវែកញែកសាច់រឿង ចេះគិតពិចារណា ដោះស្រាយចំណោទនៅក្នុងសាច់រឿង ហើយចេះនិពន្ធសាច់រឿង ល្អៗដោយទេពកោសល្យពិសេសរៀងៗខ្លួន ។ រីឯសុធីវិញក៏ជួយ ណែនាំកូនៗខាងវេយ្យាករណ៍ អក្ខរាវិរុទ្ធនិងឧត្តមគតិផ្សេងៗ ឲ្យ កូនរៀនបណ្តុះដាំបញ្ចូលគំនិតរបស់ខ្លួនទៅក្នុងសាច់រឿង ។ ថ្ងៃខ្លះ សុធីយកចំណោទប្រាជ្ញ ផ្នែកនព្វន្តសាស្ត្រផ្សេងៗ មកសួរកូន ជួនសួរជាភាសាបារាំង ជួនជាភាសាខ្មែរ ។ ក្មេងៗក្នុងផ្ទះក៏ឆ្លើយ តបទៅវិញតាមកម្រិតដែលគេចេះដឹង រួចហើយសុធីតែងតែផ្តាំកូន ចៅថា ៖

- ការខំរៀននោះជាការប្រសើរហើយ តែកុំខំរៀននៅពេលប្រថុច ញ៉ុចអី ។ បើចង់ប្រឡងអោយជាប់ ត្រូវរៀនពីចម្ងាយទៅ...កូន ត្រូវក្រោកពីព្រឹករៀននោះទើបស្មារតីមូលល្អ ហើយយើងមិនចាំ បាច់ ធ្វើជាសិស្សពូកែលេខមួយរហូតគ្រប់មុខវិជ្ជាទេ តែក៏កុំអោយ អន់គ្រប់មុខវិជ្ជាដែរ ។ ធ្វើយ៉ាងណាអោយទៅសាលាទៀងទាត់ ស្តាប់គ្រូទៀតទាត់ ហើយចេះសាកសួរគ្រូពេលណាមានចម្ងល់ ។ បើកូនអាចប្រឹងរៀនរហូតអាចប្រឡងជាប់គ្រប់មុខវិជ្ជាទៅ នោះ ទើបជាការសមរម្យប្រពៃបំផុត ។

នៅរវាងឆ្នាំដែលនិមលត្រូវប្រឡងចូលអនុវិទ្យាល័យ សុធីបាន ដើរមកជិតនាងតូចហើយមានប្រសាសន៍ថា ៖

- និមល ! កូនមិនបាច់ប្រឹងប្រឡងយកលេខមួយទេ តែកូនត្រូវ ប្រឹងធ្វើយ៉ាងណាអោយប្រឡងជាប់រាល់ឆ្នាំ ។ ប៉ុន្តែ បើកូនប្រឡង ធ្លាក់មួយឆ្នាំ កូននឹងខាតពេលមួយឆ្នាំ ក្របានចេញធ្វើការ ។ ឧទាហរណ៍ថា កូនត្រូវចេញធ្វើគ្រូ

បានប្រាក់ខែបួនរយក្នុងមួយខែ បើសិនណាកូនចេញធ្វើការយឺតមួយឆ្នាំ នោះមានន័យថាកូននឹងខាត អស់ប្រាក់ខែ១២ខែត្រូវជាបួនពាន់ប្រាំបីរយ ។ តើកូនសុខចិត្តខាតប្រាក់ខែច្រើនអញ្ចឹងទេ ? បើមិនសុខចិត្តទេ តើកូនត្រូវធ្វើយ៉ាង
ណាវិញ ?

មែនហើយ! ជាតិជាក្មេងអាយុត្រឹម១១ឆ្នាំ មានដែលទៅគិត វែងឆ្ងាយឯណា ? ចៃដន្យពេលឮឪពុកនាងមានប្រសាសន៍ដូច្នោះ និមលភ្ញាក់ស្មារតីព្រើតតែម្តង ។ ការពិត កុមារីធ្លាប់ទទួលប្រាក់ មួយថ្ងៃមួយរៀលពីម្តាយនាងសំរាប់ទិញនំញ៉ាំ ។ មួយឆ្នាំនាងក៏សន្សំបានមួយរយម្តង ឆវីមានអារម្មណ៍សែនរំភើប គិតថាខ្លួននាងជា អ្នកមានដល់សូរហើយ ។ ចុះទំរាំបួនពាន់ប្រាំបីរយទៀតនោះ ? អីយ៉ា! ពិតជាច្រើនណាស់! នាងមិនគួរនឹងបាត់បង់លាភដ៏សែនធំ មហិមានោះឡើយ ។ បើសិនជាប្រឡងធ្លាក់ ហើយចេញធ្វើការយឺត អស់មួយឆ្នាំមែននោះ និមលពិតជាស្តាយលាភដែលនឹងបាត់បង់ទៅ នោះស្លាប់ហើយ!!

ពាក្យមួយប្រយោគរបស់សុធីនោះ បានរណ្តំជាប់ក្នុងអារម្មណ៍ នាងតូចជារៀងរហូតមក ម្ល៉ោះហើយនិមលប្រឹងប្រែងព្យាយាម រៀនសូត្រម៉ត់ចត់ជាងក្មេងធម្មតា ។ នោះមិនមែនដោយសារនាង ជាក្មេងឧស្សាហ៍ចម្លែកខុសគេទេ ការពិត កុមារីយើងខ្ជិលដូចតែក្មេងទូទៅឥចឹង ប៉ុន្តែ ដោយសារតែនាងស្តាយលាភនៅនាអនាគត នោះទេតើ ទើបធិតាតូចប្រឹងដើបឡើងមុនគេ ។ ថ្ងៃណាក៏នាង ស្រម័យឃើញប្រាក់ខែមួយដុំដែលបំរុងនឹងបាត់ទៅវិញដែរ ដូច្នេះ និមលត្រូវខំរៀនដើម្បីឆក់យកវាអោយទាន់ពេល មិនឲ្យបាត់បង់ ទៅដោយអាសារបង់ឡើយ ។

ឆ្នាំដដែលនោះ គេមានធ្វើពិធីសម្ពោធពិសេសមួយនៅសាលា បឋមសិក្សារបស់និមល ។ លោកគ្រូចាងហ្វាងក៏បានរើសសិស្សស្រី ពីថ្នាក់នាងខ្លះ ពីថ្នាក់ជាប់គ្នានោះខ្លះ សុទ្ធតែជាសិស្សនារីដែលបំរុង ប្រឡងចូលអនុវិទ្យាល័យ ។ ចៃដន្យ គេរើសយកតែសិស្សនារី ដែលមានរូបសោភ័ណសោភា ហើយមានរូបរាងពេញវ័យជាងគេ ។ កាលនោះ និមលមិនបានជាប់ឈ្មោះនឹងគេទេព្រោះដោយសារនាង មិនមានរូបស្អាតហើយនៅតូចពេកផង ។ តាមពិត និមលជាសិស្សស្រីដែលមានមាឌតូចជាងគេបង្អស់នៅក្នុងថ្នាក់ ។ សូម្បីតែដានីជា មិត្តអង្គុយតុជាមួយនាង ក៏គេមានរូបរាងស្រស់ស្អាតសុភាពរមទម្យ ជាស្រីក្រមុំជាងនាងដែរ ។ នៅពិធីសម្ពោធនោះ

CHANBOKEO.COM

និមលបានទទួល ឋានៈត្រឹមតែស្លៀកឯកសណ្ឋាន ជាយុវនៃយុវតីសង្គមរាស្ត្រនិយម ឈរបង្ហូតទង់ជាមួយមិត្តរួមថ្នាក់ម្នាក់ទៀតភេទ ប្រុសឈ្មោះហុង ។
ថ្ងៃនោះមិត្តស្រីរបស់នាងឈ្មោះ សុផាន់ណា គិមឡី និងស្រីម៉ាច តែងខ្លួនស្រស់ស្អាត ស្លៀកសំពត់ផាមួងចងក្បិន ពាក់អាវប៉ាក់ បួងសក់ដាក់ផ្កាម្លិះ ។
នៅលើផ្ទៃមុខមានផាត់ក្រែមម្សៅយ៉ាងស្អាត ប្លែករហូតមើលមិនចង់ស្គាល់ ទិះតែច្រឡំស្មានថា គេទាំងបីជា ក្រមុំទេពអប្សរមកពីស្ថានលើឯណោះ ។

ឪពុករបស់និមលក៏បានមកចូលរួមពិធីនោះដែរ ។ កាលបើ ឃើញធិតាយើងនៅស្ងៀមៗ លួចសម្លឹងតែមិត្តស្រីរបស់ខ្លួនដ៏ ស្រស់ស្អាតទាំងបីនាក់នោះមិនដាក់ភ្នែក សុធីខ្លាចនិមលបាក់ទឹកចិត្ត ដែលគេមិនបានជ្រើសរើសធ្វើជានារីកាន់ជើងពាន ក៏សសៀរដើរ ចូលមកជិត ហើយមានវាចាខ្សិបៗ ជាមួយកូនស្រីថា ៖

- ឃើញមិត្តរបស់កូនស្រស់ស្អាតណាស់មែនទេ ទើបកូនឈរមើល គេភ្លឹកស្មារតីអញ្ចឹង ។
- ចាស ប៉ា! គេតែងខ្លួនយ៉ាងនេះទៅ មិនសមជាសិស្សរៀនថ្នាក់ ស្មើនឹងកូនសោះ ។ មើលទៅហាក់ដូចជាមនុស្សពេញវ័យតែម្តង ។
- មនុស្សស្រីក៏ដោយ ប្រុសក៏ដោយ មានរូបសោភណ៍ស្រស់ស្អាត សង្ហាទៅតាមបែបបថរបស់គេណាកូន ។ ចំណែកឯនិមលវិញ កូន មានសោភ័ណ មានមោទនភាពតាមបែបបថរបស់កូនដែរ ។

និមលជ្រួញចិញ្ចើម ត្បិតមិនយល់ថា សុធីឪពុកនាង ចង់មាន ន័យថាម៉េចទេ ។ ភ្លាមនោះ សុធីក៏ពោលបន្តទៀតថា ៖

- កូនឃើញទេ! ពេលមិត្តនីរបស់កូនទាំងបីនាក់ឡើងកាន់ថាសផ្កា ទៅជូនភ្ញៀវកត្តិយស គេលំទោនសិរសាកាយាយ៉ាងរាបទាប ប៉ុន្តែ ភ្ញៀវទាំងឡាយ បែរជាសាទរប្រគល់មោទនភាពនិងកិត្តិយសទៅ បុគ្គលដែលឈរកាត់ខ្សែបូរជំនួសទៅវិញ ។ ចំពោះនិមល និងហុង មិត្តរបស់កូនដែលឈរបង្ហូតទង់ជាតិអំបាញមិញ គ្រូនិងសិស្សពេញ មួយសាលាផ្តល់នូវក្តីគោរពចំពោះទង់ជាតិ ដែលមានកូននិងមិត្តជា អ្នកបង្ហូត ។ គ្រានោះរូបកូននឹងហុងជាអ្នកត្រួតត្រាស្ថានការណ៍ក្នុង ដៃ ហើយទាំងអស់គ្នារាប់រយរាប់ពាន់ត្រូវគោរពតាមទាំងអស់ ។ នោះគឺជាតម្លៃដ៏ឧត្តុង្គឧត្តមមួយ ដែលកូនបានទទួលពីគ្រប់ៗគ្នា ។ ដូច្នេះ គេមិនត្រូវសម្លឹងមនុស្សត្រឹមរូបក្រៅខ្លួននោះទេ តែគួរ សម្លឹងហួសឆ្ងាយជាងនោះរាប់រយដង ។ និមល! កូនប្រាកដជានឹង អាចឈោងអនាគតបានខ្ពស់

CHANBOKEO.COM

ហើយឆ្ងាយជាងមិត្តនារីរបស់កូនទាំង អស់ គ្រប់គ្នា
បើសិនណាកូនមិនយករូបសោភ័ណមកធ្វើជាត្រីមុខ សំរាប់វាស់តម្លៃរបស់ខ្លួន ។ កូនមានសោភណ៍
ខាងសតិប្រាជ្ញ សម្បទានិងទេពកោសល្យដទៃទៀត ដែលកូនអាចបញ្ចេញបង្ហាញ ទៅសង្គម
អោយគេឃើញតម្លៃរបស់កូនបាន ដោយមិនបាច់ពឹង សំបកក្រៅរបស់កូននោះជាកត្តា
យល់ទេកូន ?

សុធីក៏យកដៃអង្អែលក្បាលរបស់និមលហាក់ដូចជាចង់បបោស
លួងលោមកុំឲ្យធីតូចចិត្ត ដែលនាងពុំមានរូបសម្បត្តិគ្រប់គ្រាន់ ។ ចៃដន្យ
និមលមិនមានអារម្មណ៍គិតដូច្នោះនៅឡើយទេ ព្រោះកុមារី ទើបតែមានអាយុ១១ឆ្នាំ
មិនដឹងចង់ស្អាតយកមកធ្វើអ្វីទេ ។ ការ ពិត តរុណីកំពុងគិតថា បើគេតែងខ្លួនស្អាតយ៉ាងហ្នឹង
តើគេត្រូវ ចំណាយពេលយូរប៉ុនណាដើម្បីតែងខ្លួន ហើយអស់លុយប៉ុន្មាន
ដើម្បីទិញប្រដាប់ប្រដាតុបតែង រួចនរណាជាអ្នកចេញលុយចំណាយ លើរបស់ទាំងនោះ ។
បើចំណាយខ្លួនឯងវិញ តើតែងខ្លួនមួយពេល អស់លុយប៉ុន្មានរៀល ? បើសិនឡើងឆាកច្រើនដង
ក្នុងមួយឆ្នាំ តើត្រូវចំណាយប៉ុន្មានទៀត ? តែបើសន្សំលុយអស់នោះទុកទិញ សៀវភៅរៀនវិញ
តើអាចប្រើបានប៉ុន្មានឆ្នាំដែរ ? គឺនិមលកំពុង
រៀនចាក់ស្មុគ្រ័កាច់ក្បាច់ទៅតាមប្រសាសន៍របស់ឪពុកនាង កាលពី ថ្ងៃមុន
ដែលនិយាយពីការខាតបង់លុយកាក់ទៅអនាគតទេតើហ៎ ។
កុមារីយើងញញឹមតបទៅសុធីជាឪពុកវិញ តែមិនបានជំរាបប្រាប់ ឪពុកទេថា
នាងកំពុងគិតពីអ្វីឡើយ ។

មែនហើយ! មួយប្រយោគដែលលោករៀបរាប់អំពីការខាត បង់នៅនាអនាគត
ធ្វើឲ្យនិមលតែងគិតពិចារណាគ្រប់ពេលទាំង អស់អំពីអ្វីៗជុំវិញខ្លួន ។
នាងតែងតែយកមកវិភាគទៅតាមវ័យ និងការចេះដឹងរបស់ខ្លួនឯង ។
ធិតាចូលចិត្តរៀនកត់ចំណាំទុក ជានិច្ច ដើម្បីចង់ដឹងថា តើទៅអនាគត នាងនឹងខាតបង់អ្វីខ្លះ
ចំណេញអ្វីខ្លះ បើសិននាងប្រើទ្រឹស្តីរបស់ឪពុកនាងជាគោល ដើម្បី វាស់គំនិតចេះ
ដឹងនិងការប្រព្រឹត្តរបស់នាង ។

ថ្ងៃប្រកាសលទ្ធផលប្រឡងចូលវិទ្យាល័យក៏បានមកដល់...

និមលក៏ឡើងជិះកង់ទៅវិទ្យាល័យអ៊ាបយុត ដើម្បីស្តាប់ការ
ប្រកាសឈ្មោះបេក្ខជនដែលប្រឡងជាប់ ប៉ុន្តែ ក្នុងជំរៅចិត្តរបស់ នាងវិញនោះ

CHANBOKEO.COM

និមលមានជំនឿយ៉ាងកក់ក្ដៅរួចទៅហើយថាធិតា ច្បាស់ជាប្រឡងជាប់ ។
អ្វីដែលនាងចង់អ៊ុតជាងគេនោះគឺ ថាតើ
និមលបានចំណាត់ថ្នាក់ខ្ពស់ត្រឹមណាក្នុងចំណោមសិស្សរាប់ពាន់ដែល
មកប្រឡង ។

ថ្ងៃនោះ សុធីបានដើរមកស្រដីលើកទឹកចិត្តនារីតូចថា ៖

- កូនស្រីប៉ាពិតជាមិនធ្វើអោយប៉ាខកបំណងមែន! ឥឡូវកូនដើរ
ឡើងទៅកាំជណ្ដើរថ្មីទៀតហើយ ។ កាំលើកក្រោយនេះ ខ្ពស់ហើយ ឆ្ងាយផង តែប៉ាជឿថា
កូននឹងដើរឡើងដល់កំពូល បើសិនកូនប្រឹង ពីចម្ងាយ ដូចដែលកូនធ្លាប់ធ្វើកន្លងមក ។
ដាំស្វាយមួយដើម យើងត្រូវរង់ចាំប្រហែលដប់ឆ្នាំ ទើបបានបេះផ្លែ ។ ដាំអនាគតល្អ
ត្រូវការពេលវែងជាងហ្នឹង ។ ចូរកូនព្យាយាមតស៊ូហើយអត់ធ្មត់ បំផុត ទំរាំងលក់កូនបេះផលសំរេច
កុំលះបង់ការព្យាយាមឲ្យសោះ ។

ជួនកាល និមលស្ដាប់ពាក្យអប់រំប្រដៅប្រដៅរបស់សុធី មិន យល់ទេ
ព្រោះអត្ថន័យជ្រាលជ្រៅពេក សំរាប់ឲ្យក្មេងស្រីតូចដូច នាងយល់ ។ សំណាងល្អថែងន្យ
សុធីចូលចិត្តអោយកូនសរសេរ ទុកក្នុងសៀវភៅប្រចាំថ្ងៃ ម្ល៉ោះហើយ និមលក៏កើតមានទម្លាប់
សរសេរទុកនូវអ្វីដែលនាងបានឮ បានឃើញ ។ យូរៗធិតាយើង យកចេញមកអានម្ដង
ទើបភ្ញាក់ផ្អើលដោយបានដឹងថា ធិតា បានទទួលការចេះដឹងជាច្រើនរាប់មិនអស់
ថែមពីមួយឆ្នាំទៅមួយ ឆ្នាំ តាំងពីចិត្តគំនិតនិងការប្រព្រឹត្ត គឺនាងមានជំរឿនផ្នែកចំណេះ
និងគំនិតយ៉ាងលឿន ខុសក្មេងធម្មតាទូទៅ ។

*oooooooooooooo*

*ooooo*

*o*

CHANBOKEO COM

# វគ្គទី៥
# គូនិស្ស័យ

មង្គលបុរី ឆ្នាំ១៩៥២...

សុធីបានទទួលច្បាប់បីថ្ងៃ ជិះកង់ត្រឡប់ទៅមង្គលបុរីដើម្បីទៅ សែនដូនតាចូលឆ្នាំចិន ។

នៅមាត់ជណ្ដើរកុដិព្រះគ្រូអធិការ...

សុធីអង្គុយសំកុកអោបសៀវភៅធ្វើមុខស្មើក ហាក់ដូចជាធុញ ថប់ក្នុងចិត្ត ។ ព្រះគ្រូឃើញដូច្នោះក៏កូកហៅពីក្នុងកុដិមកថា ៖

- សុធីអើយ!
- កូណា លោកតា! (សុធីឆ្លើយទាំងភ្ញាក់ក្រញាង)
- ហេតុអ្វីមិនទៅរកសែនដូនតានឹងគេ? ក្រែងបងយីង របស់ឯង សែនដូនតាចូលឆ្នាំចិនដែរហ៍ មែនទេហ៍?
- បាទ! ពេលនេះប្រហែលជាគាត់កំពុងរៀបចំសែនហើយ តែ... ខ្ញុំមិនហ៊ានអើតមុខទៅទេ ។
- ហេតុអ្វីទៅ ចៅ?
- ព្រោះខ្លាចគាត់ជេរថា ខ្ញុំអើតមុខទៅរកប្លមសាច់ជ្រូកខ្វៃរបស់ គាត់ ។ ម្យ៉ាងទៀត បងយីងនិងបងថ្លៃធ្លាប់បានជេរកាត់កាល់ខ្ញុំដែរ មុនពេលខ្ញុំចាកចេញពីគាត់ ទៅរៀននៅបាត់ដំបង ។ ពេលនេះ ខ្ញុំមិនដឹងថា ខ្ញុំគួរទៅចូលរួមសែនដូនតានៅឯណា ជាមួយនរណា ទេ លោកតា ។
- ចុះក្រែងឯងមានបងប្អូនដទៃទៀត នៅមង្គលបុរីនេះដែរតើហ៍ ម៉េចក៏មិនទៅរកជួបជុំនឹងគេទៅ បើឯងមិនហ៊ានទៅផ្ទះបងយីង ទេនោះ?
- ខ្ញុំធ្លាប់តែឮចាស់ៗនិយាយប្រាប់ថា មានបងប្អូនដែរ តែខ្ញុំមិន ដែលបានស្គាល់នរណាទេ ព្រោះបងយីងមិនដែលអោយខ្ញុំចេញ មុខទៅស្គាល់សាច់ញាតិនៅឯណាសោះ ព្រោះគាត់ខ្លាចខ្ញុំរកផ្លូវ ឃើញ ហើយរត់ចោលគាត់ដូចបងៗពីរនាក់មុននោះទៀត ។
- ស្លាប់ហើយ! ឯងពិតជាមិនស្គាល់បងប្អូនរបស់ឯងមែនហ្ន៎ស? នែ៎ក ដឹងទេ? ឯងមានបងប្អូនច្រើនណាស់នៅមង្គលបុរីនេះ ។ ខ្លះជាដង្កៅស្រែ ខ្លះធ្វើចៅកែឡានឈ្នួល

CHANBOKEO.COM

ខ្លះមានរបរជំនួញផ្សេងៗ ទៀត ។ ឯម្នាក់ដែលលោកតាស្គាល់ជាងគេនោះ គឺបងប្អូនជីដូនមួយរបស់ឯងម្នាក់ធ្វើការនៅពេទ្យសត្វ ឈ្មោះប៉ិហួត ។

សុធីភ្ញាក់ព្រើត សួរថា ៖

- ហើយចុះផ្ទះគាត់នៅឯណាដែរទៅ លោកតា ?

- អឺ! បើឯងចង់ទៅ ចាំតាប្រាប់ផ្លូវអោយទៅរក សង្ឃឹមថាគេនឹងរាប់រកឯងជាសាច់ញាតិផងចុះ ព្រោះហោចណាស់ នាយហួតមិនមានសន្តានចិត្តទ្រឹស្នរដូចបងយីងឯងនោះដែរ ខុសតែគេជាអ្នក ផឹកស៊ីខ្ជះខ្ជាយបន្តិចហើយមានប្រពន្ធច្រើនផង ។ លោកតាឮគេ និយាយតៗគ្នាមកថាប្រពន្ធក្រោយរបស់នាយហួតនៅក្មេងណាស់ អាយុប្រហែលសុធីឯងដែរតែមានកូនមួយពីរទៅហើយ ។

- ពុទ្ធោអើយលោកតា! បើដូច្នោះមែន ខ្ញុំមិនហ៊ានទៅទេ ខ្លាចគាត់ប្រចណ្ឌ័ប្រពន្ធដាក់ នាំតែមានរឿងរ៉ាវរំខានចិត្តឥតអំពី ។

- យី! បើឯងមិនរវីរវល់នឹងប្រពន្ធគេ តើឲ្យគេប្រចណ្ឌ័នឹងឯង យ៉ាងម៉េចកើត ? ការពិតឯងមកលេងបុណ្យចូលឆ្នាំតែម្ដៃពីរ រួច ក៏វិលទៅបាត់ដំបងវិញទៅហើយ មានអីដែលត្រូវសាំញ៉ាំគ្នាកើត នោះ ? ចំមែនរើយ កូននេះ! ចេះនិយាយផ្ដេសផ្ដាសកើត ?

បន្តិចមក លោកតាចៅអធិការក៏ប្រាប់ផ្លូវអោយសុធីចេញទៅរកបងប្អូននោះ ។ ការពិត មាណពយើងធ្លាប់ឮឈ្មោះសាច់ញាតិនោះ ពីមុនមកដែរ គ្រាន់តែគេមិនដែលទៅមករាប់រកគ្នាទេ ព្រោះបង យីងរបស់គេ មិនសូវចូលចិត្តរាប់ញាតិ ។ គាត់រាប់តែលុយតែម្យ៉ាង ប៉ុណ្ណោះ ព្រហាមឡើងបើកទ្វារ គឺធ្វើយ៉ាងណាអោយលុយរត់ចូលផ្ទះតែមួយមុខ មិនគិតអ្វីផ្សេងទៀតទេ ។

សុធីក៏បានមកដល់ផ្ទះមួយ ដែលមានមនុស្សសើចហោរអ៊ូអរ មានភ្ញៀវគគ្រឹកគគ្រេង ។ គេដើររ៉េរ៉ៃ មិនហ៊ានសួរថា មួយណា ជាប៉ិហួត បងប្អូនជីដូនមួយរបស់គេឡើយ ព្រោះនៅទីនោះមាន ភ្ញៀវចាស់ក្មេងប្រុសស្រីខ្មៀវខ្មាច្រើនមមាញឹកពេក ។ ម្យ៉ាងដោយឃើញគេគ្រប់គ្នាស្លៀកពាក់ស្អាតបាត ឯរូបនាយវិញ ខោមិនខោ អាវមិនអាវ គេក៏រារែកមិនហ៊ានចូលផ្ទះធំ សាកសួរអ្វីឡើយ ។ ភ្លាមនោះគេក៏នឹកភ្នកដើរសរសៀរតាមចំហៀងៗផ្ទះ ចេញទៅ ខាងក្រោយ ដើម្បីឆ្វៀលមើលទិដ្ឋភាពផ្ទះផង ដើម្បីសំងំសង្កេត បរិយាកាសផង ថាតើនរណាជាម្ចាស់ផ្ទះនោះ រួចនាយវិញ តើត្រូវ

CHANBOKEO.COM

ណែនាំខ្លួនយ៉ាងណាចំពោះក្រុមគ្រួសារមួយនេះ កាលបើនរៈមិន ដែលធ្លាប់ទៅមកជាមួយពួកគេពីមុនមកសោះ ។

នៅពេលជាមួយគ្នានោះ នៅផ្ទះជិតខាងក៏មានគេសែនព្រេន ដូនតាចូលឆ្នាំចិនដែរ ។ ភាពអ៊ូអរទាំងផ្ទះបងជីដូនមួយរបស់សុធី រួមផ្សំនិងភាពអ៊ូអរនៃផ្ទះអ្នកជិតខាង ពេលនោះគ្មាននរណាចាប់ ភ្លឹកអំពីវត្តមានរបស់សុធីនៅគ្រានោះឡើយ ។ លុះមាណពដើរចេញទៅដល់ខាងក្រោយផ្ទះ គេក៏ប្រទះឃើញមានស្រីៗពីរបីនាក់នៅធ្វើការនៅរានហាលខាងលើ ។ គ្រាន់តែឃើញសម្លៀកបំពាក់ របស់ស្រីៗទាំងនោះ សុធីក៏អាចកាត់ ស្មានបានទៅហើយថាស្រីៗ ទាំងនោះ ជាអ្នកបំរើរបស់ផ្ទះប៊ុហ្វតតែម្តង ។

រំពេចនោះ នាយក៏ដាក់ភ្នែកទៅចំនារីមួយរូប ក្នុងវ័យប្រហែល ១៧ឆ្នាំ កំពុងអង្គុយឈ្ងោកមុខលាងចានផង លួចជូតញើសជា ញឹកញាប់ផង ។ គេមើលមុខនាងមិនច្បាស់ប៉ុន្មានទេ ត្បិតធិតាបាន យកក្រមាមកទទូរបាំងមុខបាត់អស់ពាក់កណ្តាលទៅហើយ ។ លុះ នាយលួចឈរសង្កេតយូរបន្តិចទៅ ទើបដឹងថានាងកំពុងលួចផ្ចិត ទឹកភ្នែកចេញពីរង្វង់មុខ មិនមែនផ្ចិតញើសទេ ។ នរៈក៏ជ្រួញចិញ្ចើមនឹកភ្ញាក់ចាប់អារម្មណ៍ពីរូបមាណវីម្នាក់នោះភ្លាមមួយរំពេច ។ សុធីនៅឈរផ្ទៀកសសរពិចារណាមិនអស់មិនហើយ ព្រោះថ្ងៃនេះ ជាថ្ងៃចូលឆ្នាំចិន ជាថ្ងៃដែលនរណាៗសប្បាយដែរ មិនថាម្ចាស់ផ្ទះឬ ជាអ្នកនៅជាមួយនោះទេ ។ ចុះហេតុអ្វីក៏មាណវីបែរជាធ្វើការផងលួចសម្រក់ទឹកភ្នែកផងអញ្ចឹង ? ចំណែកស្រីៗដទៃទៀតដែល កំពុងដាំស្លនោះក៏នាំគ្នាធ្វើការឲ្យតត្រុក គ្មាននរណាអើពើនឹងសុខ ទុក្ខរបស់ធិតានោះម្នាក់សោះឡើយ ។

ភ្លាមនោះ សុធីក៏នឹកទៅដល់អតីតកាលរបស់ខ្លួន ដែលធ្លាប់ជាក្មេងកំព្រារស់នៅបំរើនៅក្នុងផ្ទះរបស់បងយីង ។ ថ្វីបើរូបគេជាប្អូនបង្កើតរបស់ម្ចាស់ផ្ទះក៏ពិតមែន ប៉ុន្តែជីវិតរបស់គេនៅក្នុងគ្រួសារនោះមិនមានខុសឋានៈគ្នាពីខ្ញុំកញ្ជះរបស់គេឡើយ ។ នៅរៀងរាល់ ពេលចូលឆ្នាំចិនរបៀបនេះ គេក៏លួចមកសំរក់ទឹកភ្នែកជាមួយទឹក លាងចានឯចង្ក្រានបាយដូចគ្នានឹងនារីមួយរូបនេះណាស់ ។ គេមិន ដែលបានទៅអុជធូបជូនដូនតាម្តងណាទេ ព្រោះម្ចាស់ផ្ទះគេមិនអនុញ្ញាត្តិអោយដើរចេញមុខផ្តេសផ្តាស នៅក្នុងផ្ទះរបស់គេឡើយ ។ ខណៈនោះ សុធីហាក់ដូចជាលែងចាប់អារម្មណ៍ នឹងតាមសង្កេតរក មើលបងជីដូនមួយរបស់ខ្លួនហើយ ។ គេបែរជាប្តូរមុខព្រួញ មក ផ្តោតអារម្មណ៍ទៅលើនារីមួយរូបនោះជំនួសវិញ ។ ចៃដន្យ នារី

CHANBOKEO.COM

មួយរូបនោះមិនបានចាប់ភ្លឹកទេថា មានប្រុសកម្លោះម្នាក់មកឈរ
លបលួចគយគន់រូបនាងពីចំហៀងផ្ទះរបស់នាង ។

សុធីឈរអោបដៃលួចសរសើរសោភណ៌នារីនោះយ៉ាងយូរ ទំរាំ
តែមានមនុស្សមកគោះស្មាមាណពស្រដីថា ៖

- អានាងហ្អ៊ា! មកពីខាងណាដែរហើយ ជួយដឹកដៃយាយទៅបង្កន់ បន្តិច ព្រោះម្តុំនេះ ក្តារវាទទឹក
យាយខ្លាចដើររអិលដួលណាស់ ។

នរៈភ្ញាក់ព្រើតបែរក្រោយ ឃើញដូនចាស់ម្នាក់អាយុប្រហែល ចិតសិបឆ្នាំ
ពាក់អាវសជាមួយសំពត់មួយអារពណ៌ខ្មៅ កំពុងដើរ សសៀរទៅរកបន្ទប់ទឹក ។
គេក៏លូកដៃជួយទប់ដូនចាស់ នាំគាត់ រហូតដល់មុខបន្ទប់ទឹកទើបព្រលែងគាត់ទៅ ។
សុធីនៅចាំរេរាមួយ ស្របក់ ដូនចាស់ក៏ដើរចេញមកវិញ ។ ភ្លាមនោះ ស្រាប់តែគាត់
ញញឹមគ្រហាញដាក់មាណពយើង រួចហើយសួរនាយថា ៖

- អានាងឯងជាប្អូនប្រុសរបស់ប៉ិយីងមែនទេ ?

មាណពភ្ញាក់ព្រើតដែលដូនចាស់សួរត្រូវចំៗអញ្ចឹង ។

- បាទ មែនហើយ! លោកយាយស្គាល់គាត់ដែរ ?
- អើ ថីមិនស្គាល់! ជាបងប្អូនសាច់សន្តាននឹងគ្នាទៅហើយ តែវា មិនសូវរាប់រកនរណាទេ
វារស់នៅដាច់តែវាទៅ ។ ហើយចុះឯង ជានរណាមួយ អាយ៉ាង ឬ អាយេង ?
- គឺ អាហ្វាងយូ ទេតើហ៎ បាទ!
- អើហ៎! ពួកឯងមានមុខមាត់ស្រដៀងៗគ្នាពេក បានជាយាយចាំ ឯងមិនបានថាជាមួយណា ។
ឮថា សព្វថ្ងៃនេះ ឯងទៅនៅរៀន
ឯក្រុងបាត់ដំបងឯនោះ មែនទេហ៎ ?
- បាទ យាយ! តែពេលនេះ សុំច្បាប់គេមកចូលឆ្នាំចិន ។
- អឺ ខំរៀនទៅណ៎អានាង ។ ក្រុមគ្រួសារសន្តានរបស់យើងនេះ គ្មាននរណាបានរៀនខ្ពស់ទេ
មានតែអាហ្វួតម្នាក់ តែឯងមើលវាចុះ! គ្រាន់តែវាមានការធ្វើជាពេទ្យសត្វ មានលុយពេលណា
វាផឹកស៊ី ចាយ ហើយមានប្រពន្ធច្រើន... ហ្អើយ ឈឺក្បាលណាស់! នែ៎ក! ពេលឯងធំឡើង
រៀនចប់ កុំប្រព្រឹត្តត្រាប់តាមបងហ្វួតឯងណ៎ ឮហើយនៅ ? ធ្វើយ៉ាងហ្នឹង ឃើញទេ
វាសប្បាយតែម្នាក់វាទេ តែក្រុមគ្រួសារប្រពន្ធកូនវិញ គ្មាននរណាគេសប្បាយជាមួយសោះ

CHANBOKEO.COM

រួចអាហួតក៏ដែរ មិនដឹងចិត្តវាធ្វើពីស្អី បានជាវាមើលមិនឃើញ ទឹកភ្នែកនិងការឈឺចាប់របស់ប្រពន្ធកូនវាអីបន្តិចសោះអញ្ជឹង ?

ដូនចាស់នោះនិយាយខ្លាំងៗ ហាក់ដូចជាមិនក្រែងចិត្តនរណា ទេ ។ បន្ទាប់មក គាត់ក៏សួរតទៅទៀតថា ៖

- ហើយចុះហេតុអ្វីថ្ងៃនេះ អានាងឯងអាចមកដល់ទីនេះផង ? អា ឃើញវាមិនទុកឯងប្រើនៅផ្ទះវាទេ ?
- បាទ! គឺខ្ញុំមិនបានចូលផ្ទះបងយើងទេ...
- អូហ៍ ហេតុអ្វីមិនចូល ?
- ព្រោះខ្ញុំខ្លាច...
- ហើយចុះនរណាហៅឯងអោយមកផ្ទះអាហួតនេះ ?
- គឺ ខ្ញុំមកខ្លួនឯង... ព្រោះមិនស្គាល់កន្លែងផ្សេងនឹងទៅ ។
- អើ! បើអញ្ជឹង បានជាមកហើយ ចូលអុជធូបជូនដូនតាបន្តិច ទៅណ៎! ព្រោះយើងមានដូនតាខាងឪពុកជាមួយគ្នាទេ ។

ពេលនោះ ដូនចាស់ក៏ដឹកដៃមាណព ឡើងទៅលើផ្ទះភ្លាម ។ នៅទីនោះ គេបានជួបនឹងបុរសចំណាស់មួយរូប ក្នុងវ័យប្រហែល ហាសិប ប្រហាក់ប្រហែលបងយើងដែរ កំពុងពេនភ្នែនវាតវង់ ជា មួយមិត្តភក្តិពីរបីនាក់ទៀត ជុំវិញដបស្រានិងសាច់ក្លែម ។

- អាហួតអើយ! នេះនែ៎អាយូ ប្អូនប្រុសអាយីង វាមកលេង!

ដូនចាស់កូកហៅបុរសនោះ ។

បុរសចំណាស់នោះងើបមុខឡើង មើលមកនាយសុធី ។ ភ្លាម នោះ ដូនចាស់មានប្រសាសន៍ប្រាប់មកសុធីថា ៖

- នេះអាហួតជាបងប្អូនជីដូនមួយនឹងឯងខាងឪពុក ។

សុធីក៏ឱនគោរព ។ ចៃដន្យ បងប្រុសជីដូនមួយម្នាក់នោះ កំពុងទន់បបូរមាត់ ធ្លាក់ភ្នែកបន្តិចហើយ មិនមានពេលមកគួរសម នឹងបងប្អូនណាទេ ។ គាត់គ្រាន់តែញញឹមដាក់សុធីបន្តិច ហើយ ក៏ស្រដីឡើងថា ៖

- អឺៗ! អញ្ជឹង អាយូឯងទៅរកអីស៊ីម៉ាម៉ាត់ទៅវើ៎យ! នៅខាង ក្រោយមានម្ហូប មានបាយច្រើនណាស់ ។ បើមិនទាន់អុជធូបទេ ទៅអុជធូបថ្វាយដូនតាសិនទៅ ។

CHANBOKEO.COM

ចំណែកយើងវិញ សុំពេលផឹកស៊ី បន្តិចសិនវើយ មិនបានគួរសមនឹងឯងទេ ។ ឯងធ្វើម៉េចស្រួល ក៏ធ្វើទៅ !

ថាហើយ គាត់ក៏បែរខ្លួនត្រឡប់ចូលហ្វូងរបស់គាត់វិញទៅ ។ សុធីក៏ដើរតាមក្រោយដូនចាស់នោះ ទៅដល់មុខកន្លែងមួយដែល មានតាំងរូបថតពណ៌ខ្មៅស មានផើងជើងធូបយ៉ាងធំមួយ នឹងមាន សំណែនសព្វមុខពាសពេញតុ ។ គេក៏អុជធូបធ្វើតាមដូនចាស់ ។

នៅក្បែរនោះ មានស្រីក្មេងមួយរូប អាយុស្រករនាយសុធីដែរ កំពុងពទារកនៅដៃ អង្គុយធ្វើមុខក្រញូវ ។ នាងមានរូបរាងស្រស់ ស្អាតណាស់ដែរ ខុសតែមុខចងចិញ្ចើម ធ្វើកិរិយាហាក់ដូចជា កំពុង ទូលពិភពលោកនេះតែម្នាក់ឯងអញ្ចឹង ។ ពេលនោះ សុធីគិតថា នារីនោះប្រហែលជាប្រពន្ធចុងរបស់បងហ្លួតរបស់គេហើយ ។

លុះដូនចាស់នាំសុធីដើរហួសមិនបានណែនាំ មាណវីនោះស្រែក វ៉ាងឡើងថា ៖

- យើ! ចង់ចេញចង់ចូលស្រេចតែចិត្តតែម្តងហើយហ្ន៎! ចង់នាំ អាណាដើរកាត់ពេញផ្ទះ ក៏ស្រេចតែក្បាលវ៉ាល់ ធ្វើឫកមើលតែខ្លួន ហ្អឹងម្ចាស់ផ្ទះអញ្ចឹង...!

ដូនចាស់ជ្រួញចិញ្ចើម មិនតបតអ្វីទេ តែបែរជាអូសដៃនាយ សុធីយកទៅខ្សិបប្រាប់ថា ៖

- នោះហើយជានាងណារាយដែលជាប្រពន្ធចុងរបស់អាហ្លួតនោះអី ឯងឃើញហើយមែនទេ ? គេកំពុងតែសម្តែងឫទ្ធិរបស់គេជាម្ចាស់ ផ្ទះហ្លួងហែងផែនដីហើយ ។ មិនដឹងថា អាហ្លួតវាទៅរើសពីណា មកទេ សំដីបាតផ្សារ ឫកពាបាតសង្គមដល់ហើយ ។ នេះបើកុំតែ បានរូបសម្បត្តិវាយោងបន្តិច កុំអីគ្មាននរណារើសវាយកធ្វើប្រពន្ធ ទេ ។ អញ្ចឹងក៏សមមុខវាហើយ ដែលវាមកបានប្តីចាស់ ប្រមឹក ខ្ជបដូចអាហ្លួតនេះ ព្រោះវាចរិតវាយ៉ាប់បែបហ្អឹងអញ្ចឹង មើលចុះ! គ្រាន់តែអាហ្លួតវាមានការងារជាកូនមន្ត្រីរាជការតូចតាច បុណ្យសក្តិ ត្រឹមពេទ្យសត្វប៉ុនហ្អឹង ក៏ខំធ្វើវាយឫកធំ លើសស្តេចឯកមកពីក្នុងវាំង ទៅទៀត ។

មើលទៅដូនចាស់នោះ ដូចជាមិនចូលចិត្តណារាយប្រពន្ធម្ចាស់ ផ្ទះឡើយ ទើបបានជាគាត់មានសំដីយ៉ាងហ្អឹង ។ សុធីលួចសង្កេត ឃើញថា នារីនោះមិនត្រឹមតែមានកូនតូចទេ តែនាងកំពុងតែមាន ផ្ទៃពោះថែមទៀតផង ។ គេក៏នឹកអនិច្ឆាក្នុងចិត្តតែម្នាក់ឯង ជំនួស នារីម្នាក់នោះណាស់ ៖

- ហេតុអ្វីទៅហ្ន៎ ? នាងនៅក្មេងសោះ បែរជាមកវៀបការជាមួយ

CHANBOKEO .COM

មនុស្សចាស់ដូចឪពុកទៅវិញ ? តើជីវិតនាងទាល់ច្រកយ៉ាងណា ទៅ
ទើបសុខចិត្តមកព្រលែងអនាគតខ្លួនបែបនេះអញ្ចឹង ? ហេតុ
អ្វីគេមិនស្ដាយអនាគតរបស់ខ្លួនឯង ? ឬក៏គេដោះស្រាយតែមួយ ច្រកៗ មួយពេលៗ
ដោយមិនចាំបាច់យកខួរក្បាលទៅគិតអ្វីសំរាប់ ថ្ងៃស្អែក ?
ហើយហេតុអ្វីបានជាគេមានឫកកោងកាច ? តើអតិត កាលរបស់គេនោះវាជូរចត់យ៉ាងណា
បានជាពេលនោះ គេមាន កិរិយាហាក់ដូចជា ពិភពលោកនេះចង្អៀត ពិបាកដកដង្ហើមរបៀប
ហ្នឹង ? មើលទៅមុខគេចុះ មិនខុសអីពីបងយ៉ាវ ប្រពន្ធបងយីង អ្វីបន្តិចសោះ...
គឺជាទឹកមុខរបស់មនុស្សមានចិត្តចង្អៀតចង្អល់ អាត្មានិយមទ្រឹស្ដីរកលេខដាក់គ្មានទេ ។

ប៉ុន្តែ សុធីគ្មានពេលនឹងរកចម្លើយនោះទេ ព្រោះដូនចាស់បាន
នាំមាណពមកដល់ចង្ក្រានបាយទៅហើយ ។

- អានីហ្នុំស ! មកនេះ ! ដួសបាយដួសសម្លអោយឪពុកមា ឯងបន្តិចមើល ។ នែះ !
វាទើបតែមកពីបាត់ដំបង មកលេងក្រុម គ្រួសារយើងណ៎ា !

ភ្លាមនោះ សុធីឃើញមាណវីដែលលួចជូតទឹកភ្នែក មុននេះ បន្តិចនោះ
ដើបឡើងលាងដៃហើយស្ទុះមករៀបតុ ដួសបាយ ដួសម្ហូបអាហារទទួលនាយភ្លាម ។
គេលួចគិតក្នុងចិត្តថា ៖

- នាងមានឈ្មោះនី ទេតើហ៍ ! ស្ដាប់ទៅដូចជាមិនមែនកូនចៅចិន
ទេ ! មិនដឹងថា នាងជាប់សាច់ឈាមនឹងយើងបែបណា បានជា ដូនចាស់នោះប្រាប់នាងថា
យើងជាឪពុកមារបស់នាង ?

ឯមាណវីវិញ គិតតែឈ្ងោកធ្វើការមិនព្រមងើបមុខនិយាយរក នរណាទេ ។ ពេលនោះ
សុធីនឹកចម្លែកក្នុងចិត្តទៀតហើយ ៖

- ស្រីក្មេងម្នាក់មុននេះអំបាញមិញមានមាត់ មានសំដី ឮខ្លាំងជ្រុល
(សុធីគិតក្នុងចិត្ត) ដល់ស្រីម្នាក់នេះវិញបែរជាស្ងាត់ជ្រុល មិនរួស រាយអីបន្តិចសោះ ។ គិតទៅ
មនុស្សក្នុងផ្ទះនោះចម្លែកណាស់ហ្ន៎ !

ភ្លាមនោះ ដូនចាស់ទាញដៃមាណពយើង ៖

- នែះ ! អង្គុយចុះមក បរិភោគបាយទៅ ទាន់ក្ដៅៗ !
- ហើយចុះលោកយាយនោះ បាទ ?
- អឺ ! យាយក៏ទទួលទានជាមួយឯងដែរ ព្រោះយាយកំពុងតែរក គ្នាបរិភោគនេះឯង ។

CHANBOKEO.COM

បន្តិចមក គាត់ក៏ងាករកធិតាមួយរូបនោះ ៖
- អឺនែក អានីអើយ! មកនេះវិញមើល៍ ចៅ!
នារីក៏ដើបដើរត្រឡប់មកវិញ ។ សុធីលួចសម្លឹងមុខនាងឃើញ
ធិតាមានមុខមាត់ស្រស់ស្អាតណាស់ ស្អាតជាងណាលីដែលគេធ្លាប់ លួចស្រឡាញ់នោះទៅទៀត
ខុសតែម្យ៉ាងទេ គឺនាងមិនចេះញញឹម អ្វីបន្តិចសោះ! ទឹកមុខនាងក្រៀមក្រំអស្ចារ្យ
ឯភ្នែកវិញដក់ដោយ តំណក់ទឹកភ្នែក ថ្វីបើនាងលួចផ្ចិតចេញញឹកញាប់ក៏ដោយ ក៏មិនអាច
លាក់ពីក្រសែភ្នែកសុធីបានឡើយ ថានាងមិនបានយំ ។
- ទៅយកចានដួសបាយមកបរិភោគជាមួយយាយមកចៅ!
ដូនចាស់បង្គាប់នារី តែនាងបែរជាគ្រវីក្បាលហើយឆ្លើយថា៖
- ខ្ញុំចាំបរិភោគក្រោយគេចុះ យាយ ព្រោះខ្ញុំមិនទាន់ឃ្លានទេ ។
- កុំរៀនអត់បាយដូច្នេះណា៎! ប្រយត្ន័វាឈឺទៅ! អូហ៍ យាយ ភ្លេចសួរអោយឈឹង!
ហើយឯងទាំងពីរស្គាល់គ្នាហើយមែនទេ?
សុធីលួចសម្លឹងនារីភ្លៀកៗ ស្រាប់តែប្រទះឃើញនាងលួច
ចោលកន្ទុយភ្នែកត្រឡប់មកនាយវិញដែរ ។ លុះប្រទះនឹងកែវភ្នែក របស់នាយយើង
ធិតាក៏ងាកបែរចេញ យ៉ាងរហ័សហើយគ្រវីក្បាល តែមិនឆ្លើយថាម៉េចទេ ។ សុធីឃើញដូច្នោះ
ក៏ស្រដីតបដូនចាស់
ទៅវិញថា ៖
- គឺ យើងមិនដែលជួបគ្នាទេ លោកយាយ!
ដូនចាស់ឮដូច្នោះក៏ញញឹមឡើង រួចមានប្រសាសន៍ ៖
- បើអញ្ចឹង ស្គាល់គ្នាទៅ! នេះ អាយូ ប្អូនជីដូនមួយរបស់ប៉ា ឯងណា៎អានី!
រួចហើយ គាត់ក៏ងាកមកនរ:រួចស្រដីថា ៖
- នេះគឺនាងមណី ជាកូនស្រីច្បងរបស់អាហ្វួត ។ ម៉ែនាងនីជា ប្រពន្ធដើមបង្អស់របស់អាហ្វួត
តែបានស្លាប់តាំងពីយូរហើយ ។
ភ្លាមនោះ អ្នកទាំងពីរលួចចោលភ្នែកដាក់គ្នាទៅវិញទៅមក
ម្តងទៀតរួចហើយក៏នៅអេះអុញរៀងៗខ្លួន ត្បិតគេមានអារម្មណ៍
ប្លែកៗចំពោះគ្នាយ៉ាងណាមិនដឹងទេ ។ ការពិត នរ:យើងកំពុង
ចាប់អារម្មណ៍ចំពោះនារីមួយរូបនេះណាស់ តាំងពីវិនាទីដំបូងដែល គេឃើញនាងម្ល៉េះ ។

CHANBOKEO.COM

ក្នុងចិត្តរបស់គេ មិនបានគិតថានាងជាក្មួយ ស្រីរបស់គេទេ តែបែរជាមានអារម្មណ៍ថា មាណវីជាទេពធិតាមួយ រូបដែលធ្វើអោយបេះដូងរបស់គេ រន្ធត់ញាប់ញ័រយ៉ាងចម្លែកខុស ធម្មតា កាន់តែលួចគន់យូរ កាន់តែលួចចាប់ចិត្តប្រតិពទ្ធ័ខ្លាំងឡើង តែម្តង ។ នេះគេមិនទាន់ជួបនាងពេញមួយថ្ងៃផង គេចាប់ចិត្តប៉ុន ហ្នឹងទៅហើយ... ចុះបើគេមានពេលស្គាល់គ្នាច្បាស់ជាងនេះតទៅ ទៀត តើគេនឹងចាប់ចិត្ត ចំពោះនាងយ៉ាងណា ? តើនេះជានិស្ស័យ ឬជាបណ្តាសារបស់ព្រហ្មលិខិត ?

ដោយនឹកខ្មាសនឹងក្រសែភ្នែករបស់សុធី ដែលចេះតែតាមលួច សម្លឹងនាងភ្លៀកៗ មិនព្រមដាក់សោះ ធិតាក៏ទាញក្រមាបាំងមុខ រួចដើរឈ្ងោកមុខគេចចេញទៅធ្វើការឯចង្ក្រានវិញបាត់ទៅ ទុកឲ្យ នរៈយើងនៅបរិភោគបាយតែពីរនាក់ដូនចាស់មួយរូបនោះ ទាំងចិត្ត សោកស្តាយដែលគេមិនបានឃើញមុខនាងតទៅទៀត ។

- លោកយាយត្រូវជាយ៉ាងម៉េចហ្នឹងពួកយើងដែរ បាទ ?

សុធីសួរដូនចាស់ ។

- អើ! ជាសាច់ញាតិដូចតែគ្នាហ្នឹងណា៎! តែឯងត្រូវហៅយើងថា អ៊ីមិនមែនយាយទេ ។ តាមពិតអ៊ីនោះឈ្មោះ គិមហួយ ណា៎!

- ពុទ្ធោ អោយខ្ញុំហៅអ៊ីធ្វើម៉េចសមរម្យ បើខ្ញុំនៅក្មេងម្លឹងៗនោះ ?

- បើខ្មាសមាត់អញ្ចឹង ឯងចង់ហៅអីក៏ហៅទៅ អោយតែហៅ ចេញពីក្នុងចិត្តមក ថាយើងជាសាច់ញាតិនឹងគ្នា កុំអោយដូចអ្នកខ្លះ និយាយជាមួយមនុស្សចាស់ អត់ឈ្មោះហើយព្រហើនឆ្គាំឆ្គងនោះ អោយសោះ ឮហើយនៅ ?

ដូនចាស់មានប្រសាសន៍ផង លួចចោលកន្ទុយភ្នែកទៅក្នុងផ្ទះ វិញផង ទំនងចង់សំដៅរកនាងណារាយហើយ ។ មើលទៅ ដូន ចាស់ជាមនុស្សរួសរាយហើយមានសន្តានចិត្តល្អទូលំទូលាយ ប៉ុន្តែ ចៃដន្យ គាត់មិនមែនជាសមាជិករស់នៅក្នុងផ្ទះនោះទេ គឺគ្រាន់តែ មកលេង ពេលសែនដូនតាចូលឆ្នាំចិននេះប៉ុណ្ណោះ ។ ផ្ទះយាយ គិមហួយក៏នៅមង្គលបុរីដែរ មិនឆ្ងាយប៉ុន្មានពីផ្ទះប៊ុហួតទេ ។

លុះបរិភោគបាយហើយ យាយគិមហួយក៏ប្រាប់សុធីអោយជូន គាត់ទៅផ្ទះវិញ ព្រោះគាត់ទើសទាល់ចង្អៀតចិត្តនឹងនាងណារាយ ប្រពន្ធចុងម្ចាស់ផ្ទះនោះដល់ក៏រិតហើយ ។

CHANBOKEO.COM

ចំណែកប៊ុហ្វួតវិញ មិនខ្វល់ថានរណាទៅនរណាមកទេ គឺខ្វល់តែចានដាក់គ្រឿងក្លែម
និងកែវស្រារបស់គាត់ ជាមួយពួកម៉ាកមួយហ្វូងនោះតែប៉ុណ្ណោះ ។

បន្តិចមក សុធីក៏សុំខ្ចីកង់ម្ចាស់ផ្ទះឌុបដួនចាស់ចេញទៅ មួយ ស្របក់
គេក៏ត្រឡប់យកកង់មកសងវិញ ។ ថៃដន្យ អ្នកក្នុងផ្ទះ ប៉ុន្មាននាក់
នោះហាក់ដូចជាគ្មាននរណាខ្វល់ខ្វាយនឹងវត្តមានរបស់
មាណពដែលដើរចេញចូលផ្ទះប៊ុហ្វួតពេលនោះទេក្រៅ តែពីប្រពន្ធ
ចុងម្ចាស់ផ្ទះតែម្នាក់ដែលអង្គុយសម្លឹងសម្លក់ភ្ញៀវគ្រប់ៗគ្នា មិនថា នរណាជានរណាទេ ។
តាមមើលកិរិយាទៅ ទំនងដូចជានាងកំពុង តែរាប់ឈ្មោះភ្ញៀវគិតក្បាលការថ្ងៃក្រោយហើយ ។

សុធីមិនចូលចិត្តក្រសែភ្នែករបស់ប្រពន្ធចុង ម្ចាស់ផ្ទះនោះទេ
ព្រោះពេលគេឃើញក្រសែភ្នែកនោះពេលណា គេក៏នឹកស្រម័យទៅ
ដល់បងថ្លៃរបស់គេភ្លាមតែម្តង រួចហើយគេមានអារម្មណ៍ថា មាន
មេបិសាចមេធ្មប់កំពុងតែចង់ច្របាច់ក បំរុងអោយរូបគេស្លាប់សាជា ថ្មីម្តងទៀតហើយ ។ ប៉ុន្តែ
នរៈក៏មិនបាននៅប្រណាំងប្រជែងយក ឈ្នះក្រសែភ្នែកនោះធ្វើអ្វីដែរ ព្រោះគេ
មិនមែនជាអ្នករស់នៅផ្ទះ នោះឯណា ។ បន្តិចមក សុធីក៏គេចទៅក្រោយផ្ទះ ក្នុងចិត្តនឹកថា
ទៅរកនាងមណី ប៉ុន្តែបែរជាឃើញតែស្រីបំរើពីរបីនាក់នោះកំពុង រៀបអីវ៉ាន់ទុកដាក់
បាត់តែរូបមាណវីម្នាក់នោះទៅណាមិនដឹង ។

កាលបើឃើញនាយឈររេរានៅទីនោះយូរ ក្មេងស្រីបំរើម្នាក់ សួរភ្លាមថា៖
- ពូមករកបងមណី ក្មួយស្រីពូឯងហ្នឹងមែនទេ ?

ចំចំណុចកើតែម្តង! សុធីគេចមិនរួច ក៏ឆ្លើយបន្លប់តបទៅ នាងវិញ ធ្វើព្រងើយ ថា ៖
- មែនហើយ! ទើបតែជួបគ្នា មិនទាន់បាននិយាយអីម៉ាម៉ាត់សោះ ស្រាប់តែបាត់មុខតែម្តង ។
- ហើយចុះពូឯងប្រញាប់រកគាត់ធ្វើអី មើលតែគ្មានពេលជួបគ្នា ទៀតអញ្ចឹង ?
- ព្រោះតែវាអត់ពេលហ្នឹងហើយ បានជាចង់មកជួបនាងហ្នឹងណាំ!
ខ្ញុំត្រូវត្រឡប់ទៅបាត់ដំបងវិញខានស្អែកនេះហើយ ។
- អូហ៍! បើអញ្ចឹង ចុះទៅមាត់កំពង់ទៅ គាត់ទើបតែចុះទៅមុជ ទឹកអំបាញមិញនេះឯង ។

សុធីឮដូច្នោះ ក៏ញញឹមដាក់នាងតូចម្នាក់នោះ ដែលឆ្លើយប្រាប់
តម្រុយអោយនាយទៅរកនារីស្រស់ស្អាតមួយរូបនោះ ។ គេក៏បែរ

CHANBOKEO.COM

ខ្លួនចុះដើរសំដៅមាត់កំពង់យ៉ាងរហ័សតែម្តង ។ ភ្លាមនោះ អ្នកបំរើ ម្នាក់រាងចំណាស់បន្តិច យកដៃទៅជន្លរកខោកក្បាលក្មេងស្រីម្នាក់ នោះ ហើយស្រដីថា ៖
- ភ្លើណាស់ឯងនេះ! នៅមិននៅ យកជ័រភ្លៅត្បៀតត្បៀកហើយ!
- ត្បៀតត្បៀករឿងអីទៅមីង?
- គឺត្បៀតមកពីរឿងឯងទៅប្រាប់មនុស្សប្រុសកម្លោះ អោយទៅ លួចមើលស្រីក្រមុំចុះងូតទឹកស្ទឹងនោះអី?
- កម្លោះស្អី? ក្រែងគាត់ជាមាក្ខុយនឹងគ្នាទេតើ!
- យី! ល្ងើណាស់ឯងនេះ! នែ៎! យ៉ាងម៉េចយ៉ាងម៉ា បើនាង មណីត្រូវរំពាត់វិញ អញថា ឯងនេះហើយជាដើមហេតុ ។
- ហ្អ៎ក! ម៉េចបានថែមណីគាត់ត្រូវរំពាត់ទៅវិញ?
- អើ! ព្រោះតែទីនេះមានភ្នែកទីទុយម៉ាគូអង្គុយសម្លក់ពីលើផ្ទះ មក ចាំតែមើលបំណាំនាងមណីនោះ ឯងមិនឃើញទេ? អោយ តែចៅហ្វាយប្រុសបែរខ្នងមិនទាន់ទេ... ទីទុយនោះវាអើតកបើក ភ្នែកក្រឡោតមកហើយ!
- ទីទុយណាមួយទៅ មីង? ម៉េចមិនឃើញអញ្ចឹង?
- ម៉េចក៏ថាមិនឃើញ? ទីទុយមួយហ្នឹង វាមានភ្នែកក្រឡោតៗ ខុសគេក្នុងផ្ទះនេះនោះអី ឯងមិនស្គាល់ទេ?
- អូហ៍... ទីទុយមួយហ្នឹងប៉ែស្ស? ប៉ែសៗ! ខ្ញុំដឹងហើយ!

នាងតូចនោះស្រដីផង សើចកខឹកផង លួចបែរមើលទៅខាង លើផ្ទះផង ធ្វើកិរិយាហាក់ដូចជាហួសចិត្តយ៉ាងណាមិនដឹង ។

នៅមាត់កំពង់...

សុធីដើរចុះទៅក្នុងស្ទឹងធ្វើកិរិយាស្ងៀមស្ងាត់ ភ្នែករំពៃរកមើល នារីដែលបេះដូងរបស់គេកំពុងដង្ហោយហៅ ។ ភ្លាមនោះ គេប្រទះ ឃើញនារីម្នាក់ស្លៀកសារុងចងពុងពណ៌ស្វាយចាស់ កំពុងអង្គុយ លើទូក សំយុងជើងទៅក្នុងទឹកស្ទឹង ឈ្ងោកយកផ្តិលដងទឹកចាក់ លើខ្លួនតិចៗ បន្តើរៗ ទំនងហាក់ដូចជាចង់ឲ្យសរសៃទឹកនោះមក អង្អែលថ្នាក់ថ្នមខ្លួននាង អោយត្រជាក់ក្សេមក្សាន្ត ។ មើលចុះ! មាណវីមានសាច់សស្អាត រាងស្តើងខ្ពស់ស្រឡះ មុខមាត់ក៏មាន សោភណ័គួរចាប់ចិត្តបេតីប្រតិពទ្ធ័បំផុត ប៉ុន្តែ... គួរអោយស្តាយ

CHIANBOKEO.COM

នាងបែរជាមានទឹកមុខស្រពាប់ស្រពោន ខ្វះភាពញញឹម ខ្វះភាព រីករាយទៅវិញ ។ ចំណែកនៅលើសាច់ខ្នងនិងដើមដៃរបស់នាង វិញ បានបង្ហាញនូវស្នាមរំពាត់ដាច់ដាំពាសពេញខ្លួនទាំងអស់ ។ រីឯរង្វង់ភ្នែកទាំងគូរបស់នាងក៏ដក់ជាប់នូវទឹកភ្នែក ដែលហូរស្រក់ ចុះមកឥតស្រាកស្រាន្ត ធ្វើឲ្យសុធីរិតតែចង់ដឹងណាស់ថា តើនាង កំពុងមានវិបត្តិអ្វីខ្លះនៅក្នុងជីវិតរបស់ធិតា ។ ហេតុអ្វីក៏នាងទទួល ទារុណកម្មធ្ងន់ធ្ងរដល់ម្លឹងផងនោះ ? គេឈរផ្ទៃកនឹងគល់ដូងដែល ដុះទេរទៅក្នុងទឹក លួចសម្លឹងគយគន់ពិនិត្យសោភ័ណនារីផង លួច ពិចារណា ហេតុផលផង ថែមទាំងគិតរកឱបាយណាដែលអាចឲ្យ គេបានទៅនិយាយស្និទ្ធស្នាលនឹងកល្យាណីដ៏សោភាមួយរូបនោះ ។

ពេលវេលាកន្លងទៅយ៉ាងយូរ...

ធិតានៅតែមិនដឹងថា មានប្រុសកម្លោះមកលួចឈរគយគន់ សម្ផស្សរបស់នាងពីចម្ងាយទេ ។ ពេលនោះ ព្រះអាទិត្យកំពុងធ្វើ ដំណើរទៅរកលាក់ខ្លួនពួនផ្ទំសំរាកកាយាហើយ ។ ផ្ទៃមេឃស្រកា នាគបានចោលពន្លឺពណ៌មាសមកលើរូបមាណវី ធ្វើអោយសោភ័ណ របស់ធិតាកាន់តែអណ្តែតលេចធ្លោឡើង នៅចំពោះមុខបុរសយើង យ៉ាងល្អត្រកាល ។ ភ្លាមនោះ សុធីមានអារម្មណ៍ថាបេះដូងរបស់គេ កំពុងតែរណ្តំប្រគំសៀងស្នេហាយ៉ាងចម្លែកមួយ ដែលគេមិនដែល មានអារម្មណ៍បែបនេះពីមុនមកម្តងណាឡើយ ។ គេលួចញញឹម ត្រេកត្រអាលនឹងសោភ័ណនារីយ៉ាងស្ងៀមស្ងាត់តែម្នាក់ឯង ។

បន្តិចមក នារីក៏បែរមុខងាកមកខាង ក៏ប្រទះនឹងក្រសែភ្នែក របស់កម្លោះយើងតែម្តង ។ នាងភ្ញាក់ព្រើត ងាកស្រវាទាញក្រមា យកមករុំដណ្តប់ខ្លួនយ៉ាងប្រញាប់ប្រញាល់តែម្តង រួចហើយក៏រេខ្លួន បំរុងដើបដើរចេញពីទូកបំរុងឡើងដីគោកវិញ ។ សុធីឃើញដូច្នេះ ក៏ស្ទុះរឹង ទៅហក់ទៅជិត ស្កាត់ដំណើររបស់មាណវីភ្លាម ៖

- សួស្តី មណី! (សុធីហៅឈ្មោះមាណវីចំៗ)

ធិតាសម្លឹងមុខនរ: ទាំងស្រឡាំងកាំង រួចនៅអង្គុយទ្រឹងលើ ទូក មិនឃើញឆ្លើយតបអ្វីនឹងសុធីវិញទេ ។ ភ្លាមនោះ មាណពហក់ ឡើងទៅលើទូក ទាញច្រវ៉ាភ្លាម ។ ស្រាប់តែ...

- នែ៎! ធ្វើអីហ្នឹង ? (មាណវីស្រែកអោយនរ:យើង)

- គឺចង់អុំទូកនាំស្រីស្រស់សោភាដើរលេងតាមដងស្ទឹង ។

CHIANBOKEO.COM

សុធីឆ្លើយវិញ ទាំងលួចញញឹមដាក់នាងផង ។
- ឆ្កួតទេ ? ធ្វើអីអញ្ចឹង ? វាមិនសមរម្យទេណា៎!
តែសុធីមិនស្ដាប់ទេ ។ គេបែរជាទាញច្រវាចែវយ៉ាងរហ័ស ។
- នែ៎! ឈប់ទូក! ខ្ញុំត្រូវត្រឡប់ទៅផ្ទះវិញហើយ (មណីវាចា)
- ត្រឡប់ទៅធ្វើអី ? យើងនៅជជែកគ្នាសិន មិនបានទេ ?
- ជជែកគ្នា បែបនេះហ្ន៎ស ? តើភ្នែកអ្នកផង គេនឹងគិតថាយ៉ាង ណាបើសិនគេឃើញ... នឹងទេ ថាអ្នកកំពុងនាំរឿងរ៉ាវមិនល្អដល់
ជីវិតរបស់ខ្ញុំហើយ!
មាណវីនិយាយផង ជ្រួញចិញ្ចើមផង ធ្វើមុខទំនងដូចជាខឹង
តែក៏ដូចជាភ័យយ៉ាងណាមិនដឹង ។ សុធីឃើញដូច្នោះ ក៏បញ្ឈប់ ច្រវា
រួចហើយក៏ចែវអែបខាងត្រឡប់ទៅកន្លែងដើម ។
- សូមទោសណា៎ ដែលខ្ញុំធ្វើអោយនាងភិតភ័យ ។ ការពិត ខ្ញុំគ្រាន់ តែចង់លេងទេតើហ៏!
(សុធីស្រដីបន្ធូរបរិយាកាស)
តែមាណវីមិនបានធ្វើកិរិយាសប្បាយចិត្តអ្វីនឹងការដែលបានជួប មុខនាយយើងទេ ។
គ្រាន់តែទូកអែបខាងមិនទាន់ដល់ច្រាំងផង នារីក៏ហក់ចុះទឹកប្រូង ដើរលុយទឹកសំដៅច្រាំង
យ៉ាងលឿន ។ រំពេចនោះ បុរសយើងក៏ស្រែកពីក្រោយទៅថា ៖
- អីក៏ខ្លាចសុធីម្ល៉េះ ? ខ្ញុំនេះមិនមែនយក្សទេណា៎! កុំរត់គេចទៅ លឿនពេក ប្រយត្ន័ដួល!
សុធីស្រដីមិនផុតពីមាត់ផង មាណវីក៏ដួលព្រូសទៅលើដីមាត់ ច្រាំងដូចនាយថាមែន ។
មាណពភ្ញាក់ព្រើត ស្ទុះហក់ចុះពីទូកទៅ រកជួយនាងលើកនាង ស្រាប់តែត្រូវធិតាគំហកអោយថា
៖
- នែ៎កុំប៉ះខ្ញុំ! មនុស្សមាត់ស្អុយ! ប៉ិនដាក់ទំនាយគេបែបនេះ មិន គួរអោយរាប់ជាគ្នាទេ ។
ថាហើយ នាងដើបសម្លក់សុធីដោយក្រសែភ្នែកយ៉ាងមុតទំនង ដូចជាខឹងហើយខ្មាស់ផង ។
ចៃដន្យ នរៈមិនបានខឹងតបតនឹងនាង ទេ បែរជាស្រដីបន្លប់ទៅវិញថា ៖
- បើសុធីមានមាត់ទិព្វ ប៉ិនទាយឆុតអញ្ចឹងមែន សុធីសូមដាក់
ទំនាយសាថ្មី ថាសូមអោយមណីនឹងជួបគ្នាជាមួយសុធីជានិច្ច ព្រឹក ល្ងាចយប់ថ្ងៃ
ចាប់តាំងពីថ្ងៃនេះតទៅរហូតដល់ថ្ងៃស្លាប់ មិនអោយ គេចមុខគ្នារួចមួយថ្ងៃណាបានឡើយ ។

CHANBOKEO.COM

ស្រាប់តែ មាណវីក៏ងាកសម្លក់នរៈម្តងទៀតកាលបើឮប្រយោគ មួយនេះភ្លាម ។ សុធីឃើញហើយ ក៏ញញឹម ធ្វើមុខរាងកំប្លែងតប ទៅវិញ ។ ធិតាយើងនឹកខ្មាសចំពោះក្រសែភ្នែករបស់មាណពពេក ក៏ដើបឡើងដើរគេចទៅ ទាំងប្រឡាក់ដីស្រមក ។ បុរសក៏ឈរ លបលួចញញឹមតែម្នាក់ឯង ហើយបែរសម្លឹងតាមមើលមាណវីពី ក្រោយរហូតដល់ធិតាឡើងទៅលើផ្ទះបាត់ទៅ ។

យប់នោះ សុធីនៅរេរាៗ មិនចង់ត្រឡប់ទៅគេងនៅវត្តវិញទេ ព្រោះជើងរបស់គេហាក់ដូចជាកំពុងត្រូវជ័រឆក់ ស្អិតជាប់នឹងផ្ទះបង ហ្លួតរបស់គេទៅហើយ ។ ចំណែកឯម្ចាស់ផ្ទះគិតតែពីរឿងពួកម៉ាក មិត្តភក្តិគ្នីគ្នារបស់គាត់ ម្តងនៅផឹកជុំគ្នានៅផ្ទះនេះ ម្តងលើកគ្នាទៅ ផ្ទះក្បែរនោះ ទៅមកៗ ហាក់ដូចជាមិនគិតខ្វល់ពីនរណាឡើយ ។

សុធីក៏នៅអង្គុយលេងនៅខាងមុខផ្ទះជាមួយញាតិខ្លះដែលនាយ ធ្លាប់ស្គាល់ពីមុនមក ។ យប់បន្តិច គេក៏នឹកភ្នកទៅដល់ធិតាយើង ។ គេក៏លួចគេចទៅឈរនៅខាងក្រោយផ្ទះ លួចឈរមើលពីដីទៅ ខាងលើរានហាលដែលបែរទៅស្ទឹង ក្រែងលោឃើញធិតានៅទី នោះ ប៉ុន្តែគេមិនបានប្រទះនាងសោះ ។ គេក៏ដើរត្រឡប់មកខាង មុខផ្ទះវិញ ។ សុធីនៅសំកុកមួយសន្ទុះមិនអស់ចិត្ត ក៏ដើរឡើងទៅ លើផ្ទះធំ ស្រាប់តែគេប្រទះឃើញស្រមោលមនុស្សពីរនាក់នៅឯ ចង្ក្រានបាយ ក៏ស្ទុះទៅមើលភ្លាម ។ ភ្លាមនោះ គេបានជួបណារាយ ប្រពន្ធក្មេងរបស់បងហ្លួតនោះ កំពុងស្រវាបោចសក់មណីនារីកំពូល ដួងចិត្តរបស់គេ ថែមទាំងយាររំពាត់នៅដៃម្ខាងទៀត វាត់លើខ្លួន នាងលាន់ខ្ទាប់ៗ រួចជេរប្រទេចញាប់មាត់ផងថា ៖

- យើ! នាងឯង! ថ្លើមធំណាស់ហ្ន៎ស ឥឡូវហ្នឹង ? គ្រាន់តែឪ ពុកជាប់រវល់មានភ្ញៀវបន្តិច ក៏តាំងលួចគេចពីការងារក្នុងផ្ទះ ទៅ ណាត់ជួបប្រុសនៅមាត់ស្ទឹងផងហ្ន៎ស ស្រីល្អ ?

មាណវីខំបម្រះពីដៃម្តាយចុងហើយតបថា ៖

- អត់ទេ មីង! ខ្ញុំមិនបានណាត់ជួបនរណាទេ គឺខ្ញុំចេញទៅដងទឹក តែម្នាក់ឯងទេតើហ៎!

តែនាងណារាយនៅតែមិនបញ្ឈប់ដៃទេ គិតតែស្រវាបោចសក់ មាណវីគ្រវី ហើយយាររំពាត់វាត់យ៉ាងញាប់មិនដាក់ដៃលាន់ខ្ទាប់ៗ ស្ទើរសង្អៀរត្រចៀក ៖

CHANBOKEO.COM

- យ៉ស! តមាត់នឹងយើងផងឬ នាង ? មិនបាច់កុហកយើងទេ យើងឃើញនឹងភ្នែករបស់យើង
ឃើញឯងជិះទូកសាសងគ្នាទៀត ផង ។ ឯងនេះ មុខក្រាស់ណាស់ បានតែវ៉ៃអោយងាប់!
វ៉ៃអោយ ងាប់ៗ មីកូនកញ្ជះគេ!

សុធីឃើញហេតុការណ៍ដូច្នេះភ្ញាក់ផ្អើលខ្លាំងណាស់ ។ គេទ្រាំ បញ្ឈរភ្នែក
អោយម្តាយចុងវាយនាងមណីតទៅទៀតមិនបានទេ ព្រោះវាហាក់ដូចជាទារុណភ្នែកពេកក្រៃ ។
មាណពក៏យកខ្លួនទៅរង រំពាត់ជំនួសមាណវី ហើយក៏យកដៃចាប់រំពាត់កន្ត្រាក់យកចេញពី
ដៃរបស់បងថ្លៃស្រីនោះចេញ ព្រមទៅស្រែកឃាត់ថា ៖

- ឈប់វាយនាងទៅ បងស្រី! នាងមិនបានធ្វើអ្វីខុសទេ ហេតុអ្វី
បានជាមកត្រូវរំពាត់រហោមរហាមដូច្នេះផង ?

ណារាយងើបមុខឡើង សម្លក់សុធីសឹងស៊ីសាច់ ៖

- ហើយចុះឯងជាស្អីដែរ មកហ៊ានតដៃ តមាត់អញបែបនេះ ?
- គឺខ្ញុំជាមនុស្សបាទ! ឈ្មោះ សុធី មានសតិស្គាល់ខុសនិងត្រូវ
មិនដូចអ្នកខ្លះនោះទេ..!
- ឯងចង់ថាអោយអញថាអត់សតិមែនទេ ?
- បើបងស្រីចង់លើកដាក់ខ្លួនក៏យកទៅ! សុធីក៏មិនកំណាញ់ដែរ!
- ដើ! អាស្អីគេនោះ ព្រហើនណាស់តើហ៍! ហើយឯងដឹងទេ ថា
ឯងកំពុងតែនិយាយជាមួយនរណាគេដែរ ?
- ថីក៏មិនដឹង! ដឹងថា ខ្ញុំកំពុងនិយាយជាមួយមនុស្សដែលចេះតែ ប្រដៅគេ
តែភ្លេចប្រដៅខ្លួនឯង ។
- ចុម! អានេះមាត់ធំណាស់តើហ៍ ហ៊ានជេរអញផងហ្ន៎ស ?
- នែ៎! បងស្រី កុំប៉ិនបង្កាច់ពេកមើល ។ សុធីអត់មានជេរម៉ាម៉ាត់ ណាទេ បាទ!
កុំនិយាយបែបនេះ នាំតែបាបធ្លាក់នរកទាំងរស់ទេ លោកអើយ!
- អាព្រហើន! នេះឯងមិនទាន់ទទួលទោសទេ ដែលឯងទៅលួច
ណាត់គ្នាអុំទូកនៅស្ទឹងជាមួយនាងមណីតែពីរនាក់ ។ ពេលនេះ បើ បងហ្លួតគាត់ដឹង
គាត់នឹងវាយឯងបាក់ឆ្អឹងជនីរមិនខាន ។
- ខ្ញុំថា បើបងហ្លួតគាត់ដឹង ហើយយករំពាត់មកវាយវាត់កូនចៅ ទាំងទទឹងទទែងនោះ
ក៏ព្រោះតែគាត់ត្រចៀកស្រាល ជឿសំដីអុជ អាលចាក់ចុចរបស់អ្នកខ្លះ ។

CHANBOKEO.COM

- ឯង! បិទមាត់! នាយឈ្លើយ! (នាងណារ៉ាយគំហក)
- រឿងអីត្រូវបិទផង បាទ?
- អាងាប់! យើងមិនអោយឯងរួចខ្លួនទេ!

និយាយហើយ ណារាយបែរសម្លក់សុធីសឹងស៊ីសាច់ រួចក៏ស្ទុះដើរតាំងៗចេញទៅយ៉ាងលឿន ។ សុធីមើលតាមពីក្រោយនឹកហួស ចិត្តតែម្នាក់ឯង ៖
- ហេតុអ្វីស្ត្រីក្មេងមួយរូបនេះ កាចឆ្នាសទទឹងទិសយ៉ាងនេះ? ឬក៏គេបរិភោគស្រាដូចបងហួតដែរទេដឹង បានជា...?

ភ្លាមនោះ គេងាកមករកនាងមណី ឃើញនាងអង្គុយទ្រោប មុខទៅនឹងជញ្ជាំង ។ នៅលើខ្លួននិងដៃជើងរបស់នាង មានស្នាម ឈាមហូររឹមៗតាមស្នាមរំពាត់ថ្មី លើស្នាមរំពាត់ចាស់ដែលមិនទាន់ រលប់បាត់ពីស្បែកនៅឡើយ ។ គេហាក់ដូចជានឹកអាសូរនាងខ្លោច ចិត្តតែម្តង កាលបើយល់នូវភាពទារុណដែលនាងបានទទួល ចំពោះមុខនាយយ៉ាងប្រត្យ័ក្សពេលនោះ ។ ពាក្យពេចន៍រយលានវាចាក៏មិនអាចរៀបរាប់បានស្មើនឹងសេចក្តីអាណិតអាសូររបស់គេចំពោះ នារីពេលនេះបានឡើយ ។ គេរន្ធត់ចិត្តជំនួសនាងក្រៃណា ព្រោះគេ ក៏ធ្លាប់ហែលឆ្លងកាត់ជីវិតរបៀបនេះមិនខុសគ្នាប៉ុន្មានពីមាណវី ឡើយ ។ សុធីក៏ដាក់ខ្លួនអង្គុយចុះក្បែរនាង ហើយស្រដីថា ៖
- ម៉ោះ! ដើបទៅខាងក្នុងផ្ទះវិញ ចាំខ្ញុំលាបប្រេងកូឡាអោយណ៎ា ក្រែងលោបានគ្រាន់បើ!

ពេលនោះរូបកាយធិតាយើងមានសភាពទ្រុឌទ្រោមស្ទើរតែដើរ មិនរួចទៅហើយ ។ សុធីឃើញនាងមានដៃត្រជាក់ស្រេប ទឹកមុខ ស្លេកស្លាំងខុសធម្មតា ថែមទាំងឃើញនាងញ័រខ្លួនចំប្រប់ដូចកូន សត្វធ្លាក់ទឹកដូច្នោះឯង ។ គេក៏ស្ទុះទៅយកក្រមាមួយមកដណ្តប់ អោយធិតាហើយក៏លើកគ្រាហ៍នាងឡើងដើរចូលផ្ទះវិញ ។ វីមាណវី វិញក៏បណ្តោយខ្លួន អោយសុធីជួយគ្រាហ៍តាមសម្រួល មិនឃើញប្រកែកតបតអ្វីជាមួយនាយ ដូចកាលពីព្រលប់ឡើយ ទំនងដូចជានាងកំពុងត្រូវការមនុស្សជួយនាងហើយ ។

គ្រាន់តែឈានដើរបានពីរបីជំហាន ស្រាប់តែអ្នកទាំងពីរភ្ញាក់ វាក់អើនឹងវត្តមានរបស់ប៉ិហួត ដែលនៅឈរច្រត់ចង្កេះមាត់ទ្វារ រាំងផ្លូវអ្នកទាំងពីរ ព្រមទាំងមានណារាយប្រពន្ធក្មេងរបស់គាត់នៅ
ឈរច្រត់ចង្កេះពីក្រោយផង ។

CHANBOKEO.COM

- ចង់នាំនាងមណីទៅណា អាហ្វាងយូ ? (ប៉ិហ្វូតសួរ)
- បាទ! គឺទៅរកប្រេងខ្យល់ប្រេងកូឡាលាបស្នាមរំពាត់ឲ្យនាង ។
- ហើយឯងជាស្អីដែរ បានជាហ៊ានមកហៃហៃក្នុងផ្ទះអញ ?
- គឺ...ជាបងប្អូនសាច់ញាតិនឹងគ្នា មិនអាចទ្រាំបញ្ឈរភ្នែកមើលគេ
ធ្វើបាបសាច់ឈាមខ្លួនឯងទាំងវេទនាបានទេ ។
- តែកិរិយារបស់ឯងមិនបានប្រាប់ថា ឯងកំពុងគិតពីមណីជាសាច់ ញាតិទេ ។
ឯងគឺជាក្មេងព្រហើន ហ៊ានលួចណាត់កូនស្រីអញនៅពី ក្រោយខ្នងចាស់ៗ...
- មិនមែនទេ បាទ! យើងមិនបានណាត់គ្នាទេ... គឺខ្ញុំបានជួប មណីដោយចៃដន្យ
នៅឯមាត់ស្ទឹងប៉ុនហ្នឹងឯង ។
- កុហក! តើវាជាចៃដន្យស្អីដែរ ដែលនាំឯងអោយទៅចែវទូក លេងក្នុងស្ទឹង ជាមួយគ្នានោះ ?
- គឺ...គឺ... ខ្ញុំ...
- និយាយលែងរួចហើយមែនទេ ? នេះឯងទៅលួចជួបគ្នាប៉ុន្មាន ដងហើយ ?
- មិនដែលទេ បាទ!
- តើនរណាទៅនឹងជឿសំដីឯងនោះ ?

រំពេចនោះ ប៉ិហ្វូតក៏បែរមករកកូនស្រី ហើយគំហកថា ៖

- នាងឯងមិនទាន់ពេញវ័យស្រួលបួលទេ ប៉ុន្តែរៀនថ្លើមធំណាស់
តើហ៎ ។ ស្បែកនាងនឹងនាងធ្វើពីស្អី បានជាមិនញោចរំពាត់យ៉ាង នេះ ?
ណាវាយម៉ែចុងឯងវាយឯងនោះ វាសមឫកឯងហើយដែល
ឯងពុំមានខួរក្បាលគិតធ្វើអ្វីអោយបានល្អសមរម្យ ជាកូនស្រីក្រមុំ ។ ត្រូវប៉ុននេះ វាតិចពេកផង!
ពេលនេះ ឯងចង់តវ៉ាស្អីទៀតទេ!

មាណវីនៅស្ងៀម មិនតបមកឪពុកវិញទេ ត្បិតនាងយល់ថា ទោះបីពន្យល់យ៉ាងណា
ក៏ឪពុកនាងមិនយល់ដែរ ព្រោះគាត់កំពុង
តែឈ្លក់វង្វេងនឹងប្រពន្ធក្មេងរបស់គាត់នោះដល់កម្រិតទៅហើយ ។
ណាមួយគាត់ក៏កំពុងស្រវឹងជោគផង ។

បន្តិចមក ប៉ិហ្វូតក៏បែរមកសុធីវិញ ៖

CHANBOKEO.COM

- ឯងត្រឡប់ទៅផ្ទះវិញទៅ ហើយកុំត្រឡប់មកអោយអញឃើញ មុខទៀតអោយសោះ ។ ថ្ងៃនេះ អញចាប់ឯងបានលើកទីមួយ អញ លោះអោយម្តង ប៉ុន្តែបើឯងប្រព្រឹត្តដូច្នេះលើកទីពីរទៀត អញមិន អត់ឱនឲ្យទៀតទេវើយ!

ប៉ុន្តែសុធីមិនស្ងប់ចិត្តទេ កាលបើធិតាយើងនៅតែទទួលការ មួលបង្កាច់ដោយអយុត្តិធម៌ពីម្តាយចុងរបស់នាងយ៉ាងនោះ ។ គេក៏ ប្រកែកភ្លាមថា ៖

- សុធីអាចទៅវិញបាន តែមិនអាចឈប់មកទៀត បានទេ!

- ហេតុអី ឈប់មិនបាន ? (ប៊ិហ្វួតគំហក)

- ព្រោះខ្ញុំមិនទុកចិត្តថា មណីនឹងចាកផុតពីការវាយដំធ្វើទារុណកម្ម លើរូបកាយ ។

- យើងជាឪ ជាម៉ែវា រឿងអីដែលយើងគ្មានសិទ្ធិវាយកូន ពេល ដែលវាធ្វើខុសផង ?

- ចុះបើគេមិនបានធ្វើខុសសោះ ហេតុអ្វីក៏ត្រូវរំពាត់ដែរ ?

- ឯងកាន់ជើងនាងមណីមែនទេ ? ហើយឯងត្រូវជាស្អីនឹងវាដែរ បានជាឯងចេញមុខការពារវាយ៉ាងព្រហើនដាក់យើងបែបនេះ ?

- ត្រូវជាអ្វីមិនសំខាន់ទេ! ដែលសំខាន់នោះ គឺមណីបានទទួល ទណ្ឌកម្មចំពោះរឿងដែលខ្លួនមិនបានប្រព្រឹត្ត វាដូចជាអយុត្តិធម៌ ពេកណាស់!

- ម៉េចក៏ថាមិនបានប្រព្រឹត្ត ? នរណាៗក៏ឃើញដែរថាវានៅលើ ទូកតែពីរនាក់ក្នុងស្ទឹងជាមួយឯង កាលពីព្រលប់ៗ...ឯងនៅខំប្រឹង ប្រកែកយ៉ាងណាទៀត ?

- តែនោះជាកំហុសរបស់ខ្ញុំទេ បើចង់វាយ... វាយខ្ញុំវិញទៅ! កុំ វាយដាក់ទោសខុសមនុស្សអី ។ មណីជាក្មេងស្រីទន់ខ្សោយម្នាក់ បើវាយគ្នាធ្ងន់ធ្ងរយ៉ាងនេះ ប្រាកដជា...

ភ្លាមនោះ សុធីក្លាយជាអួលដើមក ចង់ស្រក់ទឹកភ្នែកមួយ រំពេច ។ មាណវីយើងឃើញដូច្នេះ ក៏ងើបមុខឡើងសម្លឹងសុធីវិញ ដោយក្តីរំជើបរំជួលក្នុងចិត្ត ត្បិតមិននឹកស្មានថានាយហ៊ានយកខ្លួន មករងការពាររូបនាងដល់ម្លឹងទេ ។ នារីក៏ស្រដីទៅសុធីថា ៖

- អ្នកមិនបាច់យកខ្លួនមកជួយរងទណ្ឌកម្មជំនួសខ្ញុំទេ ។ ឪពុកខ្ញុំ ប្រដៅប្រដៅកូនបន្តិចបន្តួច ព្រោះគាត់ចង់អោយកូនល្អ ។ គាត់មិន បានសម្លាប់ឯណា ។ សូមអ្នកត្រឡប់ទៅផ្ទះវិញទៅ ដើម្បីកុំអោយ មានរឿងអ្វីធ្ងន់ធ្ងរជាងនេះ!

សុធីបែរមើលទៅធិតា រួចហើយមើលស្នាមរំពាត់ចម្រុះលើខ្លួន របស់នារី... បន្ទាប់មក គេក៏គ្រវីក្បាល ធ្វើទឹកភ្នែករលីងរលោង ទំនងហាក់ដូចជាអាណិតស្រណោះនារីអនេក

CHANBOKEO.COM

មិនដាច់ចិត្តអោយ នាងរងទណ្ឌកម្មដូច្នោះតទៅទៀតឡើយ ។ បេះដូងរបស់គេក៏រណ្តំ ឡើង ដោយក្តីអណោចអធម្មរកអ្វីប្រៀបមិនបានឡើយ ។ ភ្លាមនោះ
គេក៏បែរទៅប៊ិហ្ស៊ួត រួចវាចាទៅកាន់គាត់ថា ៖
- ខ្ញុំមិនទៅទេ! ខ្ញុំមិនទៅណាទាំងអស់ ដរាបណាមណីនៅតែរង ទណ្ឌកម្មមិនស្រាកស្រាន្ត ។ បើសិនជាខ្ញុំទៅមែន សូមអោយខ្ញុំ យកមណីទៅតាមជាមួយផង!
- ឯងនិយាយឆ្កួតៗអីហ្នឹង អាហ្វាងយូ ? (ប៊ិហ្ស៊ួតគំហក)
- ខ្ញុំមិនឆ្កួតទេ! ខ្ញុំកំពុងមានសតិគ្រប់គ្រាន់ណាស់ ប៉ុន្តែមិនចង់
ឃើញនារីស្លូតត្រង់ម្នាក់ត្រូវទទួលទោសដោយសារកំហុសរបស់ខ្ញុំ ។
រំពេចនោះ ស្រាប់តែនាងណារាយស្រែកឡៀៗមកថា ៖
- បើវាចង់ទៅ ក៏អោយវាទៅទៅ! មីកូនចិញ្ចឹមចំបង់បាយ ទុកនាំ តែចង្រៃផ្ទះ
នាំអាមាសអោយគ្រួសារទេ ។ ឬកវាមិនខុសពីម៉ែវាទេ គឺ រហេមរហាមកែមិនឡើង!
ស្រាប់តែមាណវីច្រឡោតតូង ងើបមុខឡើង តបថា ៖
- នែ៎មីង! កុំជេរម៉ែខ្ញុំណា៎! គាត់ស្លាប់បាត់យូរយារហើយ ហេតុអី
ក៏ហែកផ្នូរយកគាត់មកជេរផង ?
- ស្ងាត់មាត់ នាងនី! ឯងគ្មានសិទ្ធជេរប្រពន្ធអញទេ ។
ប៊ិហ្ស៊ួតស្រែកជំទាលកាន់ជើងប្រពន្ធក្មេងភ្លាម ។ នាងណារាយ បានចិត្តក៏ច្រត់ចង្កេះ
ស្រែកកាន់តែខ្លាំង ៖
- បើអញជេរវាយ៉ាងម៉េច ? នាងឯងមានមារយាទអន់មិនខុសអីពី ម៉ែសម្រែរបស់នាងឯងទេ
កំពូជរហេមរហាម ។
- ខ្ញុំប្រាប់ហើយថា កុំជេរម៉ែខ្ញុំ! មីងមិនស្គាល់ម៉ែខ្ញុំទេ កុំចេះតែ ជេរប្រមាថមិនដឹងរឿងអី!
តែនាងណារាយមិនឈប់មាត់ក៏ព្រួយមួយប្រាវទៀត ។ មណីខំ អត់ធ្មត់តទៅទៀតមិនបាន
ក៏ស្ទុះហក់មករកម្តាយចុង ។ ទាំងពីរ នាក់ក៏ប្រវាយគ្នាឡើង ។ រំពេចនោះ ប៊ិហ្ស៊ួតក៏ហក់រឹង
ស្រវាចាប់ កូនស្រីទាញចេញមក រួចហើយក៏បោកកូនផ្ទប់នឹងជញ្ជាំងផ្ទះលាន់ ភឹង ។ ពេលនោះ
គាត់កំពុងស្រវឹងស្រាប់ផង មិនបានគិតថាអ្វីខុស អ្វីត្រូវទេ
គឺធ្វើតាមតែអារម្មណ៍ឆេវឆាវយកឈ្នះកូនតែប៉ុណ្ណោះ ។
- អញប្រាប់ហើយ ថាអោយឈប់! ម៉េចមិនស្តាប់អញ នាងកូន អប្រិយ៍ទុរយស ?
(ប៊ិហ្ស៊ួតគំហក)

CHANBOKEO . COM

ភ្លាមនោះ គាត់ក៏លើកដៃឡើង វាយនាងពីរបីដៃទៀតយ៉ាង ធ្ងន់ ។
ធិតាយើងវិលខ្វាល់ដួលប្រូសទៅលើក្ដារផ្ទះជាថ្មី ហូរឈាម ពីមាត់ពីច្រមុះមួយរំពេច ស្រាប់តែ
នាងងើបឈរឡើងបែរសម្លឹង មុខឪពុក ដោយក្រសែភ្នែកយ៉ាងមុត ជាលើកដំបូង ។ បន្តិចមក
មណីក៏ស្រដីទាំងទឹកភ្នែករលីងរលោងទៅឪពុកវិញថា ៖
- កាលពីដើម កូនមិនយល់ទេ ថាហេតុអ្វីម៉ែគាត់ធ្វើអត្តឃាតខ្លួន ឯង ទុកកូនចោលឲ្យនៅកំព្រា...
តែពេលនេះ កូនយល់ហើយ... ហើយកូនគិតថា ម៉ែរបស់ខ្ញុំបាននសំរេចចិត្តយ៉ាងល្អបំផុត ព្រោះ
គាត់បានគេចផុតទារុណកម្មពីប្ដីទុរយសរបស់គាត់តរៀងទៅ ។
- ហ៊ានជេរអញផងហ្ន៎ស មីកូន...
- ប៉ាមិនបាច់ហត់ជេរខ្ញុំតទៅទៀតទេ! (មណីឆ្លើយកាត់) ចាប់ពី ពេលនេះតទៅ
ខ្ញុំមិននៅទីនេះអោយទើសមុខទើសមាត់ប៉ាទៀត ឡើយ ។ សូមប៉ាឈប់ចង្អៀតចិត្តទៀតទៅ!
ថាហើយ មាណវីក៏ត្រដរងើបឡើងទាំងតតេះតតះ ដើរចេញពី ផ្ទះទៅទាំងកណ្ដាលយប់ងងឹត...
- នាងនី! ឯងចង់ទៅណា ? (ប៊ុហួតស្រែកពីក្រោយ)
- ទៅឃាត់វាធ្វើអី បើវាមានឆ្អឹងធំដល់ម្លឹងទៅហើយនោះ ? វាចង់ ទៅណាអោយវាទៅទៅ!
ឬកធំយ៉ាងហ្នឹងទាល់តែអោយវាស្គាល់ រសជាតិជីវិតខ្លះៗទើបវាចុះញ៉មយើង ។
ណារាយប្រពន្ធក្មេងរបស់ប៊ុហួត ស្រែកគំហកពីក្រោយ យ៉ាង
ញាប់មាត់ ។ ប៊ុហួតក៏បែរមើលស្រមោលកូនពីក្រោយ នឹកហាក់ដូច ជាចង់ឃាត់កូនដែរ
តែមិនហ៊ាន ព្រោះខ្លាចបាក់មុខដែលខ្លួនជា ឪពុក ម្ល៉េះហើយ
គាត់ក៏សំរេចចិត្តបិទមាត់ស្ងៀមទៅវិញ ។
ចំណែកសុធីយើងដែលឈរស្រឡាំងកាំងយូរមកហើយ កាល
បើឃើញធិតាដើរចេញទៅ គេក៏ស្ទុះប្រុយយ៉ាងលឿនតាមពីក្រោយ ភ្លេចទាំងលាម្ចាស់ផ្ទះផង ។
- មណី! (នរៈស្ទុះទៅស្ទាក់ផ្លូវ) គិតទៅណាទាំងយប់ហ្នឹង ?
ឆវីយើងទុចង៉ក់ ហើយឈ្ងោកមុខឆ្លើយខ្សិបៗតបវិញថា ៖
- ខ្ញុំមិនដឹងទេ...
បន្តិចមក ធិតាក៏ដាក់ខ្លួនអង្គុយចុះផ្អែកនឹងដើមត្រសេកមួយ តាមដងផ្លូវ
មិនឆ្ងាយពីផ្ទះនាងប៉ុន្មានទេ រួចហើយក៏ក្ដោបមុខ យំខ្សឹកខ្សួល
ទម្លាយនូវភាពធុញថប់សោកសៅក្នុងចិត្ត ។

CHANBOKEO.COM

- មណីអើយ! ការពិត នោះជាកំហុសរបស់ខ្ញុំទេ ។ ខ្ញុំមិនគួរ
ទៅលេងសើចនឹងនាងរហូតដល់មានរឿងដូច្នេះ កើតឡើងឡើយ ។
- មិនមែនជាកំហុសនរណាទេ (នារីឆ្លើយទាំងទឹកភ្នែក) គេធ្វើ ដូច្នេះចំពោះខ្ញុំ
រាល់ថ្ងៃតែអញ្ចឹងទៅហើយ ។
សុធីក៏ដាក់ខ្លួនអង្គុយក្បែរនាង ហើយស្រដីថា ៖
- តែបើរឿងវាជ្រុលវែងឆ្ងាយដល់ថ្នាក់នេះទៅហើយ យើងគួរនាំ
គ្នាគិតរកផ្លូវដោះស្រាយវិញប្រសើរជាង មែនទេមណី ?
ធិតាឈ្ងោកមុខនៅស្ងៀម បន្តិចមកក៏ស្រដីថា ៖
- ពិភពលោកនោះចង្អៀតហើយងងឹតណាស់ មិនគួរអោយចង់រស់ នៅតទៅទៀតសោះ ។
- កុំនិយាយអញ្ចឹងអី! ពិភពលោកនេះទូលាយណាស់ បើកាលណា
យើងបើកចិត្តបើកអារម្មណ៍អោយទូលាយសម្លឹងទៅមុខហើយដើប ដើរយ៉ាងក្លាហាន ។
- ហេតុដូចម្តេចបានជាអ្នកយល់ថាពិភពទូលាយដូច្នេះ ?
- គឺមកពីខ្ញុំបានឆ្លងកាត់រួចមកហើយ នូវរសជាតិជីវិតយ៉ាងជូរចត់
មិនខុសគ្នាពីរឿងរបស់មណីទេ តែខ្ញុំមិនព្រមចុះចាញ់ងាយៗដែរ
ខ្ញុំនៅប្រឹងតស៊ូដើម្បីជ័យជំនះមួយ ដែលនឹងធ្វើអោយអ្នកដែលធ្វើ
បាបយើងនោះនឹងដេកគិតស្តាយក្រោយចំពោះអំពើរបស់គេ ។
យប់នោះ អ្នកទាំងពីរអង្គុយនិយាយជាមួយគ្នារហូតដល់ជិតភ្លឺ
រកដំណោះស្រាយសំរាប់ជីវិត ។ មិនដឹងជាហេតុអ្វីទេ អ្នកទាំងពីរ ទើបតែជួបគ្នាមួយថ្ងៃសោះ
តែគេមាននិស្ស័យនឹងគ្នាយ៉ាងជិតដិត បំផុត ហាក់បីដូចជាធ្លាប់ស្គាល់គ្នាយូរឆ្នាំមកហើយអញ្ចឹង ។
ទីបំផុត អ្នកទាំងពីរក៏ព្រមព្រៀងថា នាងមណីនឹងទៅស្នាក់នៅផ្ទះយាយ
គិមហួយបណ្តោះអាសន្ន ។
សំណាងល្អ យាយគិមហួយមិនបានភ្ញាក់ផ្អើលរឿងនាងមណីកូន ស្រីរបស់ប៉ិហួតទេ
ព្រោះគាត់ដឹងមុនរួចទៅហើយ ថាជីវិតរបស់ នាងនៅជាមួយឪពុកនោះមានសភាពយ៉ាងណា ។
គាត់ក៏ទទួលយក ចៅស្រីដោយអំណរ ត្បិតយាយក៏ត្រូវការគ្នីគ្នាកំដរជីវិត របស់គាត់ ដែរ
កុំអោយត្រមង់ត្រមោចពេក ។ រីឯសុធីវិញ ក៏ធ្វើដំណើរវិល ត្រឡប់ទៅរៀន នៅបាត់ដំបង
នៅថ្ងៃបន្ទាប់នោះ ។

CHANBOKEO.COM

*oooooooooooooooooooo*

*ooooo*

*o*

CHANBOKEO.COM

# វគ្គទី៦
# អប់រំ

- យំទៀតហើយ កូនប៉ា ? (សុធីលាន់មាត់)
- ព្រោះរឿងប៉ា រឿងម៉ាក់កំសត់ពេកនោះអី! (និមលតបទៅវិញ)
- នៅមានកំសត់តទៅទៀតណាកូន! នេះកូនទើបតែចាប់ផ្តើម ស្តាប់បានត្រឹមពាក់កណ្តាលទេ នៅសល់ពាក់កណ្តាលទៀត ។
- អញ្ចឹងកូនសូមសំរាកអារម្មណ៍សិន ប៉ា! ចាំអាទិត្យក្រោយ ប៉ា និទានរឿងប៉ាប្រាប់កូនទៀត ។
- អឺ! អញ្ចឹងក៏បាន! តែកុំភ្លេចណា! ចូរសរសេររឿងប៉ាទុកផង ក្រែងថ្ងៃក្រោយកូនអាចយករឿងនេះទៅប្រាប់ប្អូនៗ អោយបានដឹង ជាពិសេសពេលដែលប៉ាមិនបាននៅជិតៗកូនទៀត ។

និមលញញឹម ហើយប្រឹងធ្វើការបន្តជាមួយឪពុករហូតដល់ ហើយរួចរាល់ ។

ថ្ងៃខែចេះតែកន្លងទៅ...

នៅរៀងរាល់ព្រឹកថ្ងៃអាទិត្យ សុធីតែងតែទៅជួយនិមលបោក គក់ខោអាវនៅមាត់ស្រះទឹកក្រោយផ្ទះ ហើយយកពេលនោះជជែក ជាមួយកូនពីរឿងផ្សេងៗ ដូចជារឿងអតិតកាលរបស់មាណពផង អំពីរឿងរៀនរបស់កូនផង អំពីរឿងក្រុមគ្រួសារផង ។

យុវតីយើងមានប្អូនប្រុសម្នាក់ ឈ្មោះ និវត្ត មានអាយុ៦ឆ្នាំ ។ ដោយគេជាកូនប្រុសដំបូងក្នុងគ្រួសារ នាងមណីជាម្តាយ ដូចជា ទំយើរូបគេបន្តិច ។ ពេលណានិវត្តយំកាលណា មណីតែងតែទាញ រំពាត់មកសម្លុតកូនបងៗគ្រប់គ្នា ថាកុំឲ្យលលេងប្អូនអោយយំ ប៉ុន្តែ គាត់ភ្លេចមើលថា តើនិវត្តយំនោះសមហេតុសមផលឬទេ ? ឬក៏គេ កំពុងយំទឹកភ្នែកក្រពើ ដើម្បីទាមទារការចាប់អារម្មណ៍ពីម្តាយ ? កាលបើគេធ្វើដូច្នោះបានម្តង គេក៏ធ្វើម្តងទៀតមិនព្រមលែង ហើយ មណីក៏ចេញមុខមកការពារនិវត្ត ដដែលជាដដែល មិនផ្លាស់ប្តូរ ដែលជាហេតុធ្វើអោយកុមារកើតមាន ចរិតព្រហើនកាន់តែខ្លាំង ។ ឯនិមលវិញមិនចូលចិត្តលក្ខណៈ

CHANBOKEO.COM

ដែលម្តាយរបស់នាងកាន់ជើងកូន ប្រុសរបៀបនេះទេ ។ លុះឃើញនិមលធ្វើមុខជូរយូរថ្ងៃ សុធីក៏ហៅ ទៅសួរ ។ កុមារីក៏ជំរាបឪពុកតាមត្រង់ ស្រាប់តែម្តាយនាងខឹងថា និមលនេះពូកែពិតទូលរករឿងប្អូន ។ គាត់ក៏ទាញរំពាត់បំរុងវាយ និមលជាថ្មីម្តងទៀត ។ សុធីឃើញប្រពន្ធធ្វើដូច្នោះ ក៏ទាញរំពាត់ ចេញពីដៃនាង រួចមានប្រសាសន៍ថា ៖

- អូនមានចាំទេ ? កាលយើងនៅពីក្មេង ពេលចាស់ៗទាញរំពាត់ វាយយើងម្តងៗ តើយើងឈឺចាប់យ៉ាងណា ? យើងខឹង តូចចិត្ត ប៉ុនណា ? យើងខ្លាចភាពទារុណទាំងនោះយ៉ាងណា ? ដូច្នេះ យើង មិនគួរធ្វើអ្វី ដែលបណ្តាលអោយកូនយើងមានអារម្មណ៍ទារុណក្នុង ចិត្តរបស់គេដូចយើងនាគ្រាមួយនោះទេ ។ បើកូនមានការខុសឆ្គង ពិតមែន យើងគួរហៅវាស្តីប្រដៅទៅ កុំវាយកូនអីណា! ម្យ៉ាង ទៀត ការប្រដៅកូនដោយភាពគំហកកំហែង វាមិនអាចជួយអោយ កូនយើងកែខ្លួនប្រសើរឡើងបានទេ ក្រៅតែពីកាធ្វើអោយកូនរឹងរិត តែភិតភ័យឡើង ជួនកាលអាចធ្វើអោយកូនតូចចិត្តនឹងយើងដែល ជាឪពុកម្តាយកាន់តែច្រើនឡើងក៏មានដែរ ។

ឮសុធីមានប្រសាសន៍ដូច្នោះ មណីក៏បោះរំពាត់ចោល រួច ហើយក៏ដើរចេញទៅ ទុកអោយនិមលនៅនិយាយជាមួយសុធីតែពីរ នាក់ ។ ការពិត សុធីស្រឡាញ់កូនអប់រំកូនទៅតាមអាយុ ទៅ តាមភេទ និងវ័យរបស់គេ ។ ក្រោយពីស្តាប់រឿងពីមាត់កូនម្នាក់ ហើយ មាណពតែងតែហៅទាំងអស់គ្នាមកបញ្ជាក់ ហើយរក ដំណោះស្រាយទាំងអស់គ្នា មិនអោយនរណាកាន់ជើងនរណាអោយ ខូចខុសទម្លាប់ល្អទេ ។ និវត្តខ្លាចឪពុកណាស់ ព្រោះដឹងថាគាត់មិន កាន់ជើងនាយម្តងណាឡើយ ។ ថ្វីបើសុធីមិនដែលប្រើរំពាត់អប់រំ កូនមែន ប៉ុន្តែទាំងកូនបង្កើត ទាំងក្មេងដែលសុធីចិញ្ចឹមទំនុកបំរុង នៅក្នុងផ្ទះទាំងឡាយនោះ គោរពកោតខ្លាចសុធីឥតឧបមា មិនថា នៅចំពោះមុខ ឬនៅពីក្រោយខ្នងទេ ។ ក្មេងទាំងនោះខ្លាចត្រង់ថា សុធីមានគំនិតភ្លឺថ្លា និយាយអ្វី ប្រដៅអ្វី មានប្រសិទ្ធភាពក្រៃលែង ព្រោះបុរសយើងតែងតែយកការពិត យកភាពសុចរិត គុណធម៌ និងសីលធម៌ជាគោលសំរាប់ប្រដៃប្រដៅជានិច្ច ហើយតែងតែ ចៀសវាងមិនប្រើពាក្យអសុរស និងការប្រើរំពាត់ដំបងវាយសម្លុត កូន ពេលប្រដៃប្រដៅពួកគេ ។

អ្វីដែលនិមលគោរពឪពុកនាងបំផុតនោះគឺ សុធីមិនដែលហៅ នាងទៅជេរស្តីបន្ទោសទាំងទទឹងទទែងទេ ជាពិសេសបើឃើញកូន កំពុងអានសៀវភៅ

CHANBOKEO.COM

ធ្វើលំហាត់សាលា ឬធ្វើអ្វីៗដែលទាក់ទងនឹង ការរៀនសូត្រ សុធីមិនដែលបានរំខានអារម្មណ៍រៀនសូត្រឡើយ ។ គេរង់ចាំរហូតដល់កូនទំនេរ ទើបហៅមកជិតដើម្បីនិយាយគ្នា ។ និយាយអោយពិតទៅ និមលខ្លាចឪពុកណាស់ តែក៏ចូលជិតឪពុក ណាស់ដែរ ព្រោះសុធីតែងតែផ្ដល់គំនិតប្លែកៗ អោយនាងដោះស្រាយចម្ងល់ជានិច្ច ជាពិសេសអ្វីៗដែលទាក់ទងនឹងការសិក្សា ។

ម្យ៉ាងទៀត ពេលមានលោកជាបង្គោល និមលហាក់ដូចជាមាន លំនឹងក្នុងចិត្ត ព្រោះដឹងថា ហោចណាស់នាងមានមនុស្សចាស់ ដើម្បីពិគ្រោះគ្នាជាមួយបាន ដោយមិនបាច់ភ័យថា ខ្លួននឹងត្រូវរំពាត់ ឬត្រូវលោកសើចយំឡើយ ។ សុធីតែងតែផ្ទៀងស្ដាប់គំនិត យោបល់របស់កូនជានិច្ច ។ បើសិនគេយល់ថា អ្វីដែលកូនគិតនោះ មានលក្ខណៈសមស្រួន នោះនរៈក៏សរសើរលើកទឹកចិត្តរួចជំរុញ កូនអោយឆ្ងើតទៅទៀត ។ ប៉ុន្តែបើឃើញថា គំនិតរបស់កូននៅខ្ចី សុធីក៏ជួយបំភ្លឺហេតុផលផ្សេងៗ ដើម្បីពង្រឹងចិត្តកូនអោយប្រឹងគិត ប្រឹងធ្វើសាជាថ្មី ។ សុធីមិនងាយហារមាត់បន្ទោសកូនផ្ដេសផ្ដាសឲ្យ បាក់ទឹកចិត្តកូនទេ ជាពិសេសគឺចៀសវាងការជេរស្ដីកូនពេញវ័យ នៅចំពោះមុខគេមុខឯង ។ បើសិនឃើញអ្វីទាស់ចិត្ត សុធីតែងតែ ហៅកូនទៅជួបនៅក្នុងបន្ទប់ ហើយក៏និយាយគ្នាស្ងាត់ៗវិញជា ជាង ។ នៅថ្ងៃបន្តបន្ទាប់មក កូនចៅដែលសុធីហៅណែនាំនោះ តែងកែប្រែចរិតកិរិយាបថប្លែកហើយល្អជាងមុនជានិច្ច...

នៅឆ្នាំដែលនិមលបានចូលរៀនអនុវិទ្យាល័យ...

ព្រហាមថ្ងៃបវេសនកាល...

សុធីនាំមណីដើរមកពិនិត្យកូនស្រី ដែលកំពុងសិតសក់នៅមុខ កញ្ចក់ ។ មណីហុចកៅស៊ូកងមួយមកអោយកូន រួចហើយមាន ប្រសាសន៍រំលឹកនាង ថា ៖

- និមល! ចងសក់ទៅកូន កុំឲ្យសក់ធ្លាក់ចូលមុខបាំងភ្នែក នាំតែ រំខានដល់ការអាន និងការសរសេររបស់កូន ។ ព្រឹកនេះ កូនត្រូវ ជិះកង់ទៅរៀនដោយខ្លួនឯងហើយ ជិះហើយមើលផ្លូវកុំអោយធ្លាក់ គន្លុកគន្លួល... កុំឆៀងចូលលេងពួកម៉ាក កុំឈប់ទិញនំញ៉ាំតាមផ្លូវ ។ ព្រឹកឡើង កូនត្រូវបរិភោគពីផ្ទះអោយឆ្អន់ពោះឲ្យហើយទៅ នោះ កូននឹងសល់ពេល បានជួបគ្នាជាមួយមិត្តនៅសាលា ជជែកគ្នាលេង សប្បាយ ដោយមិនបាច់ប្រឹងត្របាញ់រត់ទិញនំញ៉ាំ ពេលសាលា វាយជួងចេញលេងម្ដងៗ ។ ការបរិភោគកញ្ចក់កញ្ចៀតអាចនាំ អោយកូនឈឺពោះមិនស្រួលខ្លួន ។ ពេលនោះ កូនក៏មិនអាចមាន អារម្មណ៍ល្អស្ដាប់គ្រូបានដែរ ។

CHANBOKEO.COM

បើសិនកូនញ៉ាំអីឆ្អែតពីផ្ទះពេល ព្រឹកទៅ កូននឹងមានកម្លាំង មានស្មារតីប្រាជ្ញនឹងនួន មិនញ័រដៃញ័រជើង ពេលកូនអង្គុយស្តាប់គ្រូពន្យល់នៅក្នុងថ្នាក់ ឬពេលកូនសរសេរចម្លងពាក្យពន្យល់របស់លោកគ្រូទុក ។

ភ្លាមនោះ សុធីក៏មានវាចាបន្ថែមថា ៖

– ចំណែករឿងពួកម៉ាកវិញ បើកូនមានគ្នាលេងជាមួយច្រើននោះ ក៏ប្រសើរហើយ ព្រោះកូនមិនអផ្សុកផង ប៉ុន្តែ បើមានពេលទំនេរ កូនយកពេលពិគ្រោះរឿងកិច្ចការសាលាវិញ នោះវារិតតែប្រសើរ ណាស់ទៅទៀត ។ ម្យ៉ាងទៀត បើមានមិត្តល្អៗដូច្នេះ ចូរកុំភ្លេចណែនាំអោយប៉ាម៉ាក់ស្គាល់ពួកគេផង នឹងអាលឲ្យប៉ាបានសរសើរលើកទឹកចិត្តគេដោយផ្ទាល់មាត់របស់ប៉ាផងណាំកូន ។

ដំបូងនិមលគិតថា ម្តាយឪពុកនាងមានទ្រឹស្តីសាំញាំដល់ហើយ ផ្តាំកូនច្រើនអីច្រើន ដាក់វិន័យដាក់កិរិតកូនស្ទើរតែរើខ្លួនមិនរួច ។ ប៉ុន្តែ លុះដល់នាងទម្លាប់ធ្វើដដែលៗរាល់ថ្ងៃទៅ អ្វីៗក៏ប្រែក្លាយជា ការងាយស្រួលទាំងអស់គ្រប់យ៉ាង មិនពិបាកគិតអ្វីឡើយ ។ នាងតូចក៏បានញ៉ាំឆ្អែតពីផ្ទះរាល់ព្រឹក មានពេលលេងជាមួយពួកម៉ាក រាល់ ពេលចេញលេងរួចហើយក៏មានអារម្មណ៍ល្អ សំរាប់ស្តាប់គ្រូ បង្រៀនក្នុងថ្នាក់ជាងគេដែរ ។ រីឯឪពុកនាងវិញក៏ស្គាល់មិត្តរួម ថ្នាក់របស់នាងទាំងអស់គ្រប់គ្នា ព្រោះធិតាបានទៅជំរាបជូនគាត់ រាល់ពេលត្រឡប់ពីសាលាវិញ រាយការណ៍ជំរាបអំពីអ្វីៗដែលនាង បាន ធ្វើនៅថ្ងៃនោះ ។ ដូច្នោះហើយ សុធីមិនដែលព្រួយបារម្ភទេ ថាកូនសេពគប់មិត្តភក្តិមិនល្អ ។

កាលនោះ ថ្វីបើនិមលទៅរៀននៅសាលា ដែលសុធីបង្រៀន ដដែលនោះក៏ដោយ ក៏បុរសយើងមិនឌុបនិមលជាកូនទៅជាមួយទេ តែបែរជាឲ្យនាងជិះកង់ទៅសាលាដោយខ្លួនឯង ។ ពីផ្ទះទៅសាលា មានចម្ងាយប្រហែលជាងបីគីឡូម៉ែត្រ ។ នៅថ្ងៃដំបូង និមលគិតថា សាលារៀនឆ្ងាយអើយសែនឆ្ងាយ ព្រោះនាងនៅតូចពេក ឡើងជិះ កង់មិនដល់កែបទេ តែបើឡើងជិះលើកែប ជើងនាងក៏ជាន់មិន ដល់ឈ្នាន់ដែរ ។ ទោះបីជាយ៉ាងណា ឪពុកនាងនៅតែបណ្តោយឲ្យ នាងជិះកង់ទៅរៀនដោយខ្លួនឯង ហើយអោយរៀនទទួលខុសត្រូវរក្សាកង់ចាស់មួយនោះជាទ្រព្យរបស់ខ្លួនអោយបានល្អ ។ ដំបូងៗ និមលនឹកឆ្ងល់ថា ហេតុអ្វីសុធីមានចិត្តអាក្រក់ចំពោះនាងជាកូនម្ល៉េះ កាលបើទៅសាលាជាមួយគ្នាសោះ ហេតុអីឪពុកនាងសុខចិត្តជិះ វេសប៉ាទៅម្នាក់ឯង មិនព្រមឌុបកូនទៅជាមួយផងទេ ។ ប៉ុន្តែ

CHANBOKEO.COM

លុះធិតាយើងហ្វឹកហ្វឺនធាក់កង់ប្អូនដប់ថ្ងៃទៅ សាលារៀនឆ្ងាយក៏ ក្លាយទៅជាជិត
រួចហើយនាងក៏ជិះកង់មានល្បឿន មិនចាញ់មនុស្ស ធំឡើយ ។ ពេលនោះ ស្រីតូចក៏យល់ភ្លាមថា
ឪពុកកំពុងអោយ នាងរៀនហ្វឹកហ្វឺនរូបកាយ ឲ្យរឹងប៉ឹង មានកម្លាំងមាំមួន មិនទំរន់
ខ្លួនទំរេតពឹងផ្អែកតែលើអ្នកដទៃឲ្យដឹកខ្លួនទៅសាលារៀន ។ តាំង ពីពេលនោះមក ពេលណា
ក្រុមគ្រួសារមានអាសន្នអន់ក្រពេលថ្ងៃ ឬយប់ព្រលប់ និមលក៏ ក្លាយទៅជាពំនាក់របស់ចាស់ៗ
ឬប្អូនៗ ព្រោះនាងរហ័សរហួន មាំមួនរវាសរវៃ ហើយក្លាហានជាងគេ ។

រាល់ល្ងាច សុធីចេញទៅបង្រៀនឈ្នួល តាមផ្ទះអភិជនខ្លះៗ
ដែលគេជួល អោយទៅជួយបង្រៀនកូនចៅរបស់គេម៉ោងពិសេស
ថែមទៀតបន្ទាប់ពីចេញពីសាលាពេលល្ងាច ។ សុធីបង្រៀនសិស្ស
ពីរថ្នាក់ដែលមានកំរិតខ្ពស់ជាងនិមល តែបុរសយើងអោយនាងជិះ កង់ទៅរៀនក្បាលព្រលប់
ពីម៉ោង៦ល្ងាចរហូតដល់ ម៉ោង៨យប់ ជួនកាលក៏យប់ជ្រៅជាងហ្នឹងក៏មាន ។ នាសម័យនោះ
រង្វង់នីក្រុង បាត់ដំបងមានបង្គោលភ្លើងគោមអគ្គីសនីពណ៌ស រាយមួយៗ តាម ដងផ្លូវ
ប៉ុន្តែមួយកំណាត់ផ្លូវត្រឡប់ទៅផ្ទះនិមលវិញ គ្មានភ្លើង គោមបំភ្លឺតាមផ្លូវទេ ។
តរុណីយើងត្រូវពឹងលើភ្លើងហ្វារតូចមួយ ដែលប្រើដោយកម្លាំងឌីណាម៉ូកង់ ។ ចៃដន្យ
ក្មេងស្រីតូចវ័យនិមល នោះ ទ្រាំទ្រមិនបានប៉ុន្មានទេ ។ ពេលនាងធាក់កង់ត្រឡប់មកផ្ទះ
ទាំងកណ្តាលយប់ងងឹត បន្ទាប់ពីចាយកម្លាំងរៀនផង ធាក់កង់
ចុះឡើងៗពេញមួយថ្ងៃរហូតមកផង ស្រីតូចហាក់ដូចជារយាលជើង បន្តិចហើយ
ម្ល៉ោះហើយពន្លឺភ្លើង ដោយកម្លាំងឌីណាម៉ូកង់នោះក៏វា អ៊ីវទៅតាមហ្នឹងដែរ ។
កុមារីជិះកង់មើលផ្លូវសឹងតែមិនឃើញ សោះរហូតដល់ផ្ទះរាល់ៗយប់ មួយអាទិត្យចំនួន៦ថ្ងៃ
ដើម្បីទៅ សំកុករៀនក្នុងថ្នាក់ពិសេសដែលឪពុកនាងបង្ហាត់នៅផ្ទះគេ ។

ការពិត មាណវីអផ្សុកណាស់ ព្រោះមួយថ្ងៃៗ ឪពុកនាងបង្ខំ
អោយអង្គុយកៀនៗខាងៗស្តាប់គាត់បង្រៀន តែមិនឲ្យសួរអ្វីឡើយ
បានត្រឹមចម្លងតែម្យ៉ាងប៉ុណ្ណោះ ព្រោះមិនចង់ឲ្យ កូនរំខានថ្នាក់រៀន របស់គេឡើយ ។ ចៃដន្យ
អ្វីដែលស្រីតូចចម្លងសុទ្ធតែមានសារៈ ប្រយោជន៍ទាំងអស់ ទាំងខាងគណិតវិទ្យា
ទាំងខាងភាសាបារាំង ទាំងអក្ខរាវិរុទ្ធនិងវេយ្យាករណ៍ ។ នៅឆ្នាំបន្ទាប់ៗមក ពេលនាង ឡើងថ្នាក់
ស្រាប់តែកុមារីយល់កិច្ចការដោយឯងៗ ហើយក៏ប្រឡង

CHANBOKEO.COM

ជាប់ទទួលពិន្ទុលើសគេលើសឯងយ៉ាងចម្លែកតែម្តង រហូតដល់មិត្ត ក្នុងថ្នាក់ខ្លះគិតច្រឡំថា ប្រហែលជាលោកគ្រូៗទាំងនោះអោយពិន្ទុ រើសមុខ ហើយព្រោះនាងជាកូនគ្រូបង្រៀន ។

ថ្ងៃមួយ សុធីហៅនិមលមកសួរថា ៖

- ប៉ាឲ្យកូនជិះកង់ទៅរៀនពេលយប់ជិតមួយឆ្នាំហើយ ពេលនេះ ប្រាប់ប៉ាអោយត្រង់មើល តើកូនមានអារម្មណ៍យ៉ាងណាដែរ ?

ការពិត សុធីកំពុងចង់ដឹងថាតើកូនស្រីខ្លាចខ្មោចដែរឬយ៉ាង ណា ។ ចៃដន្យ និមលមិនខ្លាចខ្មោចព្រាយបិសាចមកលងទេ តែ ខ្លាចចោរ ខ្លាចមនុស្សយាយីទៅវិញទេតើ ។ ស្រីតូចក៏ជំរាបឪពុក តាមត្រង់ ស្រាប់តែសុធីភ្ញាក់ព្រើត ស្រដីថា ៖

- និមល ! កូនដើរមុនប៉ាមួយជំហានហើយ ។ ការពិត ប៉ាចង់ បង្រៀនកូនកុំអោយខ្លាចយប់ងងិត ចេះពង្រឹងស្មារតីកូនឲ្យជំនះនូវ អារម្មណ៍ដែលភ័យខ្លាចខ្មោចលង តែប៉ាបែរជាប្រហែសមិនបានគិត ដល់រឿងសុវត្ថិភាពរបស់កូនស្រីប៉ាសោះ ។ អរគុណណាស់ដែល កូនមកប្រាប់ប៉ាអោយដឹង ។

ចាប់តាំងពីថ្ងៃនោះមក សុធីក៏អោយកូនស្រីកាត់សក់ខ្លីរួចពាក់ មួកកន្តិប ពាក់ខោអាវប្រុស(អាវរបស់សុធី) ហើយឲ្យនាងហាត់ កីឡាបន្ថែមទុកគ្រាន់ការពារខ្លួន ពេលជិះកង់ទៅរៀននៅពេល យប់ ។ នារីតូចធ្វើយ៉ាងនេះរហូតបានដល់ថ្នាក់ត្រៀមប្រឡងឌីប្លូម ទើបអាក់ខានលែងបានទៅរៀនទៀត ព្រោះនាងពេញវ័យហើយ ដូច្នេះ ការធ្វើដំណើរយប់ព្រលប់ ដូចជាមិនសូវជាសមរម្យទេ ។

រាល់ថ្ងៃ សុធីមិនដែលទំនេរទេ វៀរលែងតែពេលបុរសយើង ចូលដំណេក ។ គេធ្វើការមិនដែលដាក់ដៃឡើយ ហើយក៏ព្យាយាម បង្ហាញផ្លូវជីវិតដល់កូនគ្រប់គ្នា នៅរៀងរាល់ថ្ងៃដែលគេជួបជុំគ្នា ។ មានថ្ងៃមួយនោះ សុធីបានស្ងោរត្រឡាចដាក់ទឹកយ៉ាងច្រើនរួចហើយ លីងល្ងរបុកលាយអំបិលយកមករោយលើបាយបរិភោគ ។ ចំពោះ និមល ម្ហូបនោះមិនប្លែកទេត្បិតនាងធ្លាប់បរិភោគបែបនោះ កាល ក្រុមគ្រួសារនាង រស់នៅស្រុកស្រែក្រីក្រ ។ កាលនោះ នៅភូមិ ត្រពាំងថ្មខែប្រាំង មុននឹងសុធីផ្លាស់មកធ្វើការឯបាត់ដំបង គេមិន សូវមានអាហារអ្វីប្រសើរជាងនោះឡើយ ។ តែប្អូនៗរបស់និមល ដែលមានកំណើតនៅទីក្រុង ធំឡើងរស់នៅទីក្រុង គេមិនយល់ពី ជីវិតអត្តខាត់បែបនោះទេ ។ និវត្តក៏សួរសុធីជាឪពុកថា ៖

CHANBOKEO.COM

- ហេតុអ្វីក៏ថ្ងៃនេះ យើងបរិភោគបែបនេះអញ្ចឹង ប៉ា ?

ពេលនោះ សុធីញញឹមហើយមានប្រសាសន៍តបវិញថា ៖

- គឺដើម្បីឲ្យកូនស្គាល់រសជាតិថា តើជីវិតអ្នកក្រគេរស់យ៉ាងណា... ទីមួយគឺ ថ្វីបើរសជាតិអាហារមិនសំបូរបែប តែក៏យើងនៅតែអាច បរិភោគរស់ហើយមានកម្លាំងធ្វើការដូចអ្នកទីក្រុងដែរ ។ ទីពីរគឺ តម្លៃនៃការជួបជុំគ្រួសារ... ថ្វីបើសម្លមើលទៅមិនឆ្ងាញ់ក៏ដោយ តែ ដោយយើងបានបរិភោគជុំគ្នាជាគ្រួសារ យើងក៏សប្បាយរីករាយនឹង សុភមង្គលគ្រួសារយើង ម្ល៉ោះហើយអាហារមួយពេលនេះនឹងមាន រសជាតិប្លែកហើយឆ្ងាញ់ជាទីបំផុត ។ ទីបី ថ្វីបើសម្លមិនឆ្ងាញ់ តែ ចំពោះគ្រួសារដែលមានកូនច្រើន មានប្រាក់ចំណាយតិច គេត្រូវ ធ្វើបែបនេះ ដើម្បីសំចៃថវិការគ្រួសារ ។ ទីបួន ប៉ាចង់អោយកូន រិះគិតថា បើកូនមិនចូលចិត្តអាហារនេះទេ ប៉ុន្តែកូនចង់បានអាហារ ដែលសំបូរបែបជាងនេះ តើកូនត្រូវរកមធ្យោបាយអី ដើម្បីនាំជីវិត របស់កូនអោយឆ្លងទៅរកភាពសំបូរបែបខុសពីម្ហូបមួយពេលនេះ !

កូនប្រុសស្រីទាំងអស់បរិភោគផង ស្តាប់ឪពុកពន្យល់ផង ។

បន្តិចមក សុធីក៏មានប្រសាសន៍ ប្រាប់កូនបន្ថែមថា ៖

- នៅក្នុងទំនៀមទម្លាប់ចិនមួយ ដែលប៉ាធ្លាប់រស់នៅកន្លងមក គឺ ចាស់ៗបានប្រាប់ថា កុំអោយបរិភោគកោសបាយអស់ពីចានអោយ សោះ គឺត្រូវតែបន្សល់បាយទុកមួយម៉ាត់អោយនៅសល់ក្នុងចាន នោះ ទើបជាប្រផ្នូលល្អសំរាប់គ្រួសារ ត្បិតមានន័យថា គ្រួសារ យើងមិនក្រហេមរហាមរហូតដល់ បរិភោគបាយកោសថ្នាំចាន លេបចូលជាមួយឲ្យឆាប់ឆ្អែតនោះទេ ។ ប៉ុន្តែនៅក្នុងទំនៀមទម្លាប់ ខ្មែរដែលប៉ាធ្លាប់ទទួលការអប់រំមក គឺ ចាស់ទុំបានប្រដៅថា យើង ត្រូវបរិភោគអោយអស់បាយស្អាតពីចាន ទីមួយបញ្ជាក់ថា យើង មិនខ្ជះខ្ជាយព្រះមែដែលឪពុកម្តាយខិតខំរក យកមកអោយកូន បរិភោគ ទីពីរយើងមិនប្រមាថមើលងាយកម្លាំងអ្នកស្រែ ដែលខិត ខំដាំស្រូវមកផ្គត់ផ្គង់ពួកយើង ទីបីយើងមិនមាក់ងាយប្រមាថស្នាដៃ អ្នកដាំស្ល ថាធ្វើម្ហូបមិនឆ្ងាញ់ ទើបបរិភោគលេបមិនរួច រហូតសល់ បាយពាសពេញក្នុងចានដូច្នោះ ។

ពេលនោះ និមលនឹកឆ្ងល់ក៏សួរសុធីឡើងថា ៖

CHANBOKEO.COM

- ចំពោះទំនៀមទម្លាប់ពីរបែបផ្ទុយគ្នានេះ តើកូនៗត្រូវជ្រើសរើស ទំនៀមណាមួយជាក់ច្បាស់ជារបស់ខ្លួនឯង កាលបើទ្រឹស្តីនិងការ អនុវត្តន៍វាផ្ទុយគ្នាយ៉ាងហ្នឹង ? តើធ្វើតាមទំនៀមទម្លាប់បែបចិន ល្អ ឬក៏ធ្វើតាមទំនៀមទម្លាប់ខ្មែរទើបប្រពៃ ?

សុធីញញឹមហើយមានប្រសាសន៍ពន្យល់កូន យ៉ាងក្បោះក្បាយ អោយស្តាប់ថា ៖

- នៅអនាគត បើសិនណាជីវិតកូនប្រទះនូវភាពខុសគ្នានៃវប្បធម៌ ពីរ ចូរកូនត្រិះរិះត្រងយកមួយណា ដែលធ្វើអោយជីវិតរបស់កូន ចំរុងចំរើន ហើយស្ថិតនៅក្នុងគន្លងសីលធម៌ល្អជាងគេ ។ ចូរកូន ចៀសនូវជំនឿឬទំនៀមទម្លាប់អ្វី ដែលនាំអោយជីវិតរបស់កូនដើរ ថយក្រោយ ។ កូនត្រូវតែរៀនរៀសរវៃ មើលអ្វីអោយគ្រប់ជ្រុង ជ្រោយ ។ កុំជឿអ្វីតាមតែគេថាឬតាមតែគេប្រាប់ ។ កុំប្រព្រឹត្តខ្លួន ជាមនុស្សដែលភ្ញាក់ផ្អើល ចូលចិត្តឆាប់ជឿគេដោយខ្វះការពិចារណា ហេតុផលល្អអាក្រក់នោះឲ្យសោះ ។ ចូរកូនប្រើប្រាជ្ញនិងសតិ ដើម្បី វិភាគហេតុផលជានិច្ច ។ ថ្វីបើកូនៗមានជាប់សាច់ឈាមជាចិនពិត មែន តែកូនកើតស្រុកខ្មែរ រស់ស្រុកខ្មែរ ហើយក៏មានសាច់ឈាម ជាខ្មែររបស់ខ្លួនដែរ ។ ឯប្រទេសខ្មែរវិញក៏មានគុណដល់គ្រួសារ យើងណាស់ ។ ពិតមែនតែរូបប៉ានេះជាជនជាតិចិន តែក្រុមគ្រួសារ របស់ប៉ាបានត្រូវរដ្ឋាភិបាលចិនធ្វើទុក្ខបុកម្នេញ រហូតមិនអាចនៅ ស្រុកខ្លួនឯងតទៅទៀតបាន ទើបរត់ភៀសខ្លួនមកនៅស្រុកខ្មែរ ។ សំណាងល្អណាស់ដែលប្រជាជនខ្មែរនៅទីនេះ មានសន្តានចិត្តល្អ ទូលំទូលាយ ខុសប្លែកពីស្រុកចិន ដែលគេធ្វើបាបពួកយើងដែលជា ជាតិចិនដូចគ្នា ។ មើលចុះ ! សូម្បីតែពេលរូបប៉ាបានក្លាយជាក្មេង កំព្រា គ្មានទីពំនាក់ ពេលបងប្រុសជាតិចិនរបស់ប៉ា គ្មានចិត្តថ្លើម ថែរក្សាប៉ាដែលជាប្អូនអ្វីបន្តិចសោះនោះ ក៏ប៉ាអាចរស់នៅបានរហូត មកដល់សព្វថ្ងៃ ។ នោះក៏ព្រោះដោយសារសគុណបាយបាត្រដែល អ្នកស្រុកផ្តល់ទៅវត្ត រួចហើយវត្តផ្តល់មកប៉ាបន្តទៀត តរៀងមកជា យូរឆ្នាំរហូតដល់ប៉ាពេញវ័យ កុំអីប៉ាមិនមានឱកាសបានរៀនសូត្រ ចេះដឹង មានការធ្វើល្អៗដូច្នេះដែរ ។ ប៉ុន្តែជាភព្វវាសនាល្អ ដែល ជាតិខ្មែរមិនបានប្រកាន់ថា ប៉ាជាជនជាតិចិន ឬជាតិសាសន៍អ្វីទេ ទាំងអ្នកស្រុក ទាំងជាតិខ្មែរទាំងមូល បានផ្តល់ការសិក្សានិងការងារ ឲ្យប៉ាធ្វើ ដូចជាខ្មែរដទៃទៀតក្នុងប្រទេសកម្ពុជាដែរ ។ ដូច្នេះចូរ កុំរមិលគុណបុណ្យរបស់ជាតិខ្មែរណា៎កូនណា៎ ! រីឯការដែលយើង បានក្លាយជាមនុស្សល្អ

CHANBOKEO.COM

មានប្រាជ្ញឈ្លាសវៃ ហើយបានទទួលជោគ ជ័យប្រសើរក្នុងជីវិតនោះ
មិនមែនដោយសារគុណបុណ្យរបស់ យើងជាពូជកូនចៅចិននោះទេ
តែដោយសារគុណបុណ្យអ្វីៗសព្វ យ៉ាងទាំងអស់ជុំវិញខ្លួនយើងជាច្រើនទៀត រួមទាំងដូនតាចិន
ទាំង ដូនតាខ្មែរ ទាំងអ្នកស្រុកភូមិផងរបងជាមួយទាំងអស់គ្រប់ៗគ្នា រួមទាំងជាតិខ្មែរទាំងមូល ។
កូនកុំឈ្លក់នឹងជោគជ័យរបស់ខ្លួន លើកជើងចិនជាន់កខ្មែរ
ឬលើកជើងខ្មែរជាន់កដូនតាចិនវិញអោយ សោះ ព្រោះដូនតារបស់យើងមានទាំងសងខាង ។
យើងត្រូវចេះ គោរពអ្នកមានគុណទាំងឡាយ មិនថាជាដូនតាចិន ឬដូនតាខ្មែរ
ឬនរណាដទៃទៀតឡើយ អោយតែគេនោះជាមនុស្សល្អ មានបំណង ល្អចំពោះយើង
ផ្តល់នូវគំនិតណែនាំល្អដល់យើង ហើយជួយបណ្តុះ បណ្តាលយើងអោយមានជីវិត
មានអនាគតល្អ... ចូរកូនចងចាំ សូម្បីតែអ្នកមានគុណដែលធ្លាប់ហុចមកយើងជាដុំបាយមួយដុំក្តី ជា
ទឹកមួយផ្តិលក្តី ឬក៏ត្រឹមជាគំនិតបំភ្លឺផ្លូវក្តី ។ កូនត្រូវរៀនត្រេក ត្រងត្រាប់យកនូវអំពើល្អ
គំនិតល្អរបស់គេ ហើយតបស្នងគេវិញ ដោយសេចក្តីល្អនិងការគោរពរបស់កូន
យ៉ាងពេញលក្ខណៈ ។ កុំ ជោរភ្លេចខ្លួនអីណា៎កូនណា៎! ពេលនេះ យើងរស់នៅ ក្នុងស្រុកខ្មែរ
ដីខ្មែរ យើងត្រូវទទួលត្រងយកបែបផែននៃការរស់នៅជាខ្មែរសម សួន
អោយមានការចុះសម្រុងនឹងសង្គម មិនឆ្គង ឆ្វេងមែក តែម្នាក់ឯង ខុសរបៀបឡើយ ។

*0000000000000000*

*00000*

*0*

CHANBOKEO.COM

# វគ្គទី៧
## ចំណងជីវិត

មង្គលបុរី ឆ្នាំ១៩៥២...

សុធីបានត្រឡប់មករៀនវិញដូចធម្មតា ។ គេខំរៀនណាស់ មិន ធ្វេសប្រហែសសោះឡើយ ខុសតែម្យ៉ាងត្រង់ថា គេជានិស្សិតក្រីក្រ មិនដែលមានខោអាវស្លៀកពាក់ល្អ ឬមានប្រាក់កាសចាយវាយដូច សិស្សដទៃទេ ។ គេត្រូវសន្សំសំចៃគ្រប់យ៉ាង ហើយមិនដើរលេង ផ្តេសផ្តាសបែកអារម្មណ៍ចោលសាលាផង ។ តាំងពីគេត្រឡប់មកពី មង្គលបុរីលើកនេះ សុធីខំរៀនលើសពីដើមទៅទៀត រហូតដល់ សិស្សដែលរៀនស្រករគ្នានោះចំអន់លេងរាល់ថ្ងៃថា សុធីកំពុងបង្ខំ រៀនអោយឆាប់ចប់នឹងអាលការប្រពន្ធ ។ សុធីមិនដែលហ៊ានចេញស្តីអ្វីតបនឹងពាក្យចំអន់របស់មិត្តទេ ព្រោះសុធីកំពុងមានបំណងវិល ទៅរកមណីវិញឆាប់ៗពិតមែន ។ តាំងពីគេបែកគ្នាមក អារម្មណ៍ របស់គេគួចនឹកទៅរកនារីគ្មានស្រាកស្រាន្តសោះឡើយ ។ ថ្ងៃណាក៏ សុធីគេងស្រមៃនឹករង្វង់ភក្រ្តដ៏ស្រស់ស្អាតមួយនោះដែរ ។ ពេល នេះ រូបណាលីបានរលត់សូន្យ ពីក្រអៅបេះដូងរបស់គេទៅហើយ នៅសល់តែស្រមោលមណីតែម្នាក់ប៉ុណ្ណោះ ដែលតែងតែមកអង្អែល បេះដូងរបស់មាណពយើង ឲ្យរំជើបរំជួលគ្មានស្រាកស្រាន្ត ។

បីខែក្រោយមក...

សុធីក៏បានទទួលវិស្សមកាលសាលាចំនួនពីរអាទិត្យ ដើម្បីទៅ លេងផ្ទះពេលចូលឆ្នាំខ្មែរ ។ នៅវេលារសៀលដែលនាយចេញពី សាលារៀននៅថ្ងៃចុងក្រោយ សុធីក៏ទាញកង់រឹង ធាក់ទៅមង្គលបុរី ទាំងយប់ត្បិតមិនអាចទ្រាំចាំដល់ស្អែកបាន ។ គេនឹកមណីណាស់ ។ ពេលនោះ បេះដូងរបស់គេស្រែកច្រៀងតែចម្រៀងមួយបទគត់ គឺ មណីកំពូលដួងចិត្ត ។ តាមផ្លូវ សុធីធាក់កង់បណ្តើរ ញញឹមតែម្នាក់ ឯងបណ្តើរ ។ បេះដូងរបស់គេលោតកញ្រ្ជោលញាប់ញ័រដោយភ្លើង ស្នេហា ប៉ុន្តែក៏នៅកន្ទះរាធុញថប់បន្តិចដែរ ព្រោះគេមិនដឹងថា តើមណីមានអារម្មណ៍យ៉ាងណាចំពោះគេវិញ ។

តុក! តុក! តុក!

CHANBOKEO.COM

- នរណាគេហ្នឹង ?

- គឺខ្ញុំណា៎យាយ! ខ្ញុំគឺ សុធី!

- សុធីណា៎អញ្ចេះ ?

ទ្វារក៏បើកឡើង ។ សុធីក៏ប្រទះឃើញយាយគិមហួយឈរកាន់ ចង្កៀងបំភ្លឺមើលមុខនាយ ។

- អូហ៍! អាយូទេតើហ៍! ដល់តែប្រើឈ្មោះខ្មែរអញ្ចឹងទៅ យាយ ចំណាំឯងមិនបានទេ ។ ម៉ោះ! ចូលក្នុងផ្ទះសិនមក៍!

សុធីដើរចូលទៅ ឃើញផ្ទះស្ងាត់ឈឹង មិនឃើញនរណាទៀត សោះ ក៏ប្រហោងពោះធ្លុងតែម្តង ។ គេនឹកក្នុងចិត្តថា ប្រហែលជា ឪពុកមណីមកតាមយកនាងត្រឡប់ទៅវិញហើយ ។

- យាយនៅផ្ទះតែម្នាក់ឯងទេ ? (សុធីសួរ)

- ពីរនាក់ទ៎ុយ មិនមែនម្នាក់ឯងទេ ។

សុធីអរភើត កាលបើឮដូច្នោះ ។ គេក៏សួរបន្តថា ៖

- ហើយចុះឯណាម្នាក់ទៀតនោះ យាយ ?

- គឺអាដាង ឆ្កែយាយនោះអី ។ អាហ្នឹងវាទ្រមក់ណាស់ យប់ឡើង វាដេកទល់ភ្លឺ មិនចេះព្រុសចោរណាបានម្នាក់ទេ ។

សុធីខកចិត្តស្រឡេត កាលបើអ្នកទីពីរនោះមិនមែនជាមណី ។ គេក៏ដាច់ចិត្តសួរយាយត្រង់ៗថា ៖

- ហើយចុះមណីវិញនោះយាយ ? គេសុខទុក្ខយ៉ាងណាហើយ ?

ស្រាប់តែយាយគិមហួយញញឹមឡើង ៖

- មកដល់មិនឃើញសួរសុខទុក្ខយាយម៉ាម៉ាត់សោះ ឃើញតែសួរ សុខទុក្ខអ្នកដទៃទៅវិញ..! ឯងមិននឹកយាយខ្លះទេហ្ន៎ស ?

មាណពភ្ញាក់ព្រើត ដែលខ្លួនភ្លេចសួរសុខទុក្ខមនុស្សចាស់ ។ គេក៏លើកដៃសំពះឡើង ៖

- អោយចៅសូមទោសផងដែលសួរសុខទុក្ខអ្នកដទៃ មុនយាយ! ការពិតនោះ ចៅនឹកយាយពេញបេះដូងចៅឯណោះ ។

ស្រាប់តែយាយគិមហួយសើចខឹកៗ ឆ្លើយថា ៖

- យាយនិយាយលេង ។ កុំភ័យអី! ការពិត នាងមណីគេមិនបាន នៅទីនេះទេចៅ ។

- អូហ៍... គេត្រឡប់ទៅផ្ទះវិញហើយឬយាយ ?

CHANBOKEO.COM

- ហ្នឹងហើយ! គេទៅប្អូនដប់ថ្ងៃហើយ ប៉ុន្តែឮថាមកវិញព្រឹក ស្អែកនេះ ។
- ស្លាប់ហើយ... ទៅផ្ទះវិញ... វីវរ មណីត្រូវទណ្ឌកម្មឈឺខ្លួនទៀត ហើយទេដឹង យាយ ?
- អត់ទេ! មណីមិនបានវិលទៅផ្ទះរបស់ឪពុកនាងទេ តែនាងវិល
ទៅស្រុកកំណើតខាងម្ដាយ ដើម្បីធ្វើបុណ្យហើយត្រូវវិលត្រឡប់មក មង្គលបុរីថ្ងៃស្អែក
ព្រោះនាងបានទទួលសំបុត្រឯងថា ឯងនឹងឡើង មករកនាងពេលសំរាកចូលឆ្នាំខ្មែរ ។ ឥឡូវនេះ
ស្រាប់តែឯងបែរ ជាមកដល់មុនម៉ាង៉ៃទៅវិញ អញ្ចឹងហើយ បានជាឃ្លាងមិនបានជួប
គ្នានោះអី ។

អំបាញមិញ សុធីនឹកខកចិត្តស្រឡេតទៅហើយ តែដល់ឮថា មណីនឹងមកដល់វិញព្រឹកស្អែក
គេមានកម្លាំងចិត្តប្រឹសតែម្ដង ។

- អាចៅឯងបរិភោគហើយឬនៅ ?
- បាទ! នៅទេយាយ!
- អញ្ចឹងទៅរកស្ទីដាក់ពោះម៉ាម៉ាត់នៅឯចង្ក្រានទៅ ។ យាយមាន សល់ម្ហូបក្រៀមក្រោះខ្លះដែរ ។

សុធីមិនទាន់ដើបទៅផង ស្រាប់តែ...

តុក! តុក! តុក! សូរសម្លេងគោះទ្វារ ។

- នរណាហ្នឹង ? (យាយគិមហួយសួរ)
- ចាស គឺជាមណី យាយ!

សុធីភ្ញាក់ព្រើតដែលធិតាមកដល់ផ្ទះវិញ ព្រមពេលគ្នាជាមួយ នាយដូចណាត់ទុក ។
យាយគិមហួយក្រឡេកឃើញទឹកមុខរបស់ មាណពយើងក៏យល់ភ្លាម
ថានាយកំពុងមានអារម្មណ៍យ៉ាងណា ។ គាត់ញញឹមរួចហើយក៏ដើរទៅបើកទ្វារ ។
មណីលើកដៃជំរាបសួរ ដូនចាស់ ស្រាប់តែភ្ញាក់ក្រញាងដែលឃើញសុធីមកដល់មុននាង ។
ឆវីឈរធ្វើភាំង មិនដឹងថាចង់និយាយថាម៉េច ព្រោះមិនបានគិតថា
នរៈនឹងមកដល់ទាំងយប់ដូច្នោះផង ។ ឃើញចៅប្រុសចៅស្រីឈរ ធ្វើមុខអេះអុញដាក់គ្នា
យាយគិមហួយក៏មានប្រសាសន៍ឡើង កាត់បរិយាកាសដ៏ស្ងាត់ស្ងៀមនោះ ថា ៖

- អ៊ើ! មណី! បាននរណាជូនមក បានជាមកដល់ផ្ទះទាំងយប់ ដូច្នោះ ?
- គឺខ្ញុំអោយមនោ ប្អូនប្រុសរបស់ខ្ញុំជួយឌុបកង់ពីភូមិជប់មកវិញ តាំងពីថ្ងៃត្រង់ម្ល៉េះ ។
- ចុះពេលនេះ មនោវាទៅណាហើយ ?
- គេចេញទៅគេងឯផ្ទះប៉ាខ្ញុំវិញហើយ ។

CHANBOKEO.COM

ពេលនោះ ធិតាហាក់ដូចជានឹកខ្មាសក្រសែភ្នែករបស់សុធីដែលសម្លឹងនាងមិនដាក់ភ្នែកនោះណាស់ រហូតដល់បែកញើសខ្នង... ត្រជាក់អស់បាតដៃបាតជើងតែម្តង ។

- ហើយ ចៅបរិភោគបាយហើយនៅ ?
- ចាំស! គឺ... នៅទេយាយ!

គ្រាន់តែឮដូច្នោះ សុធីហក់រឹងចូលចង្ក្រានបាយរករៀបចំស្តុក អាហារយ៉ាងរហ័ស រួចហើយក៏ត្រឡប់មកហៅមណីវិញ ៖

- មកបរិភោគជាមួយខ្ញុំទៅ នី! ខ្ញុំក៏មិនទាន់ញ៉ាំបាយល្ងាចដែរ ។

យាយគិមហួយហាក់ដូចដឹងចិត្តចៅទាំងពីរ ក៏ដើបគេចខ្លួនចូល សំរាន្តបាត់ទៅ ទុកឲ្យអ្នកទាំងពីរនៅអង្គុយបរិភោគបាយតែពីរនាក់ ក្រោមពន្លឺក្រហមស្រទន់នៃចង្កៀងប្រេងកាតតូចមួយ ។ អ្នកទាំងពីរលូកដៃចាប់បាយបរិភោគបណ្តើរ លួចចោលកន្ទុយភ្នែកដាក់គ្នា ភ្លៀកៗបណ្តើរ ប៉ុន្តែមិនមាននរណាសួរអ្វីនរណាសោះ ទំនងដូចជាគេកំពុងលួចញាប់ញ័រក្នុងចិត្តហើយអៀនខ្មាស់រៀងៗខ្លួន ។

មួយស្របក់មក ទើបសុធីកាត់ចិត្តអៀនខ្មាស សួរមណីថា ៖

- នី! សុខសប្បាយទេ កន្លងមកនេះ ?

ធិតានៅតែឈ្ងោកមុខដដែល ប៉ុន្តែសុធីសង្កេតឃើញមានស្នាមញញឹមមួយដក់ជាប់លើផ្ទៃមុខរបស់នាង ហាក់ដូចជាចម្លើយប្រាប់ថា ជីវិតរបស់នាងបានគ្រាន់បើជាងមុនហើយ ។ លុះរំងាប់ភាពញាប់ ញ័រនៅក្នុងចិត្តបានហើយ ទើបធិតាឆ្លើយវិញថា ៖

- យាយថៃទាំខ្ញុំកក់ក្តៅណាស់ ។ ចុះ... អ្នក... ?

តាមតំបន់ខ្លះនៅបាត់ដំបង ពាក្យថា អ្នក មានន័យថាបងថ្លៃ ប៉ុន្តែនៅកន្លែងខ្លះទៀត មានន័យថា អ្នកម្តាយ គ្រាន់តែគេនិយាយ កាត់អោយខ្លី ។ ចំណែកតំបន់ខ្លះទៀត គេប្រើពាក្យ អ្នក ចំពោះ មនុស្សដែលមានវ័យច្រើនជាងខ្លួន ។

- ខ្ញុំសុខជាទេ នី! ប៉ុន្តែ ខ្ញុំនឹកដល់នីណាស់... គឺ... មានន័យថា... ខ្ញុំនឹកដល់សុខទុក្ខរបស់នី...បារម្ភក្រែងមិនបានសុខសប្បាយ...

CHANBOKEO.COM

សុធីនិយាយក្នុងសំនៀងញាប់ញ័រ អួលអាក់ ហាក់ដូចជាកំពុង រន្ធត់នឹងសំណោកទារុណជីវិតរបស់មណី នៅក្នុងបេះដូងរបស់គេ នៅឡើយ ។ មណីឮដូច្នោះ ក៏ងើបមុខឡើង សម្លឹងនរៈដោយ ក្រសែភ្នែកភ្លឺថ្លា ៖

- ជីវិតខ្ញុំបានប្រសើរវិញហើយ... អ្នកឈប់បារម្ភទៅ ប្រយត្ន័ខូច អារម្មណ៍ រៀនមិនកើតណា៎!

សុធីញញឹមភ្លាម កាលបើនឹងថា ធិតាហាក់ដូចជាគិតមកដល់ សុខទុក្ខរបស់នាយដូចគ្នា ។ បន្ទាប់ពីបរិភោគបាយហើយ សុធីក៏ យករបស់មួយប្រអប់មកហុចអោយមណី ។ ធិតាភ្ញាក់ក្រញាង សម្លឹងមុខនរៈទាំងងឿងឆ្ងល់ ប៉ុន្តែសុធីបែរជាញញឹម ស្រដីថា ៖

- គឺខ្ញុំបានតាំងចិត្តថា យកមកផ្ញើ នី...

មណីលូកដៃទទួលយកមកបើកមើល ស្រាប់តែឃើញប្រាក់ជា ច្រើន ចងជាបាច់ៗ ៖

- មានន័យថាម៉េចហ្នឹង ?... (មណីសួរ)

- កុំគិតវែងឆ្ងាយអី! នេះគ្រាន់តែជាសោហ៊ុយជួយទប់ទល់ការខ្វះ ខាតរបស់នី ពេលនីស្នាក់នៅជាមួយយាយ ។ ពេលណាខ្ញុំរកបាន ទៀត ចាំខ្ញុំផ្ញើមកទៀត តាមក្រោយ ។

- ប៉ុន្តែ... នីមិនហ៊ានទទួលទេ ព្រោះ...

- មិនជាការខុសត្រូវអ្វីទេ នី! នេះជាប្រាក់ដែលខ្ញុំរកដោយកម្លាំង របស់ខ្ញុំផ្ទាល់ មិនបានលួចនរណាទេ ។

- ប៉ុន្តែ វាមិនសមរម្យទេ បើខ្ញុំទទួលយក... គឺថា... អ្នកយកគួរ យកទៅផ្ញើនឹងយាយវិញទៅ ទើប...

- ខ្ញុំមានចំណែកសំរាប់ផ្ញើជូនយាយហើយ (សុធីស្រដីកាត់) ប៉ុន្តែ ចំណែកមួយនេះ ជារបស់នី សំរាប់ចូលឆ្នាំខ្មែរ...

- ដូចជាច្រើនណាស់... សំរាប់... ខ្ញុំមិនអាចទទួលបានទេ!

- បើអញ្ចឹង ឲ្យខ្ញុំផ្ញើទុកជាមួយនីផងបានទេ ចាំថ្ងៃណាខ្ញុំត្រូវការ ចាំខ្ញុំមកយកវិញ ព្រោះនៅកន្លែងស្នាក់ឯសាលាបាត់ដំបង គ្មាន កន្លែងទុកដាក់អោយគង់វង្សទេ អាចបាត់ងាយណាស់ ។

មណីសម្លឹងមុខនរៈ ឃើញគេញញឹម សម្តែងការទុកចិត្តមកលើ នាងទាំងស្រុង ។ ក្រសែភ្នែករបស់គេបានផ្តល់ភាពកក់ក្តៅយ៉ាង ចម្លែកក្នុងបេះដូងមាណវីយើង ។ រំពេចនោះ នាងក៏ញញឹមតបវិញ ហើយក៏ទទួលប្រអប់នោះយកទៅទុក មិនឮប្រកែកអ្វីតទៅទៀត ដែរ

CHANBOKEO.COM

ទំនងដូចជានាងមានមោទនភាព ចំពោះការដែលបុរសទុក
នាងរហូតចិត្តហ៊ានផ្ញើលុយកាក់ដែលគេខំសន្សំទុកនោះជាមួយធនី ។

យប់នោះ គេនៅអង្គុយអេះអុញដាក់គ្នាយ៉ាងយូរ ព្រោះរកនឹក អ្វីមកនិយាយគ្នាមិនបាន បន្ទាប់មកក៏នាំគ្នាលូនចូលដំណេក គេង រសាប់រសល់រៀងៗខ្លួន រហូតទល់ភ្លឺ ។

ព្រហាមឡើង...

- ឯងធ្វើអីហ្នឹង អាង៉ា ? (យាយគិមហួយសួរ)
- គឺដណ្តាំអាហារពិសេសជូនយាយនិងមណីពិសារ (សុធីឆ្លើយ)
- បានស្អីដែរទៅហ្ន៎ស ?
- គឺខ្ញុំដើបទៅផ្សារតាំងពីព្រហាមស្រាងៗ ទិញគ្រឿងយកមកបបរ សាមចុក ពេលនេះឆ្អិនហើយបាទ! យាយអញ្ជើញអង្គុយមក ខ្ញុំ ដួសជូន ។

យាយគិមហួយទទួលបបរពីចៅ ហើយដួសទទួលទានយ៉ាង ឆ្ងាញ់ពិសារ ។

- នី មិនបរិភោគទេហ៏ ?

សុធីសួរមណីដែលអង្គុយសម្លឹងបបរធ្វើភ្នែកម៉ក់ៗ ។ កាលបើ ឮមាណពសួរ នាងក៏ឆ្លើយវិញថា ៖

- ខ្ញុំមិនសូវចូលចិត្តបបរទេ ។

សុធីភ្ញាក់ព្រើត មួយភ្លែតមកក៏ញញឹមហើយស្រដីថា ៖

- អញ្ចឹង នីចង់ញុាំអីដែរ ចាំខ្ញុំធ្វើជូន ។

ការពិត មណីមិនដែលធ្លាប់អោយនរណាបំរើទេ កាលបើមាន គេបំរើយកចិត្តទុកដាក់ដូច្នេះ នាងរអៀសខ្លួនណាស់ ក៏ឆ្លើយថា ៖

- មិនអីទេ ចាំខ្ញុំធ្វើដោយខ្លួនឯងចុះ ។
- ប៉ុន្តែ សុធីរ៉ាកងទំនេរដល់ទៅពីរអាទិត្យ មកស្នាក់បំរើនៅទីនេះ ជាសាច់ញាតិ នីកុំទើសទាល់អីណា៎ ។

យាយគិមហួយលួចមើលគ្រប់កាយវិការរបស់សុធី ឃើញថា នាយធ្វើអ្វីដោយទឹកចិត្ត មិនមែនធ្វើពើជាឧស្សាហ៍ទេ ។ គេជា មនុស្សរវាសរវៃ ហើយធ្វើអ្វីមានលក្ខណ៍មានជា ខុសពីមណីដែល មិនហ៊ានធ្វើអ្វីគិតអ្វីដោយខ្លួនឯងទេ ព្រោះខ្លាចខុសត្រូវមាត់ ឬត្រូវ រំពាត់ចាស់ៗ ។ ចំណែកសុធីវិញ គេឆាប់យល់ស្ថានការណ៍ណាស់ ហើយអាចសម្របសម្រួលខ្លួនគេ

CHANBOKEO.COM

បានឆាប់រហ័ស ។ ព្រឹកនេះ គេ ដើបតាំងពីព្រហាម រែកទឹកដាក់ពាង ហើយដណ្តាំបបរអោយដូន ចាស់និងមណីបរិភោគយ៉ាងឆ្ងាញ់ទៀតផង ។ យាយគិមហួយលួច ញញឹមតែម្នាក់ឯង ហាក់ដូចជាមានគំនិតគិតអ្វីម្យ៉ាងចំពោះចៅប្រុស ចៅស្រីទាំងពីរហើយ ។

- អានាងហ្នឹស! ឯងទំនេរទេ ព្រឹកនេះ ?

- បាទ ទំនេរយាយ! ទំនេរដល់ទៅពីរអាទិត្យឯណោះ ។ យាយ មានការអ្វីប្រើចៅមកចុះ ចាំចៅបំរើយាយអោយអស់ពីសមត្ថភាព តែម្តង ។

- អឺ! បើអញ្ចឹង ជូនយាយយកចង្ហាន់ទៅវត្តបន្តិច ។

- បាទ!

ព្រឹកនោះ សុធីក៏ដុតដៃដុតជើងជួយធ្វើអាហារទៅវត្ត ។ បន្តិច មក គេក៏អុំទូកនាំយាយគិមហួយនិងមណីទៅត្រើយម្ខាង ។ ពេល ទៅដល់ ស្រាប់តែអ្នកទាំងអស់គ្នា ប្រទះមេឃុំនៅទីនោះដែរ ។ ក្រោយពីក្រាបបង្គំព្រះចៅអធិការហើយ យាយគិមហួយក៏មាន ប្រសាសន៍ ថា ៖

- ខ្ញុំព្រះករុណាសូមនិមន្តព្រះគ្រូ ច្រូចទឹកចងដៃចៅប្រុសចៅស្រី កំព្រារបស់ខ្ញុំទាំងពីរនាក់នេះផង ។

សុធីនិងមណីភ្ញាក់ក្រញាង បែរមើលមុខគ្នាយ៉ាងរហ័ស កាល បើឮដូនចាស់មានប្រសាសន៍យ៉ាងដូច្នោះ ។

- ចៅទាំងពីរ ចូលអង្គុយជិតព្រះគ្រូមក នឹងអាលអោយលោក ប្រោះព្រំទឹកមន្តអោយ ។

អ្នកទាំងពីរធ្វើអេះអុញមួយស្របក់ តែក៏មិនហ៊ានធ្វើមាត់អ្វីដែរ ព្រោះគេខ្មាសចាស់ៗផង ខ្មាស់គ្នាទៅវិញទៅមកផង ។ បន្តិចមក គេក៏លូនទៅជិតព្រះគ្រូ ក្រាបក្បាលដល់កន្ទេល ដើម្បីអោយព្រះគ្រូ សូត្រប្រស់ព្រំជ័យមង្គលអោយ ទាំងអារម្មណ៍ភ្ញាក់ផ្អើលរន្ធត់ញាប់ ញ័រក្នុងចិត្ត ។ រីឯព្រះគ្រូ មេឃុំ និងដូនចាស់វិញ បែរជាញញឹម ដាក់គ្នា ទំនងដូចជាបានណាត់គម្រោងអ្វីទុកជាមុនអញ្ចឹង ។

លុះប្រគេនចង្ហាន់ដល់ព្រះគ្រូហើយ សុធីក៏អុំទូកនាំដូនចាស់ និងមណីត្រឡប់មកផ្ទះវិញ ។ ប៉ុន្តែ លើកនេះ អ្នកទាំងពីររិតតែ អេះអុញដាក់គ្នាលើសដើមតែម្តង ។ មានតែយាយគិមហួយទេដែល មានកិរិយាថាគាត់មានសេចក្តីសុខជាទីបំផុត ។

មកដល់ផ្ទះវិញ យាយគិមហួយក៏ហៅចៅទាំងពីរមកជិតហើយ ស្រដីថា ៖

CHANBOKEO.COM

- ចៅមិនខឹងនឹងយាយទេ មែនទេ ដែលយាយរៀបការឯងទាំង ពីរ ជាគូជីវិត ?

សុធីនិងមណីលួចចោលភ្នែកលួចមើលគ្នាសាថ្មី ។ មែនហើយ! ចំពោះសុធី សំនួរមួយម៉ាត់នេះពេញចិត្តមាណពយើងណាស់! ចុះ មាណវីយើងនោះ ?

មណីនៅអង្គុយឈ្ងោកមុខស្ងៀមឈឹងមិនឮ ឆ្លើយតបថាម៉េចទេ ។

យាយគិមហ្វួយក៏មានប្រសាសន៍បន្តថា ៖

- បើចៅមិនឆ្លើយ មានន័យថា ចៅយល់ព្រមតាមយាយហើយ ។ អញ្ចឹង មកតាមយាយមក់!

ដូនចាស់ក៏ដើបទៅអុជធូបនៅចំពោះមុខហឹងសក្ការៈមួយ រួច ហើយក៏អោនកាយសំពះដូនតា បន្ទាប់មកក៏ហៅចៅទាំងពីរមកអុជ ធូបសំពះដូនតាដែរ ។ អ្នកទាំងពីរមើលមុខគ្នាសាជាថ្មី ថាប្រកែក ទេ ក៏មិនហ៊ាន ថានឹងព្រមទៅ វាដូចជាខ្មាសខ្លួនឯងយ៉ាងណាមិន ដឹងសោះ ។ ឃើញចៅរារែក យាយក៏ចាប់ដៃអ្នកទាំងពីរអូសមក ដល់ចំពោះមុខជើងធូបដូនតា ៖

- ឆាប់អុជធូបសំពះដូនតាទៅចៅ!

សុធីដើបឈរឡើងអុជធូប ហើយបេះធូបហុចអោយមណីមួយ ចំណែក បន្ទាប់មកគេក៏ដាក់ខ្លួនលុតជង្គង់ចុះក្បែរធិតា រួចបង្អោន សិរសាគោរពដូនតាតាមការបង្គាប់របស់ដូនចាស់ ឥតអែអង់យូរ ។ លុះចប់ពិធីហើយ ដូនចាស់ក៏ហៅអ្នកទាំងពីរមកជិត ទើបស្រដី ពន្យល់ទៅអ្នកទាំងពីរទៀតថា ៖

- ពេលនេះ យាយស្រឡះចិត្តហើយ ដែលបានរៀបការអ្នកទាំងពីរ សមរម្យតាមប្រពៃណី ទាំងចិន ទាំងខ្មែរ ថ្វីបើយើងមិនមានភ្ញៀវ សំខាន់ៗចូលរួមក៏ដោយ ក៏ដូនតាមិនប្រកាន់ខឹងដែរ ព្រោះមនុស្ស សំខាន់ក្នុងជីវិតរបស់យើង បានស្លាប់ចោលយើងអស់ហើយ នៅសល់តែអ្នកដែលមិនព្រមទទួលស្គាល់ចៅ ជាសាច់ញាតិប៉ុណ្ណោះ ។ ដូច្នេះ ចៅកុំគិតច្រើនធ្វើអ្វី ។ ស្អែកនេះ យាយនឹងនាំចៅទៅចុះ អេតាស៊ីវិលតាមច្បាប់ទៀត នោះចៅនឹងក្លាយជាស្វាមីភរិយាពេញ មុខ ដោយមិនបាច់ភ័យថា មាននរណាគេអេចអូចរឿងចៅអោយ ខូចកិត្តិយសកេរ្តិ៍ឈ្មោះតទៅទៀតឡើយ ។

ពេលបានឮដូនចាស់មានប្រសាសន៍ដូច្នោះ សុធីយល់ភ្លាមថា តាំងពីមណីចេញពីផ្ទះមក ប្រហែលជាមានពាក្យចចាមអារាមមិនល្អ ពីនាងហើយ ជាពិសេសរឿងនាងនិងសុធីតែម្តង ។ ប៉ុន្តែគេក៏ពេញ ចិត្តនឹងបំពេញបំណងនេះ ដើម្បីលាងកេរ្តិ៍ឈ្មោះអាក្រក់របស់មណី ចោលដែរ ថ្វីបើអ្វីៗកើតឡើងចំពោះនាយព្រឹកនេះ វាហាក់ដូចជា ភ្ញាក់ផ្អើលតក្កហាលបន្តិចក៏ដោយ ។

CHANBOKEO.COM

សុធីក៏លួចសង្កេតពីកិរិយារបស់មណីដែរ ប៉ុន្តែគេឃើញនាង នៅឈ្ងោកមុខធ្វើស្ងៀមស្ងាត់ មិនមាត់មិនកសោះ ធ្វើអោយនាយ នឹកពិភាល់ក្នុងចិត្ត មិនដឹងនាងគិតយ៉ាងណាពីហេតុការណ៍ដែល កើតឡើងយ៉ាងរហ័សរវាងអ្នកទាំងពីររកតែត្រៀមខ្លួនមិនទាន់ដូច្នេះ នោះ ។ បន្តិចមក យាយគិមហ្មួយក៏មានប្រសាសន៍បន្តថា ៖

- ប្រហែលជាចៅគិតថា វាឆាប់រហ័សពេកដែលយាយសំរេចចិត្ត រៀបចំអ្នកទាំងពីរជាគូ ប៉ុន្តែ ចៅក៏គួរតែដឹងហើយថា យាយចាស់ ជរា... អាយុចិត្តប្លាយហើយមិនដឹងថា នឹងលាលោកនេះទៅវិញថ្ងៃ ណាទេ ។ យាយមិនចង់ឃ្លាតទៅដោយមិនបានគិតគូររៀបចំចៅឲ្យ សមរម្យនោះឡើយ ។ ពេលនេះ យាយមានអារម្មណ៍ស្ងប់ហើយ ទីមួយ ចៅក៏បានចាកផុតមាត់ចាបមាត់ព្រាបទាំងពួង ។ ទីពីរ យាយក៏បានចងដៃចៅមុននឹងយាយលាទៅ ។ ទីបី យាយគិតថា ចៅទាំងពីរជាគូដែលសក្តិសមនឹងគ្នាបំផុត ហើយប្រាកដជាអាច រក្សាគ្នាជាគូបានយូរលង់អង្វែងតទៅ ។ សូមចៅថែរក្សាគ្នាហើយ ស្រឡាញ់គ្នាអោយបានច្រើនណា៎ចៅ! ខុសត្រូវអ្វី សូមសន្តោស អធ្យាស្រ័យចំពោះគ្នាទៅវិញទៅមក កុំយកកំហែងទល់កំហល់ឲ្យ សោះ ។ ហឹង្សាមិនអាចដោះស្រាយអ្វីរួចឡើយ ចាំទេចៅ ?

អ្នកទាំងពីរក្រាបសំពះដូនចាស់ដល់បាទា ហើយទទួលយកនូវ ពរជ័យទាំងឡាយដែលដូនចាស់ប្រទានអោយ ដោយដួងចិត្តរំភើប ក្រៃលែង ។ មែនហើយ! ដូនចាស់គ្រាន់តែជាញាតិសាច់ឆ្ងាយម្នាក់ ប៉ុន្តែហេតុអ្វី លោកមានមេត្តាធម៌ចំពោះគេទាំងពីរម្ល៉េះ ? ចំណែកឯ បងយិញ ឬ ប៊ុហ្វត... ម៉េចក៏មិនមានទឹកចិត្តអ្វីចំពោះសាច់ឈាម ខ្លួនឯងអីបន្តិចសោះអញ្ចឹង ? ពេលនេះ ថ្វីបើអ្នកទាំងពីរមិនបាន ទទួលនូវពិធីអាពាហ៍ពិពាហ៍យ៉ាងគគ្រឹកគគ្រេងដូចអ្នកដទៃក៏ដោយ ក៏សុធីមានអារម្មណ៍ថា គេមានមោទនភាពបំផុត ដែលហោចណាស់ គេមានមនុស្សចាស់ម្នាក់មានសេចក្តីមេត្តាសណ្តោសដល់រូបគេដែល គ្មានញាតិជាទីពឹង ។

ចំណែកមាណវីយើងវិញ ទោះបីជាមានកិរិយាភ្ញាក់ផ្អើលចំពោះ អ្វីៗដែលកើតឡើងថ្ងៃនេះ ប៉ុន្តែ នាងក៏មិនបានបញ្ចេញកិរិយាណា ថានាងមិនពេញចិត្តនឹងទទួលសុធីជាគូគ្រងដែរ

CHANBOKEO.COM

ឃើញតែធ្វើតាម ដូនចាស់សព្វបែបយ៉ាងដោយឥតប្រកែក ទំនងប្រហែលជានាង មានអារម្មណ៍មិនខុសពីសុធីប៉ុន្មានទេ គ្រាន់តែនាងជាស្រី មិនហ៊ាន បង្ហាញអារម្មណ៍ផ្ទាល់ខ្លួនមកក្រៅអោយគេដឹងប៉ុណ្ណោះ ។

រាត្រីនោះ ដូនចាស់បានចេញទៅស្នាក់នៅឯវត្ត ដោយសំអាង ថាគាត់ត្រូវទៅសំណាក់ធម៌ ។ ការពិត យាយគិមហួយកំពុងរក ឱកាសអោយអ្នកទាំងពីរបានស្គាល់គ្នាជិតដិតជាងមុន ។

មណីរៀបចំកន្លែងចូលដំណេក ។ ថៃដន្យ យាយគិមហួយបាន យកមុងមួយទៅជាមួយគាត់ សំរាប់ចងសំរានខ្លួនគាត់ នៅសល់តែ មុងមួយប៉ុណ្ណោះនៅឯផ្ទះសំរាប់អ្នកទាំងពីរ ។ ធិតាក៏លូនចូលគេង ក្នុងមុងបាត់ទៅ នៅតែសុធីដែលដើរត្រេះត្រុះនៅខាងក្រៅ មិន ហ៊ានចូលគេង ។ ម្យ៉ាងគេមិនបានឮនារីនិយាយរាក់ទាក់ស្វាគមន៍ នាយអ្វីមួយម៉ាត់ទេ ពេញមួយថ្ងៃហើយ ប្រហែលជានាងរន្ធត់ញាប់ ញ័រនឹងការផ្លាស់ប្តូរដ៏ឆាប់រហ័សនេះក៏មិនដឹង ។ យប់ជ្រៅបន្តិច សុធីក៏ទាញក្រមាងណ្តប់ រួចសណ្តូកជើងបិទភ្នែកនៅលើរានឫស្សី ខាងក្រៅផ្ទះតែម្នាក់ឯង ប្រឡែងលេងជាមួយហ្វូងមូសដែលមក ជំរាបសួររូបនាយជុំទិស ។

- អ្នក!...

សុធីបើកភ្នែកឡើង ឃើញមណីមកគោះជើងរបស់នាយ ។

- អញ្ជើញទៅសំរាន្តខាងក្នុងទៅ! នៅខាងក្រៅ មូសច្រើនណាស់ តិចពិបាកឆ្លងជំងឺគ្រុនចាញ់...

ថាហើយមាណវីក៏បែរខ្លួនដើរចូលផ្ទះវិញទៅ ។ សុធីនៅរារែក មួយស្របក់ ក៏ដាច់ចិត្តធ្វើតាមទាំងខ្លាចចិត្ត ។ គេផ្តេកខ្លួនលើខ្នើយ មួយក្បែរនារី ដែលកំពុងគេងបែរខ្នងមករកនាយ ក្នុងមុងដ៏សែន ចង្អៀត ។ ពេលនោះ បេះដូងមាណពយើងរណ្តំញាប់ញ័រយ៉ាង ចម្លែក លើសពេលណាទាំងអស់ក្នុងជីវិត ។ យូរៗម្តង គេដើប លបមើលមណី ឃើញនាងគេងនៅស្ងៀម កន្លែងដដែលមិនកំរើក សោះ មិនដឹងថា នាងគេងលក់ ឬ នាងគេងពើធ្វើជាលក់ទេ ។ នរៈមិនអស់ចិត្ត ក៏ស្រដីហៅមាណវីខ្សិបៗ ៖

- នី! គេងលក់ហើយនៅ ?

ភ្លាមនោះ គេឃើញធិតាកម្រើកខ្លួន ប៉ុន្តែមិនឃើញតបអ្វីមក វិញទេ ។ គេក៏ស្រដីសួរនាងទៀតថា ៖

- នី! ខ្ញុំសូមទោសណា៎ ចំពោះអ្វីៗកើតឡើងថ្ងៃនេះ... គឺថា ខ្ញុំមិន មានបំណងធ្វើអោយនីខូចចិត្តខូចអារម្មណ៍ដោយសាររឿងយើងទេ...

ភ្លាមនោះ ស្រាប់តែគេឃើញមណីញោចខ្លួនបន្តិច ហើយឆ្លើយ មកវិញថា ៖

CHANBOKEO.COM

- ខ្ញុំមិនបានបន្ទោសអ្វីអ្នកទេ! អ្នកសំរាន្តទៅ យប់ហើយ!

ពុទ្ធោ! ការពិត នាងមិនទាន់គេងលក់ឯណា គ្រាន់តែសំងំធ្វើ ជាគេងលក់តើហ៎ ។

- តែ...ខ្ញុំមិនទាន់ងងុយគេងនៅឡើយ... នីនៅជជែកលេងជាមួយ ខ្ញុំសិនបានទេ?

នរៈស្រដីផង លួចមើលធិតាយើងផង ។

- តើ...អ្នកចង់ជជែកពីរឿងអ្វីទៅ? (មណីសួរ)
- គឺថា... យើងទើបតែជួបគ្នាបានពីរដងទេ... មណីមិនចង់ស្គាល់ ប្រវត្តិខ្ញុំទេហ៎ ហ្នឹង?

ស្រាប់តែធិតាប្រែខ្លួន បែរមករកបុរសយើង ហើយស្រដីថា ៖

- បើខ្ញុំចង់ដឹង... តើអ្នកប្រាប់ដែរទេ?
- ទោះនីមិនចង់ដឹង ក៏សុធីចង់ប្រាប់នីដែរ ។
- ម៉េចអញ្ចឹង?
- ព្រោះចង់អោយយើងទុកចិត្តគ្នាទៅវិញទៅមកនោះអី ។
- អញ្ចឹង អ្នកចង់ប្រាប់អីក៏ប្រាប់មក៎ ខ្ញុំចាំស្តាប់ហើយ ។

សុធីសប្បាយចិត្តណាស់ ដែលធិតានៅចាំស្តាប់រឿងរបស់ខ្លួន ។ នេះបញ្ជាក់ថា នាងក៏ចាប់អារម្មណ៍ពីរូបនរៈដែរ គ្រាន់តែនាងមិន ហ៊ានបង្ហើបមាត់សួរមុនតែប៉ុណ្ណោះ ។ ដំបូងសុធីនឹកស្មានថានាងជា មនុស្សម្ងួរមុខហើយតើហ៎ តែការពិតខុសសោះ ។ នាងជាមនុស្ស សំដីរួសរាយ គ្រាន់តែនាងមិនស្គាល់នរៈយើងជិតស្និទ្ធិនឹងស្រដីរាក់ ទាក់តែប៉ុណ្ណោះ ។ ភ្លាមនោះ គេក៏សួរមណីវិញថា ៖

- ចុះបើសុធីនិយាយរឿងអោយនីស្តាប់ចប់ហើយ តើនីនិយាយ រឿងរបស់នី អោយខ្ញុំស្តាប់វិញទេ?
- អ្នកកុំចង់ស្តាប់អី... រឿងខ្ញុំជូរចត់ណាស់!
- ទោះជាជូរចត់ក៏ខ្ញុំចង់ស្តាប់ដែរ បើនីនិយាយប្រាប់ ។ ចំណែក រឿងសុធីវិញក៏ប្រហែលជាជូរចត់ហើយល្វីងទៀតផង ។ តើនីអាច ទទួលបានទេ?

ស្រាប់តែ សុធីឃើញមណីញញឹមឡើង ដាក់មាណពជាលើក ដំបូង ។ ក្រោមពន្លឺចង្កៀងក្រហមស្រទន់ជះមកពីលើតុតាមចន្លោះ ស្បៃមុងនីឡុងដ៏ស្តើង ពណ៌កុលាប នរៈឃើញរង្វង់មុខពងក្រពើ យ៉ាងច្បាស់ជាលើកដំបូង ព្រមជាមួយកែវភ្នែកខ្មៅក្រិបសមជើង ធ្មេញរាបស្មើស្អាតគួរឲ្យចាប់ចិត្តប្រតិព័ទ្ធក្រៃលែង ។ គេគេងសម្លឹង មុខនាងយ៉ាងភ្លន់ភ្លឹក

CHANBOKEO.COM

រហូតដល់នាងនឹកអៀនខ្មាស់នឹងក្រសែភ្នែក របស់នាយ
ហើយប្រែខ្លួនបែរខ្នងមកអោយវិញសាជាថ្មី ថែមទាំង
វាចាថា ៖
- ចុះឯណាដែលថា និយាយរឿងប្រាប់ខ្ញុំនោះ ?
 សុធីភ្ញាក់ព្រើត ពីអារម្មណ៍ភន្តភាំង លង់ក្នុងចេតនារម្មណ៍នឹ
ស្រើបស្រាល ហើយក៏ចាប់ផ្ដើមនិយាយរឿងរបស់គេតាំងពីកុមារ ភាពរហូតដល់ធំពេញវ័យ
ព្រមទាំងបុព្វហេតុទាំងឡាយដែលធ្វើឲ្យ
គេសម្រេចចិត្តត្រឡប់ចូលទៅរៀនសាងវិជ្ជានៅវិទ្យាល័យមុនីវង្ស ។
គេមិនបានភូតលាក់រឿងអ្វីមួយម៉ាត់ឡើយ សូម្បីតែរឿងរបស់នាង ណាលី ព្រោះគេគិតថា
នោះជាសក្ខីភាពបញ្ជាញនូវការស្មោះត្រង់ របស់គេផង
និងបញ្ជាក់នូវគោលគំនិតជំរុញអោយគេឈោងចាប់ យកការសិក្សាជាលើកដំបូង
ដែលគេមិនដែលគិតថានឹងធ្វើដូច្នេះ ពីមុនមក ម្ដងណាឡើយ ។
 អ្នកទាំងពីរនៅជជែកគ្នារហូតជិតភ្លឺ ទើបព្រះនាងនិទ្រាទេពី
យាងចូលមកសណ្ដំត្របកភ្នែកគេឲ្យលង់លក់រៀងៗខ្លួនទៅ ។
 ព្រឹកស្អែកឡើង...
 មណីភ្ញាក់ឡើងឃើញសុធីលើកថាសបបរក្ដៅៗមកដល់ ៖
- អ្នកក្រោកតាំងពីម៉ោងប៉ុន្មានហ្នឹង បានជាបបរឆ្អិនទៅហើយ ?
 មណីសួរ ។ សុធីឮហើយតបវិញទាំងញញឹមថា ៖
- ក្រោកម៉ាសន្ទុះមុននេះទេ ។ ម៉ោះ ! ញ៉ាំបបរសិនទៅ !
 មណីនឹករអៀសខ្លួនណាស់ដែលនាងភ្ញាក់មិនទាន់បុរសយើង ។ ឃើញនាងអឹមអៀន
គេក៏និយាយបន្ដថា ៖
- ខ្ញុំចង់ទៅលេងស្រុកកំណើតរបស់នីនៅព្រះនេត្រព្រះ ។ នីជូនខ្ញុំ ទៅលេងទេ ?
ពេលចូលឆ្នាំដូច្នេះ បើបានជួបជុំបងប្អូនយើង ធ្វើ
បុណ្យ ប្រហែលជាសប្បាយណាស់ ។
 គ្រាន់តែឮប្រយោគនេះភ្លាម ស្រាប់តែនារីបើកភ្នែកធំៗធ្វើទឹក
មុខភ្ញាក់ផ្អើលសម្ដែងភាពត្រេកអរវីករាយនៅលើផ្ទៃមុខភ្លាម រួច
ហើយនាងក៏ស្រដីតបថា ៖

- អរគុណណាស់ដែលអ្នកមានទឹកចិត្តចង់ស្គាល់ស្រុកកំណើតរបស់ខ្ញុំ ព្រមទាំងអ្នកទាំងឡាយដែលរស់នៅទីនោះ ។

ការពិត មាណវីចង់បបួលមាណពតាំងពីម្សិលម្ង៉ៃ តែមិនហ៊ាននិយាយ ។ កាលបើបុរសបង្អើបមាត់ដូច្នោះ នាងក៏ចាក់បណ្តោយ ភ្លាម ។ បន្តិចមក សុធីក៏នាំមណីទៅជំរាបដំណឹងដល់យាយ គិមហួយ និងព្រះគ្រូ រួចហើយក៏ជិះកង់ឌុបនាងចេញទៅ ។

- សាច់ញាតិខាងម្តាយរបស់នី នៅព្រះនេត្រព្រះទាំងអស់ហ្នៃ៎ស ?

សុធីសួរ ។

- ចា៎ស ! មែនហើយ ។
- ហើយចុះយ៉ាងម៉េចបានជានីមករស់នៅខាងឪពុកទៅវិញ ?
- នោះជារឿងរ៉ាងហ្នឹងវែងឆ្ងាយណាស់...
- អញ្ចឹង នីនិយាយប្រាប់ខ្ញុំខ្លះមក នឹងអាលខ្ញុំបានស្គាល់ផង ។
- បើខ្ញុំនិយាយប្រាប់ហើយ អ្នកកុំសើចយំក្រុមគ្រួសាររបស់ខ្ញុំណា៎ !
- មិនសើចទេ! សុធីហ៊ានស្បថជូននី!

មាណពលើកម្រាមដៃឡើងជាសញ្ញា ។

- បានហើយ! មិនបាច់ស្បថទេ... ចាំខ្ញុំនិយាយប្រាប់ចុះ ។

សុធីក៏ញញឹមឡើង ប្រឹងធាក់កង់បន្តទៅទៀត នៅក្នុងឱកាសដែលមណីរៀបរាប់រឿងរបស់នាងសង្ខេបៗអោយនាយស្តាប់ ដើម្បីអោយបានស្គាល់ក្រុមគ្រួសាររបស់ធិតាកាន់តែច្បាស់ ។

oooooooooooooooooo

oooooo

o

CHANBOKEO.COM

# វគ្គទី៨
# ម្លប់ចិត្ត

កាលពី២០ឆ្នាំមុន...

ម្តាយរបស់មណីឈ្មោះមាលី ជាកូនស្រីច្បងរបស់ដង្ហៅស្រែ ឈ្មោះម៉ានិន ដែលមានកូនក្នុងបន្ទុកចំនួន៦នាក់ ។ នៅអាយុ ១៧ឆ្នាំ មាណវីក៏ត្រូវឪពុកលើកផ្សំផ្គុំអោយទៅបុរសសញ្ជាតិចិនម្នាក់ ឈ្មោះហួត មន្ត្រីរាជការតូចតាចខាងពេទ្យសត្វ ។ ការពិត ជំនាន់ នេះ មានបុរសក្នុងភូមិល្អៗជាច្រើនចូលស្តីដណ្តឹងមាលី តែតាដង្ហៅ ម៉ានិនមិនព្រមលើកអោយទេ ព្រោះគាត់មានទស្សនៈចម្លែក គិតថាអ្នក ដែលមានសាច់ឈាមជាខ្មែរសុទ្ធច្រើនជាមនុស្សល្ងង់ មិនឆ្លាតវៀង វៃចេះរកស៊ីជួញដូររកលុយដូចពួកចៅចិនទេ ម្ល៉ោះហើយគាត់មិន ព្រមលើកកូនស្រីអោយបុរសខ្មែរនរណាសោះឡើយ ។ លុះឃើញ នាយហួតចៅចិនចូលស្តីដណ្តឹង ម៉ានិនក៏លើកកូនស្រីអោយភ្លាម ព្រោះគិតសង្ឃឹមថា នាយហួតនឹងក្លាយជាកូនប្រុសដ៏ប៉ិនប្រសព្វ រកស៊ីមួយរូប មកជួយមើលកិច្ចការរកស៊ីខាងប្រវាសស្រែស្រូវ ។

ថៃដន្យមិនល្អ កូនប្រសារចៅចិនដែលដង្ហៅម៉ានិនជ្រើសរើស មកនោះ ជាមនុស្សពូកែល្បិចសព្វយ៉ាង គឺចេះតាំងពីលួចលក់ស្រូវ ជង្រុកលេងអាប៉ោង ហើយភូតឪពុកក្មេកថា ពួកអាចោរជើងមួយ ចូលប្លន់ ។ លុយដែលទារបានពីឈ្នួលថ្លៃស្រែនិងបំណុលដែលអ្នក ស្រុកជំពាក់ទាំងឡាយ បានត្រូវនាយហួតបំផ្លាញទៅលើស្រា ស្រី ល្បែងពាលាសព្វយ៉ាងរហូតដល់ប្រពន្ធចុងជាច្រើនទៀតផង ។

ដោយហេតុដូច្នោះហើយ ទើបដង្ហៅម៉ានិនក្លាយជាខកចិត្តយ៉ាង ខ្លាំងហើយក៏ចែកទ្រព្យ អោយមាលីនិងហួតចេញទៅរស់នៅដោយ ខ្លួនឯង ។ លុះមាលីប្រសូត្របានកូនទីពីរ នាយហួតបានបំផ្លាញ កេរ្តិ៍គល់ដែលដង្ហៅម៉ានិនចែកអោយនោះអស់រលីង ។ ដោយសារ មូលហេតុរឿងស្រីស្រានិងល្បែងរបស់នាយហួត មាលីចេះតែមាន ទំនាស់នឹងប្តីញឹកញាប់ រហូតដល់មានការវាយទះតប់គ្នា ។ មាលី ទ្រាំនឹងភាពកម្រោលរបស់ប្តីមិនបាន ក៏សុំលះលែង ។

CHANBOKEO.COM

នាយហួត ក៏សុំចែកកូនទីពីរឈ្មោះមនោ ហើយអោយមាលីទទួលយកមណីជា
កូនច្បងត្រឡប់ទៅរស់នៅជាមួយឪពុកឯព្រះនេត្រព្រះវិញ ។

តាំងពីថ្ងៃនោះមក មណីនិងមនោក៏ត្រូវរស់បែកគ្នាហើយទទួល ការអប់រំផ្សេងគ្នាដែរ ។
ជាសំណាងអភព្វរបស់មណីណាស់ នាង មិនទាន់ធំដឹងក្តីផង ដង្វៅម៉ានិន
ជីតារបស់នាងបានត្រូវពួកចោរភ្នំ ជញ្ជាំងចូលប្លន់ជាច្រើនដង
បានវាយធ្វើបាបនិងសម្លាប់សាច់ញាតិ អស់ខ្លះ ព្រមទាំងប្លន់យកអស់នូវទ្រព្យមាសពេជ្រ
ដែលជីតាជីដូន របស់នាងសន្សំទុកជាយូរមកហើយអស់រលីង គ្មានសល់អ្វីឡើយ
ក្រៅពីសំបកផ្ទះនិងជង្រុកស្រូវ ។ មិនយូរប៉ុន្មាន ជីដូនរបស់នាង
ក៏ចែកឋានទៅដោយជំងឺក្រំចិត្ត ។ ក្រោយមកម្តាយរបស់មណីក៏
បានធ្វើអត្តឃាដស្លាប់ចោលមណីទៅ ព្រោះគាត់មិនអាចទ្រាំនឹង
ពាក្យដៀលត្មះរបស់សង្គមជុំវិញខ្លួនបាន ដោយសារការលែងលះប្តី
រួចហើយរត់មករស់នៅជាមួយម៉ែឪវិញ ។ កាលនោះ ជីតារបស់ មណី
បានរៀបការប្រពន្ធថ្មីមួយទៀតអាយុស្រករនឹងម្តាយរបស់ នាង
ប៉ុន្តែគាត់មានសន្តានចិត្តល្អណាស់ ។ ថ្វីបើមណីកំព្រាម្តាយ កំព្រាជីដូនទៅមែន
តែនាងបានទទួលការកក់ក្តៅយ៉ាងគ្រប់គ្រាន់
ពីជីដូនថ្មីរបស់នាង ។

មណីរស់នៅជាមួយជីតាទាំងកណ្តោចកណ្តែងចិត្តនឹកម្តាយរហូត
ទល់ពេលមួយដែលជីតាបានទទួលរងគ្រោះ ដោយអគ្គីភ័យឆេះផ្ទះ
ឆេះឥវ៉ាន់របស់ទ្រព្យអ្វីៗអស់រលីង... ដង្វៅម៉ានិនដែលធ្លាប់តែមាន ឈ្មោះល្បីជាសេដ្ឋីប្រចាំភូមិ
ក៏បានក្លាយទៅជាទុគ៌តជន រស់នៅ យ៉ាងលំបាក ។ ក្រោយមក
ដង្វៅម៉ានិនបានសម្រេចចិត្តអោយកូន ប្រុសៗចូលបួសខ្លះ ការប្រពន្ធខ្លះ
ចេញទៅរកស៊ីនៅទីក្រុងខ្លះ ហើយចុងក្រោយបង្ហួស់យកមណីទៅអោយនាយហួត ឪពុករបស់
នាងចិញ្ចឹមវិញ ព្រោះគាត់គិតថាគាត់ខ្វះសមត្ថភាព នឹងទប់ទល់ សេចក្តីត្រូវការក្នុងគ្រួសារបាន ។
កាលនោះ មណីទើបតែមានវ័យ ១២ឆ្នាំ ។ ព្រមពេលជាមួយគ្នានោះដែរ នាយហួតក៏ទើបតែ រៀប
ការប្រពន្ធក្មេងអាយុ១៦ឆ្នាំ ឈ្មោះណារាយ យកមកនៅលើផ្ទះ
ដំណាលៗពេលគ្នានឹងមណីដែលមកពីព្រះនេត្រព្រះដែរ ។

CHANBOKEO.COM

ថៃដន្យ នាងណារាយនោះមិនមែនជាមនុស្សដែលមានសន្តាន ចិត្តសទ្ធាដូចមនុស្សទូទៅទេ ។ នាងជាមនុស្សទ្រឹស្នូរឃើញតែចូល សូម្បីជាមួយមនោដែលជាកូនប្រុសរបស់នាយហ្លួត ដែលនាយហ្លួត ជំទើតជំទើជិតស្លាប់ ក៏នាងហ៊ានទាញរំពាត់វាយមនោនៅចំពោះ មុខប្តីរបស់នាងដែរ ព្រោះនាងដឹងថា នាយហ្លួតកំពុងតែឈ្លក់នឹង សម្រស់របស់នាង ផ្កាប់មុខដើបមិនរួចទៅហើយ ។ តាំងពីពេល នោះមក ជីវិតសុខដុមរបស់មណីក៏ត្រូវបិទឆាក នៅសល់តែទឹក ភ្នែកដែលស្រក់ចុះមកដោយការឈឺចាប់ចំពោះទារុណកម្មទាំងឡាយ ដែលនាងបានទទួលពីម្តាយចុងផង ពីឪពុកផង ជាពិសេសពីការ ដៀលត្មះពីញាតិខាងឪពុក ដែលម្តាយនាងសុំលែងលះប្តី ។ កាលពី ជំនាន់នោះ ស្ត្រីដែលរងគ្រោះដោយសារហឹង្សារបស់ប្តីមិនអាចធ្វើអ្វី បានទេក្រៅតែពីខាំមាត់ស៊ូទ្រាំដូច្នោះរហូតដល់ស្លាប់ ។ បើសិនជា រើបម្រះរកទីជ្រកសុខអោយផុតពីការវាយធ្វើបាបរបស់ប្តី ដូចដែល មាលីធ្វើនោះ សង្គមខ្មែរទូទៅនឹងសើចយំស្ត្រីនោះ ថាមិនចេះមាន ការអត់ធ្មត់ មិនចេះរក្សាគ្រួសារអោយនៅជួបជុំមាំមួន ប៉ុន្តែគ្មាន នរណាមួយក្នុងសង្គមជួយដាក់ទោសបុរសដែលធ្វើបាបភរិយាដោយ អំពើហឹង្សាទាំងកំរោលរបស់គេនោះឡើយ ។ ដូច្នេះ បុរសមានសិទ្ធិ ខ្លាំងណាស់ ទាំងនៅក្នុងផ្ទះ ទាំងនៅក្រៅផ្ទះ ។

មណីរស់នៅយ៉ាងសែនវេទនាអស់រយៈប្រាំឆ្នាំគត់ ក្នុងក្រញាំដៃ ឫស្យារបស់ម្តាយចុងចិត្តមារ និងឪពុកដែលមិនចេះទទួលខុសត្រូវ រឿងអ្វីនៅក្នុងជីវិត ។ ប្រាំឆ្នាំក្រោយមក នាងក៏បានជួបសុធីដោយ ថៃដន្យ... ហើយខ្សែជីវិតបានទាញនាងចេញពីផ្ទះរបស់ឪពុក មក រស់នៅជាមួយយាយគិមហ្លួយរហូតមក ។ សំណាងល្អ ប៊ុហ្លួតឪពុក របស់នាង វាយឫកធំ មិនព្រមមកតាមហៅមណីអោយត្រឡប់ទៅ ផ្ទះទេ ។ ម្ល៉ោះហើយ មណីក៏បានរស់នៅស្ងប់ស្ងៀមជាមួយយាយ គិមហ្លួយបានសុខមួយរយៈពេល ។

ក្រោយមក យាយគិមហ្លួយក៏លួចមានគម្រោងចង់ផ្គូផ្គុំនាង មណីអោយទៅសុធីទាន់គាត់នៅមានដង្ហើម ទើបដូនចាស់យើងរត់ ទៅពិគ្រោះមេឃុំនិងព្រះគ្រូចៅអធិការ ដើម្បីដោះស្រាយរឿងកូន ចៅ រហូតដល់គាត់សម្រេចចិត្តថា គាត់នឹងទុកដាក់អ្នកទាំងពីរជាគូ នឹងគ្នា

CHANBOKEO.COM

ដើម្បីបញ្ឈប់មាត់ចាបមាត់ព្រាប ដែលបួញបាញមាត់វែង មាត់ខ្លីអ្វី អំពីចៅស្រីចៅប្រុសរបស់គាត់តទៅទៀត ។

តាមផ្លូវទៅព្រះនេត្រព្រះ...

សុធីនិងមណីជិះកង់បណ្ដើរ និយាយគ្នាបណ្ដើរ ។ ពេលនេះ អ្នកទាំងពីរហាក់ដូចជាបើកចិត្ត បើកអារម្មណ៍ ទទួលគ្នា បានទូលំ ទូលាយជាងមុន មិនសូវខ្លាចគ្នាដូចរាល់ដងទេ ។ គេចុះទិញបាយ កញ្ចប់នៅផ្សារសេរីសោភ័ណ រួចហើយក៏បន្តដំណើរទៅមុខទៀត ។ ពេលថ្ងៃត្រង់ គេក៏បានមកដល់ខ្នងភ្នំព្រះនេត្រព្រះ ទាន់ចង្ហាន់ត្រង់ ល្មមដែរ ។ អ្នកទាំងពីរបានសូធ្យមន្តបង្សុកូលជូនម្ដាយនិងជីដូន របស់មណីយ៉ាងសមរម្យហើយ ទើបចុះពីភ្នំទៅជំរាបសួរតាម៉ានិន ជីតារបស់មណីទៀត ។

ជីតារបស់មណីកាន់តែចាស់ទៅហើយ ។ ប្រពន្ធទីពីរបស់គាត់ ទើបចែកស្ថានទៅថ្មីៗនេះឯង ។ កាលបើឃើញមណីនាំសុធីទៅ សំពះជំរាបសួរ គាត់មានការភ្ញាក់ផ្អើលណាស់ ប៉ុន្តែ មិនឮគាត់ស្ដី បន្ទោសអ្វីទេ បែរជាសំដែងនូវទឹកចិត្តសោមនស្សទៅវិញ ដែល យាយគិមហួយសំរេចចិត្តផ្គូផ្គងអ្នកទាំងពីរ ។

- សុធីអើយ! តាសុំផ្ញើមណីផងណាំចៅ! ប៉ុន្មានឆ្នាំនោះ តា ដេកមិនដែលលក់ទេ តាំងពីដឹងថា មណីរស់នៅមិនបានសុខស្រួល ដូចកូនគេកូនឯងទូទៅ តែតាខ្វះសមត្ថភាពនឹងចិញ្ចឹមវានៅព្រះនេត្រព្រះនេះ ។ ដូចឯងឃើញស្រាប់ហើយ កូនរបស់តាមានដល់ ទៅ១២នាក់ ខ្លះក៏មានជីវិតគាប់ប្រសើរ ខ្លះទៀតក៏ជួយខ្លួនមិន បាន ខ្លះក៏នៅតូច ។ ពេលនេះ ប្រពន្ធតាស្លាប់ទៅអស់ទាំងប្រពន្ធ មុន ទាំងប្រពន្ធក្រោយ ។ កូនតាក្រោយៗ៦នាក់ នៅតូចៗមិនទាន់ ពេញវ័យហើយក៏នៅរៀនគ្រប់គ្នា ។ តាគិតថា តាបានធ្វើខុស ចំពោះកូនមាលី ហើយក៏ធ្វើខុសរឿងចំពោះចៅមណីម្នាក់ទៀត ។ ពេលនេះ តាសង្ឃឹមលើឯងហើយ ថាឯងនឹងមិនធ្វើអោយមណី ទទួលទឹកភ្នែកដូចម្ដាយរបស់នាងទេ ។

សុធីស្ដាប់ហើយ ក៏សំពះទទួលសំដីរបស់តាម៉ានិនភ្លាម ៖

- ពិតមែនតែចៅក្រីក្រ ហើយពេលនេះក៏ជាសិស្សនៅរៀនមិន ទាន់ចប់ មិនមានសញ្ញាបត្រ័ មិនមានការធ្វើត្រឹមត្រូវ ប៉ុន្តែ ចៅនឹងរៀបចំផ្លូវជីវិតអោយបានប្រពៃបំផុត មិនអោយមណីទទួល ការលំបាកអ្វីនៅក្នុងជីវិតតទៅទៀតឡើយ ។ សូមលោកតាទុកចិត្ត ចៅចុះ ។

CHANBOKEO.COM

តាម៉ានិនយកដៃអង្អែលក្បាលចៅប្រុសចៅស្រី ហើយក៏យក អំបោះសចងដៃអ្នកទាំងពីរ ហើយក៏ទទួលចៅសុធីជាចៅប្រសារ យ៉ាងពេញមុខមាត់នៅថ្ងៃនោះតែម្តង ។ ពេលនោះ ថ្វីបើតាម៉ានិន មិនបានទទួលខាន់ស្លាអ្វីជាដុំកំភួនពីកម្លោះសុធី ក្រៅពីម្រាមដៃដប់ របស់នាយ ប៉ុន្តែតម្លៃតម្រេះវិជ្ជារបស់សុធីនៅអនុវិទ្យាល័យបាន ធ្វើឲ្យតាម៉ានិនមានមោទនភាពណាស់ ព្រោះកូនប្រុសៗរបស់គាត់ គ្រប់គ្នាមិនទាន់មាននរណាមួយ រៀនបានដល់កម្រិតនោះឡើយ ។ ពេលនោះ តាម៉ានិនសង្ឃឹមថា ចៅមណីនឹងមានសេចក្តីសុខគ្រប់ យ៉ាងនៅពេលសុធីចេញធ្វើការ មានប្រាក់បៀវត្សត្រឹមត្រូវ ហើយក៏ សង្ឃឹមថា កូនចៅរបស់គាត់ខ្លះនឹងស្រង់គម្រូតាមសុធីខ្លះៗអំពី វិន័យនៃការរៀនសូត្រមិនខាន ។ ពេលនោះ តាម៉ានិនបានលះបង់ ទន្ទិរើសកូនប្រសារចៅប្រសារ ដោយសារគេជាកូនចៅចិន ចៅ ខ្មែរ អ្វីទៀតហើយ ។ អ្វីដែលគាត់សម្លឹងជាខាន់ស្លានៅពេលនេះ គឺវិជ្ជា សម្បត្តិ និងលក្ខណៈសម្បត្តិរបស់បុគ្គលផ្ទាល់ខ្លួននោះជាជាង ព្រោះ កូនប្រសារដំបូងរបស់គាត់ បានផ្តល់មេរៀនយ៉ាងច្រើនដល់ តាម៉ានិន រហូតនិយាយលែងចេញតែម្តង ។

ចំណែកសុធីវិញ ថ្វីបើគេមិនបានរៀបពិធីមង្គលធំដុំដូចកម្លោះ ក្រមុំទូទៅ ប៉ុន្តែគេបែរជាមានចិត្តរំភើបសោមនស្សណាស់ដែលគេ បានទទួលពិធីរៀបចំផ្សំផ្គុំតាមប្រពៃណីពីចាស់ទុំ រហូតដល់ទៅបី ដងក្នុងរយៈពេលពីរថ្ងៃ ។ ចំណែកមណីនារីយើងវិញ ក៏ចេះញញឹម បន្តិចៗហើយទោះបីជាមិនសូវមានមាត់មានកក៏អ្វីក៏ដោយ ។ ជា ពិសេស ពីរថ្ងៃកន្លងមកនេះ មណីបានញញឹមយ៉ាងស្រស់ដាក់សុធី ជាច្រើនដង ធ្វើឲ្យនរៈលួចរំភើបញាប់ញ័រក្នុងចិត្តតែម្នាក់ឯង រក ពាក្យអ្វីមកថ្លែងអោយសមស្មើមិនបានឡើយ ។

តាម៉ានិនបានរៀបចំកន្លែងទទួលចៅប្រុសចៅស្រី អោយស្នាក់ នៅលេងជាមួយគាត់និងក្រុមគ្រួសារបួនប្រាំថ្ងៃ ដើម្បីនាំសុធីដើរ ជំរាបសួរចាស់ទុំជាសាច់ញាតិអោយស្គាល់គ្នាជាបងប្អូន ។ ប្រាំថ្ងៃ ដែលសុធីស្នាក់នៅព្រះនេត្រព្រះ មាណពមានអារម្មណ៍ថានាយមាន សេចក្តីសុខកក់ក្តៅអ្វីម្ល៉េះ ។ ថ្វីបើបងប្អូននៅទីនោះក្រីក្រ ប៉ុន្តែ គេ មានទឹកចិត្តចំពោះគ្នាណាស់ មិនដូចបងយីញឬប៉ុហ្អូតឪពុករបស់ មណីទេ ដែលស្គាល់តែភាពហឹង្សានិងភាពអាត្មានិយម មិនស្គាល់ សាច់ញាតិបងប្អូនណាម្នាក់ឡើយ ។ វេលាប្រាំថ្ងៃនោះ សុធីក៏បាន ស្គាល់មណីយ៉ាងច្រើន ព្រោះនៅទីនោះ នាងចេះញញឹម ចេះសើច

CHANBOKEO.COM

ចេះនិយាយស្ដី មិនទឹកភ្នែក មិនចងចិញ្ចើម មិនមូរមុខ ដូចដែលនាយធ្លាប់ឃើញនៅឯមង្គលបុរីនោះឡើយ ។

មិនតែប៉ុណ្ណោះ មណីបានបង្ហាញនូវភាពរីករាយរបស់នាង ចំពោះសុធីយ៉ាងពិសេសជាច្រើនដង ធ្វើអោយសុធីរីកថ្លើមប្រមាត់ ធំជាងចង្អេរទៅទៀត ។

នៅក្នុងបន្ទប់មួយ មុងមួយតែពីរនាក់...

សុធីប្រែខ្លួនសម្លឹងមុខមណី ដែលបិទភ្នែកសម្ងំស្ងៀមបែរខ្នងក្បែររូបនាយ ។ នរៈខ្សឹបហៅតិចៗថា ៖

- នី!...

ភ្លាមនោះ មណីឆ្លើយវិញទាំងបិទភ្នែកថា ៖

- ចា៎ស!
- អោយបងសុំអ្វីពីអូនបន្តិចបានទេ?
- ចា៎ស! សួរមកចុះ?
- គឺ... បងចង់សុំអោយនីឈប់គេងបែរខ្នងដាក់បងតទៅទៀត... បានទេ នី?

ស្រាប់តែគេឃើញមណីញោចខ្លួន... មិនឃើញតបអ្វីមួយម៉ាត់ សោះ មិនដឹងថានាងមានអារម្មណ៍យ៉ាងណាទេ ។ សុធីខ្លាចចិត្ត ធិតាណាស់ ក៏ស្រដីទៀតថា ៖

- កុំខ្លាចបងអីនី! បងមិនប៉ះពាល់អូនទេ! បងគ្រាន់តែចង់បាននូវភាពស្និទ្ធស្នាលរវាងយើងទាំងពីរប៉ុណ្ណោះ គឺថា... បងមិនចង់ អោយអូនខ្លាចបងដូច្នេះទេណា៎! បងដឹងថា យើងមកជួបគ្នារហ័ស ពេក បានជាអូនត្រៀមចិត្ត ត្រៀមខ្លួនមិនទាន់... ចំណែកបងក៏ដូច គ្នាដែរ... គឺ...

រំពេចនោះ មណីក៏ប្រែខ្លួនងាកមកមុខមករកសុធី ៖

- ខ្ញុំមិនបានខ្លាចអ្នកឯណា?

ស្រាប់តែសុធីញញឹមឡើងតែម្ដង ៖

- បើមិនខ្លាចបង ម៉េចគេងបែរខ្នងអោយបងធ្វើអ្វី?
- មកពីខ្ញុំមិនចូលចិត្តអ្នកគេងស្រមុខនោះអី ។

ឮដូច្នោះ សុធីសើចខឹកៗ ៖

- ពុទ្ធោអើយ! អញ្ចឹង អូនគេងបែរខ្នងក៏បែរទៅ តែពេលព្រលប់ពេលបងគេងមិនទាន់លក់ អោយបងសុំគេងមើលមុខអូនផងបាន

CHANBOKEO.COM

ទេ ? កុំអោយខ្លួនបងអញ្ជឹងទៀតណា៎ បងអផ្សុកណាស់ ! ណា៎... បានទេ នី ?

ពេលនោះ សុធីឃើញមណីប្រែខ្លួន ហើយបែរមុខមករកនាយ ដោយមាននាំស្នាមញញឹមមួយយ៉ាងស្រស់ចំព្រង មកប្រគល់ឲ្យ មាណពផង ។ ភ្លាមនោះ បេះដូងរបស់នរៈក៏កម្រើករំជើបរំជួល ញាប់ញ័រឡើង ដោយក្ដីរំភើបនឹងស្នេហាយ៉ាងធំធេង ៖

- អោយបងសុំកាន់ដៃអូនគេងផងណា៎ នី !

ថាហើយ សុធីក៏លូកស្រវាចាប់ដៃនារីថ្នមៗ ។ មណីក៏បណ្ដោយ អោយនរៈចាប់ដៃនាង មកអោបផ្ទាប់នឹងទ្រូងរបស់នាយតាមសំរួល មិនមានឮនាងស្រដីថាម៉េចទេ ។ ភ្លាមនោះ សុធីមានអារម្មណ៍ថា បេះដូងរបស់មាណព បានទទួលនូវភាពកក់ក្ដៅមួយយ៉ាងចម្លែក ។ អ្នកទាំងពីរគេងញញឹមដាក់គ្នាទៅវិញទៅមកយ៉ាងយូរ ទើបមណី ហើបមាត់ស្រដីថា ៖

- អោយខ្ញុំសុំអ្វីមួយបានទេ អ្នក ?

សុធីឮហើយ ងក់ក្បាលភ្លាម ៖

- កុំថាសុំត្រឹមមួយ... សុំអ្វីក៏អោយដែរ អោយតែសុធីរកអោយបាន សុធីអោយទាំងអស់ ។ អូនប្រាប់បងមកចុះ !

- គឺ... នីចង់សុំពេលរក្សាខ្លួនសិនណា៎ ព្រោះពេលនេះ អ្នកក៏នៅរៀន...នីវិញក៏មិនទាន់មានការធ្វើ យើងមិនដឹងជារស់នៅយ៉ាងណា ទេ ។ បើអ្នកពិតជាអាណិតស្រឡាញ់នីមែន យើងគួររក្សាខ្លួន យើងឲ្យល្អ កុំអោយជ្រុលជ្រួស ក្រែងលោយើងមានកូនចៅ មុន ពេលដែលយើងអាចមានលទ្ធភាពចិញ្ចឹមគេបាន តើអ្នកយល់យ៉ាង ណាដែរ ?

សុធីភ្ញាក់ព្រើត ដែលមណីហ៊ានពិគ្រោះរឿងជីវិតយ៉ាងចំហ ចំពោះនាយដូច្នេះ ។ ភ្លាម នោះ គេក៏ញញឹមឡើង ៖

- នីកុំភ័យអី ! បងបានគិតដូច្នោះរួចហើយ គ្រាន់តែបងមិនទាន់ ហ៊ានពិគ្រោះជាមួយអូន ព្រោះខ្លាចអូនខ្មាស់... ការពិត បងក៏គិត រឿងនេះ មិនខុសពីអូនទេ គឺបងចង់ទុកឱកាសអោយអូនទំនេរ ខ្លួន រហូតដល់បងរៀនចប់ មានការធ្វើសិន ។

- រឿងអនាគតដូច្នោះ នីមិនខ្មាស់ទេ ព្រោះនីមិនចង់ដើរធ្លាក់ផ្លូវ ជីវិតវេទនាលំបាក ដោយការគិតខុស ប្រព្រឹត្តខុសនោះឡើយ ។ នីចង់មានគ្រួសារដែលមានសុភមង្គលពេញលក្ខណៈ

CHANBOKEO.COM

កុំឲ្យដូចឪពុក ម្ដាយរបស់ខ្ញុំ ហើយនីជឿថា អ្នកនឹងអាចដឹកដៃនីដើរទៅរកត្រើយសុខនោះបានយ៉ាងល្អប្រាកដណាស់ ។

សុធីសប្បាយចិត្តណាស់ ដែលមណីមានគំនិតគិតវែងឆ្ងាយ ។ នេះបើនាងមានក្រុមគ្រួសារសុខដុមរមនាវិញ ប្រហែលជានាងមានឱកាសរៀនបានខ្ពស់ឆ្ងាយណាស់ ។ សុធីញញឹមឡើងយ៉ាងត្រកាល ហើយក៏សួរបន្តថា ៖

- ហើយអូនរៀនដល់ណាដែរ នី ?

- គឺ.. ប្រឡងចូលអនុវិទ្យាល័យធ្លាក់ ប៉ាខ្ញុំក៏អោយឈប់រៀនទៅណាមួយត្រូវម៉ែចុងខ្ញុំចាក់អុជអាលផង ទើបគាត់...

ឃើញមណីធ្វើទឹកមុខមិនស្រួល សុធីក៏ដូរប្រយោគវិញ ៖

- ហើយអូនមានចិត្តចង់ធ្វើអ្វីដែរពេលនេះ ?

- ខ្ញុំមិនទាន់ដឹងទេ... គិតថា ចង់រៀនធ្វើពេទ្យ គ្រាន់នឹងព្យាបាលអ្នកភូមិជិតៗផ្ទះយកកម្រៃចិញ្ចឹមជីវិតបណ្ដោះអាសន្នសិនចុះ ។

- គំនិតល្អណាស់! បងថា អូនមានការធ្វើជាពេទ្យ ក៏ល្អដែរ បានជួយជីវិតមនុស្សផង បានស្រង់កម្រៃចិញ្ចឹមជីវិតខ្លួនឯងផង ។ ចាំ ដល់បងចេញធ្វើការ ចាំយើងគិតសាជាថ្មីទៀត មែនទេ នី ?

- ចាស!

អ្នកទាំងពីរក៏ញញឹមដាក់គ្នាឡើងយ៉ាងបំព្រង ដែលគេពីរនាក់អាចនិយាយពិគ្រោះគ្នាស្ដាប់គ្នាបាន ។ សុធីក្រសោបដៃធិតាអោបក្នុងលង្វែកទ្រូងរបស់ខ្លួនរួចបិទភ្នែកនិទ្រាទាំងដួងចិត្តក្សេមក្សាន្ត ។ ចំណែកនារីយើងវិញក៏មិនខុសគ្នាដែរ ។ ពេលនេះ នាងមាន អារម្មណ៍ថា ជីវិតរបស់នាងកំពុងឈានទៅរកសេចក្ដីសុខដ៏ភ្លឺថ្លា មួយ យ៉ាងត្រចះត្រចង់បំផុត ។

មិនយូរប៉ុន្មាន សុធីក៏ត្រូវឃ្លាតមណីមួយគ្រាដើម្បីវិលត្រឡប់ទៅបន្តការសិក្សានៅបាត់ដំបងវិញ ប៉ុន្តែ គេក៏មានការកក់ក្ដៅក្នុង ចិត្តណាស់ ព្រោះបានដឹងថា មណីនៅរង់ចាំការវិលត្រឡប់របស់គេ ជានិច្ច ។ ជាពិសេសចំណងដៃអាពាហ៍ពិពាហ៍ឥតព្រៀងទុករបស់គេទាំងពីរបានក្លាយទៅជាចំណងចិត្តដ៏មាំចងរូបគេទាំងពីរ ឲ្យមានជំនឿចំពោះគ្នាទៅវិញទៅមកយ៉ាងជ្រាលជ្រៅជាទីបំផុត ។ ថ្វីបើ

CHANBOKEO.COM

នារីមិនដែលវាចាអ្វីបង្ហាញនូវអារម្មណ៍របស់នាងចំពោះសុធីក៏ដោយ ក៏កិរិយារបស់នាងបានស្រដីប្រាប់មាណពរួចហើយថានាងនៅរង់ចាំ សុធីវិលត្រឡប់មកផ្ទះគ្រប់ពេលវេលាទាំងអស់ ។

*000000000000000000*

*00000*

*0*

CHANBOKEO.COM

# វគ្គទី៩
# ទំនាយឪពុក

- សំណេរហ្នឹងល្អមើលទេ និសា ?

និមលសួរប្អូនស្រីដែលកំពុងយកដៃផ្ទិតទឹកភ្នែកចេញពីថ្ពាល់...

- ពុទ្ធោអើយ បងនិមលប៉ិនសរសេរម៉្លេះ ? ដូចរឿងពិតអញ្ចឹង!
មើលហ្នែ៎ រឿងនេះវែងមែន តែល្អមើលណាស់!
- នេះជារឿងពិតណា៎... គឺរឿងពិតរបស់ម៉ាក់ប៉ាយើងនោះអី ។
- យី! ហេតុអ្វីក៏បងដឹងច្បាស់ម៉្លេះ ?
- គឺប៉ានិយាយប្រាប់បងណា៎! គាត់ប្រាប់បងរាល់ពេលដែលបង
ដើបទៅជួយបោកខោអាវជាមួយគាត់ ។
- អូហ៍! មានរឿងពិរោះស្តាប់យ៉ាងហ្នឹង ម៉េចក៏បងមិនដាស់និសា អោយទៅអង្គុយស្តាប់ផង ?
- មានអី! បើប្អូនចង់ស្តាប់ ចាំបងដាស់ ។ ប្អូនត្រៀមខ្លួនទៅ នៅ រាល់ព្រហាមថ្ងៃអាទិត្យ ។
- ចា៎ស!

ពេលនោះ និមលដឹងថា ប្អូនស្រីរបស់នាង មានវ័យគ្រប់គ្រាន់
ល្មមអាចយល់ដឹងអំពីឫសគល់កំណើតរបស់ខ្លួនហើយ ។

រាល់ថ្ងៃ និមលតែងតែមានកាលវិភាគរបស់នាងជានិច្ច ។ នាង តែងតែរកឱកាសទៅជួបឪពុក ដើម្បីទទួលនូវការណែនាំប្លែកៗ ហើយដែលនាងអាចយកមកប្រើជាប្រយោជន៍ ពេលនៅសាលា ឬសូម្បីពេលនៅផ្ទះ ជួបជុំគ្រួសារ ។

ការពិត សុធីចូលចិត្តណែនាំអ្វីប្លែកៗដល់កូន ដូចជាការរៀន
និពន្ធកាព្យឃ្លោងចំរៀងដូចជាបទពាក្យ ៧ ពាក្យ៨ ពាក្យ៩ ពាក្យ ១០និងពាក្យ១២ ។
សុធីតែងប្រាប់កូនថាតូរ្យតន្ត្រីអាចនាំអោយ អារម្មណ៍មនុស្សទទួលនូវភាពក្សេមក្សាន្ត
ទាំងអ្នកនិពន្ធកំរងពាក្យ ពេចន៍ជាបទចំរៀង ទាំងអ្នកប្រគំភ្លេង ទាំងអ្នកស្តាប់ ។ រីឯភាព
ហ្មួហ្មងក្នុងចិត្តរបស់គេ ក៏រសាយអស់ទៅជាមួយទំនុកនិងចង្វាក់ ភ្លេងដ៏ស្រទន់ទាំងឡាយនោះ ។
សុធីបានណែនាំពន្យល់នូវបែបបទ និពន្ធកំណាព្យជាច្រើនបែប

ដែលអាចទាក់ទាញមនោសញ្ចេតនា មនុស្ស
ឲ្យអណ្តែតអណ្តូងទៅតាមរលកអត្ថន័យរបស់ទំនុកភ្លេង និងទៅតាមសៀងសូរសព្ទ
នៃការប្រគំបទភ្លេង របស់បទចំរៀង និមួយៗ ។ រីឯនិមលវិញចូលចិត្ត
ស្តាប់ឪពុកនាងនិយាយអំពីតន្ត្រី ចំរៀងនិងកំណាព្យជាងនិសា ម្ល៉ោះហើយ ព្រឹកថ្ងៃអាទិត្យជាពេល
ដែលនិមលសប្បាយចិត្តជាងគេបង្អស់ ព្រោះយុវតីបានជជែក ជាមួយឪពុកអស់ចិត្តអស់ចង់
អំពីតូរ្យតន្ត្រីខ្មែរ ពីការនិពន្ធកាព្យ
និងការនិពន្ធសាច់រឿងផ្សេងៗឲ្យបានប្លែកៗអត្ថរសនិងអត្ថន័យ ។

ការពិត សុធីចេះលេងឧបករណ៍ភ្លេងខ្លះៗដែរ ។ មាណពពូកែ
វាយស្គរម៉ុងសាយជាងគេបំផុត ។ សូម្បីតែពេលនេះ គេចូលវ័យ ចំណាស់បន្តិចហើយ
ហើយក៏មានកូនចៅច្រើននាក់ក៏ដោយ ក៏នៅ តែប្រឹងឆ្លៀតឱកាស
ទៅវាយស្គរម៉ុងសាយពេលចូលឆ្នាំចិនមិន ដែលខានទេ
ព្រោះនោះជាការកំសាន្តអារម្មណ៍ម្យ៉ាងរបស់នាយ ។ បន្ទាប់ពីនោះគឺការវាយស្គរ ឡាំថូន ស្គរដៃ
ស្គរឆាយាំ ទាត់ ម៉ង់ដូលីន ទាត់ហ្គីតា និងលេងអាគ័រដេអុង  ។ល ។ រាល់ល្ងាចថ្ងៃ អាទិត្យ
សុធីតែងតែទាញស្គរ ឬទាញម៉ង់ដូលីនមកទាត់លេង ថែម ទាំងនាំកូនច្រៀងកំសាន្តជាមួយផង ។
ជួនកាលសុធីតែងកំណាព្យ ពាក្យគ្រលាស់ រួចហើយក៏យកច្រៀងជាមួយនឹងការទាត់ឧបករណ៍
ភ្លេងរបស់ខ្លួនដូចជាហ្គីតាឬម៉ង់ដូលីនជាដើម ។ ចំណែកកូនៗក៏នៅ
អង្គុយស្តាប់សើចក្អាកក្អាយខ្ជាយ ទឹកមាត់ ចុកពោះ គាំងដង្ហើម គ្រប់ៗគ្នាតែអញ្ចឹងទៅ ។

លុះនិមលចេះអានចេះសរសេរខ្មែរស្ទាត់ជំនាញ នាងក៏រៀនពី សុធីនូវរបៀបនិពន្ធកាព្យឃ្លោង
ហើយក៏ចេះសរសេរកំណាព្យពាក្យ គ្រលាស់ប្រណាំងនឹងឪពុកនាងទៀតផង ។ ជួនកាល
នាងសរសេរ ចែកមិត្តភក្តិ ឬ ចែកលោកគ្រូអ្នកគ្រូនៅឯសាលាអានលេង ។
ដោយមានគំនិតប្រាជ្ញានិងការណែនាំរបស់ឪពុកជាគោល និមលក៏
សុំទៅរៀនបន្ថែមពីព្រះសង្ឃផ្សេងៗដទៃទៀតជាច្រើនអង្គ រហូត
ដល់ចេះនិពន្ធកំណាព្យបានច្រើនហើយប្លែកៗរហូតមក ។

សុធីមានទម្លាប់អោយនិមលសរសេរកាព្យ ជាបទពាក្យ៧ ឬ ពាក្យ៨
រួចហើយក៏យកមកច្រៀងបញ្ចូលជាមួយភ្លេង ដែលសុធី ទាត់អោយស្តាប់ ។
ពិតមែនតែសុធីមានសម្លេងស្អកស្អាបន្តិច តែ
អាចច្រៀងបានពិរោះសមសាច់ភ្លេងល្មមនាំការសប្បាយដល់គ្រប់ៗ គ្នា ដែលអង្គុយស្តាប់ជុំវិញ ។

CHANBOKEO.COM

នៅជំនាន់ក្រោយៗមក ពេលនិមល ស្តាប់សម្លេងអ្នកចំរៀងហួឡាវី
មាណវីតែងតែនឹកស្រម័យទៅដល់ ឪពុកនាងជានិច្ច
ព្រោះលោកហួឡាវីមានសំនៀងស្អកស្អាប្រហាក់ ប្រហែលគ្នានឹងសុធីដែរ ជាពិសេស
ចំពោះបទចំរៀងណាដែលរិត ខ្សែសម្លេងច្រៀងតឹងៗ ។

ជំនាន់ឆ្នាំ១៩៧០-៧៥ ពេលកាសែ្សតរ៉ោយហួរ ហាស់សាឡន ឯលបុណ្ណ ពស់មាស
បាត់ដំបង គង្គប៊ុនឈឿន ស៊ិនស៊ីសាមុត និងក្រុមកាសែ្សតប៉ៃលិន
បានចេញលក់ចំរៀងបន្តកន្ទុយប្រជែងគ្នា ពេញផ្សារ
សុធីប្រមូលទិញគ្រប់កាសែ្សតទាំងអស់មិនមានចន្លោះ មួយទេ
ហើយក៏បង្គាប់អោយនិមលអង្គុយកត់ទំនុកចំរៀង ចេញពី កាសែ្សតចម្រៀងចម្រុះទាំងនោះ
ទាំងក្រាំង ទាំងសៀវភៅ ដើម្បី យកមករៀនច្រៀងលេងទាំងអស់គ្នាក្នុងគ្រួសារ ។
កាលជំនាន់នោះ កាសែ្សតមួយៗអាចមួលបិទសម្លេងអ្នកច្រៀង បញ្ចេញតែសម្លេង
ភ្លេងសុទ្ធបាន ។ ពេលសុធីចាក់ភ្លេងម្តងៗ មាណពតែងតែទាញ ឧបករណ៍ម៉ង់ដូលីន
អាគ័រដេអុងឬទាញស្គរមកវាយតាមសាច់ភ្លេង
ទុកឲ្យកូនៗជាអ្នករួមចំណែកជាមួយក្នុងការច្រៀងជាពួក ថែមទាំង
អោយកូនជួយទះដៃបន្ទរជាចង្វាក់ផង ។ រីឯផ្ទះរបស់និមលវិញ មានរានហាលបែរមុខទៅផ្លូវ
អាចអោយអ្នកស្រុក ឈរមើលឃើញ ពីថ្នល់ភូមិមកយ៉ាងងាយ ។
នៅថ្ងៃណាគ្រួសារនិមលជួបជុំគ្នាច្រៀង កំសាន្ត ឯខាងលើរានហាលមុខផ្ទះរបស់នាង
នៅថ្ងៃនោះគឺតែងតែ មានបងប្អូនអ្នកភូមិជិតខាង ឬសូម្បីអ្នកដំណើរតាមផ្លូវ មកឈប់ មុខផ្ទះ
ឈរមើលរហង់ ។ ខ្លះទៀតក៏ឡើងឡូករាំនៅធ្លាមុខផ្ទះ តាម
ចំរៀងដែលបងប្អូននិមលច្រៀងឡើងហុយដីទ្រលោម ជាពិសេស ចម្រៀងជាចង្វាក់រាំវង់ ឡាំលាវ
និងរាំក្បាច់ ជួនកាលក៏លាយបទ បរទេសចង្វាក់ញាក់ៗមួយៗដែរ ។ មានកាលខ្លះ សុធីហៅបបួល
គ្នាដងទឹកស្រះបាចលើដី រួចយកដើងដីរីដើរដំធ្លាលាន ពង្វាតទីរាំ
កំសាន្តជូនដល់អ្នកស្រុកទាំងឡាយនោះ ក៏មានដែរ ។

កាលជំនាន់នោះ អ្នកស្រុកទាំងឡាយសុភាពរាក់ទាក់ណាស់
មិនកោងកាចដូចក្មេងៗសព្វថ្ងៃទេ ។ គេជួបជុំគ្នារាំវង់ពិតមែន តែ មិនមានក្រុមបងធំបងតូចណា
មកអុកឡុករំខានការសប្បាយនោះ ឡើយ ហើយក៏គ្មានការផឹកស្រាស្រវឹងអួទីន្ទ
រំខានការជួបជុំកំសាន្ត នោះដែរ ជាពិសេស គឺការដាល់តប់ផ្ទើលហ្វូងរាំនោះ គឺមិនដែល

CHANBOKEO.COM

ឃើញមានម្តងណាឡើយ ។

នៅពេលចប់បុណ្យ សុធីតែងហៅកូនចៅមកប្រជុំទូន្មានប្រាប់ ពួកគេថា ៖

- កូនឃើញទេ ? គ្រួសារយើងមានសេចក្តីសុខណាស់ ហើយតន្ត្រី និងចំរៀងក៏បាននាំភាពរីករាយដល់គ្រួសាររបស់យើងថែមទៀត ។ មើលហ្ន៎! សេចក្តីសុខ សេចក្តីរីករាយ និងសុភមង្គលក្នុងគ្រួសារ របស់យើង វាមិនត្រឹមតែពង្វាតឥទ្ធិពលដណ្តប់ចិត្តយើងអោយយល់ នូវភាពក្សេមក្សាន្តតែប៉ុណ្ណោះទេ សូម្បីតែញាតិជិតខាងភូមិផង របងជាមួយ ឬសូម្បីតែអ្នកដំណើរតាមផ្លូវ ក៏គេបានទទួលនូវចំហាយឥទ្ធិពលនៃសេចក្តីសុខនេះផងដែរ ។ ចូរកូនរក្សាចំណងនៃសេចក្តីស្រឡាញ់និងសេចក្តីសុខថ្ងៃនេះ អោយជាប់នៅក្នុងចិត្តកូន ណា៎កូនណា៎ ហើយកុំភ្លេចពង្រាយអំពើល្អអោយបានច្រើន មិនថា កូនរស់នៅទីណាទេ ។ ធ្វើអំពើល្អច្រើន នោះកូននឹងបានទទួល សេចក្តីសុខជាការតបស្នងវិញ ដូចជីវិតរបស់កូនថ្ងៃនេះអញ្ចឹង ។

និមលស្តាប់ហើយពិចារណាជានិច្ច នូវពាក្យអ្វីៗដែលឪពុកនាង តែងអប់រំអោយកូនអោយចងចាំ ជាគោលគំនិតសំរាប់ស្វែងរក សេចក្តីសុខក្នុងជីវិតរបស់ខ្លួនតទៅថ្ងៃមុខ ។ ថ្វីបើនិមលមិនដឹងថា ពាក្យប្រដៅរបស់ឪពុក មានប្រសិទ្ធិភាព ឬមិនមានយ៉ាងណាក៏ ដោយ ក៏ស្រីតូចតែងតែលួចកត់ទុកនូវអ្វី ដែលនាងបានទទួលពី ឪពុករបស់នាង ។ សព្វថ្ងៃនេះ និមលបានដឹងថា អ្វីដែលឪពុកនាង ធ្លាប់មានប្រសាសន៍ប្រាប់ សុទ្ធសឹងមានប្រយោជន៍សំរាប់ជីវិតនាង ទាំងអស់ ស្ទើរតែថៀសមួយម៉ាត់មិនបាន ។

កាលនិមលអាយុប្រហែល១០ឆ្នាំ សុធីជាឪពុកបានរើសក្មេង ស្រីកំព្រាពីររូបតូចៗយកមកចិញ្ចឹម ។ ម្នាក់អាយុប្រហែល៥ឆ្នាំ ម្នាក់ទៀតប្រហែលពីរឆ្នាំ ម្តាយស្លាប់ ឪពុកឈឺដេកពេទ្យធំនៅក្រុង បាត់ដំបង ក្រោយមកក៏ស្លាប់ទៅដែរ ។ កាលនោះ សុធីមានកូន ខ្លួនឯងដល់ទៅបួននាក់រួចទៅហើយ ដោយមិនរាប់បញ្ចូលបងប្អូន របស់និមលពីរនាក់ដែលស្លាប់ដោយរោគកុមារ និងចំនួនក្មេងៗ ដែលជាកូនចៅអ្នកភូមិអ្នកស្រុកជាសាច់ញាតិខ្លះ មិនសាច់ញាតិខ្លះ ដែលគេបានយកមកផ្ញើ អោយលោកជួយចិញ្ចឹមដើម្បីរៀនសូត្រ ផងនោះឡើយ ។ កាលនោះ សុធីប្រឹងត្រដាងស្លាបរបស់គេយ៉ាង ធំធេងណាស់ ដើម្បីផ្តល់ម្លប់ដល់ក្មេងក្រីក្រខ្វះខាត មិនថាក្មេងនោះ ជាសាច់ញាតិ ឬមិនសាច់ញាតិរបស់គេនោះឡើយ ។ ថ្វីបើខែខ្លះ ឆ្នាំខ្លះ

CHANBOKEO.COM

សុធីខើចលុយខើចកាក់សំរាប់ផ្គត់ផ្គង់គេទាំងនោះក៏ដោយ ក៏និមលមិនដែលឮពាក្យរអ៊ូតម្អូញមួយម៉ាត់ ចេញពីមាត់ឪពុកនាងដែរ ឃើញតែគាត់ប្រឹងធ្វើការឲ្យតត្រុកស្ទើរតែគ្មានពេលសំរាក ។

កូនចិញ្ចឹមទាំងពីរនាក់នោះបានទទួលវណ្ណៈនិងការអប់រំស្មើៗគ្នា ដូចនិមលនិងប្អូនៗជាកូនបង្កើត ហើយក៏មានសិទ្ធិហៅសុធីនិង មណីថា ប៉ាម៉ាក់ដូចគ្នាដែរ ។ គេបានទទួលការសិក្សារៀនសូត្រ ទទួលសេចក្ដីស្រឡាញ់ និងការរស់នៅដ៏មានសេចក្ដីសុខនៅក្នុងគ្រួសារដូចពួកនាងជាកូនបង្កើតមិនខុសគ្នាឡើយ ។ ឪពុកម្ដាយនាងបានចិញ្ចឹមក្មេងទាំងនោះដោយក្ដីមេត្តាសណ្ដោស ហើយបានណែនាំ ផ្លូវល្អដល់គេដោយគ្មានចិត្តក្នុងក្រៅជាមួយក្មេងទាំងនោះឡើយ ។

មានកាលខ្លះ សុធីនាំនិមលនិងបងប្អូនកូនក្មួយដើរមើលសាលា ជាន់ខ្ពស់ ថ្វីបើកូនចៅខ្លះៗនៅតូចៗមិនទាន់ប្រឡងឌីប្លូមនៅឡើយ ក៏ដោយ ។ គាត់បង្ហាញតាំងពីសាលាពេទ្យ សាលាតិចណូ សាលា ស្យង់ សាលាគរុកោសល្យ... ។ល ។ ឲ្យតែសុធីមានឱកាស គឺគាត់ នាំក្មេងដើរឆ្វេលក្នុងបរិវេណសាលានានា ជំរាបសួរលោកគ្រូ អ្នកគ្រូនោះតែអញ្ចឹងទៅ ។ ការពិត សុធីធ្វើបែបនេះ ដើម្បីពង្រឹងស្មារតី ក្មេងផង និងដើម្បីបណ្ដុះចំណង់ចំណូលចិត្តនិងក្ដីស្រម័យល្អៗ ឲ្យ កូនចាប់អារម្មណ៍អំពីកិត្តិនាមល្បីៗរបស់អ្នកប្រាជ្ញចេះដឹងទាំង ឡាយនោះផង ។

សុធីធ្លាប់នាំកូនៗចូលបណ្ណាល័យសាលាជាច្រើន នៅក្នុងទីក្រុងភ្នំពេញដែលលោកសុំគេនាំកូនចៅចូលមើលទិដ្ឋភាព និងការសិក្សា ក្នុងសាលានិមួយៗ ។ គេបង្ហាញអំពីសៀវភៅដែលអ្នកប្រាជ្ញល្បីៗ បានស្រាវជ្រាវទ្រឹស្ដីប្លែកៗ យកមកសរសេរចងក្រងទុកឲ្យសិស្ស ជំនាន់ក្រោយបានរៀនសូត្រ ទាំងគណិតសាស្ត្រ វិទ្យាសាស្ត្រ សេដ្ឋសាស្ត្រ វេជ្ជសាស្ត្រ ។ល ។ សុធីតែងរំលឹកប្រាប់កូនៗថា ៖

- កូនអើយ! បើកូនរៀនពូកែហើយអាចចេះចងក្រងសំណេរ តាំង តែពីតូច ទៅថ្ងៃមុខ កូនច្បាស់ជាអាចក្លាយជាគន្ថការីយ៉ាងពូកែ មួយរូបដែលនឹងយកស្នាដៃល្អៗរបស់កូនមកប្រជ្រៀតតម្រៀបជួរ នៅក្នុងបណ្ណាល័យ ដូចអ្នកប្រាជ្ញទាំងឡាយនេះមិនខានឡើយ ។

និមលឈរជិត បានឮហើយ គ្រាន់តែញញឹម មិនហ៊ានឆ្លើយ ទៅឪពុកថាម៉េចទេ ។ ពេលនោះ នាងគិតក្នុងចិត្តថា យុវតីមិនដឹង ជាចេះសរសេរអ្វីមកបោះពុម្ពអោយអ្នកដទៃអានទេ ។ ម្យ៉ាងទៀត នាងមិនដែលចង់ក្លាយជាអ្នកនិពន្ធផង ។ និមលចង់ធ្វើអ្វីផ្សេងៗ ទៀត

CHANBOKEO.COM

ដូចជាធ្វើជំនួញពាណិជ្ជកម្មធំៗ ដើម្បីរកលុយបានច្រើនៗ ជួយគ្រួសារ កុំឲ្យឪពុកនាងលំបាកនឿយហត់ធ្វើការតទៅទៀត ។ ស្រីតូចចង់អោយឪពុកបានចូលនិវត្តន៍ឆាប់ៗ ព្រោះនាងចង់បង្ហាញ ថ្វីដៃថា ថ្វីបើនាងជាស្រីពិតមែន តែយុវតីក៏មានសមត្ថភាពអាច ជ្រោមជ្រែងគ្រួសារបានយ៉ាងល្អ មិនចាញ់កូនប្រុសឡើយ ។

ទោះបីជាយ៉ាងណា ក៏យុវតីយើងបានរៀនចេះនិពន្ធកំណាព្យ មុនវិជ្ជាអ្វីផ្សេងៗទៀត ហើយបានចងក្រងសំណៅទុកជាក្រាំងជូន ឪពុកអាន ខុសផងត្រូវផង ជាច្រើនរយសំណៅ ។ ក្រោយមក នាងក៏រៀននិពន្ធរឿងខ្លីៗដែលមាន លាយការអប់រំបន្តិចបន្តួចនៅ ក្នុងនោះផង ។ នៅក្នុងវ័យប្រមាណ១៦ឆ្នាំ និមលអាចនិពន្ធរឿង ប្រលោមលោកបានរហូតដល់ទៅពីរ រយទំព័រចំនួនជាច្រើនរឿង ។ ថ្វីដៃនេះបានធ្វើឲ្យសុធីជាឪពុកមានមោទនភាពណាស់ ព្រោះថា ការនិពន្ធចងក្រងសំណេរជាសៀវភៅ គឺជាស្ពានមាសស្ពានប្រាក់ របស់អ្នកប្រាជ្ញ ក្នុងការដឹកនាំចម្លងមនុស្ស ឆ្ពោះទៅរកការចេះដឹង គ្រប់ប្រភេទទាំងអស់ តាំងពីនយោបាយ វិទ្យាសាស្ត្រ វេជ្ជសាស្ត្រ សេដ្ឋសាស្ត្រ សង្គមសាស្ត្រ ចិត្តសាស្ត្រ ។ល ។ ជំហានទីពីរ គឺសុធីនឹងបណ្តុះកូនៗទាំងអស់ ឲ្យក្លាយទៅជាអ្នកចេះដឹងខ្ពង់ខ្ពស់ តាមសមត្ថភាព ដែលកូននិមួយៗអាចធ្វើទៅបាន ។ ពេលនោះ ពួកគេនឹងអាចចងក្រងអត្ថបទស្រាវជ្រាវល្អៗផ្សេងៗ យកមកចែក ចាយដល់បច្ឆាជនរៀនបន្ត បណ្តុះការ ចេះដឹងអោយកាន់តែ ខ្ពង់ខ្ពស់ឡើងៗ ដូចជាគុម្ពឫស្សី ដែលចេះតែបែកសាយគុម្ព ធំទៅៗ ជាលំដាប់ ។

*oooooooooooooooooooo*

*ooooo*

*o*

# វគ្គទី១០
# ជំហានជីវិត

ឆ្នាំ១៩៥៣...

សុធីជិះកង់យ៉ាងលឿនដូចហោះពីបាត់ដំបងសំដៅមង្គលបុរី ។ គេកំពុងមានដំណឹងល្អសំរាប់ផ្ញើមណីកំពូលដួងចិត្តរបស់គេដែលរស់នៅឯមង្គលបុរី ។

- នី! នី!

គ្រាន់តែមកដល់មុខផ្ទះមិនទាន់ គេទម្លាក់កង់ចោល ហើយស្ទុះ ប្រវាអោបចង្កេះមណីពីក្រោយ ពេលគេប្រទះឃើញនាងកំពុងបាច ចំណីមាន់នៅចំហៀងផ្ទះ ។

- នឹកបងទេ នី ?

មណីនឹកអៀនខ្លួនណាស់ ដែលនរៈស្ទុះមកអោបចង្កេះនាងទាំង កណ្ដាលថ្ងៃ ក៏លូកដៃបេះចេញ ៖

- នែ៎! លេងអីអាក្រក់ម្ល៉េះ ? ខ្មាស់អ្នកភូមិស្លាប់ហើយ ?

- ខ្មាស់អី ? បើបងនឹកប្រពន្ធបងសឹងស្លាប់ទៅហើយនោះ ?

បន្តិចមក គេក៏ដឹកដៃនារីត្រឡប់សំដៅទៅកង់វិញ ហើយក៏ ស្រាយសំពៀតចេញមក យកក្រដាសមួយសន្លឹកមកបង្ហាញមណី ៖

- នេះ! អូនមើលទៅ ថាជាអ្វីដែរ ?

មណីទាញយកមកអាន ស្រាប់តែបើកភ្នែកធំៗ ឧទានថា ៖

- បងប្រឡងគ្រូជាប់ហើយមែនទេ ?

- បាទ! មែនហើយ!

- ព្រះអើយ! នីត្រេកអរខ្លាំងណាស់!

ភ្លាមនោះ មណីក៏ស្រវាអោបបុរសដោយក្ដីរំភើបរីករាយ ។ នរៈ ក៏បន្លំលួចថើបថ្ពាល់ប្រពន្ធខ្សឹត ធ្វើឲ្យនាងភ្ញាក់ព្រើតតែម្ដង ៖

- យី! លេងខូចម្ល៉េះ ?

- ពុទ្ធោ! មិនដឹងនរណាទេ លេងខូច លោតអោបកបងមុន ។

CHANBOKEO.COM

ព្វន្ធច្នោះ មណីអៀនរឹងខ្លួនតែម្តង មិនហ៊ានងើបមុខទេ បែរ
ជាកញ្ឆក់សំពៀតខោអាវសុធីដើររឹងចូលក្នុងផ្ទះយ៉ាងរហ័ស ។ សុធី ឃើញនាងអៀនក្រហមមុខ
ក៏ឈរសម្លឹងតាមមើលនាងទាំងភក្ត្រា ញញឹមពព្រាយ ។ ពេលនោះ គេមានអារម្មណ៍ថា
គេកំពុងទទួល សេចក្តីសុខមួយយ៉ាងធំធេងនៅក្នុងជំរៅដួងចិត្តរបស់គេ ។
យាយគិមហួយឃើញចៅមកដល់ ក៏ស្ទុះមកទទួលនាយទាំង ត្រេកអរកខិបកខុប ។
ទាំងបីបានជួបជុំគ្នា បរិភោគអាហារយ៉ាង ឆ្ងាញ់បំផុតជាលើកដំបូងក្នុងជីវិត ។
- អាង៉ាអើយ! តើរាជការគេអោយឯងទៅធ្វើការខាងណាដែរ ?
- បាទ យាយ! គឺខែក្រោយនោះ ខ្ញុំត្រូវទៅបង្រៀននៅសាលា បឋមសិក្សាត្រពាំងថ្ម
ភ្នំស្រុកហើយ ។
- ហើយឯងមានដែលទៅឃើញស្រុកទេសគេនោះហើយនៅ ?
- បាទនៅទេយាយ! តែខ្ញុំគិតថា ខ្ញុំទៅម្នាក់ឯងមើលកន្លែងសិន មិនចង់អោយមណីទៅតាមទេ
ព្រោះមិនដឹងថាការរស់នៅស្រុក ស្រែជនបទតូចៗអញ្ចឹងលំបាកយ៉ាងណា
ម្យ៉ាងខ្ញុំមិនចង់អោយនាង អផ្សុកផង ។ នៅទីនេះ គ្រាន់នឹងបានយាយជាគ្នា មិនស្ងាត់ពេក ។
- អើ! ទៅទីនោះ ក៏វាមិនស្ងាត់ដែរ ព្រោះបានឯងកំដរដែរតើហ៍
ប្តីប្រពន្ធអោយរស់នៅឆ្ងាយគ្នាយ៉ាងម៉េចនឹងបាន ?
សុធីព្វន្ធច្នោះ ក៏លួចដៀងភ្នែកមើលមណី ឃើញនាងនៅ ស្ងៀមមិនឃើញនិយាយអ្វីទេ
មួយថ្ងៃហើយ ។ គេក៏សួរនាងថា ៖
- នី! មានរឿងអ្វីក្នុងចិត្តហ្នែស បានជាជ្រួញចិញ្ចើម ?
- គឺ... ខ្ញុំបារម្ភពីយាយ ពេលខ្ញុំចេញទៅនៅត្រពាំងថ្មជាមួយបង...
ភ្លាមនោះ ស្រាប់តែយាយគិមហួយមានប្រសាសន៍ថា ៖
- កុំបាច់បារម្ភពីយាយអីចៅ ។ បើឯងមិននៅ ចាំយាយហៅកូន
ចៅសាច់ញាតិយើងម្តុំៗនេះអោយវាមកដេកកំដរចុះ ។
មែនហើយ! យាយគិមហួយអាយុចិត្តប្លាយពិតមែន តែនៅ
រហ័សរហួនហើយមានប្រាជ្ញាវាងវៃណាស់ ដូចជាមិនទាន់ទ្រុឌ
ទ្រោមដូចចាស់ៗស្រករគាត់ទេ ។
នៅខែបន្ទាប់មក សុធីក៏ធ្វើដំណើរទៅភ្នំស្រុកតែម្នាក់ឯង ទុក មណីអោយនៅមង្គលបុរីសិន ។
ការពិត ភូមិត្រពាំងថ្ម គ្រាន់តែជា កូនភូមិតូចមួយ មានប្រជាពលរដ្ឋមិនបាន៥០គ្រួផង ។

CHANBOKEO.COM

នៅមិន ឆ្ងាយពីត្រពាំងថ្មប៉ុន្មាន មានភូមិក្លួយពីរបីទៀតដែរ ដែលជួនកាល មានអ្នកស្រុកក្លួយ រែកអំពៅ សត្វព្រៃនិងផ្លែឈើព្រៃចូលមកដល់ ភូមិត្រពាំងថ្ម ដើម្បីដូរយកអំបិល ដូរប្រេងនិង ដូរសៀងប៉ោត ត្រឡប់ទៅវិញ ។ អ្នកស្រុកទីនោះរស់នៅស្មោះត្រង់សុចរិតណាស់ មិនមានចោរឃ្មួញ មិនមានជនទុច្ចរិតទេ ។ លុះសុធីបានស្នាក់នៅ ក្នុងវត្តប៉ុន្មានអាទិត្យ អ្នកស្រុកក៏មូលមតិគ្នាប្រវាសដៃសង់ផ្ទះស្បូវ មួយអោយសុធីស្នាក់នៅក្បែរជើងវត្តតែម្តង ។ ម្យ៉ាងដោយសារ អ្នកស្រុកដឹងថា សុធីមានប្រពន្ធនៅមង្គលបុរី មិនសូវបានជួបមុខ គ្នា ទើបគេសំរេចចិត្តជួយជ្រោមជ្រែងអោយសុធីមានកន្លែងរស់នៅ ត្រឹមត្រូវ នឹងអាលទៅទទួលប្រពន្ធយកមករស់នៅជុំគ្នាវិញ ។ អ្នក ស្រុកទីនោះ មានសន្តានចិត្តល្អណាស់ ពិតមែនតែពួកគេក្រីក្រ តែ គេមិនដែលមើលបំណាំគ្នាទេ ។ គេតែងតែស្រោក់ដៃជួយគ្នាជានិច្ច ពេលណាមានអាសន្នអន់ក្រ ។

មិនយូរប៉ុន្មាន សុធីក៏ត្រឡប់មកទទួលប្រពន្ធពីមង្គលបុរី យក ទៅនៅត្រពាំងថ្មជាមួយគ្នា ។ កាលជំនាន់នោះ ការធ្វើដំណើរទៅ ភូមិត្រពាំងថ្ម មានការលំបាកណាស់ ។ គេអាចធ្វើដំណើរចូលបាន ដោយរទេះគោនិងកង់តែប៉ុណ្ណោះ ។ នៅខែប្រាំង ឡានហ្ស៊ីបអាច បរចូលបានម្តងមួយយាម ។ មណីក៏ត្រូវបែកពីយាយគិមហួយទាំង ចិត្តសោកសៅ ។ ប៉ុន្តែគួរឲ្យសរសើរយាយគិមហួយណាស់ ។ គាត់ មានចិត្តនិងស្មារតីរឹងប៉ឹងក្រៃលែង ។ មុននឹងចេញដំណើរ យាយ បានហៅចៅស្រីចៅប្រុសទៅប្រដៅសព្វគ្រប់អំពីការរស់នៅជាក្រុម គ្រួសារ ក្នុងខណៈដែលខ្លួនគ្មានចាស់ទុំនៅក្បែរនឹងពិគ្រោះគ្នា ។

មណីក៏បានមករស់នៅជាមួយសុធី ជាប្តីប្រពន្ធពេញមុខ ដូចគេ ដូចឯង ។ ថ្វីបើជីវភាពរបស់អ្នកទាំងពីរអត្តខាត់បន្តិច ប៉ុន្តែគេមាន សុភមង្គលក្រៃលែង ។ សុធីបានថែទាំរក្សាភរិយាបានយ៉ាងល្អបំផុត ដែលមណីមិនដែលគិតថា សុធីអាចធ្វើបានល្អដូច្នោះឡើយ ។ នាយ ថ្នាក់ថ្នមប្រពន្ធដូចកែវភ្នែក រហូតដល់អ្នកស្រុកអ្នកភូមិទាំងឡាយ នឹកច្រណែននឹងសេចក្តីសុខសុភមង្គល ដែលមណីបានទទួលពីនរៈ ណាស់ ។ គេក៏នាំគ្នាប្រតិស្ឋឈ្មោះអោយអ្នកទាំងពីរថា ជាគ្រួសារ គំរូប្រចាំភូមិត្រពាំងថ្មនោះ ។

ភូមិត្រពាំងថ្មស្ថិតនៅឆ្ងាយពីថ្នល់ជាតិ ឆ្ងាយផ្សារនិងទីប្រជុំជន ម្ល៉ោះហើយ អ្នកទាំងពីរខ្សត់មិនសូវបានបរិភោគសាច់ស្រស់ដូចជា សាច់ជ្រូក សាច់គោ សាច់មាន់ឬត្រីញឹកញាប់ទេ ។ គេច្រើនតែ ទទួលទានអាហារក្រៀមក្រោះដូចជាត្រីងៀត ត្រីឆ្អើរ

CHANBOKEO.COM

ប្រហុក ម៉ាំ ផ្អក ជា ដើម ។ល ។ នៅខែវស្សា គេអាចមានបន្លែស្រស់ៗធ្វើ
អាហារហើយក៏អាចទិញបានត្រីស្រែមកធ្វើអាហាររាល់ថ្ងៃបាន ។ តែ នៅរដូវប្រាំង
គេត្រូវទៅរែកទឹកឆ្ងាយពីភូមិរាប់គីឡូម៉ែត្រ ហើយ មិនសូវបានបរិភោគចំណីស្រស់ៗទេ ។
ប៉ុន្តែជីវភាពបែបនោះមិន បានធ្វើអោយមណីនិងសុធី ថមថយសេចក្តីសុខក្នុងជីវិតរបស់គេ
ឡើយ ។ ផ្ទុយទៅវិញ គេស្រឡាញ់គ្នាណាស់ ហើយរក្សាថ្នាក់ថ្នម
ទឹកចិត្តគ្នាទៅមកដោយគ្មានរឱស្ថាន ។ ដោយសារតែគេមិនសូវ ចាយវាយនោះហើយ
ទើបគេសន្សំបានប្រាក់កាសបង្គួរសំរាប់ផ្ញើជូន យាយគិមហួយ
និងជូនតាម៉ានិននៅព្រះនេត្រព្រះរៀងរាល់ខែ ។

មិនយូរប៉ុន្មាន មណីក៏ប្រសូត្របានកូនស្រីមួយឈ្មោះ និលរត្ន តែមិនបានប៉ុន្មានខែផង
ទារិកាបានទទួលជម្ងឺមួយជាទម្ងន់ ។ កាល បើភូមិត្រពាំងថ្ម នៅឆ្ងាយពេទ្យឆ្ងាយទីប្រជុំជនដល់ម្លឹង
កូនខ្ចីដំបូង របស់សុធីមិនបានទទួលការព្យាបាលជម្ងឺបានត្រឹមត្រូវទេ ។ នាងក៏
ទទួលមរណកាលទៅនៅក្នុងរង្វង់ដៃម្តាយ ពេលសុធីជិះកង់ឌុប
ប្រពន្ធទៅរកពេទ្យនៅឯទីប្រជុំជនសេរីសោភ័ណ ។ ទាំងពីរនាក់ប្តី
ប្រពន្ធក៏បីសពកូនយកមកបូជានៅវត្តត្រពាំងថ្មវិញ ទាំងដួងចិត្ត រៃងសោកសៅហួសព្រំដែន ។
ពេលនោះ អ្នកទាំងពីរដឹងខ្លួនច្បាស់ ណាស់ថាខ្លួនគេគ្មានការពិសោធន៍គ្រប់គ្រាន់ទេ
អំពីរបៀបថែរក្សា សុខភាពទារក ទើបបណ្តោយអោយកូនច្បងរបូតបាត់ពីរង្វង់ដៃទៅ
ទាំងតក្កហល ។

ក្រោយមក មណីប្រសូត្របានកូនស្រីម្នាក់ទៀតឈ្មោះនិមល ។ ពេលនេះ ទាំងសុធី
ទាំងមណីមានការប្រុងប្រយត្ន័អំពីរបៀបថែ រក្សាកូនជាងមុន ។ រាល់ថ្ងៃ
សុធីទៅធ្វើការឯសាលាឆ្ងចធម្មតា ទុក អោយប្រពន្ធនៅផ្ទះរក្សាកូននិងទុកដាក់ផ្ទះសម្បែង ។
កាលជំនាន់ នោះ អ្នកស្រុកទម្លាប់អោយស្ត្រីបរិភោគស្រាថ្នាំកូនខ្ចី ដើម្បីរក្សា
សាច់ឈាមនិងសុខភាពរបស់ម្តាយ ។ មណីក៏ធ្វើតាមពាក្យចាស់ៗ និងយាយហ្មបក្នុងភូមិណែនាំ ។
សំណាងមិនល្អ កូនទីពីររបស់គេ ក៏ទទួលជម្ងឺឆ្លន់សាជាថ្មី ។
- នី! និមលយ៉ាងម៉េចទៅហើយ ? (សុធីសួរប្រពន្ធពេលមក
ដល់ផ្ទះពីសាលក្រោយពីប្រពន្ធអោយក្មេងទៅតាមហៅ)

CHANBOKEO.COM

- គេឈប់រាគហើយ តែមួលឈាម ហើយគ្រុនក្ដៅទៀតផង ។ គេ យំពេញមួយថ្ងៃ រហូតអស់សម្លេងយំលេងឮហើយ បង! ខ្ញុំគិតថា យើងមិនគួរបង្អង់ទៀតទេ ក្រែងឆ្លងដូចនិលរត្នម្នាក់ទៀត ។

- អញ្ចឹង បងទៅរៀបចំឥវ៉ាន់ ។ អូនទៅរៀបចំខ្លួនទៅ ។ យើង ទៅរកពេទ្យ ដើម្បីព្យាបាលកូនអោយទាន់ពេលវេលា ។

បន្តិចមក សុធីក៏ជិះកង់ឌុបប្រពន្ធចេញទៅភ្នំស្រុក ។ ពេទ្យ នៅភ្នំស្រុកប្រាប់ថា នាងតូចឈឺធ្ងន់ណាស់ ទាល់តែយកទៅពេទ្យ នៅសេរីសោភ័ណ ។ មណីក៏បីទារកជិះកង់ចេញទៅជាមួយប្ដី ។ ពេលនោះ សុធីបានជួបសាច់ញាតិជាអ្នករត់ឡានឈ្នួល ពីស្វាយទៅ បាត់ដំបង ។ គេប្រាប់ថាមានពេទ្យបារាំងនៅបាត់ដំបងពូកែព្យាបាល រោគកូនក្មេងណាស់ ។ សុធីក៏យកកង់ទៅផ្ញើមិត្តភក្តិ រួចហើយក៏នាំ ប្រពន្ធឡើងជិះឡានឈ្នួល ទៅបាត់ដំបងបន្តទៀត ។ ទំរាំទៅដល់ ក៏ព្រលប់ល្មម ។ សំណាងល្អ ម្ចាស់ឡានឈ្នួលជាសាច់ញាតិនោះមាន ទឹកចិត្តណាស់ ។ គេទម្លាក់ម៉ូយហើយ ក៏បើកនាំសុធីនិងប្រពន្ធមក ទម្លាក់នៅមុខមន្ទីរពេទ្យតែម្ដង ។

លុះលោកគ្រូពេទ្យបារាំងនោះពិនិត្យរោគនិមលទៅ ក៏សួរថា ៖

- នាងបំបៅកូននឹងទឹកដោះមែនទេ ?

- ចា៎ស លោកគ្រូពេទ្យ!

- ហើយចុះនាងមានញ៉ាំស្រាទេ ?

- ចា៎ស! ខ្ញុំបានញ៉ាំស្រាថ្នាំកូនខ្ចី ដើម្បីរក្សាសុខភាព ។

- នោះហើយជាប្រភពជម្ងឺ ។ ការពិត បើទារកនៅបោះដោះ ចូរ នាងចៀសវៀងញ៉ាំស្រា ឬអ្វីក៏ដោយអោយតែមានជាតិស្រា ព្រោះ ជាតិស្រាអាចប៉ះពាល់ដល់សុខភាពកូនតូច តាមរយៈទឹកដោះដែល នាងបំបៅ ។ ជាតិស្រាអាចបំផ្លាញប្រពន្ធ័ការពារសុខភាពរបស់ក្មេង ធ្វើអោយគេរាគរួចហើយមួលឈាម គ្រុនក្ដៅហើយបាត់បង់ប្រាជ្ញា និងស្មារតីចងចាំ ។ ជាពិសេសទៅទៀត បើគេនៅរស់មានជីវិត ធំឡើង គេនឹងក្លាយជាមនុស្សឆាប់ខឹងច្រឡោតឬក៏មួម៉ៅច្រើន ។

មណីបែរសម្លឹងមុខសុធីជាប្ដី ។ ការពិត នាងកំពុងមានការ ភ្ញាក់ផ្អើលខ្លាំងណាស់ ព្រោះមិនបានដឹងរឿងនេះពីមុនៗមក ។ នាងបានចូលរៀនពេទ្យចំនួន៦ខែដែរ តែមិនដែលឮគ្រូនិយាយ អំពីរឿងស្រាថ្នាំកូនខ្ចីទេ ។ នាងគិតថា ប្រហែលជាដូច្នោះទេដឹង

CHANBOKEO.COM

ទើបកូនទីមួយរបស់នាងស្លាប់ ព្រោះនាងប្រើស្រាថ្នាំរក្សាសុខភាព ហួសកំរិត ពេលកូននៅបៅនៅឡើយ ។

តាមផ្លូវ ត្រឡប់មកផ្ទះវិញ សុធីនិងមណី មានអារម្មណ៍សោក សៅផងរីករាយផង សោកសៅដោយគេបាត់បង់កូនទីមួយទៅ ដោយគេមិនបានដឹងដិតដល់ថា ជាតិស្រាថ្នាំដែលម្តាយបរិភោគ អាចសម្លាប់ជីវិត ឬបំផ្លាញសុខភាពរបស់កូនពេលគេបំបៅ ។ បើសិនជាគេដឹងមុន ម្ល៉េះសមកូនទីមួយរបស់គេមិនស្លាប់ឡើយ ។ ប៉ុន្តែគេក៏រីករាយព្រោះបានដឹងទាន់ពេល អាចសង្គ្រោះជីវិតរបស់និមលអោយចាកផុតពីសេចក្តីស្លាប់បាន ។ តាំងពីថ្ងៃនោះមក សុធី ប្តេជ្ញាចិត្តថា នឹងបណ្តុះនិមលអោយរឹងប៉ឹង សងជំនួសពេលវេលា ៩ខែដែលនាងទទួលជំងឺរាំរ៉ៃ ដោយកំហុសអចេតនារបស់ឪពុក ម្តាយទាំងពីរនាក់ ។

ក្រោយមក តាម៉ានិនបានផ្ញើកូនស្រីពៅរបស់គាត់អាយុ៧ឆ្នាំឲ្យមករស់នៅជាមួយមណីនិងសុធីឯត្រពាំងថ្ម ។ នៅថ្ងៃដែលអ្នកទាំងពីរទៅទទួលនាងនេតកូនតាម៉ានិននោះ គេសង្កេតឃើញថា នាង មានជំងឺកមពេញក្បាល ស្ទើរតែគ្មានកន្លែងអោយសក់ដុះបាន ។

- ហេតុអ្វីក៏នេតកើតកមពេញក្បាល ? (មណីសួរ)
- មកពីអត់ទឹកមុជ អត់សាប៊ូដុសណា៎បង! (នាងនេតឆ្លើយ)
- ហើយចុះពុកនឹងបងៗមិនរែកទឹក មិនទិញសាប៊ូអោយទេឬ ?
- ពុកនិងបងធំៗចេញរកស៊ី ។ បងតូចៗនៅរៀន ។ នេតនៅផ្ទះ ម្នាក់ឯងរាល់ថ្ងៃ មិនមាននរណានៅផ្ទះអោយនេតពឹងទេ ។
- ហើយប៉ុន្មានថ្ងៃបានងូតទឹកម្តង នេត ?
- គឺខ្ញុំមុជរាល់ពេលមានភ្លៀង តែបើអត់ភ្លៀង គឺត្រូវចាំរហូតដល់ បងៗរែកចាក់ពាងអោយ ទើបមុជបាន ។

តាំងពីម្តាយស្លាប់ទៅ នាងតូចនេតមិនដែលមាននរណាថែទាំទេ គឺចេះរស់នៅតាមតែដំណើរ ហើយមិនសូវបានងូតទឹកសំអាតខ្លួន ត្រឹមត្រូវ ដូច្នេះ ហើយទើបនាងមានជំងឺកមពេញក្បាល ពេញខ្លួន ពិបាកនឹងព្យាបាលណាស់ ។

មណីបានចាប់នាងនេតងូតទឹកដុសសាប៊ូ លាបថ្នាំយ៉ាងត្រឹមត្រូវ មិនយូរប៉ុន្មាននាងក៏ជាសះស្បើយ ហើយបានត្រូវសុធីឌុបកង់ ទៅ រៀនសាលាជាមួយរាល់ព្រឹក ។

CHANBOKEO.COM

ពីរបីខែក្រោយមកទៀត ជីតា របស់នាងបញ្ជូនកូនប្រុសមួយទៀតជាកូនបន្ទាប់ពៅ ឈ្មោះនន្ទ
មក នៅជាមួយទៀត ដើម្បីអោយអ្នកទាំងពីរជួយទំនុកបំរុងផង
ជួយមើលអោយគេរៀនសូត្រផង ។ ដោយហេតុថាមណីនិងសុធី
ធ្លាប់ជាមនុស្សកំព្រីកំព្រាពីក្មេងមក គេមិនហ៊ានប្រកែកអោយអាក់
ទឹកចិត្តមនុស្សចាស់ឬក្មេងៗទេ ។ គេក៏ទទួលយកដោយបេះដូងដ៏
សែនទូលាយរបស់គេទាំងពីរនាក់ ។

នៅឆ្នាំបន្ទាប់ៗមក សុធីធ្វើការសាងស្នាដៃយ៉ាងល្អប្រចាំសាលា ហើយក៏រក្សាទំនាក់ទំនង
ជាមួយមជ្ឈមណ្ឌលគ្រូបង្រៀនប្រចាំខេត្ត ដើម្បីសុំផ្លាស់ទៅនៅបាត់ដំបង
ព្រោះគេមានបំណងនាំកូនចូល រៀនសាលាល្អ សំរាប់អនាគតរបស់គេ ។ ដោយការខំប្រឹងប្រែង
ព្យាយាមយ៉ាងមោះមុត សុធីក៏បានទទួលការសរសើរជាខ្លាំងពី សំណាក់ក្រសួងសិក្សាធិការខេត្ត
ហើយគេក៏អនុញ្ញាត្តិអោយសុធី ផ្លាស់មកធ្វើការជាគ្រូនៅទក្ខិណសាលា ក្រុងបាត់ដំបង ។ ពេល
នោះ និមលចំរើនវ័យបានអាយុជាងពីរឆ្នាំហើយ ។

- ជួលផ្ទះបានហើយឬបង ? (មណីសួរ)
- បានហើយ នៅក្រោយកុងស៊ីបញ្ញាំភូមិភាស៊ីស្រោ មិនឆ្ងាយពី សាលារៀនប៉ុន្មានទេ ។

សុធីក៏នាំប្រពន្ធអោយទៅមើលផ្ទះនោះ ឃើញជាផ្ទះឈើប្រក់ ស្បូវ
សង់ខ្ពស់ពីដីប្រហែលមួយម៉ែត្រ ហើយពុះចែកល្វែងជាបីផ្ទះ មានជណ្ដើរនិងទ្វារដាច់គ្នា ។
គេក៏ជួលនៅមួយល្វែងខាងចុងគេ ។
ពេលនោះ មណីកំពុងមានផ្ទៃពោះកូនទីបី គឺនិសា ។ នាងមិនសូវ បានធ្វើការអ្វីជួយប្ដីប៉ុន្មានទេ
ព្រោះជិតគ្រប់ខែត្រូវសម្រាលឆាប់ៗ នេះហើយ ម្ល៉ោះហើយ
សុធីត្រូវរត់ធ្វើអ្វីៗដោយខ្លួនឯងទាំងអស់ ។
ចំណែកកុមារនន្ទនិងនាងតូចនេត កូនរបស់តាម៉ានិន ក៏បានតាម
មកជាមួយគ្រួសាររបស់សុធីឯបាត់ដំបងនេះដែរ ។

នៅល្ងាចថ្ងៃដំបូង ក្នុងផ្ទះថ្មីដែលសុធីទើបជួលបាន...

សុធីធ្វើម្ហូបអាហារហើយ ក៏រៀបចំហៅប្រពន្ធបរិភោគ ។ គេ
អង្គុយបរិភោគបាយដៃមួយចំហៀង ឯមួយចំហៀងទៀត កាន់កូន ស្រីនិមលរបស់គេ
ដាក់នៅលើភ្លៅម្ខាង បញ្ចុកបាយកូនបណ្ដើរ
បរិភោគខ្លួនឯងបណ្ដើរ ។

CHANBOKEO.COM

- យ៉ាងម៉េចដែរ ? ឆ្ងាញ់ទេ នី ?
- ចាំស ! ឆ្ងាញ់ណាស់ ! គ្រាន់តែអស់កម្លាំងបន្តិច ទើបហាក់ដូច ជាញ័រខ្លួន ទើបខ្ញុំមិនអាចទទួលអាហារច្រើនបាន ។

សុធីឃើញភរិយាមានទឹកមុខស្វាយល្ហុក ក៏ស្ទុះទៅរៀបកន្លែង អោយប្រពន្ធទំរេត ។

- បើអញ្ចឹង អូនសំរាកសិនទៅ បើមិនស្រួលក្នុងខ្លួន ។ ចាំដល់ មានអារម្មណ៍ស្រួលគ្រាន់បើ ចាំងើបមកបរិភោគវិញណា៎ !
- ចាំសបង !

មណីញញឹមទាំងមុខស្លេកៗតបទៅប្តីវិញ រួចហើយក៏លូនទៅ រកខ្នើយភ្លាម ។ មើលចុះ ! គេមានកូនបីហើយ តែសុធីនៅតែថ្នាក់ ថ្នមភរិយា ហាក់ដូចជាប្តីប្រពន្ធទើបនឹងរៀបការថ្មីថ្មោងអញ្ចឹង ។ ការពិត សុធីស្រឡាញ់ប្រពន្ធជាទីបំផុត ព្រោះនាងជាទ្រព្យមរតក ជីវិតតែមួយគត់ដែលនាយមាន ។ ក្រៅពីបងឃីញនិងបងថ្លៃចិត្ត សាមាន្យនោះចេញ គេគ្មាននរណាទៀតឡើយ ។ បងប្រុសពីរនាក់ ដែលរត់ចោលផ្ទះទៅ ក៏មិនដែលត្រឡប់មកផ្ទះ ឬផ្តល់ដំណឹង អោយប្អូនដឹងថាគាត់នៅឯណា សុខទុក្ខយ៉ាងម៉េច ហើយក៏មិនដែល មកមើលប្អូនថា កន្លងមក ប្អូនពៅនោះសុខទុក្ខយ៉ាងណាដែរទេ ។ ឯញាតិសំខាន់ៗទៀតដូចជា ប៉ិហួត លោកគ្រូចៅអធិការ យាយ គិមហួយ និងលោកតាមេឃុំនោះ ក៏បាននាំគ្នាធ្វើមរណកាលទៅ ជាបន្តបន្ទាប់គ្នា ។ ម្ល៉ោះហើយ មណីនិងសុធីក៏រស់នៅកណ្តោច កណ្តែងតែពីរនាក់ប្តីប្រពន្ធ យ៉ាងកំសត់ត្រមង់ត្រមោច ។ ប៉ុន្តែក្តី ស្រឡាញ់ ការថ្នាក់ថ្នម ការយល់ចិត្តគ្នា និងការស្គាល់ទុក្ខធុរៈ របស់គ្នាទៅវិញទៅមក បានធ្វើឲ្យជីវិតគ្រួសាររបស់គេ បានទទួល សុភមង្គលយ៉ាងពេញបរិបូណ៌ ។

សុធីថៃទាំថ្នាក់ថ្នមប្រពន្ធរបស់គេ រហូតដល់អ្នកជិតខាងផ្ទះនាំ គ្នាចំអន់ព្រឹកល្ងាចឡើងសាំទៅហើយ ប៉ុន្តែមាណពមិនខឹងទេ បែរ ជាញញឹមដាក់អ្នករាល់គ្នាហើយឆ្លើយយ៉ាងកំប្លែងថា ៖

- មួយជីវិតរបស់ខ្ញុំនេះ ទេវតាបានអោយមកចាប់កំណើត ដើម្បី មកបំរើរក្សាទេពធិតាមួយអង្គនេះ ដូច្នេះ សុធីមិនហ៊ានធ្វើអោយ ក្តៅសចិត្តទេ ខ្លាចទទួលបណ្តាសា ។

ស្ត្រីអ្នកជិតខាងលួចរអ៊ូដាក់មណី ខ្សិបៗថា ៖

CHANBOKEO.COM

- បើសិនជាប្ដីខ្ញុំប្រព្រឹត្តដូចលោកគ្រូសុធី នោះប្រហែលជាខ្ញុំរីក ថ្លើមប៉ុនចង្អេរមិនខាន ។

ប៉ុន្តែ បុរសខ្លះទៀត បែរជារអ៊ូដាក់សុធីថា ៖

- ឯងបំរើប្រពន្ធមិនអោយគ្នើសចិត្តរបៀបនេះ ធ្វើអោយខូចមុខ មាត់បុរសអស់ហើយ ។ គេជាប្រពន្ធណា៎ ឯយើងជាអ្នករកលុយមក ចិញ្ចឹមពួកគេ ដូច្នេះ គេត្រូវតែបំរើយើង ។ បើបំរើមិនត្រូវចិត្ត យើងឆាក់ក្បាលចោល ។ រឿងអីដែលយើងត្រូវយកចិត្តប្រពន្ធនោះ កាលបើប្រពន្ធចាំតែដេកស៊ីអង្គៀមលុយដែលប្ដីរកបាន...

ឮសំដីនិងគំនិតអសុរសដូច្នោះ សុធីមិនស្ដាប់ទេ ។ គេបែរជា និយាយតបថា ៖

- ថៃដន្យ សុធីមិនបានគិតថា ប្រពន្ធជាអ្នកបំរើទេ តែនាងជាគូ ជីវិតទៅវិញទេតើ ។ កាលបើនាងជាទ្រព្យដែលខ្ញុំស្រឡាញ់បំផុត ក្នុងជីវិត ខ្ញុំត្រូវតែថែទាំរក្សាអោយបានល្អ ។ កាលណានាងមាន សេចក្ដីសុខ ខ្ញុំក៏មានសេចក្ដីសុខដូចគ្នា ។ បើសិនជានាងមាន អារម្មណ៍មិនល្អ ចិត្តខ្ញុំក៏ខ្វះសេចក្ដីសុខដែរ ។ ថ្វីបើខ្ញុំនឿយហត់ផ្លូវ កាយ ដើម្បីជួយដៃជើងប្រពន្ធបន្តិចមែន ប៉ុន្តែក៏មិនទាស់ខុសអី ដែរ ព្រោះនាងជាប្រពន្ធរបស់ខ្ញុំហើយជាម្ដាយរបស់កូនៗខ្ញុំគ្រប់ៗ គ្នា ។ បើនាងមានអារម្មណ៍ល្អ មានសេចក្ដីសុខ នាងនឹងថែរក្សា កូនខ្ញុំអោយមានសេចក្ដីសុខ មានការរីករាយក្នុងគ្រួសារទៅតាម នោះដែរ ។ ខ្ញុំមិនបានគិតថា ការជួយដៃជើងប្រពន្ធនៅក្នុងផ្ទះ ជា ការអាប់ឱនឡើយ ព្រោះខ្ញុំមិនបានយកខ្លួនទៅបំរើអ្នកដទៃ ហើយ បំផ្លាញគ្រួសារខ្លួនឯងឯណា មានតែបន្ថែមសេចក្ដីសុខអោយក្រុម គ្រួសារថែមទៀត តែប៉ុណ្ណោះ ។

តាំងពីបានស្ដាប់គតិរបស់សុធីមក អ្នកជិតខាងក៏ក្លាយជាដូរទដ្ឋិ ឈប់ចំអន់សុធីអស់រលីង ហើយបែរជានាំគ្នាខិតខំប្រឹងធ្វើខ្លួនល្អ ប្រណាំងប្រជែងនឹងគ្រួសារសុធីទៅវិញ ដើម្បីចង់ដឹងថា តើនរណា នឹងក្លាយជាមេគ្រួសារគំរូប្រចាំភូមិក្រោយភាស៊ីនោះ ។

មិនបានមួយឆ្នាំពេញផង កេរ្តិ៍សុធីបានល្បីកាត់ទីក្រុងបាត់ដំបង ទាំងមូល ទីមួយដោយសារការដែលសុធីប៉ិនថ្នាក់ថ្នមរក្សាប្រពន្ធកូន ទីពីរដោយសារគេប្រឹងធ្វើការយ៉ាងឧស្សាហ៍បំផុត ហើយក៏ប្រសព្វ បង្រៀនសិស្សទៀត ។ ឪពុកម្ដាយរបស់សិស្សសាលាជាច្រើនរត់ បន្តកន្ទុយគ្នា យកកូនមកផ្ញើនឹងសុធីអោយជួយប្រដៅ ជួយណែនាំ ក្នុងការរៀនសូត្រ ។ ចំណែកតាម៉ានិននៅព្រះនេត្រព្រះ បានដឹក កូនម្ដងមួយៗយកមកផ្ញើនឹងអ្នកទាំងពីរបន្ថែមទៀត ឲ្យជួយចិញ្ចឹម ទំនុកបំរុងរៀនសូត្រដែរ ។

CHANBOKEO.COM

ទីបំផុត សុធីក៏ក្លាយជាបង្គង ជាសំបុក ជាម្លប់ជ្រកកោនរបស់ក្មេង ក្រីក្រជាច្រើននាក់ មកពីភ្នំស្រុកក៏មាន ពីព្រះនេត្រព្រះក៏មាន ពីមង្គលបុរីសេរីសោភ័ណក៏មាន ។

សុធីប្រឹងធ្វើការរាជការផង បង្រៀនថ្នាក់ក្រៅៗផង ដើម្បី ចិញ្ចឹមគ្រួសារ និងចិញ្ចឹមក្មេងៗទាំងប៉ុន្មាននាក់ មកពីស្រុកស្រែ ក្រីក្រ ។ មួយខែៗ គេចំណាយលុយស្ទើរតែមិនសល់ក្នុងហោប៉ៅ ។

ចំណែកមណីវិញ ក៏ត្រដាងស្លាបការពារថែទាំក្មេងៗទាំងឡាយ ដែលមកស្នាក់អាស្រ័យនៅក្នុងផ្ទះ បានយ៉ាងល្អបំផុត ។ ថ្វីបើការ រស់នៅមិនជាសំបូរសប្បាយប៉ុន្មានដូចដែលនាងចង់បាន ប៉ុន្តែអ្នក ទាំងពីរបានសន្យាចំពោះខ្លួនឯងថាមិនរៀនជំពាក់គេ មិនទិញអីវ៉ាន់ ជឿគេ មិនឆបោកកេងប្រវ័ញ្ចនរណា ជាពិសេសបំផុត គឺនាងសន្សំ ប្រាក់ដែលប្ដីរកបាននោះ បង់ថ្លៃផ្ទះបីខែទៅបួនខែទុកមុនជានិច្ច ។ ប្រហែលបួនឆ្នាំក្រោយមក សុធីនិងមណីក៏ទិញដីមួយដុំរបស់មេភូមិ ក្រោយភាស៊ីស្រានោះ ដើម្បីសង់ផ្ទះមួយខ្នងរស់នៅដោយខ្លួនឯង ដោយមិនបាច់ជួលផ្ទះគេនៅតទៅទៀត ។

oooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី១១
# និពន្ធ

ឆ្នាំនេះ និមលត្រូវខំរៀនជាងមុន ដើម្បីប្រឡងយកមធ្យម សិក្សាបត្រ ។ ប៉ុន្តែ ដោយសារស្រុកកើតសង្គ្រាមផង ដោយនាង ចូលវ័យពេញក្រមុំផង សុធីឪពុករបស់នាងក៏បញ្ឈប់កូនស្រីនិង ក្មេងដែលនៅជាមួយទាំងប៉ុន្មាននោះ ឲ្យឈប់ជិះកង់ទៅរៀនគួរ cours ថ្នាក់ពិសេសតទៅទៀត ព្រោះអសន្តិសុខអាចកើតមាន គ្រប់វេលា ។ និតាក៏មានពេលច្រើននៅផ្ទះជាមួយម្តាយនិងប្អូនៗ ។ ប៉ុន្តែនាងមានចរិតខុសគេបន្តិច ត្រង់ចូលចិត្តគេចពីការប្រឡែង លេងជាមួយបងប្អូន ហើយលួចទៅសម្ងំសរសេរ សៀវភៅតែម្នាក់ ឯង ។ មិនយូរប៉ុន្មាន នាងក៏បានបញ្ចប់សំណៅប្រលោមលោកអប់រំ ជាច្រើនក្បាល ។ នាព្រលប់មួយនោះ យុវនារីយើងបានយក សំណៅចុងក្រោយ ទៅជូនឪពុកជួយពិនិត្យ ។

- កូនសរសេររឿងទាំងពីរនេះដោយខ្លួនឯងមែនទេ និមល ?
- ចា៎សប៉ា! ខ្ញុំបានអង្គុយសរសេររាល់ថ្ងៃ មួយថ្ងៃបន្តិច ជាងបីខែ មកហើយ ។

លោកគ្រូសុធីលើកសៀវភៅដែលសរសេរដោយដៃនោះ យក មកបើកមើលម្តងមួយសន្លឹក រួចហើយក៏ញញឹមឡើង ៖

- លើកនេះ ល្អជាងលើកមុនច្រើនណាស់ ជាពិសេសវាជាអត្ថបទ អប់រំមួយដែលក្មេងជំទង់ៗអាចយកអានហើយស្រង់យកវិន័យល្អៗ សំរាប់ខ្លួនគេ ។ ឯសាច់រឿងក៏ប្លែកហើយពិរោះទៀតផង ។

និមលញញឹមខ្មិបតែម្តង កាលបើឮឪពុកនាងសរសើរដូច្នេះ ។ រំពេចនោះ សុធីក៏ពោលបន្តថា ៖

- ប៉ុន្តែ ពេលកូនសរសេរលើកក្រោយ ចូរកូនរៀនបង្កប់អាថ៌កំបាំង ខ្លះៗ នោះក្មេងគេរិតតែចង់អាន ចង់តាមដានសាច់រឿង ។

និមលសើចខឹកៗ តបទៅឪពុកនាងវិញថា ៖

CHANBOKEO.COM

- ខ្ញុំខំប្រឹងធ្វើដែរ តែទៅមិនទាន់រួច ។ ប្រហែលជាកូនត្រូវអាន សៀវភៅស៊ើបអង្កេត ឬសៀវភៅរបស់បរទេសខ្លះៗថែមទៀត ដើម្បីសង្កេតមើលថា តើគេបង្កើតសន្ទេហាវិធីរបៀបណា ក្នុងការ បង្កើនចំណាប់អារម្មណ៍របស់អ្នកអាន ។

- ល្អណាស់! ពេលនេះ កូនយល់ហើយមែនទេ ថាហេតុអ្វីប៉ាចង់ អោយកូនអានសៀវភៅអោយបានច្រើន ។

- ចាស ប៉ា! ការអានសៀវភៅច្រើន កូនទទួលការចេះដឹងច្រើន មិនតែប៉ុណ្ណោះ សៀវភៅទាំងនោះអាចជួយអោយកូនបណ្តុះគំនិត ប្លែកៗ មិនអោយសរសេរច្រំដែលសាច់រឿងទៀតផង ។

- ហើយចុះពេលនេះ កូនយកសៀវភៅរបស់កូនទៅផ្សព្វផ្សាយ ឯណាខ្លះដែរ ?

- គឺកូនយកទៅផ្ញើតូបគេដាក់ជួលនៅផ្សារលើ និងនៅផ្សារ ក្រោម ។ មួយថ្ងៃបានឈ្នួលមួយរៀល ក្នុងមួយក្បាល ហើយចែក គ្នាជាមួយម្ចាស់តូប ម្នាក់ពាក់កណ្តាល ។

- ហើយយ៉ាងម៉េចបានជាកូនយកតែមួយរៀលក្នុងមួយក្បាល ?

- គឺកូនធ្វើនេះមិនមែនដើម្បីចំណេញប្រាក់ទេ ប៉ុន្តែចំណេញចំនួន អ្នកអាន ព្រោះថាបើកូនជួលថោកៗ អ្នកអានក្មេងៗដែលគ្មានប្រាក់ ក៏អាចមានសមត្ថភាពជួលអានបានដែរ ។ ម្យ៉ាងទៀត មួយរៀល ក្នុងមួយរឿង ជាវិធីដែលអាចធ្វើអោយខ្ញុំរាប់ចំនួនអ្នកអានក្នុង ក្បាលនិមួយៗនោះបានងាយផង ។

- បើដូច្នេះ ប៉ាគិតថា កូនស្រីប៉ានឹងក្លាយជាមហាសេដ្ឋី ឆាប់ៗនេះ ហើយ ព្រោះអាចរកលុយដោយកម្លាំងប្រាជ្ញាស្មារតីបានតាំងពីក្មេង ល្អប្រសើរជាងប៉ាកាលនៅអាយុប្រហែលកូននោះទៅទៀត ។

និមលមានកម្លាំងចិត្តប្រឹស កាលបើឮឪពុកពោលលើកទឹកចិត្ត ដូច្នោះ ។ លុះនាងត្រឡប់ចេញទៅវិញ ម្តាយរបស់នាងក៏ដើរចូល មកជួបលោកគ្រូ ៖

- ខ្ញុំគិតថា បងដូចជាបណ្តោយកូនពេកហើយ ។

- បងបណ្តោយកូនរឿងអ្វីទៅ នី ?

- គឺអោយគេសរសេរសៀវភៅរឿងតែពាសតែពាសបែកអារម្មណ៍ ខានរៀននោះអី !

- នរណាថា ? ការពិត កូនយើងកំពុងហ្វឹកហ្វឺនប្រាជ្ញ គំនិត និង ការចេះដឹងរបស់គេណ៎អូន ។ ម្យ៉ាងទៀត បងក៏បានពិនិត្យគ្រប់ សំណៅ ដែលកូនបានសរសេរដែរ មិនឃើញមានអ្វីឆ្គាំឆ្គងទេ ។ គេសរសេរបានល្អគួរអោយសរសើរណាស់ ។

CHANBOKEO.COM

- ហើយចុះហេតុដូចម្ដេចបានជាបងបណ្ដោយ ឲ្យកូនយកសំណៅទាំងនោះទៅដាក់ជួលយកលុយតាមផ្សារទៅវិញ ?

- នេះជាការធ្វើតែសសាកល្បងមើលស្នាដៃកូនណា៎ ថាតើចំណេះ ប្រាជ្ញ គំនិតដែលគេមានហើយអាចបញ្ចេញមកក្រៅចែកគេអាន នោះអាចមានប្រសិទ្ធភាពទាក់ទាញចំណាប់អារម្មណ៍អ្នកអានទូទៅ បានកំរិតណា ល្អកំរិតណា ហើយមានខ្វះអ្វីទៀតដែលកូនត្រូវកែកុន រៀនបន្ថែម ។ បើមានអ្នកជួលកាន់តែច្រើន មានន័យថាស្នាដៃ របស់កូនយើង កាន់តែមានប្រសិទ្ធភាពហើយ ។

- ប៉ុន្តែ ខ្ញុំមិនយល់ដូចបងទេ ។

- ព្រោះហេតុអ្វីទៅ ?

- ព្រោះអូនគិតថា ធ្វើជាអ្នកនិពន្ធ រកលុយបិទក្រពះមិនគ្រប់ទេ ។ អូនចង់អោយគេរៀនធ្វើពេទ្យបណ្ឌិត ធ្វើវិស្វករ ឬអ្វីដែលនាំអោយគេអាចរកបៀវត្សសមរម្យជាងយើងសព្វថ្ងៃ ណា៎បង ។

- នីគិតខុសហើយ អ្នកនិពន្ធទាំងឡាយមិនមែនសុទ្ធតែជាអ្នកក្រ ឬជាអ្នកដែលមានប្រាក់ខែតិចទេ ។ ឯការរៀនចងក្រងតាំងពីក្មេង នោះនឹងធ្វើឲ្យគេចូលចិត្តរៀនហើយចូលចិត្តស្រាវជ្រាវណាស់ បើ មិនដូច្នេះទេ គេមិនអាចសរសេរបានចំរើន ហើយប្លែកៗឡើយ ។ នៅក្នុងមួយជីវិតគេ បើនៅតែចង់សរសេរចងក្រងសៀវភៅនោះ គេនឹងក្លាយជាមនុស្សដែលរៀនរហូតមួយជីវិត គឺរៀនមិនចេះធុញ ទ្រាន់... ហើយផលនៃការសិក្សានេះ ត្រូវការពេលយូរឆ្នាំណាស់ទំរាំកូនយើងអាចបេះផលបាន ។

- អូនមិនយល់ប្រសាសន៍បងទេ (មណីពោលតប)

- ចាំបងពន្យល់អូនណា៎! អូនមើលទៅសាលាជាន់ខ្ពស់និមួយៗទៅ មើល ។ នៅថ្នាក់និមួយៗ មិនថា សាលាវេជ្ជសាស្ត្រ ទន្តសាស្ត្រ សេដ្ឋសាស្ត្រ សង្គមសាស្ត្រ វិស្វកម្ម ស្ថាបត្យកម្ម ចិត្តសាស្ត្រ អ្វីទេ គឺគេតែងតែមានយកសំណៅក្រាស់ៗរាប់រយក្បាលមកអោយសិស្ស រៀន ។ តើសៀវភៅទាំងនោះសរសេរចងក្រងដោយនរណា ?

- គឺដោយអ្នកប្រាជ្ញខាងមុខវិជ្ជានិមួយៗ ទាំងឡាយនោះ ។

- នោះហើយ ជាចម្លើយដ៏ល្អបំផុតណា៎អូន ។ គឺបងកំពុងតែបណ្ដុះកូនអោយឈានទៅរកកំរិតជាអ្នកប្រាជ្ញបណ្ឌិតម្នាក់ ក្នុងមុខវិជ្ជាណា មួយ មិនថា

CHANBOKEO.COM

ខាងគណិតសាស្ត្រ ខាងវេជ្ជសាស្ត្រ គីមីសាស្ត្រ ឬអ្វី ទៀតឡើយ អោយតែកូនយើងចាប់យកបាន ហើយបងក៏កំពុងឲ្យ គេរៀននិពន្ធសៀវភៅពីពេលនេះទៅ ។ ទំរាំគេរៀនចប់ដល់កំរិត បណ្ឌិត គេនឹងពូកែខាងនិពន្ធផុតលេខតែម្តង ហើយបើគេបានក្លាយ ជាវេជ្ជបណ្ឌិត គេនឹងសរសេរសៀវភៅដែលទាក់ទងទៅនឹងការថែ រក្សាសុខភាពនិងការព្យាបាលជម្ងឺ ។ បើគេជាគណិតវិទូ គេសរសេរ អំពីសំណៅគណិតសាស្ត្រជាន់ខ្ពស់ចែកសិស្សរៀន ។ បើគេជាចិត្តវិទូ គេនឹងសរសេរសៀវភៅអប់រំចិត្តនិងសតិប្រាជ្ញ ដល់សង្គម ដោយវិធីអហឹង្សា ពន្លត់ភាពក្តៅងំនៅក្នុងចិត្ត ពន្លត់កំហឹងនិងការ គុំគួនចំពោះគ្នា ជាពិសេសគឺការរៀនដោះស្រាយបញ្ហាក្នុងគ្រួសារក្តី ក្នុងសង្គមក្តីដោយមិនប្រើការគម្រាមកំហែងជាគោល ពោលគឺយក វិធីដោះស្រាយដោយសន្តិវិធី ដោយប្រើសតិប្រាជ្ញជាជំនួសវិញ ។ ជាពិសេសទៅទៀត ដើម្បីឲ្យស្នាដៃរបស់គេកាន់តែល្អប្រសើរនោះ កូនយើងនឹងត្រូវការការសិក្សាស្រាវជ្រាវក៏កាន់តែច្រើនដែរ ។ នៅពេលណាគេស្រាវជ្រាវកាន់តែច្រើន គេក៏ចេះកាន់តែច្រើនដែរ គឺ គេរៀនមិនចេះចប់ទេ ។ មួយជីវិតនេះ បើគេប្រាថ្នាចង់សរសេរ សៀវភៅទាំងឡាយ ដែលអាចក្លាយជាប្រយោជន៍ឧត្តង្គឧត្តមក្នុង កម្មវិធីសិក្សាអប់រំ នោះគេនឹងប្រឹងស្រាវជ្រាវហើយ រួចក៏អាច សរសេរចងក្រងដោយចំណាប់ចំនួនបំផុត ព្រោះគេធ្លាប់មានការ ពិសោធន៍ខាងសរសេរតាំងពីក្មេងវ័យមក រួចស្រេចទៅហើយ ។ ពេលនោះ កូនរបស់យើងមិនត្រឹមតែមានការចេះដឹងខ្ពស់ទេ តែគេ អាចយកការចេះដឹងរបស់គេមកបំរើជាប្រយោជន៍ដល់បច្ឆាជនជាន់ ក្រោយ អោយបានរៀនសូត្រ បែកគំនិតចេះដឹងល្អៗបន្តទៅទៀត ផង ។ ពេលនេះ បងកំពុងតែ ទន្ទឹងចាំថ្ងៃមួយដែលជនសាមញ្ញ ក្រីក្រម្នាក់ដូចកូនរបស់យើងជាដើម អាចបណ្តុះខ្លួន អោយក្លាយទៅ ជាអ្នកប្រាជ្ញបណ្ឌិតបំរើសង្គមវិញយ៉ាងពូកែហើយយ៉ាងល្បីអស្ចារ្យ ។

- បងពិតជាគិតថា កូនយើងអាចទៅដល់កំរិតកំពស់ហ្នឹងទេបង ?
- បងជឿថាពិតជាដល់ ហើយបងនឹងប្រឹងប្រែងជួយណែនាំនិង លើកកម្លាំងចិត្តដល់កូនរបស់យើងអោយអស់សមត្ថភាព ។ ការពិត បងក៏ចង់ធ្វើដំណើរទៅមុខជាមួយកូនដែរ ចង់បណ្តុះវិជ្ជាអោយ រូបបងក្លាយជាបណ្ឌិតបរិញ្ញា ប៉ុន្តែស្រុកយើងនេះមិនមានកម្មវីធី សិក្សាណាដែលជ្រោមជ្រែងមនុស្សចាស់អោយរៀនបន្ត

CHANBOKEO.COM

ដូចជានៅ បស្ចឹមប្រទេសឡើយ ម្ល៉ោះហើយ បងក៏នៅទាល់តែត្រឹមកំរិតនេះ ទៅ ។ ម្យ៉ាងទៀត កូនចៅយើងក៏ធំពេញវ័យ ត្រូវការការទំនុក បំរុងអោយរៀនសូត្រទាំងថវិកានិងកម្លាំងចិត្ត ដូច្នេះបងត្រូវប្រគល់ អ្វីៗដែលបងរកបាន អោយទៅកូនយើងវិញ ដើម្បីបណ្តុះអនាគត របស់គេអោយល្អប្រសើរជាងបង ដែលមិនមានលទ្ធភាពអាចទៅ ឆ្ងាយបាន ថ្វីបើបងមានសមត្ថភាពយ៉ាងណាក៏ដោយ ។

- បងពិតជាគិតវែងឆ្ងាយណាស់ ។ ពេលនេះ អូនបានភ្លឺវិញហើយ ថាហេតុអ្វីបងជំរុញនិមលមិនឈប់ឈរសោះ ។ រីឯនិមលវិញក៏ដែរ អូនឃើញគេចាប់ប្អូនៗអោយរៀនសូត្រម៉ឹងម៉ាត់ណាស់ ។ កូនរបស់ យើងគ្រប់គ្នាគេខិតខំតាមគម្រូបងស្រីដោយយើងមិនបាច់ប្រើពេល វេលាដាស់តឿនច្រើន ។ គិតទៅ អូនគួរអរគុណបងជាងគេដែល មានវិធីដ៏មានប្រសិទ្ធភាពជំរុញកូនយើងអោយឈានទៅរកអនាគត គាប់ប្រសើរ ។

ទាំងពីរនាក់ក៏ញញឹមដាក់គ្នាឡើង កាលបើគេបានពិគ្រោះគ្នា យល់ជាក់ច្បាស់ពីគម្រោងជួយកូនអោយរៀនបានជោគជ័យ ។

ពីរបីថ្ងៃក្រោយមក...

និសាជិះកង់ត្រឡប់ពីរៀនមកដល់ផ្ទះវិញ ក៏រត់ទៅឱ្យបជំរាប ឪពុកម្តាយទាំងពីរនាក់ថា ៖

- ប៉ា! ម៉ាក់! ព្រឹកមិញនេះ មានសិស្សច្បងប្រុសម្នាក់ រៀន ស្រករៗគ្នានឹងបងនិមលដែរ បានពឹងអោយខ្ញុំយកទឹកអប់និងផ្កាម្លិះ រួតមួយទងទៅអោយបងនិមល ។ ខ្ញុំទទួលពីគាត់ហើយ តែមិន ហ៊ានយកទៅអោយបងនិមលទេ ព្រោះខ្លាចមិនសមរម្យ ទើបយក មកប្រគល់ជូនប៉ាម៉ាក់ពិគ្រោះ ។

លោកគ្រូសុធីសម្លឹងមុខភរិយា ។ បន្តិចមក មីងមណីក៏ស្រដី ប្រាប់និសា ជាកូនស្រីថា ៖

- ល្អហើយដែលកូនយកមកពិគ្រោះនឹងម៉ាក់ប៉ា ។ ប៉ុន្តែ នៅលើក ក្រោយ កូនកុំទទួលបញ្ញើអ្វីពីនរណាទៀត ឮហើយឬនៅ ?

- ចាស ម៉ាក់!

និសាក៏សុំខ្លួនចេញទៅវិញ ។ មួយស្របក់ក្រោយមក និមលក៏ ជិះកង់មកដល់ផ្ទះដែរ ដោយមានទិញអាហារកញ្ចប់ពីផ្សារមកផង៖

CHANBOKEO.COM

- ជំរាបសួរប៉ាម៉ាក់! (និមលលើកដៃសំពះកាលបើឃើញឪពុកម្តាយរបស់នាងចុះដណ្តើរមកដល់) ថ្ងៃនេះ កូនទៅប្រមូលលុយថ្លៃឈ្នួលសៀវភៅបានច្រើនគួរសម ក៏ទិញទាខ្វៃហាលនិងសាច់ជ្រូក ខ្វៃផ្ញើម៉ាក់ប៉ានិងប្អូនៗ ។

- អរគុណណាស់និមល ដែលកូនចេះនឹកមកដល់ម៉ាក់ប៉ានិងប្អូន ។

លោកគ្រូសុធីញញឹមឆ្លើយតបទៅកូនវិញ ។ បន្តិចមក និមល និងនិសាក៏ជួយគ្នារៀបអាហារថ្ងៃត្រង់ សំរាប់ឪពុកម្តាយនិងក្រុម គ្រួសារ ។ លុះបរិភោគរួចហើយសុធីនិងមណីក៏ហៅនិមលទៅ ក្នុងបន្ទប់របស់លោកដើម្បីនិយាយគ្នា ។ ពេលនោះ សុធីនិងភរិយាបានលួចសង្កេតកិរិយារបស់និមលជាកូន សព្វយ៉ាង ។

- និមល! ឆ្នាំនេះកូនមានពួកម៉ាកជិតស្និទ្ធទេ? (មីងមណីសួរ)

- ចាស៎មាន ម៉ាក់! កូនមានច្រើននាក់ណាស់! (និមលឆ្លើយ)

- ហើយចុះកូនមានមិត្តពិសេសទេ? (ឪពុកនាងសួរបន្ថែម)

- មិត្តរបស់កូន សុទ្ធតែពិសេសផ្សេងៗគ្នា ។ ប៉ាម៉ាក់ចង់ស្គាល់មួយ ណា ចាស៎?

- គឺ ចង់ស្គាល់ទាំងអស់ ទាំងប្រុស ទាំងស្រី ។

- មិត្តក្នុងថ្នាក់ ខាងពិគ្រោះគ្នារៀន មានពីរនាក់ ប្រុសមួយស្រីមួយចំណែកមិត្តខាងសរសេរប្រកួតថ្មីដៃនិពន្ធ មកពីសាលាផ្សេងមាន ពីរនាក់ដែរ ប្រុសទាំងពីរ ។ ចំណែកមិត្តជិះកង់ទៅរៀនរាល់ព្រឹក ជាមួយគ្នាមានម្នាក់ជាស្រី ។ គេជាមនុស្សល្អណាស់ ។

- ហើយចុះមិត្តប្រុសទាំងនោះមានដែលបញ្ចេញលក្ខណៈឥរិយាបថអ្វីចំពោះកូនអោយលើសពីមិត្តសម្លាញ់ទេ?

- មិនមានទេ ប៉ា! មានតែសិស្សដែលរៀននៅសាលាផ្សេង ចូលចិត្តមកឈរលែបខាយដាក់ខ្ញុំនិងសារៀងមិត្តស្រីរបស់ខ្ញុំដែលជិះកង់ ទៅរៀនជាមួយគ្នារាល់ព្រឹក ។ នឹកៗទៅ ខ្ញុំហាក់ដូចជាស្អប់ចរិត ពួកប៉ុន្មាននាក់នោះណាស់ ប៉ុន្តែខ្ញុំប្តឹងសាលាមិនកើត ព្រោះសិស្ស ទាំងនោះ ប្រព្រឹត្តអំពើឆ្គាំឆ្គងនោះ នៅក្រៅសាលាពេលយើងជិះ កង់ទៅរៀន ។

- អូហ៍? ហើយគេធ្វើយ៉ាងម៉េចខ្លះដែលកូនមិនចូលចិត្តនោះ?

- គេវាយភ្នែក ញាក់ចិញ្ចើម សរសេរសំបុត្រស្នេហាមកហុចអោយ

CHANBOKEO.COM

ហើយយកទឹកអប់យកផ្កាមកផ្ញើ ។ អូហ៍! មែនហើយ ព្រឹកមិញ នេះ មានម្នាក់គេយកផ្កានិងទឹកអប់ម៉ាកូនដបតូច មកអោយខ្ញុំទៀត ផង តែខ្ញុំមិនទទួលទេ ហើយក៏ដើរគេចចូលថ្នាក់រៀនទៅ ។

ពេលនោះ សុធីភ្ញាក់ព្រើតលួចមើលមុខប្រពន្ធ ហើយក៏បែរមក កូនស្រី រួចសួរថា ៖

- តើមូលហេតុអ្វីដែលធ្វើអោយកូនប្រកែក មិនទទួលយកផ្កា និង ទឹកអប់ដែលគេយកផ្ញើមកអោយ ? កិរិយានេះមានន័យថាគេកំពុង បង្ហាញសេចក្តីស្រឡាញ់របស់គេចំពោះកូន មិនមែនទេ ?

ស្រាប់តែនិមលសើចខឹកៗឡើង ឆ្លើយថា ៖

- ព្រោះនិមលមិនចូលចិត្តទឹកអប់ មិនចូលចិត្តផ្កាតាំងពីដើម ហើយ ម្យ៉ាងទៀត យើងជាកូនសិស្សនៅរៀន មិនគួរណានឹងយកពេលទៅ គិតអ្វីផ្ដេសផ្ដាសក្រៅពីរឿងរៀនទេ ។ ផ្កានិងទឹកអប់អាចធ្វើអោយ នារីខ្លះវង្វេងនឹងអត្ថន័យក្លែងក្លាយរបស់វា រួចហើយក៏លះបង់ សេចក្តីថ្លៃថ្នូររបស់ខ្លួន ជាសិស្សល្អក្នុងសាលា ជាកូនល្អរបស់ឪពុក ម្ដាយ មកទទួលយកការលួងលោមពីយុវជនក្មេងៗដែលកំពុងភ្លើត ភ្លើនទៅតាមកាមារម្មណ៍យុវវ័យ ដែលមានតម្លៃត្រឹមតែផ្កាមួយទង និងទឹកអប់មួយដប ។ ប៉ុន្តែចំពោះនិមលវិញ ទង្វើទាំងនោះធ្វើឲ្យ និមលគិតថា យុវជននោះកំពុងវាយតម្លៃយ៉ាងថោកដល់អនាគត របស់និមល អោយចុះធ្លាក់ស្មើត្រឹមតែតម្លៃផ្កាមួយទង និងទឹកអប់ មួយដបនោះ ។ ដូច្នេះ និមលមិនព្រមទេ ព្រោះគិតថា ជីវិត អនាគតរបស់ខ្ញុំមានតម្លៃខ្ពស់ជាងនោះឆ្ងាយហៅមិនឮ ។ ខ្ញុំមិនចង់ ទទួលផលតិចតួច ត្រឹមតែទឹកអប់មួយដប ផ្កាមួយទង និងការលួច ស្រលាញ់គ្នាពីក្រោយខ្នងឪពុកម្ដាយឬសង្គមទេ ។ ខ្ញុំចង់បានទទួល ផលដែលមានទំហំជាងនេះច្រើនដងទៀត ដូចជាសញ្ញាបត្រនិង ប្រាក់បៀវត្ស ព្រមទាំងសេចក្តីស្រឡាញ់ពីបុរស ដែលក្រុមគ្រួសារ និងសង្គមទទួលស្គាល់យ៉ាងពេញមុខថ្លៃថ្នូរ ។ ពេលនោះ និមល អាចងើបមើលមុខនរណាក៏បាន ដោយមិនបាច់នឹកគិតភ័យថាសង្គម សើចយំចំអករឿងអ្វីឡើយ ។

ឮប្រយោគនេះ លោកគ្រូសុធីញញឹមយ៉ាងស្រស់ដាក់កូនវិញ តែម្ដង រួចក៏មានប្រសាសន៍ថា ៖

- ហើយចុះកូនមានយកទ្រឹស្តីរបស់កូនមួយប្រយោគនេះ ទៅដាក់ ក្នុងសៀវភៅដែលកូនសរសេរទេ ។ ប៉ាគិតថា សិស្សនារីក្នុងសាលា

CHANBOKEO.COM

គួរតែបានអានហើយទទួលនូវឧត្តមគតិមួយនេះពីកូនគ្រប់ៗគ្នា ។
- ចា៎ស ប៉ា! នៅក្នុងសំណៅខែក្រោយ ខ្ញុំនឹងបញ្ចូលសាច់រឿង ដើម្បីអោយក្មេងស្រីខ្លះទៀត បានយល់ហើយឈប់វង្វេង នឹងល្បិច ល្បួងចិត្តរបស់យុវជន អោយភ្លើតភ្លើនភ្លេចការសិក្សា ។

កាលបើកូនស្រីបានឆ្លើយយ៉ាងល្អអស់ទៅហើយ លោកគ្រូក៏ មិនសួរអ្វីទៀតដែរ ក្រៅតែពីសរសើរនិងលើកកម្លាំងចិត្តរបស់កូន បន្ថែមទៀតប៉ុណ្ណោះ ៖
- ប្រសើរណាស់កូនដែលកូនអាចប្រព្រឹត្តអ្វីដោយមនសិការខ្ពង់ខ្ពស់ មិនចាំបាច់អោយប៉ាម៉ាក់តាមមើលកូនគ្រប់ជំហាន ។ ប៉ាគិតថា កូនស្រីរបស់ប៉ានឹងក្លាយជាជំហររបស់គ្រួសារយ៉ាងមាំមួន ពេលណាអត់ ពីប៉ាម៉ាក់ទៅ ។

*ooooooooooooooooo*

*ooooo*

*o*

CHANBOKEO . COM

# វគ្គទី១២

# ព្រាបស

ថ្វីបើលោកគ្រូសុធីបានចេញធ្វើការយូរឆ្នាំមកហើយក្តី ក៏លោក នៅតែបន្តការសិក្សាជានិច្ច ។ ពេលនេះ លោកបានត្រូវក្រសួង សិក្សាធិការតម្លើងថាននូរសក្តិទៅជាសាស្ត្រាចារ្យ ហើយបានផ្លាស់ ទៅធ្វើការនៅឯវិទ្យាល័យអាិបយុតវិញ ព្រោះលោកគ្រូមិនត្រឹមតែ បង្រៀនសិស្សយ៉ាងជំនាញតែម្យ៉ាងនោះទេ ប៉ុន្តែលោកក៏បានរៀន សូត្រខ្លួនឯងបន្ថែមរាល់ៗឆ្នាំដែរ ។ ចំណែកសិស្សដែលរៀននៅ ថ្នាក់ដែលលោកគ្រូបង្រៀននៅសាលាបឋមសិក្សា សុទ្ធតែបាន ប្រឡងជាប់ចូលអនុវិទ្យាល័យក្នុងពិន្ទុគាប់ប្រសើរគ្រប់ៗគ្នា ដែល ជាហេតុធ្វើអោយសិស្សសាលា ឪពុកម្តាយរបស់សិស្ស និងក្រសួង សិក្សាធិការខេត្ត ពេញចិត្តនឹងថ្វីដៃលោកគ្រូឥតឧបមា ។

តាំងពីឆ្នាំ១៩៦៨មក លោកគ្រូសុធីក៏ចាប់ផ្តើមបង្រៀនសិស្ស ត្រៀមប្រឡងឌីប្លូម នៅវិទ្យាល័យអាិបយុត ព្រមទាំងនៅវិទ្យាល័យ ឯកជនឈ្មោះត្រៃមិត្រ និងវិទ្យាល័យសង្កែទៀតផង ។ នៅល្ងាចថ្ងៃ រៀន លោកគ្រូទៅបង្រៀនតាមផ្ទះអភិជន ។ ចំណែក នៅថ្ងៃ អាទិត្យ លោកបង្រៀនថ្នាក់ពិសេសនៅឯផ្ទះរបស់ខ្លួន ដោយមាន សិស្សចូលរៀនរាប់រយនាក់មកចូលរៀនរាល់ខែមិនដែលខាន ។

ដោយសារតែជោគជ័យទាំងនោះ លោកក៏រកប្រាក់ចំណូលបាន ច្រើនជាងគ្រូបង្រៀនធម្មតា ។ មិនតែប៉ុណ្ណោះ ចំណេះប្រាជ្ញរបស់ លោក បានធ្វើអោយកូនៗទាំងអស់ ក្មេងៗដែលសុធីទំនុកបំរុង ព្រមទាំងសិស្សទាំងឡាយដែលសុធីបង្រៀន បានទទួលនូវការណែ នាំល្អៗ ការចេះដឹងកាន់តែច្រើន ខាងមុខវិជ្ជាដែលខ្លួនកំពុងរៀន ព្រមទាំងទទួលនូវល្បិចរៀន ដែលមានប្រសិទ្ធភាពពីសុធីទៀត ផង ។ ក្រោយមក ក្មេងទាំងឡាយនោះក៏បានក្លាយទៅជាបញ្ញវន្ត័ មានការធ្វើខ្ពង់ខ្ពស់ ហើយភាគច្រើនក៏បានវិលមកសំពះថ្លែងអំណរ គុណ លោកគ្រូសុធីដោយផ្ទាល់ទៀតផង ។

CHANBOKEO.COM

លទ្ធផលទាំងនេះ បាន ធ្វើអោយលោកមានមោទនភាពណាស់ ព្រោះបានបណ្តុះក្មេងជាច្រើនអោយមាន ការចេះដឹង ហើយទទួលយកអនាគតល្អប្រសើរ ។ ឯកេរ្តិ៍ឈ្មោះរបស់សុធីក៏កាន់តែបោះសម្លេងសុះសាយគ្រប់ទីកន្លែង នៅក្នុងខេត្ត ។

ថ្ងៃ១៨មិនា១៩៧០...

កម្ពុជាបានបើកទំព័រប្រវត្តិសាស្ត្រថ្មី ដែលមានលោកឧត្តម សេនិយលន់នល់ជាអ្នកដឹកនាំធ្វើរដ្ឋប្រហារមួយ ផ្តួលរំលំរបបលទ្ធិ រាជានិយមរបស់សម្តេចនរោត្តមសីហនុ រួចហើយប្រតិស្ឋនាមថ្មី អោយកម្ពុជាថា សាធារណរដ្ឋខ្មែរ ដោយមានបំណងឃោងចាប់យកលទ្ធិសេរីនិយមអាមេរិកាំង ធ្វើជាគោលដំហរ ។ កាលនោះ សិស្សានុសិស្សទាំងឡាយនៅក្នុងខេត្ត ក្នុងក្រុង ព្រមទាំងគ្រូៗនិង សាស្ត្រាចារ្យបានត្រូវរដ្ឋាភិបាលកេណ្ឌអោយចូលហាត់កុម្មង់ដូគ្រប់ៗ គ្នា ។ និមលក៏បានជាប់កំណេណ្ឌនឹងគេដែរ ហើយបានចូលហាត់ រៀនហ្វឹកហ្វឺនជាសិស្សកុម្មង់ដូនៅវាលបែកចានបាត់ដំបង ។ រីឯ លោកគ្រូសុធីក៏ត្រូវរដ្ឋការកេណ្ឌអោយចូលបំរើកងទ័ពម្តងម្កាលនៅ

ពេលណាដែលរដ្ឋាភិបាលតម្រូវ ។

នន្ទនិងនេត ព្រមទាំងក្មេងដែលរស់នៅជាមួយលោកគ្រូសុធីបី នាក់ទៀត បានប្រលងជាប់មធ្យមសិក្សាហើយនាំគ្នាចេញទៅរៀន នៅភ្នំពេញអស់ នៅសល់តែកូនរបស់លោកគ្រូប្រាំនាក់ កូនចិញ្ចឹម ម្នាក់ និងសាច់ញាតិសន្តានមួយរយ ពីរបីនាក់ទៀត ។

នៅវេលាព្រឹកមួយ...

លោកគ្រូសុធីកំពុងអង្គុយធ្វើការ នៅក្នុងការិយាល័យ ស្រាប់តែឮសូរភាពអ៊ូអរអឺងកងនៅក្នុងបរិវេណសាលា ។ លោកគ្រូយើងក៏ រត់ចេញទៅមើលសភាពការណ៍ ស្រាប់តែប្រទះឃើញសិស្សនិស្សិត យុវជនយុវនារីកំពុងប្រមូលគ្នាដើរចេញពីសាលា ធ្វើចលនាបាតុកម្ម លើកបដាស្រែកហ៊ោរលាន់គ្រេវៗ មិនដឹងថាសិស្សទាំងនោះធ្វើ បាតុកម្មដើម្បីអ្វីទេ ។ រំពេចនោះ លោកគ្រូយើងក៏ក្រឡេកឃើញ កូនស្រីនិមល និងនិសារត់សំដៅមករកលោក ។

- និមល ! និសា ! កូនកុំទៅដើរហែបាតុកម្មតាមគេអី ! !

- ហេតុអ្វីទៅ ប៉ា ? (និមលសួរ)

CHANBOKEO.COM

- មើលហ្ន៎! កូនមិនឃើញទេ ? សិស្សច្បង សិស្សប្អូនទាំងឡាយ
នោះកំពុងតែជះអំពើហឹង្សាទៅលើអ្នកស្រុកសាមញ្ញហើយ ។ គេ ដុតឡាន ដុតកង់ ចូលផ្ទះផ្សារវើអីវ៉ាន់របស់អ្នកលក់ យកទៅដុត ពាសថ្នល់ តើបានប្រយោជន៍អ្វី ? ពួកអ្នកស្រុកទាំងនោះមិនមែន ជាអ្នកដឹកនាំនយោបាយឯណា ម្តេចក៏កូននាំគ្នាបះបោរបំផ្លាញអ្នកស្រុកសាមញ្ញធម្មតាទៅវិញ ? ធ្វើដូច្នោះគឺជាការបំផ្លាញអ្នកស្រុក អ្នកភូមិខ្លួនឯង បំផ្លាញជាតិឯងណា៎កូន ។ ម្យ៉ាងទៀត កូនជាសិស្ស មិនទាន់ពេញវ័យគ្រប់១៨ឆ្នាំទេ ។ កូនស្ថិតនៅក្រោមឱវាទនិងការ ឃុំគ្រងរបស់ឪពុកម្តាយ ។ បើនឹងធ្វើអ្វី ប្រព្រឹត្តអ្វី ចូរកូនពិគ្រោះនឹងឪពុកម្តាយសិន មិនមែនស្តាប់មិត្តភក្តិហើយក៏ធ្វើតាមគ្នាទាំង ភ្ញក់ផ្អើលមិនមើលមុខក្រោយ ដូចសត្វទន្សាយនោះឡើយ ។

និមលនិងនិសានៅស្ងៀម មិនហ៊ានមាត់ទេ បន្តិចមកក៏នាំបង
ប្អូនវិលទៅសំកុកនៅថ្នាក់រៀនវិញរៀងៗខ្លួន ។ លុះត្រឡប់មកផ្ទះ វិញ និមលក៏សួរឪពុកនាងថា ៖

- ហេតុអ្វីលោកប៉ាមិនគាំទ្របាតុកម្មរបស់សិស្ស ? ខ្ញុំឃើញសិស្ស
ច្បងមកពីសកលវិទ្យាល័យបាត់ដំបង ដែលជាប្រធានសមាគម និស្សិតខែត្រមានប្រសាសន៍ថា គេធ្វើនោះដើម្បីប្រឆាំងនឹងអំពើពុក រលួយដែលមាននៅក្នុងជួររដ្ឋាភិបាល ។

លោកគ្រូសុធីញញឹមហើយឆ្លើយថា ៖

- ប៉ាបានឆ្លើយកូនរួចហើយ កាលពីព្រឹកមិញ ទីមួយ ប៉ាមិនចូល
ចិត្តដំណោះស្រាយដែលប្រើហឹង្សានិងការបំផ្លិចបំផ្លាញទេ ។ ទីពីរ អ្នកស្រុកទាំងនោះ
ក៏មិនមែនជនមានអំណាចនៅក្នុងជួររដ្ឋាភិបាល ដែរ
ហេតុអ្វីក៏ត្រូវទទួលទោសពីសិស្សជំនួសរដ្ឋាភិបាលផង ? ទីបី
ក្នុងឱកាសដែលស្រុកវឹកវរដោយសង្គ្រាម ម្តេចមិនសាមគ្គីគ្នាទៅ កំចាត់បច្ចាមិត្ត ? ហេតុអ្វីមកធ្វើបាបតែគ្នាឯងតូចតាចអត់កាំភ្លើង អត់អំណាច អត់បុណ្យសក្តិទៅវិញ ?

- ហើយចុះប៉ាប្រកាន់ទស្សនៈនយោបាយបែបណាដែរទៅ ?

- ប៉ាគ្រាន់តែជាគ្រូបង្រៀនសាមញ្ញម្នាក់ ដែលប្រាថ្នាត្រឹមតែនៅ
បង្រៀនសិស្សអោយគេបានទទួលចំណេះចេះដឹងមុតមាំសំរាប់ឈាន រកអនាគតល្អ ។ ប៉ាជាមនុស្សដែលមិនចូលចិត្តអំពើហឹង្សា ហើយក៏
មិនគាំទ្រអំពើហឹង្សាគម្រាមកំហែងលើជីវិតប្រជាពលរដ្ឋដែរ ។ ប៉ា មានជំនឿលើលទ្ធិណា

CHANBOKEO.COM

ដែលផ្តល់សេរីភាពដល់ប្រជាពលរដ្ឋអោយ រស់នៅសុខសប្បាយហើយមានសុវត្ថិភាព ដោយជំរុះចោលនូវ
អំពើជិះជាន់ធ្វើបាបគ្នាដោយអំណាចហឹង្សា តែប៉ុណ្ណឹងឯង ។
និមលអង្គុយស្តាប់ឪពុកផង សរសេរទុកផង នូវអ្វីដែលលោកមានប្រសាសន៍ប្រាប់នាងទាំងអំបាលម៉ាន ។
នៅរវាងពីរអាទិត្យក្រោយមក លោកគ្រូសុធីបាននាំកូនទៅ ភ្នំពេញ ដើរមើលសាលា ជួនចំពេលដែលសិស្សានុសិស្សនិងនិស្សិត កំពុងធ្វើបាតុកម្មជាថ្មីម្តងទៀត ។ លោកគ្រូក៏បាននាំកូនស្រីដើរគេច ព្រឹត្តិការណ៍ទាំងនោះ នៅពេលដែលនិមលនៅមានចិត្តព្រើលចង់ទៅរកអើតមើលគេ ដើម្បីអោយបានដឹងថា តើសាស្ត្រាចារ្យនិងសិស្សនិស្សិតទាំងឡាយនោះធ្វើបាតុកម្មដើម្បីអ្វី ។ ស្រាប់តែឪពុក នាងឃាត់ភ្លាម ៖
- កុំទៅអីកូន! យើងធ្វើដំណើរមកភ្នំពេញនេះ ដើម្បីមកមើលសាលាមហាវិទ្យាល័យដែលកូនបំរុងនឹងចូលរៀន មិនមែនមកមើល គេហែបាតុកម្មទេ ។
- ចាស ប៉ា!
- អញ្ចឹង កុំទាន់បែកអារម្មណ៍អី! យើងធ្វើការយើងសិនទៅ ។
និមលមិនហ៊ានប្រកែក ក៏នៅស្ងៀមដើរតាមក្រោយឪពុកតទៅ ទៀត ។ ថ្ងៃដន្យមហាវិទ្យាល័យក៏បិទទ្វារ មិនមានគ្រូមកធ្វើការទេ ព្រោះខ្លះបានទៅហែបាតុកម្ម ខ្លះក៏ឈប់នៅផ្ទះរង់ចាំមើលស្ថាន ការណ៍ ។ ដោយសារភាពជ្រួលច្របល់ពេញភ្នំពេញ រវាងសិស្ស គ្រូនិងរដ្ឋាភិបាល លោកគ្រូសុធីក៏សំរេចចិត្តនាំនិមលត្រឡប់ទៅ ផ្ទះ ហើយប្រកែកដាច់អហង្ការ មិនអោយកូនទៅពិនិត្យតាមដាន សកម្មភាពបាតុកម្មទាំងឡាយនោះឡើយ ដោយសំអាងថាលោកមិន
ចូលចិត្តអំពើហឹង្សានិងជម្លោះក្នុងផ្ទះ រវាងខ្មែរនិងខ្មែរ ។
លុះត្រឡប់មកដល់ផ្ទះវិញ លោកក៏មានអារម្មណ៍មិនល្អ អស់ជា យូរថ្ងៃ ព្រោះគិតបារម្ភពីកូនស្រីនិមលដែលបានបញ្ចេញឫកពាហាក់ដូចជាកំពុងឆ្លងវ័យពីយុវនារីក្រោមបន្ទុកឪពុកម្តាយ ទៅជា យុវតីដែលមានឯករាជ្យម្ចាស់ការផុតពីការឃុំគ្រងរបស់ឪពុកម្តាយ នៅរវាងពេលដ៏ខ្លីខាងមុខនេះ
បន្ទាប់ពីនាងត្រូវប្រឡងជាប់មធ្យម សិក្សាបត្រ ។ លោកគ្រូយើងកំពុងភ័យព្រួយក្រែងកូនស្រីដើរ ចូលសង្គមសិស្សនិស្សិត ធ្វើចលនាបាតុកម្មអ្វីៗនៅក្នុងប្រទេស

CHANBOKEO.COM

ដែលអាចបង្កជាអំពើហឹង្សាបំផ្លាញដល់អ្នកដទៃដែលជាខ្មែរសាមញ្ញ ដូចគ្នា ។ លោកបានពិគ្រោះនឹងភរិយាអំពីរឿងរបស់និមល ដោយ មានគំរោងចង់បញ្ចៀសកូនស្រី អោយផុតពីការចូលជាប់ជំពាក់វាក់ វិនជាមួយភាពវឹកវរផ្នែកនយោបាយនៅក្នុងប្រទេសខ្មែរ ។ កាល នោះ លោកគ្រូនិងភរិយាគិតថា ចង់បញ្ជូននិមលអោយទៅរៀននៅ បារាំង ឬនៅអាមេរិក ដើម្បីទទួលយកឧត្តមសិក្សាជំនួសវិញ ។

កាលបើឃើញឪពុកធ្វើទឹកមុខក្រៀមក្រំ និមលក៏ចូលទៅជួប ឪពុកនៅថ្ងៃទំនេរមួយ ដោយមានម្តាយនាងនិងប្អូនទាំងបួននាក់ នៅទីនោះផង ៖

- ជំរាបប្រសាសន៍ ប៉ា! និមលគិតថា មិនទៅរៀននៅភ្នំពេញទេ ពេលកូនបញ្ចប់មធ្យមសិក្សាហើយ ។

លោកគ្រូនិងភរិយាភ្ញាក់ក្រញាងតែម្តង កាលបើឮកូននិយាយ ដូច្នោះ ។

- ហើយចុះកូនចង់ធ្វើអ្វីវិញទៅ ? (មីងមណីសួរ)
- ខ្ញុំគិតថានៅរៀនសកលវិទ្យាល័យបាត់ដំបងនេះ ឬក៏ទៅរៀននៅ អាមេរិក បើសិនជាប៉ាម៉ាក់អាចជួយកូនបាន ។
- ហេតុអ្វីក៏កូនដូរចិត្តទៅវិញអញ្ចឹង ហ៎ាសកូន ?
- ព្រោះកូនចេះអង់គ្លេសស្ទាត់ជំនាញ ម្ល៉ោះហើយចង់យកប្រាជ្ញ របស់កូនទៅប្រដេញនឹងសិស្សនៅអាមេរិកមើល ថាតើកូនអាចមាន សមត្ថភាពរៀនទាន់យុវជនជនជាតិបស្ចឹមប្រទេសឬទេ ។ ម្យ៉ាង ទៀត ខ្ញុំក៏ចង់ក្លាយខ្លួនជាមនុស្សល្អម្នាក់សំរាប់បំរើជាតិខ្មែរវិញដែរ មិនឲ្យកើតមកហើយដកដង្ហើមចោលឥតប្រយោជន៍នោះទេ ។ ប៉ុន្តែ បើប៉ាមិនមានលទ្ធភាពអាចជួយឧបត្ថម្ភកូនបានទេ កូនសូមចូលរៀន នៅសកលវិទ្យាល័យបាត់ដំបងយើងនេះ រកជំនាញខាងវិស្វកម្មអ្វី ក៏បានដែរ ព្រោះកូនរៀនខាងគណិតវិទ្យានិងរូបវិទ្យាពូកែចំណាប់ ចំនួនណាស់ ។ កូនគិតថា កូនអាចរៀនខាងមុខផ្នែកនេះបាន ។
- ហើយចុះកូនមិនចង់ទៅរៀននៅភ្នំពេញទេ ? (លោកគ្រូសួរ)
- ចា៎ស មិនសូវចង់ទេ ប៉ា! នៅភ្នំពេញ មនុស្សច្រើនអ៊ូអរហើយ ប្រកាន់វណ្ណៈអ្នកមានអ្នកក្រណាស់ ។ ម្យ៉ាងទៀត ពេលនេះ ស្រុក យើងកើតសង្គ្រាម សភាពជ្រួលច្របល់កើតមានព្រឹកល្ងាចញឹកញាប់ រហូតដល់សាលាត្រូវបិទទ្វារច្រើនជាងបើក ។

CHANBOKEO.COM

តើយើងរៀនអ្វីនឹង ចេះទៅ កាលបើសិស្សនិស្សិតនិងគ្រូៗអាល័យតែយកពេលវេលា ទៅហែបាតុកម្មអស់ទៅហើយនោះ ?

ឃើញចម្លើយនិងឫកពាររបស់កូនស្រី ហាក់ដូចជាចាស់ទុំគួរឲ្យ ទុកចិត្តបាន លោកគ្រូក៏បាត់ជ្រួលច្របល់នៅក្នុងចិត្តបន្តិច ។ នៅ រាត្រីដដែលនោះ លោកគ្រូសុធីបានពិគ្រោះជាមួយភរិយា ដើម្បី បញ្ជូនកូនទៅរៀននៅអាមេរិក ៖

- យើងខើចលុយណាស់បង! ប្រហែលជាទៅមិនរួចទេដឹង ?
- បងគិតថានឹងខំធ្វើការបន្ថែម ហើយជួយរកមធ្យោបាយឲ្យនិមល ប្រឡងយកអាហារូបករណ៍មកជួយថែមខ្លះទៀត ប្រហែលជាអាច ទៅរួចហើយ..

ពិតមែនតែលោកគ្រូមិនមែនជាអ្នកមាន តែជីវភាពរបស់លោក នៅពេលនេះ ក៏នឹងនួនល្មមអាចបញ្ជូនកូនម្នាក់អោយទៅរៀននៅ បរទេសបាន ។ លោកគ្រូក៏សំរេចចិត្តជាមួយភរិយាស្ងាត់ៗថា នឹង លក់រថយន្តរបស់លោក និងដីធ្លីមួយដុំដែលលោកបានទិញទុកមក ជាយូរហើយ ដើម្បីយកទុកឲ្យនិមលចេញទៅបរទេស បន្តការ សិក្សារបស់នាង ។

ព្រឹកស្អែកឡើង...

មានទាហានពលទោម្នាក់ជិះម៉ូតូមកជំរាបលោកគ្រូ ឲ្យទៅជួបជុំ គ្នានៅឯសាលាជាការប្រញាប់ ។ លុះលោកគ្រូសុធីយើងប្រញិប ប្រញាប់ធ្វើដំណើរចេញទៅដល់សាលា ស្រាប់តែបានទទួលបញ្ជា មកពីសាលាខេត្តថា លោកគ្រូៗចំនួន៥០នាក់ពីសាលានិមួយៗ ត្រូវ ជាប់កំណេណ្ឌអោយចូលធ្វើទាហាន ដើម្បីទៅវាយខ្មែរក្រហមនៅភ្នំ វាយចាបនិងនៅភ្នំធិបតី ។ លោកគ្រូសុធីក៏ជាមនុស្សម្នាក់ ដែល ត្រូវជាប់កំណេណ្ឌដែរ ។ ការពិត លោកមិនដែលមានការហ្វឹកហ្វឺន ខាងទាហានអោយបានមួយថ្ងៃទេ ។ កាលបើត្រូវរដ្ឋាភិបាលកេណ្ឌ យ៉ាងទាន់ហន់តក្កហលដូច្នោះ លោកគ្រូសុធីធ្វើមុខស្លូតរកនិយាយ អ្វីក៏មិនចេញមួយម៉ាត់ឡើយ ។ បន្ទាប់មក លោកគ្រូយើងក៏ទទួល យកឯកសណ្ឋានពីនាយពល តែប្រកែកមិនព្រមទទួលកាំភ្លើងទេ ។ នៅរាត្រីនោះ លោកគ្រូសុធីបានហៅកូនទាំងអស់មកជួបជុំគ្នាហើយ ពោលផ្តែផ្តាំថា ៖

- កូនសម្លាញ់ប៉ា! ពេលនេះ ប៉ាកំពុងជាប់កំណេណ្ឌ ដោយមិនអាច ប្រកែកបាន ។ ស្អែកនេះ ប៉ាចេញដំណើរទៅហើយ សូមកូនជួយ មើលម៉ាក់ផងណា៎! កុំធ្វើអ្វីអោយម៉ាក់មិនសប្បាយចិត្ត

CHIANBOKEO.COM

ហើយកុំភ្លេច អុជធូបជូនដំណើរប៉ាផង! បើប៉ាមានវាសនាខ្ពស់ ប៉ានឹងវិលមក
ឃើញមុខកូនគ្រប់គ្នាជាថ្មីវិញមិនខាន ។

យប់នោះ គ្មាននរណាបានឆ្មេចមួយស្រឡេតទេ សូម្បីតែប្អូន តូចៗរបស់និមល
ក៏ទទួលអារម្មណ៍ថា គេកំពុងឆ្លងកាត់វិយោគក្នុង អារម្មណ៍មិនតិចឡើយ
ដែលឪពុករបស់គេត្រូវធ្វើដំណើរចេញទៅ
បំរើកងទ័ពនៅពេលស្អែកនេះ ។

ព្រហាមឡើង មីងមណីបាននាំកូនជូនដំណើរប្ដីរហូតដល់បន្ទាយ ទាហាន ។
មុននឹងឡើងរថយន្តចេញទៅ លោកគ្រូសុធីដោះសក្តិពី ស្មាហុចអោយទៅប្រពន្ធហើយស្រដីថា ៖
- រូបបងមិនសក្តិសមនឹងពាក់សក្តិនេះទេ ព្រោះបងមិនដែលហ្វឹក
ហ្វឺនផ្នែកទាហានម្ដងណាសោះ ។ ប្រហែលជាគេបំពាក់សក្តិធំៗឲ្យ បង
ដើម្បីលោមចិត្តបងអោយរំភើបសប្បាយ ហើយភ្លេចនូវការ
ព្រាត់ប្រាស់ពីកូនប្រពន្ធហើយមើលទៅ ។ សូមអូនយកទុកឯផ្ទះ ផងណា!
ចាំបងសុំគេធ្វើជាកូនទាហានសាមញ្ញធម្មតាចុះ ព្រោះបង មិនចង់យាយីប្រហារជីវិតនរណាទេ ។

កងទាហានកំលោះណ្ណនៅទីនោះ នាំគ្នាសម្លឹងមើលមុខលោកគ្រូ យើងព្រោងព្រាត
ដែលឃើញលោកដោះសក្តិធ្វើអោយប្រពន្ធទុក នៅផ្ទះ ។ បន្តិចមក រថយន្តក៏ចេញដំណើរទៅ
ទុកអោយមីងមណី ឈរកាន់ដៃកូន បក់បោយដៃលាប្ដីទាំងទឹកភ្នែក ដោយក្ដីអួលណែន ក្នុងចិត្ត
ព្រោះមីងមណីមិនដែលបែកលោកគ្រូសុធីមួយថ្ងៃទេ តាំង ពីបានរួមរស់ជាគូស្វាមីភរិយាមក ។
នេះជាលើកដំបូងហើយ ដែល មីងបែកឃ្លាតលោកគ្រូ តើគាត់ត្រូវបែកគ្នារហូត ឬក៏យ៉ាងណា?

ភ្លាមនោះ មីងមណីស្រក់ទឹកភ្នែកខ្លាំងឡើងៗ ហើយក៏ទន់ដៃ ទន់ជើងរសេះរសោះ
ដួលសន្លប់បាត់ស្មារតីនៅទីធ្លាវាលបន្ទាយ នោះទៅ ។ និមលឃើញដូច្នោះភិតភ័យណាស់
ក៏រត់ទៅហៅរ៉ឺម៉ក ដឹកម្ដាយនឹងប្អូនត្រឡប់មកផ្ទះវិញយ៉ាងលឿន ដោយមានអ្នកស្រុក
ជិតខាងជួយនាង ពីមុខពីក្រោយផង ។

ចាប់តាំងពីថ្ងៃនោះមក និមលក៏ក្លាយជាមេគ្រួសារទទួលខុស
ត្រូវលើអ្វីទាំងអស់សព្វយ៉ាងជំនួសឪពុករបស់នាង ។

និយាយអំពីលោកគ្រូសុធីវិញ...

តាមផ្លូវ មិត្តភក្តិនិងគ្រូៗប្អូនៗជំនាន់ក្រោយនាំគ្នាសើចចំអន់ អោយលោកគ្រូថា ៖
- ហេតុអ្វីក៏បងដោះសក្តិចោល? ខ្លាចមិនហ៊ានច្បាំងជាមួយខ្មែរ ក្រហម មែនទេ?

CHANBOKEO.COM

ម្នាក់ទៀតនិយាយថា ៖
- ធ្វើជាប្រុសនឹងគេដែរ ហេតុអ្វីក៏គ្មានចិត្តក្លាហានជាកូនប្រុសដូច គេឯងអញ្ចឹង បងធី ?
បុរសទីបីនិយាយថា ៖
- បើសិនមិនចង់ធ្វើទាហានទេ ហេតុម្ដេចក៏ឡើងឡានមកធ្វើអី ?
ម៉េចមិននៅសំកុកឯផ្ទះឯណោះទៅ ល្បងឯងនេះ ?

លោកគ្រូយើងមិនតបតនឹងនរណាមួយម៉ាត់ទេ ។ ការពិតពេល នេះ លោកគ្រូមានវ័យសែសិបប្លាយទៅហើយ តើអោយមានចិត្ត ស្ដុយប្រថុយជីវិតដូចក្មេង១៨-១៩ឆ្នាំនោះឯណាបាន ? ម្យ៉ាងទៀត លោកគ្រូកំពុងគិតថា ៖
- ការធ្វើសង្គ្រាមតែងតែមានការសម្លាប់ជីវិតមនុស្ស... តើគួរ អោយឈឺចាប់យ៉ាងណា បើសិនជាជនរងគ្រោះជាខ្លួនយើង ឬជា សមាជិកក្រុមគ្រួសាររបស់យើង ? ហេតុអ្វីទៅហ្ន៎ បានមនុស្សចូល ចិត្តធ្វើសង្គ្រាមប្រល័យគ្នាដូច្នេះ ? ហេតុអ្វីបានជាគេមិនព្រមដោះស្រាយគោលនយោបាយ ដោយសន្តិវិធី ដើម្បីរក្សាជីវិតប្រជាពល រដ្ឋក្នុងប្រទេសដូច្នេះ ? ហេតុអ្វីសម្លាប់តែខ្មែរគ្នាឯង ជាតិឯង ?

តាមផ្លូវ លោកគ្រូយើងអង្គុយធ្វើមុខស្មឹ មិននិយាយរកនរណា ទេ ក្នុងចិត្តគិតមករកតែប្រពន្ធនិងកូនប៉ុណ្ណោះ ។ ព្រលប់ងងឹត បន្តិច ក្បួនកងទ័ពក៏បានធ្វើដំណើរមកដល់ទីតាំងមួយនៅកណ្ដាល ទ្រូងព្រៃ ។ ពួកគេក៏រៀបចំខ្លួនតាមដែលមេបញ្ជាការចាត់ចែង ។ លោកគ្រូសុធីដែលមានតែសម្លៀកពីរបន្លាស់តាមខ្លួន គ្មានកាំភ្លើង គ្មានមួក គ្មានសក្តិពាក់នោះ បានស្ម័គ្រធ្វើជាចុងភៅដាំបាយប្រចាំទី តាំង ដោយដាក់រហស្សនាមអោយលោកគ្រូសុធី ថាជាពលទោ មាន់ស្ទាវ ព្រោះមាន់ស្ទាវគ្មានក្រញាំកាយដី ឬច្រាសក្រញៀនរណា បានឡើយ មិនខុសឡើយពីលោកគ្រូសុធីដែលគ្មានអាវុធអ្វីការពារ ខ្លួនដូច្នោះដែរ ។ ជួនកាលលោកគ្រូសុធីក៏ត្រូវគេតំរូវឲ្យធ្វើជាពេទ្យ ជំនួយពេទ្យ ដើម្បីជួយថែទាំទាហានដែលត្រូវរបួសទាំងឡាយ ។

នៅរវាងជាងបីខែដែលលោកគ្រូបានមករស់នៅក្នុងព្រៃជាមួយ កងទ័ពសាធារណរដ្ឋ លោកមិនដែលបានចេញសមរភូមិម្ដងណាទេ ហើយនរណាៗក៏ដឹងដែរ ថាលោកគ្រូសុធីចាស់ហើយមានរោគ ហឺតផង ហើយក៏មិនចូលចិត្តកាន់កាំភ្លើងទៀត ។ លោកគ្រូយើងក៏ មិនដែលចេញដើរតាមព្រៃអោយស្គាល់ភូមិសាស្ត្រឯណាទេ ក្រៅតែ

CHANBOKEO.COM

ពីភូមិសាស្ត្រក្នុងបរិវេណទីតាំងនោះតែប៉ុណ្ណោះ ។ បីខែដែលលោក មកភ្នំវាយចាបនេះ លោកគ្រូបានឮស្នូរគ្រាប់កាំភ្លើងធំ កាំភ្លើងតូច និងអ្នកស្លាប់ អ្នករបួសជាប្រចាំ មិនថាថ្ងៃណាទេ ។ យូរៗម្ដង រដ្ឋាភិបាលក៏បញ្ជូនទ័ពមកថែមទៀត ។ ប៉ុន្តែ សង្គ្រាមក្នុងប្រទេស កាន់តែរ៉ាំរ៉ៃទៅៗ មិនខុសប៉ុន្មានពីលោកគ្រូដែលចេះតែស្គមទៅៗ រៀងរាល់ថ្ងៃនោះដែរ ប៉ុន្តែលោកមិនដែលរអ៊ូមួយម៉ាត់ប្រាប់នរណា ឡើយ ថាមានសុខទុក្ខនៅក្នុងខ្លួនយ៉ាងណាឡើយ ។

នៅយប់មួយ...

កងទ័ពសាធារណរដ្ឋបានចេញពីទីតាំង ទៅសមរភូមិផ្សេងៗ អស់ នៅសល់តែបួនដប់គ្រាប់សំរាប់យាមបន្ទាយ ស្រាប់តែមានពួក ទាហានខ្មែរក្រហមឡើងមកឡោមពទ្ធ័ជុំជិតទីតាំង ។ យប់នោះ លោកគ្រូសុធីស្លៀកខោខ្លីបង់ក្រមា កំពុងដើរត្រឡប់មកពីភូមិអ្នក ស្រុកវិញ ដើម្បីយកសំបុត្រទៅពឹងគេ ឲ្យជួយយកផ្ញើប្រពន្ធនៅឯផ្ទះ ស្រាប់តែប្រទះឃើញភ្លើងឆេះទីតាំងពីចម្ងាយ ហើយឃើញ ទាហានខ្មែរក្រហមខ្មៅមីរកំពុងឡោមពទ្ធ័ ។ សូរសន្ធឹកកាំភ្លើងធំតូច ក៏លាន់សន្ធឹកឡើងគគ្រឹកមេឃដី ។ លោកក៏រត់គេចខ្លួនមកដោយដៃ ទទេ មានតែខោខ្លីនិងក្រមា ត្រឡប់ចូលភូមិអ្នកស្រុកវិញ ។ ប៉ុន្តែ ដោយសារភ័យអាសន្នខ្លាំងផង ដោយមិនសូវស្គាល់ភូមិសាស្ត្រទឹកដី ម្តុំនោះផង លោកគ្រូក៏វង្វេងផ្លូវដើរច្រឡំទិសអស់ពីរបីថ្ងៃ ទំរាំរក ផ្លូវមកឡើងចួលជាតិជួបអ្នកស្រុក សុំអោយគេជួយយកអាសារ ។

ពេលនោះ លោកគ្រូសុធីបានទទួលជំងឺគ្រុនសន្និបាតយ៉ាងធ្ងន់ធ្ងរ បំផុត ។ សំណាងល្អ លោកបានជួបអ្នកស្រុកម្នាក់ ដែលធ្លាប់ជាកូន សិស្សរបស់លោកនៅទក្ខិណសាលាបឋមសិក្សា ។ ពេលនេះ បុរស នោះមករស់នៅដំណាក់ស្ដៅ ហើយធ្វើដំណើរជួញដូរចុះឡើង រវាង ប៉ៃលិននិងបាត់ដំបង ម្ល៉ោះហើយគេក៏មានចិត្តសប្បុរស ជួយដឹក លោកគ្រូរហូតដល់ពេទ្យធំបាត់ដំបង ។

បន្ទាប់ពីពិនិត្យរោគរួច លោកគ្រូពេទ្យបានប្រាប់ថា លោកគ្រូ សុធីមានជម្ងឺគ្រុនចាញ់ ប៉ុន្តែ ដោយបានមកដល់ពេទ្យទាន់ពេល វេលា លោកគ្រូក៏បានទទួលការសង្គ្រោះផុតពីគ្រោះថ្នាក់ដល់ជីវិត ។

លុះភ្ញាក់ស្មារតីដឹងខ្លួនមកវិញ លោកក៏ប្រទះឃើញមណីជា ប្រពន្ធអង្គុយនៅចុងជើង ហើយកូនៗទាំងប្រាំនាក់នៅអង្គុយតម្កង់ ជុំជិតខ្លួន សម្ដែងក្តីទុក្ខផង រីករាយផង នៅលើផ្ទៃមុខគ្រប់ៗគ្នា ។

CHANBOKEO.COM

- បង! បានស្រួលខ្លួនខ្លះទេ? (មីងមណីសួរ) អូនត្រេកអរណាស់ ដែលបងបានមកដល់ផ្ទះវិញដោយសុខសប្បាយ ។

លោកគ្រូសុធីញញឹមឡើងដោយរំភើបចិត្ត កាលបើបានឃើញ មុខប្រពន្ធកូនគ្រប់ៗគ្នា ។ បីខែកន្លងមកនេះ លោកគ្រូកើតទុក្ខនឹក ពួកគេនិយាយមិនចេញទេ បានត្រឹមតែលួចផ្តាំសេចក្តីនឹករលឹកតាម ហ្វូងផ្កាយពេលយប់ប៉ុណ្ណោះ ។

- នី! អូនស្គមណាស់! ឈឺអីមែនទេ?(លោកគ្រូសួរដោយ សម្លេងខ្សាវៗ)

- ខ្ញុំសុខសប្បាយទេបង គ្រាន់តែគេងមិនសូវលក់ ព្រោះចេះតែ នឹកបារម្ភពីបងពេក ។

សុធីស្រវាដៃប្រពន្ធមកកាន់ ហើយស្រដីថា ៖

- ពេលនេះបងបានសុខសប្បាយហើយ អូនឈប់ព្រួយទៀតទៅ!

បន្តិចមក លោកគ្រូក៏បែរមករកកូនៗទាំងអស់ ។ មីងមណីក៏លើកកូនប្រុសពៅអោយទៅអង្គុយលើគ្រែក្បែរឪពុក ៖

- ប៉ា! ពៅនឹកប៉ាណាស់! សូមអោយឆាប់ជា អាលត្រឡប់ទៅផ្ទះ យើងវិញ (និរន្តជាកូនពៅស្រដីឡើង)

លោកគ្រូយកដៃអង្អែលក្បាលកូន ធ្វើទឹកភ្នែករលីងរលោង ៖

- ពីរបីថ្ងៃទៀត ប៉ាជាស្រួលបួលវិញហើយកូន ហើយប៉ានឹងត្រឡប់ ទៅផ្ទះយើងវិញមិនខាន ។

លុះលោកបែរមើលកូននិមួយៗ ក៏បានឃើញថាពួកគេនៅមាន សាច់ឈាមធម្មតាៗ ដដែល ប្លែកតែនិមលទៅដែលហាក់ដូចជាខ្មៅ
ជាងមុន ៖

- យ៉ាងម៉េចដែរនិមល ប្អូនៗមិនរំខានចិត្តទេ មែនទេ?

- ចាស ប៉ា! កូនប៉ាល្អគ្រប់ៗគ្នា និមលមិនដែលមានការលំបាកអ្វីទេ តាំងពីប៉ាចេញទៅ ។

ការពិតនាងភូតទេតើ ។ តាំងពីឪពុកនាងចេញពីផ្ទះទៅ ម្តាយ នាងឈឺរហូត ទើបតែមកដើបដើរ ដើបពិសារបាយពេលបានទទួល ដំណឹងថា ឪពុកនាងនៅរស់ ហើយនៅសំរាកព្យាបាលឯមន្ទីរពេទ្យ ពីម្សិលមិញនេះឯង ។ ចំណែកនាងវិញ ក៏ត្រូវដើរតួជាឪពុកផង ម្តាយផង ដើម្បីគ្រប់គ្រងប្អូន ។ ធម្មតាទេ នាងមិនដែលធ្វើជាឪពុកម្តាយគេ លុះដល់មកទទួលបន្ទុកពេញទីដូច្នេះ មាណវីមានការនឿយហត់ខុសទម្លាប់ធម្មតារបស់នាង ។ ម្យ៉ាងដោយនាងជាប់រវល់

CHANBOKEO.COM

ត្រៀមប្រលងបញ្ចប់មធ្យមសិក្សាផង ហើយមានគោលបំណងចង់ ចេញទៅរៀននៅឯបរទេសផង ម្លោះហើយនាងក៏ស្រវាស្រទេញ ចូលដីចំការ បេះផ្លែឈើនិងដំណាំផ្សេងៗ ពីដីចំការដែលឪពុកនាង បានទិញទុកនោះ យកទៅលក់អោយឈ្មួញនៅផ្សារ ដើម្បីសន្សំលុយសំរាប់ទុករៀនសូត្រផង សំរាប់ទប់សេចក្តីត្រូវការក្នុងគ្រួសារ របស់នាងផង ។

*0000000000000000000*

*00000*

*0*

CHANBOKEO . COM

# វគ្គទី១៣
# គ្រោះ

និមលឈរមើលម្ដាយរបស់នាងដែលកំពុងបំរើឪពុកនាងដោយ យកចិត្តទុកដាក់ ។ ថ្វីបើម្ដាយរបស់នាងជាមនុស្សមិនសូវមាត់ក ច្រើន តែនរណាក្នុងផ្ទះក៏ដឹងដែរថា មីងមណីស្រឡាញ់គោរពលោក គ្រូសុធីជាប្ដីណាស់ ។ ពេលលោកគ្រូបែកទៅនៅព្រៃចំនួនជាងបីខែ និមលយើងសង្កេតឃើញថា ម្ដាយនាងមិនដែលញញឹមថ្ងៃណាទេ ។ ថ្ងៃណាក៏គាត់ឡើងអុជធូបថ្វាយបង្គំព្រះ យ៉ាងស្រងូតស្រងាត់ដែរ ។ ប៉ុន្តែ ប៉ុន្មានថ្ងៃនេះ នាងឃើញម្ដាយញញឹមឡើងវិញ ហើយក៏ដើប ចូលចង្ក្រានធ្វើម្ហូបបំរើប្ដីដោយផ្ទាល់ដៃ មិនអោយនិមលឬសាច់ញាតិ ក្នុងផ្ទះណាមកធ្វើជំនួសឡើយ ប្រហែលជាគាត់កំពុងតែបំរើសង ពេលបីខែ ដែលលោកគ្រូសុធីមិនបានទទួលសេចក្ដីកក់ក្ដៅ ពីក្រុម គ្រួសារហើយ ។ មិនថាតែនិមលទេ ដែលមានចិត្តរីករាយដោយ ឃើញមីងមណីញញឹម សូម្បីតែប្អូនៗនិងសាច់ញាតិទាំងអស់ ដែល រស់នៅជាមួយក៏រីកប្រមាត់ដែរ ពេលដែលគេបានឃើញលោកគ្រូ វិលត្រឡប់មកផ្ទះវិញ ព្រោះ ចាប់តាំងពីថ្ងៃដែលលោកគ្រូសុធីចាក ចេញទៅ ផ្ទះមួយខ្នងនេះ ហាក់ដូចជាក្រៀមក្រំស្ងាត់ជ្រងំខុសពី ធម្មតា ថ្វីបើនៅមានមនុស្សរស់នៅពាសពេញនៅឡើយ ព្រោះអី សំណើចក្អាកក្អាយដែលធ្លាប់មាននៅក្នុងគ្រួសារ បានរសាត់បាត់ទៅ ជាមួយរូបលោកគ្រូសុធី អស់រយៈពេលជាយូរ ។

ពេលនេះ តន្ត្រីសុភមង្គលបានប្រគំរងំពិរោះរណ្ដំក្នុងគ្រួសារ របស់លោកគ្រូសុធីយើងវិញហើយ ។ គេឃើញមីងមណីចេះញញឹម ឃើញលោកគ្រូដើបពិសារអាហារបានដោយខ្លួនឯង ហើយមាន កាលខ្លះ លោកលួចទាញម៉ង់ដូលីនមកដេញលេងម្ដងៗផង ។

ព្រឹកនេះ និមលនិងប្អូនរៀបចំខ្លួនចេញទៅរៀនតាមធម្មតា ។ មណីបានគ្រាហ៍សុធីចេញមកឈរលើរានហាលលើកដៃបក់បោយជូន ដំណើរកូនដែលជិះកង់ចេញពីផ្ទះតាមក្រោយគ្នា ចេញទៅរៀន ។

CHANBOKEO.COM

និមលជិះកង់តាមពីក្រោយប្អូនរហូតដល់បថមសាលា ទើបនាងជិះយកល្បឿនតម្រង់ទៅវិទ្យាល័យរបស់ខ្លួន ។

នៅថ្ងៃនោះ លោកគ្រូថ្នាក់ដំបូងមិនស្រួលខ្លួន ក៏ឈប់សំរាក មួយថ្ងៃ ។ សិស្សក្នុងថ្នាក់ក៏នាំគ្នាចេញលេងនៅខាងក្រៅអស់ នៅសល់តែនិមលម្នាក់ដែលកំពុងសរសេរចម្លងសំណៅសិក្សាដាក់ លើក្តារខៀនតែម្នាក់ឯង ។ ភ្លាមនោះ មានមិត្តយុវជនដែលរៀនជា មួយគ្នាចំនួនបួននាក់ក៏ដើរវិលត្រឡប់ចូលមកថ្នាក់វិញ ដោយជជែកគ្នាខ្ទៀវខ្ទា ខ្លាំងៗ ធ្វើអោយរំខានដល់និមល ៖

- អេហ៍! អ្នកទាំងបួន សូមស្ងាត់បានទេ ? ទីនេះជាថ្នាក់រៀន បើ អ្នកចង់ប្រឡែងគ្នា សូមចេញទៅក្រៅទេ (និមលវាចាឡើង)

ស្រាប់តែយុវជនម្នាក់ឈ្មោះខាំ ស្រែកតបវិញថា ៖

- នែ៎វើយ ពួកយើង! មានឮតុកកែយំទេ ? ក្រមុំឬក៏មេម៉ាយ ?
- យើងថា ច្បាស់ជាមេម៉ាយមិនខាន (ម្នាក់ទៀតឆ្លើយ)

ឃើញមិត្តរួមថ្នាក់ផ្លែផ្កាដូច្នោះ និមលខឹងឆេវតែម្តង ព្រោះពួកនោះមករំខានស្មារតីរបស់នាងដែលកំពុងផ្ចង់ក្នុងការសរសេរ ៖

- បើអ្នកទាំងអស់មិនឈប់ឡូឡាទេ ខ្ញុំនឹងទៅប្តឹងការិយាល័យ សាលាហើយ!

ថាហើយនិមលក៏ងើបឡើង កាន់សៀវភៅដើរចេញត្រុយទៅ ក្រៅ ។ ឃើញដូច្នោះ ពួកយុវជនបួននាក់ក៏ភ័យខ្លួនខ្លាចនិមលទៅ ប្តឹងនៅការិយាល័យសាលា ក៏ពង្រាយគ្នារាំងទ្វារមិនអោយនារីយើង ចេញទៅបាន ។ រីឯយុវជនឈ្មោះ ខាំ នោះមុខខ្លាញ់ណាស់ មិន ព្រមបញ្ឈប់ការឌឺដង ចំពោះនាងសោះឡើយ ៖

- ពៅអើយស្រីពៅ ធ្វើសង្សារបងទៅណ៎! កុំមួម៉ៅច្រើនពេក ខូចសម្រស់អស់ហើយ ។
- នែ៎ និយាយអោយសមរម្យបន្តិចមើល៍! (និមលគំហក)

ដោយអាងមានគ្នាច្រើន នាយខាំក៏ប្រកាន់ឫកកាន់តែព្រហើន ឡើង រហូតហ៊ានចាប់ដៃនិមល បិចសក់ បិចថ្ពាល់នាងលេងទៀត ផង ។ ទ្រាំមិនបាននឹងអំពើពាលរបស់នាយខាំ ធិតាគំហកមួយម៉ាត់ ចុងក្រោយថា ៖

- ខ្ញុំមិនអោយអ្នករាល់គ្នារួចខ្លួនទេ កាលបើអ្នកមានប្រព្រឹត្តកិរិយា មិនសមរម្យមកលើខ្ញុំ ។ ខ្ញុំនឹងទៅប្តឹងលោកគ្រូអោយដាក់ទោស អ្នករាល់គ្នាអោយទាល់តែបាន ។

CHANBOKEO.COM

ថាហើយ នាងបែរខ្លួនរត់ថយក្រោយ ហក់តាមបង្អួច លោត ចេញទៅប្រុយ
បំរុងថានឹងរត់គេចទៅជំរាបលោកគ្រូ អំពីកិរិយា ព្រហើនមិនសមរម្យនៃមិត្តរួមថ្នាក់របស់នាង ។
ពេលនោះ និមល មិនមានពេលគិតច្រើនទេ ព្រោះយុវជនទាំងនោះគ្រវីគ្រវាត់ដៃ
រវីមរវាមប៉ះពាល់លើកាយនាង ដោយគ្មានគោរពព្រំដែននារីភេទអ្វី បន្តិច
ហើយថ្នាក់រៀនរបស់នាងទៀតសោត ក៏ស្ថិតនៅជាន់ទីពីរ ។ នៅខាងក្រោយអាគារនោះ
មានដីទាប ទេរចូលទៅនឹងប្រឡាយ ដែលគេជីកធ្វើជារបងសាលា
មានដើមកំប្លោកដុះពាសពេញ ។ ថៃដន្យ ជាន់អាគារនោះ រាងខ្ពស់ពីដីប្រហែលបួនប្រាំម៉ែត្រ ។
នៅ ពេលដែលនិមលហក់ធ្លាក់ចុះទៅដល់ដី ស្រាប់តែនាងមានអារម្មណ៍
ថាចុកចាប់ក្នុងខ្លួនពេញណែនពេញខ្លួនអស់រលីង រហូតនិយាយ
លែងព្វហើយក៏ដួលប្រូសទៅដីត្នោលដើបលែងរួចតែម្ដង... ថ្វីបើ
ពេលនោះនារីមានការចុកចាប់ពេញខ្លួនក៏ដោយ និមលនៅមាន ស្មារតីអាចមើលឃើញអ្វី
ព្វអ្វីសព្វយ៉ាងទាំងអស់ជុំវិញខ្លួននាង ។ រំពេចនោះ
នាងក៏ឃើញសិសដែលរៀននៅថ្នាក់រៀនជាន់ក្រោមស្រែក ឆោឡោឡើង
រួចហើយក៏ហៅគ្នីគ្នាឲ្យមកជួយ ។ បន្តិចមក ស្រាប់ តែមិត្តរួមថ្នាក់ដ៏សែនព្រហើនឈ្មោះខាំនោះ
រត់មកដល់ ធ្វើទឹកមុខ សស្លាក់សស្លើតទំនងភិតភ័យអនេក ។ គេក៏បានលើកបីនិមលរត់
សំដៅការិយាល័យសាលា ដើម្បីហៅរកការសង្គ្រោះយ៉ាងអាសន្នពី លោកគ្រូៗ ។
ចំណែកឯមិត្តពីរបីនាក់ទៀត ក៏រត់ពីក្រោយ ឈូឆរ ដូរដៃគ្នាបីនិមលរត់តម្រង់ការិយាល័យសាលា
ដែលនៅឆ្ងាយពី អាគារសិក្សា ប្រហែលបីបួនរយម៉ែត្រ ។

និមលគេងនៅលើគ្រែមួយក្នុងសាលសាលា រង់ចាំយ៉ាងយូរទំរាំ
មានឡានមកទទួលយកទៅពេទ្យ ។ នាងឃើញមិត្តយុវជនរួមថ្នាក់
ទាំងបួននាក់នោះឈរធ្វើមុខស្មេញដូចសត្វស្វាធ្លាក់ទឹក នៅខាងមុខ
សាលដែលនាងកំពុងគេងចាំឡានដឹកទៅពេទ្យ ។ ធិតាមានការឈឺ
ចាប់ពេញខ្លួនរហូតនិយាយមិនរួចមួយម៉ាត់សោះ ប៉ុន្តែនិមលបាន
តាមដានគ្រប់សកម្មភាពទាំងឡាយជុំវិញខ្លួននាង ស្ទើរគ្មានចន្លោះ អ្វីសោះឡើយ ។ ភ្លាមនោះ
រថយន្តមួយក៏មកដល់ ព្រមគ្នាជាមួយ ឪពុកម្ដាយ
ដែលមានទឹកមុខស្លេកស្លាំងដោយការភិតភ័យតក្កមា ។

CHIANBOKEO.COM

ឃើញកែវភ្នែកដ៏សែនខ្វាយខ្វល់របស់ឪពុកម្តាយនាង និមលនឹក អាណិតឪពុកម្តាយយ៉ាងខ្លោចចិត្ត ព្រោះហេតុការណ៍ថ្ងៃនោះ បានធ្វើ អោយឪពុកម្តាយនាងទទួលទុក្ខ ក្នុងចិត្តយ៉ាងធ្ងន់ធ្ងរក្រៃលែង នឹងរកពាក្យអ្វីនឹងថ្លែងអោយស្មើមិនបានឡើយ ។

នៅក្នុងសាលសង្គ្រោះ ឯមន្ទីរពេទ្យ និមលឮឪពុកម្តាយអង្គុយ ស្តាប់ក្មេងៗសិស្សសាលា ដែលជិះកង់ដេញតាមមកមើលនិមលដល់ មន្ទីរពេទ្យ ។ ខ្លះជាមិត្តស្រីរបស់នាងក្នុងថ្នាក់ ខ្លះជាមិត្តដែលរៀន នៅថ្នាក់ជាប់គ្នា ។ ពេលនោះ នាងបានឮសំដីមិត្តនាងឆ្លើយឆ្លងគ្នា ថា ៖

- នេះហើយ ទោសនៃការប្រឡែងគ្នា ហើយយើងជាស្រីសោះ
ហេតុអ្វីទៅរត់ប្រឡែងនឹងមិត្តប្រុសក្នុងថ្នាក់រហូតដល់ធ្លាក់តាមបង្អួច ពីលើសាលាមក
ត្រូវរបួសបាក់ចង្កេះ បាក់ជើងយ៉ាងនេះ ?
- យើងមិនជឿទេ ថានិមលរត់ប្រឡែងជាមួយពួកហ្នឹង ព្រោះនាង
មិនដែលស៊ីខ្សែជាមួយក្រុមហ្នឹងតាំងពីយូរហើយ ។
- អើយ! កុំទៅកាន់ជើងមនុស្សខូចធ្វើអី ទុកអោយវាបាក់ជើង បាក់ចង្កេះខ្លះអញ្ចឹងទៅ
ទើបសមមុខ ។

និមលគេងស្តាប់ឮសំដីទាំងនោះគ្រប់ម៉ាត់ ហើយនឹកអនិច្ចាក្នុង ចិត្តតែម្នាក់ឯងថា ៖

- ហេតុអ្វីមនុស្សចូលចិត្តកាត់ស្មាន ហើយដាក់ទោសជនរងគ្រោះ ? ម្តេចគេមិនស្រាវជ្រាវការពិត មុននឹងហារស្តីនិយាយដើមគេ ? ម៉េចក៏ចូលចិត្តស្តាប់ពាក្យបង្កាច់បង្ខូចម្ល៉េះ ? នេះពួកគេមិនបានដឹង ឯណាថាប្អូននាក់ថា ពួកនោះក្បាលខូច បានប្រព្រឹត្តគប្បីមកលើខ្ញុំ ?

និមលខឹងណាស់ ខឹងរហូតផ្តាំប្អូនៗមិនអោយពួកម៉ាកទាំងនោះ ចូលមកមើលនាងនៅមន្ទីរពេទ្យទៀតផង ។ ចំណែកមីងមណីម្តាយ របស់នាងក៏ធ្លាក់ទឹកចិត្ត អន់ចិត្តបន្តិចដែរ ដែលគាត់ឮពាក្យជីបអូជ ពីមិត្តរបស់និមលថា និមលប្រឡែងលេងនឹងមិត្តប្រុសរហូតដល់ ធ្លាក់ពីលើសាលារបួសបាក់ចង្កេះនិងបាក់ជើង ។ ការដែលធ្វើជា ម្តាយមានកូនក្រមុំគឺដូច្នេះឯង សុខៗ មានគេនិយាយចំអកប្រមាថ កូនស្រីរបស់គាត់ ទាំងមិនដឹងរឿង ។ ថ្វីបើ មីងមិនទាន់ដឹងទេ ថារឿងវាយ៉ាងណា មីងមណីនៅតែមិនជឿដែលថា និមលមាន ចរិតអាឡឹកអាឡក់ជាមួយក្មេងប្រុស ព្រោះកូនស្រីរបស់គាត់ជាក្មេង ម៉ឺងម៉ាត់ មិនចេះញ៉ិកញ៉ក់ដាក់បុរសណាកើតទេ ក្រៅពីនិយាយម៉ុងម៉ាំងត្រង់ៗ មិនខ្លាចចិត្ត ឬមិនអៀននរណាឡើយ ។

ក្នុងរយៈពេលប៉ុន្មានថ្ងៃដែលនិមលគេងនៅមន្ទីរពេទ្យ នារីបាន ឃើញនាយខាំ និងមិត្តទាំងបីនាក់របស់គេ បានលួចមកអើតមើល នាងនៅមន្ទីរពេទ្យជាញឹកញាប់ ព្រមទាំងសម្តែងទឹកមុខភ័យព្រួយ ដែលគេបានប្រព្រឹត្តមិនសមរម្យមកលើនាង ប៉ុន្តែគ្មានយុវជនណា មួយនៅក្នុងចំណោមទាំងបួននាក់នោះ មានចិត្តក្លាហានជាកូនប្រុស គ្រប់គ្រាន់ នឹងចេញមុខសារភាព អំពីអំពើរលើមរលាមខ្វះវិន័យ របស់ខ្លួន កាលពីថ្ងៃមុននោះទេ ។ ទាំងបួននាក់មានសេចក្តីក្លាហាន បានត្រឹមតែធ្វើជាកូនស្វាអើតតាមបង្អួច មើលនិមលពីក្រៅទៅតែ ប៉ុណ្ណោះ ។ ចំណែកនិមលវិញ ក៏នៅតែរង់ចាំអ្នកទាំងបួននោះ ចូលខ្លួនមកសារភាពកំហុសចំពោះនាង ចំពោះសាលា និងចំពោះឪពុក ម្តាយនាង ។ យុវតីបានប្តេជ្ញាក្នុងចិត្តថា បើពួកគេមិនព្រមចូលមក សារភាពខ្លួន ចំពោះឪពុកម្តាយរបស់នាង និងលោកគ្រូអ្នកគ្រូនៅ សាលាទេ នាងក៏មិនអាចទទួលអ្នកទាំងបួននោះ ជាមិត្តរបស់នាង តទៅទៀតបានដែរ ។

ក្រោយមក លោកគ្រូសុធីជាឪពុកសំរេចចិត្តនាំនិមលត្រឡប់ទៅ រក្សាជម្ងឺនៅឯផ្ទះវិញ ដើម្បីចៀសវៀងភ្នែកមនុស្សដែលចាំតែអើត ដកកលួចមើលនិងលួចបួញបាញ ដោយសន្មតសាច់រឿងថា យ៉ាង នេះ យ៉ាងនោះអំពីនិមល ដោយមិនដឹងហេតុការណ៍ពិតប្រាកដ ។ ណាមួយលោកគ្រូសុធីមិនទាន់ជាពីជម្ងឺស្រួលបួលផង កូនស្រីច្បង របស់លោកក៏មានគ្រោះថ្នាក់ទៀត ធ្វើអោយអ្វីៗក្នុងផ្ទះមានការផ្លាស់ ប្តូរច្រើនណាស់ ត្បិតអ្នកដែលទទួលបន្ទុកគ្រួសារ ត្រូវដួលរលំទាំង ពីរនាក់ ។ ចំណែកមីងមណីជាម្តាយរបស់និមល មានសុខភាពទន់ ខ្សោយតាំងពីក្មេង មិនអាចទទួលអ្វីៗបានរឹងមាំដូចសុធីនិងកូន ស្រីទេ ម្ល៉ោះហើយសាច់ញាតិជិតខាងដែលធ្លាប់ទៅមកពឹងពាក់ ស្នាក់អាស្រ័យធ្វើកូនធ្វើចៅនឹងលោកគ្រូយើង ក៏នាំគ្នាចូលមកច្រូង ច្រាងជួយជ្រោមជ្រែងពីមុខពីក្រោយ រហូតដល់និមលនិងឪពុកមាន សុខភាពគ្រាន់បើមកវិញ ។

ថ្ងៃមួយ អ្នកទាំងឡាយក្នុងផ្ទះ ចេញទៅរៀនអស់ ។ និតាយើង ក៏លើកដៃសំពះឪពុកម្តាយហើយស្រដីថា ៖

- កូនសូមអភ័យទោសដែលកូនបាននាំទុក្ខដល់ម៉ាក់ប៉ា ។ ប៉ុន្តែ បុព្វហេតុដែលធ្វើអោយកូនធ្លាក់ពីលើសាលានោះ មិនមែនជាកំហុស កូននោះទេ ។ កូនសង្ឃឹមថា ម៉ាក់ប៉ានឹងអភ័យទោសអោយកូន...

CHANBOKEO.COM

លោកគ្រូសុធីក៏យកដៃអង្អែលក្បាលកូនស្រីហើយស្រដីតបនាង
វិញថា ៖

- ប៉ាបានចិញ្ចឹមកូនដោយផ្ទាល់ដៃប៉ា តាំងពីកូននៅក្រហមបាតជើង
រឿងអីដែលប៉ាមិនស្គាល់កូនរបស់ប៉ានោះ ។ ពាក្យចចាមអារាមមិន
បាននាំអោយប៉ាបែកអារម្មណ៍ជឿពាក្យគេ ជាជាងជឿលើភ្នែកខ្លួន ឯងនោះទេ ។

- អរគុណ ប៉ាម៉ាក់ណាស់ ដែលទុកចិត្តកូន ។ ចាប់ពីថ្ងៃនេះទៅ ខ្ញុំ មិនធ្វើអោយប៉ាម៉ាក់មានអំពល់
ជាលើកទីពីរឡើយ ។

និមលសំពះអរគុណឪពុកម្តាយ រួចហើយក៏អង្វរអោយលោក ទៅសុំអនុញ្ញាត្តិសាលា
សុំកិច្ចការសាលាមកអោយនាងរៀននៅផ្ទះ ពេលនាងកំពុងគេងកន្ទេល
ដើម្បីព្យាបាលរបួសរបស់នាង អស់ ជិតកន្លះឆ្នាំនោះ
ព្រោះនាងកំពុងត្រៀមប្រឡងមធ្យមសិក្សាផង ។ នាងមិនចង់អាក់ខានការប្រឡង
ឬក៏ត្រូវប្រឡងធ្លាក់នោះទេ ។ សំណាងល្អ ការិយាល័យសាលាបានដឹងថា និមលជាសិស្សពូកែឆ្លៀវ
ឆ្លាតម្នាក់ ម្ល៉ោះហើយ គេក៏មិនចង់អោយនាងអាក់ខានការសិក្សាឆ្នាំ នោះដែរ ។
គេក៏អនុញ្ញាត្តអោយលោកគ្រូអ្នកគ្រូផ្ញើសំណៅសិក្សា មកអោយនិមលរៀននៅផ្ទះ ។ ពេលនោះ
នាងបានជំរាបឪពុក ម្តាយរបស់នាង ថា ៖

- ប៉ាម៉ាក់! ថ្វីបើកូនត្រូវគេងលើកន្ទេលអស់ជាច្រើនខែមែន ប៉ុន្តែ កូននឹងបង្ហាញប៉ាម៉ាក់
បង្ហាញសាច់ញាតិ និងមិត្តរបស់កូនទាំងអស់ នូវសមត្ថភាពរបស់កូនក្នុងការសិក្សា ។
កូនមិនអោយជម្ងឺនិងពិការ ភាពរបស់កូនទាញខ្លួនអោយអស់សង្ឃឹម ហើយដើរថយក្រោយក្នុង
ជីវិតឡើយ ។ កូននឹងខិតខំរហូតដល់បានជោគជ័យដូចសិស្សដទៃ ដែលមិនពិការនោះមិនខាន ។

ជាច្រើនខែក្រោយមក និមលក៏ត្រូវដល់ពេលចូលប្រឡង ។ ថៃដន្យ ពេលប្រឡងមកដល់
និមលមិនទាន់អាចដើបក្រោកអង្គុយ បាននៅឡើយ
ដូច្នេះនិមលមិនអាចចូលទៅធ្វើការប្រឡងបានទេ ។
ប៉ុន្តែយុវនារីយើងមិនសុខចិត្តខកឆ្នាំសិក្សារបស់នាងឡើយ ។ ធិតា ក៏ដាក់ពាក្យទទូចសុំចូលប្រឡង
តាំងពីការិយាល័យសាលា រហូត ដល់ការិយាល័យក្រសួងសិក្សាធិការប្រចាំខេត្រ
ហើយចូលទៅដល់ ការិយាល័យលោកអភិបាលខេត្រទៀត ។ រឿងរបស់និមលយើងក៏
រាយសាយល្បីកាត់ក្រុងបាត់ដំបងទាំងមូល ព្រោះនាងជាសិស្សលើក
ដំបូងដែលស្ថិតនៅលើគ្រែអ្នកជម្ងឺ ហើយដែលទទូចសុំប្រឡង មធ្យមសិក្សា ។ ពេលនោះ

CHANBOKEO.COM

និមលបានទទួលការគាំទ្រពីសាស្ត្រាចារ្យ របស់នាងគ្រប់គ្នាក្នុងសាលា ទាំងគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ទាំងអក្សរសិល្ប៍ខ្មែរ ទាំងភាសាបារាំង និងមុខវិជ្ជាដទៃទៀត ជាច្រើន ។ ទីបំផុត និមលក៏ត្រូវសាលាអនុញ្ញាត្តិអោយនាងចូល ប្រឡងបន្ទប់ពិសេស ដែលមានគ្រូម្នាក់និងពេទ្យម្នាក់នៅអង្គុយ ពិនិត្យ មើលនាងពេលនាងទទួលវិញ្ញាសាប្រឡង ដោយតម្រូវឲ្យ និមលគេងផ្កាប់មុខសរសេរ នៅលើគ្រែរុញរបស់ពេទ្យមួយ ។

នៅក្នុងសាលប្រឡងដែលមានតែនិមលជាសិស្សម្នាក់ឯង នារីលើកដៃសំពះលោកគ្រូនិងអ្នកគ្រូពេទ្យម្នាក់នោះ ហើយស្រដីថា ៖

- និមលសូមអរគុណនូវទឹកចិត្តដ៏សប្បុរសរបស់លោកគ្រូ និងអ្នកគ្រូពេទ្យដែលបានស្ម័គ្រមកធ្វើមេប្រយោគ និងមកជួយមើលការខុសត្រូវខាងសុខភាពរបស់នាងខ្ញុំ ដើម្បីអោយនាងខ្ញុំបានចូល ប្រឡងនឹងគេ ។

ការពិត លោកទាំងពីររូបនោះជាមនុស្សចម្លែក ដែលនិមលមិន ដែលស្គាល់ពីមុនមក ។ លុះឃើញនារីធ្វើដូច្នេះ លោកសម្តែងការ ភ្ញាក់ផ្អើលណាស់ ដែលនារីមានកតញ្ញូចំពោះគ្រូនិងការសិក្សា ។

ទីបំផុត ការប្រឹងប្រែងរបស់នាង ក៏បានទទួលជោគជ័យយ៉ាង គាប់ប្រសើរ គឺនាងបានប្រឡងជាប់ហើយ ក៏បានទទួលនិទ្ទេសល្អ ទៀតផង ។ ដំណឹងនេះបានធ្វើអោយមិត្តរួមថ្នាក់របស់នាងជាច្រើន ជិះកង់មកសរសើរនាងដល់ផ្ទះ ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ និមលត្រូវរងពិការភាពខាងផ្លូវកាយហើយត្រូវនៅទទួលការព្យាបាលជាយូរឆ្នាំទៀត ។ ណាមួយលោកគ្រូសុធីក៏មានជំងឺត្រូវនៅសំរាកព្យាបាលជាយូរខែដែរ ម្លោះ ហើយធនធានទ្រព្យសម្បត្តិដែលលោកគ្រូនិងភរិយាសន្សំបានទាំង ប៉ុន្មានបានត្រូវយកមកចំណាយលើការព្យាបាលជម្ងឺរបស់លោកគ្រូ និងនិមលជាកូនអស់រលីងគ្មានសល់ បណ្តាលឲ្យក្តីស្រម័យរបស់ និមលដែលប្រាថ្នាចេញទៅសិក្សានៅអាមេរិក ក៏ត្រូវពន្យារពេលមួយរយ: ។ ពេលនោះ និមលខកចិត្តខ្លាំងណាស់ ព្រោះអ្នកដែលបានកាត់បន្ថយក៏រិតជោគជ័យរបស់នាងក្នុងការសិក្សា និងអ្នកដែល ជាបុព្វហេតុធ្វើឲ្យនារីយើងពិការមួយជីវិតនោះ គឺនាយខាំ និង មិត្តរួមថ្នាក់បីនាក់ទៀត ។ និមលគិតថា

CHANBOKEO.COM

នាងពិបាកនឹងអភ័យទោស អោយពួកគេណាស់ នៅក្នុងមួយជីវិតរបស់នាង ព្រោះនាងត្រូវខក ការសិក្សានិងអនាគតល្អ ដោយសារភាពរាយមាយឈាមរាវរបស់ មិត្តរួមថ្នាក់ទាំងបួននាក់នោះ ។

កាលនោះ នាងមានមិត្តតែបីនាក់គត់ ដែលតែងតែផ្តល់កម្លាំង ចិត្តអោយនាងជានិច្ច ដើម្បីពុះពារការសិក្សាបន្តទៅទៀត ដោយ មិនបាច់បែរមើលការឈឺចាប់ក្នុងអតីតកាល ។

oooooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទី១៨
# ទារុណជីវិត

ថ្ងៃ១៧មេសា១៩៧៥...

ទំព័រប្រវត្តិសាស្ត្រមួយទៀតបានបើកទំព័រនៅកម្ពុជា ។ ទីក្រុងភ្នំពេញបានត្រូវខ្មែរក្រហមរំលោភបានហើយក៏បានប្រកាសបណ្តេញ អ្នកស្រុកចេញពីទីក្រុងគ្រប់ៗគ្នា ។ នៅបាត់ដំបង ចលនាកងទ័ព សាធារណរដ្ឋខ្មែរនៅមានសន្ទឹកខ្លាំងក្លាប្រឆាំងនឹងទ័ពខ្មែរក្រហម នៅឡើយ រហូតដល់ថ្ងៃទី ២៤មេសា១៩៧៥ ទើបដាក់អាវុធ ។

ព្រឹកនោះ ក្រុមគ្រួសាររបស់លោកគ្រូសុធី បិទទ្វាររបង សម្ងំក្នុងផ្ទះមិនមានចេញទៅណាទេ ។ ម្នាក់ៗអង្គុយចាំស្តាប់តែវិទ្យុជាតិ តែប៉ុណ្ណោះ ។ ស្រាប់តែពួកកងទ័ពខ្មែរក្រហម ដើរចូលមកដល់ដី ភូមិដែលលោកគ្រូសុធីរស់នៅយ៉ាងខ្មៅមីរ ថែមទាំងស្រែកទារពី ក្រៅរបង អោយមីងមណីដាំបាយឲ្យពួកគេបរិភោគទៀតផង ។ ដោយខ្លាចអំណាចគ្រាប់កាំភ្លើង មីងមណីក៏នាំកូនដាំបាយធ្វើម្ហូបបំរើ ពួកយោធាទាំងនោះទាំងអារម្មណ៍ភិតភ័យតក់ស្លុត ។

និមលនៅអង្គុយឯចង្ក្រានបាយ លួចមើលឃើញតាមបង្អួចឃើញពួកយោធាទាំងនោះបរិភោគដោយម្រាមដៃ លើកចានសម្ល ចែកគ្នាហុតដោយគ្មាននរណាម្នាក់ប្រើស្លាបព្រាទេ ។ រួចហើយ ស្រាប់តែពួកគេសម្លុតឲ្យមីងមណីកាត់សក់អោយកូនស្រីៗរបស់ គាត់ទាំងអស់អោយខ្លី ។ បើនៅសល់សក់វែងដដែលគេនឹងចាប់ ឲ្យអង្គការកាត់ទោស ទាំងកូនទាំងម្តាយហើយ ។ មីងមណីឮហើយក៏ចាប់កូនកាត់សក់អស់រលីងតែក្នុងរយៈពេលប្រហែលកន្លះម៉ោង ។

នៅកៀនផ្ទះ លោកគ្រូសុធីកំពុងតែអង្គុយច្រៀកអុស ស្រាប់តែនាយយោធារាងចំណាស់មួយរូបដើរមកជិតហើយប្រាប់ថា ៖

- ល្បងឯងយកល្អ នាំកូនប្រពន្ធរត់ទៅនៅស្រុកស្រែទៅ នោះនឹង បានសុខមិនខាន ។ កុំនៅទីនេះទៀតអោយសោះ ព្រោះស្អែកនេះ ទៀត អង្គការនឹងចេញបោសសំអាតមនុស្សអោយចេញអស់ពីទី ក្រុងបាត់ដំបងហើយ ។

CHANBOKEO.COM

ថាហើយ នាយនោះក៏សុំបាយមួយកញ្ចប់ពីមីងមណីហើយដើរ ចេញទៅ ។ ឮដូច្នោះ លោកគ្រូហាក់ដូចជាមានពិភាល់ក្នុងចិត្តយ៉ាង ណាមិនដឹង ក៏ខិបអោយប្រពន្ធកូនរៀបចំខ្លួន ។ ប្រហែលមួយ ម៉ោងក្រោយមក ស្រាប់តែមានកងយោធាដើរប្រកាសដេញអ្នកភូមិ អ្នកស្រុកអោយចុះចេញពីលំនៅរបស់ខ្លួនហើយធ្វើដំណើរចេញពីទីក្រុងជាប្រញាប់ក្នុងរយៈពេល២៤ម៉ោង ។ បួនដប់នាទីក្រោយមក ស្រាប់តែមានបុរសម្នាក់ជិះម៉ូតូមកហៅ ៖

- លោកគ្រូៗ ! កងទ័ពអង្គការរំដោះអោយពួកយើងដើរអញ្ជើញ លោកគ្រូៗនិងបញ្ញវន្ត័រដ្ឋការទាំងឡាយ អោយទៅជុំគ្នានៅឯវាល បែកចាន ដើម្បីចេញទៅទទួលសម្តេចឪ ។
- បាទ! អរគុណ ។

លោកគ្រូសុធីឆ្លើយទាំងជ្រួញចិញ្ចើម ព្រោះលោកគ្រូកំពុងគិត អំពីប្រយោគរបស់នាយពលយោធាខ្មែរក្រហម ចំពោះពាក្យដែលថា អង្គការនឹងបោសសំអាតទីក្រុង... រួចហើយ ពាក្យដែលថា អោយលោកចេញទៅនៅស្រុកស្រែដើម្បីរក្សាសុខ ។ ពេលនេះស្រាប់តែ មានគេមកដើរប្រមែប្រមូលអ្នករដ្ឋការអោយទៅជួបជុំគ្នាមួយកន្លែង មិនដឹងថា អង្គការថ្មីមានគម្រោងយ៉ាងណាទេ ។

លោកគ្រូក៏នាំកូននាំចៅរៀបចំអីវ៉ាន់សំខាន់ៗល្មមតែស្ពាយតាម ខ្លួនរួច ហើយក៏រៀបរបចំរុងនាំគ្នាចេញពីផ្ទះទៅ ស្រាប់តែមានគេ មកតាមលោកគ្រូយើងជាថ្មីម្តងទៀតហើយ ៖

- លោកគ្រូ! មានគេនៅចាំអោយលោកគ្រូទៅជួបជុំនៅសាលា អ៊ិបយុតជាប្រញាប់ ដើម្បីរាប់ឈ្មោះគ្រូដែលត្រូវមានឈ្មោះចូល បម្រើការងារជាមួយអង្គការ ។
- អឺ! ទៅមុនទៅ លោកគ្រូនឹងចេញទៅតាមក្រោយ ។

ប៉ុន្តែ នាយនោះមិនអស់ចិត្តទេ ក៏ចាប់លោកគ្រូសុធីឌុបវេសប៉ា ចេញទៅ ទុកអោយមីងមណីនិងកូនចៅមើលតាមលោកពីក្រោយ រហង់ ។ ភ្លាមនោះ មីងមណីក៏ទម្លាក់សំពាយចុះហើយស្រដីថា ៖

- ម៉ាក់មិនទៅណាចោលប៉ារបស់កូនទេ ។ ម៉ាក់នឹងនៅទីនេះ ចាំរហូតដល់ពេលគាត់ត្រឡប់មកវិញ ព្រោះកុំអោយវង្វេងឃ្លាងផ្លូវគ្នា ខ្លាចរកគ្នាមិនឃើញ ។

CHANBOKEO.COM

- ចុះបើពួកទ័ពថ្មីគេឃើញយើងមិនព្រមចេញពីផ្ទះនោះ តើពួកគេ
នឹងដាក់ទោសយើងយ៉ាងណា ? (និមលសួរ)

- ម៉ាក់ក៏សុខចិត្តស្លាប់ទីនេះ ដើម្បីរង់ចាំប៉ាកូនចុះ ជាជាងបែកគ្នា ដោយមិនដឹងដំណឹងពីគ្នាដែរ ។

និមលនិងប្អូនទាំងបួនព្រមទាំងប្អូនចិញ្ចឹម ក៏មើលមុខគ្នាធ្វើ ឡឹងឡង់ រួចក៏នាំគ្នាដាក់សំពៀតចុះដែរ ។ មិនបានមួយម៉ោងផង ស្រាប់តែអ្នកទាំងអស់គ្នាឃើញលោកគ្រូសុធីរត់ត្រឡប់មកវិញដោយ ជើងទទេ ។

- ប៉ា! (និមលលាន់មាត់ឡើងដោយក្ដីត្រេកអរ)

មីងមណីរត់ទៅទទួលប្ដីយ៉ាងរហ័ស ហើយសួរថា ៖

- ស្ថានការណ៍យ៉ាងណាទៅហើយបង ?

- បងមិនដឹងទេ ប៉ុន្តែ ពេលបងឃើញអ្នកស្រុកធ្វើដំណើរពពាក់ ពពូនចេញពីទីក្រុង បងនឹកពិភាល់ក្នុងចិត្តពេក ទើបលោតទម្លាក់ ខ្លួនពីម៉ូតូរត់តាមផ្លូវកាត់ ត្រឡប់មកផ្ទះយើងវិញ ។

- ហើយចុះរឿងទៅទទួលសម្ដេច និងរឿងដែលអង្គការប្រមៃ ប្រមូលបញ្ញវន្តនោះ បងគិតយ៉ាងណាទៅវិញ ?

លោកគ្រូសុធីសម្លឹងមុខប្រពន្ធហើយសម្លឹងមុខកូនទាំងអស់ រួច ហើយមានប្រសាសន៍ថា ៖

- អ្វីៗមិនសំខាន់ទេ អោយតែយើងបាននៅជួបជុំគ្នា ។ បងមិន ព្រមចេញដំណើរទៅតាមគេនោះ ព្រោះខ្លាចត្រូវជាប់កំណោណ្ឌយូរ មិនបានជួបគ្នា ទើបបងសុខចិត្តលះបង់ដំណែង ដើម្បីវិលមកជួប ជុំគ្រួសារយើងវិញ ។

មីងមណីញញឹមឡើងដាក់លោកគ្រូហើយតបថា ៖

- បានបងត្រឡប់មកវិញ អូនមានកម្លាំងចិត្តណាស់ ថ្វីបើយើងត្រូវ លះបង់ផ្ទះមួយខ្នងនេះ និងអីវ៉ាន់សព្វសារពើដែលយើងខិតខំសន្សំ ២០ឆ្នាំកន្លងមក ក៏ដោយ ក៏អូនមិនស្ដាយដែរ អោយតែអូនបានបង ត្រឡប់មកវិញដោយសុខសប្បាយ ។

ទាំងពីរនាក់ស្វាមីភរិយាក៏កាន់ដៃកូននាំគ្នាដើរចេញពីគេហដ្ឋាន ដ៏ស្កុកស្គម្ភសោភាមួយខ្នងនោះ ដែលលោកគ្រូសុធីបានសង់ឡើង ដោយកម្លាំងញើសឈាមផ្ទាល់របស់លោក ។ ថ្វីបើនៅក្នុងជំរៅដួង ចិត្តរបស់លោកគ្រូ នៅមានការសោកស្ដាយចំពោះការបាត់បង់ទ្រព្យ សម្បត្តិរបស់លោកយ៉ាងណាក្ដី ក៏លោកគ្រូបានតាំងចិត្តយ៉ាងក្លាហាន ថា ស៊ូទម្លាក់ខ្លួនមករស់នៅជាមនុស្សសាមញ្ញ

CHANBOKEO.COM

ដើម្បីប្តូរនឹងការរស់ នៅជួបជុំប្រពន្ធកូនវិញ ។ តាមផ្លូវ គេប្រទះឃើញអ្នកស្រុកធ្វើ
ដំណើរចេញពីក្រុងបាត់ដំបងយ៉ាងពពាក់ពពូន មានទាំងជនជរា ពិការ អ្នកជំងឺ អ្នកកូនខ្ចី
និងនរណាទាំងអស់ ។ ពេលនោះ កង យោធាអង្គការខ្មែរក្រហមរំដោះកម្ពុជា
មិនអនុញ្ញាត្តិអោយអ្នកស្រុក យកអ្វីតាមខ្លួនទេ ក្រៅតែពីសំពាយខោអាវមួយមុខ ។ សូម្បីតែកង់
ម៉ូតូក៏មិនអាចយកតាមខ្លួនបានដែរ ។

តាមផ្លូវ និមលដើរស្ពាយបានតែខោអាវពីរបន្លាស់ ព្រោះពិការ
ភាពរបស់នាងមិនអាចអោយនាងយួរអ្វីស្ពាយអ្វីបានឡើយ ក្រៅតែ
ពីយោងអាត្មាអោយតែផុតទីក្រុងរួចទៅប៉ុណ្ណោះ ។ ចំណែកប្អូនៗ តូចៗនិងឪពុកម្តាយក៏ស្ពាយអ្វីៗ
តាមដែលខ្លួនអាចទ្រាំទ្រស្ពាយ បាន ។ ជួនកាលយ៉ាប់កម្លាំងពេក គេក៏បោះទម្លាក់ចោលតាមផ្លូវ
ខ្លះៗដើម្បីសម្រាលស្មា ។ មួយថ្ងៃមួយយប់ក្រោយមក គេក៏បានមក ដល់ភូមិត្រាង
ហើយស្នាក់នៅជាមួយក្រុមគ្រួសាររបស់ពូមនោដែល ជាប្អូនប្រុសរបស់មីងមណី ។
ពូមនោះបានរៀបការជាមួយស្ត្រី ស្រុកស្រែម្នាក់ជាអ្នកភូមិម្តុំៗនោះ
ហើយមានកូនចៅបីបួននាក់ ។

ថ្ងៃដន្យ អភ័ព្វ ក្រុមគ្រួសារលោកគ្រូសុធីក៏ត្រូវអង្គការបំបែក សមាជិកទៅគ្រប់ផ្នែកទាំងអស់
នៅរវាងពីរបីថ្ងៃបន្ទាប់មកទៀត ។ ដោយអំណាចចុងកាំភ្លើង ពួកគេក៏ត្រូវបែកគ្នាទាំងបង្ខំ ។
លោកគ្រូ បានត្រូវអង្គការបញ្ជូនទៅធ្វើការខាងកងចល័តបុរស ។ មីងមណីធ្វើ
ស្រែនៅកៀនភូមិ ។ ចំណែកនិមលនិងនិសាបានត្រូវអង្គការបញ្ជូន អោយចូលកងចល័តនារី
ក្នុងឱកាសដែលប្អូននិងកូនចិញ្ចឹមរបស់ លោកគ្រូ ត្រូវជាប់កំណោណ្ឌជាកងកុមារឈានមុខ ។

កាលនោះ ពួកយោធាខ្មែរក្រហម មិនយល់មុខថា នរណាឈឺ នរណាពិការទេ ។
និមលបានត្រូវអង្គការលត់ដំអោយធ្វើការធ្ងន់ៗ លើសពីកម្លាំងកាយនិងសុខភាពរបស់នាង
ធ្វើអោយនិតាយើងទ្រាំ ទទួលធ្វើការទាំងនោះយ៉ាងលំបាកវេទនាបំផុត ។ និសាឃើញបង
ស្រីទទួលភាពយ៉ាប់យ៉ឺនខាងផ្លូវកាយខ្លាំងពេក ក៏រត់មកជួយដៃនាង
តែក៏ត្រូវអង្គការដាក់ទណ្ឌកម្មដូចសតធាតុ ស្ទើរតែមរណាពីលោក នេះ ម្តងៗទៅហើយ ។

ថ្ងៃមួយ ស្រាប់តែមានពួកយោធាមកកេណ្ឌពួកនារីៗ អោយទៅ ធ្វើការនៅរោងតម្បាញ ។
និមលបានត្រូវអង្គការបំបែកពីនិសាទៅ នៅភូមិពោធិហ្សស្រី ដើម្បីជួយផលិតក្រមានិងស្បៃមុង ។
នៅក្នុង រោងតម្បាញដែលមានអ្នកធ្វើការប្រហែលជា៤០នាក់ តែនិមលមិន
ស្គាល់នរណាម្នាក់ឡើយ ។ ប្រមាណបីខែក្រោយមក ពួកនារីតម្បាញ

CHANBOKEO.COM

ទាំងនោះត្រូវអង្គការចាត់អោយរៀបគ្រួសារ(រៀបការ) ជាមួយពួក យោធាពិការរបស់អង្គការ ។ និមលក៏ត្រូវអង្គការបង្ខំអោយរៀបការ ដែរ ។ ពេលនោះ និមលបានរត់គេចវេះ មិនព្រមទទួលរៀបការ នាយយោធាពិការជាប្តី ហើយបានរត់គេចខ្លួនចេញពីពោធិហ្សស្រី នោះទាំងកណ្តាលយប់ ។ ប៉ុន្តែ សំណាងមិនល្អ ឆរីយើងបានត្រូវ កងយោធាចាប់ខ្លួនបាន នៅម្តុំវាលស្រែ ខាងជើងវត្តសោមនស្ស

ហើយត្រូវគេក៏បញ្ជូននាងចូលមន្ទីរឃុំឃាំងសួរចម្លើយមួយ នៅវត្ត ឯកភ្នំ បាត់ដំបង ។

នាងបានត្រូវគេវាយដកក្រចកមេដៃទាំងពីរ សួរចម្លើយសព្វ យ៉ាងតាំងពីប្រវត្តិខ្លួន រហូតដល់ប្រវត្តិឪពុកម្តាយ តែនារីមិនព្រម តបអ្វីទេ ម្ល៉ោះហើយ គេក៏ធ្វើបាបនាងរិតតែធ្ងន់ធ្ងរឡើងៗរៀងរាល់ ថ្ងៃ ។ ជួនកាល ពួកយោធាទាំងនោះចងដៃចងជើងនាងនឹងកាំរទេះ គោ រួចហើយអោយគោអូសរទេះទៅមុខទៅក្រោយ រហូតដល់ និមលធ្លាក់ឈាមពីមាត់ពីច្រមុះ ។ ជួនគេក៏ចងជើងនាងឡើងលើ ហើយបង្កាត់ភ្លើងផ្សែងពីក្រោម បំពក់ទាល់តែនាងឈ្លក់សន្លប់នៅក្នុងចំណងតែម្តង ។ មានកាលខ្លះ ពួកយោធាទាំងនោះ ចាប់ក្បាល នាងអោយដាំចុះទៅក្នុងធុងទឹកគម្រង់ រហូតដល់នាងឈ្លក់សន្លប់ បាត់មាត់ទើបព្រលែងចោល ។ ថែដន្យ និមលជាមនុស្សក្បាលរឹង ម្នាក់ ដែលមិនព្រមចុះចាញ់បណ្តាសារបស់យមរាជដោយងាយៗ ឡើយ ។ មាណវី តែងតែដឹងខ្លួនមកវិញដោយឯកឯង រៀងរាល់ ដង មិនដឹងថា មកពីហេតុអ្វី...

នៅរាត្រីមួយ ក្រោមពន្លឺច័ន្ទមួយចំណិតនិងហ្វូងផ្កាយ ពពួក យោធាចាប់បណ្តើរអ្នកទោសជាខ្សែ ចេញពីមន្ទីរឃុំឃាំងទៅ ដោយ មាននិមលជាអ្នកទោសដើរទទ្រេតទទ្រោត យ៉ាងវេទនា នៅចុង កន្ទុយគេបង្អស់ហើយយ៉ាប់យ៉ឺនជាងគេផង ។ ពេលនោះ នាងបាន ដឹងខ្លួនច្បាស់ណាស់ថា ពួកយោធាកំពុងនាំអ្នកទោសទាំងអស់នោះ ទៅសម្លាប់ចោល រួមទាំងរូបនាងដែរ ។ មាណវីក៏ប្រមូល កម្លាំងតាំងស្មារតីក្លាហាន នៅរយៈពេលចុងក្រោយនោះ ហើយក៏ បន់ស្រន់នឹកដល់គុណមាតាបិតាជាប់ជានិច្ចថា ៖

- ចំពោះគុណទឹកដោះម៉ែថ្លៃ...! ចំពោះគុណលោកឪពុកដែលបាន អោយកំណើត អោយជីវិត និងអ្វីៗសព្វយ៉ាងដល់កូន... កូនមិនឲ្យ លោកអស់ទឹកចិត្តដោយសារកូនទេ ។ ពេលនេះ កូននឹងធ្វើអ្វីម្យ៉ាង ហើយ... កូនមិនអោយជីវិតរបស់កូនរលត់ទៅដោយអាសារឥតការ

CHANBOKEO.COM

ឡើយ ។ សូមបារមីវត្ថុសក្តិសិទ្ធិជួយតម្រែតម្រង់ផ្លូវកូនផង ។

ដោយសំអាងថា ពួកខ្លួនសុទ្ធតែមានកាំភ្លើងជាប់ដៃគ្រប់គ្នាផង ហើយដោយអ្នកទោសទាំងនោះសុទ្ធមានជម្ងឺ មានរបួសធ្ងន់ធ្ងរពីទារុណកម្មសួរចម្លើយរបស់ពួកគេវាយដំនោះផង ពពួកកងយោធា និងកងឈ្លបទាំងនោះប្រហែសមិនបានដាក់ខ្នោះអ្នកទោសទេ ។ គេគ្រាន់ក្រមារបស់អ្នកទោសចងដៃអ្នកទោសវិញប៉ុណ្ណោះ ។ និមលបានលួចរើរបូតចំណងក្រមានោះតាមផ្លូវ ។ លុះដើរមកដល់មាត់រណ្តៅមួយដែលគេជីករង់ចាំគំនរសពអ្នកទោស និមលក៏ប្រមូល កម្លាំងជាចុងក្រោយហក់យ៉ាងរហ័ស ឆក់បានកាំភ្លើងមួយដើមពីដៃ យោធាក្មេងម្នាក់ រួចហើយក៏ឆ្មេចភ្នែកលើកកាំភ្លើងបាញ់រះ ពេញ ទំហឹងប្រាថ្នាយកស្លាប់ទាំងអស់គ្នានៅពេលនោះតែម្តង ។ ការពិត និមលធ្លាប់បានហាត់កម្សាន្តរៀនប្រើកាំភ្លើងពីមុនមក ម្ល៉េះហើយ នាងអាចនៅចាំតិចៗថាតើគេប្រើកាំភ្លើងរបៀបណា ។ រីពួកយោធា ដែលមិនបានប្រុងប្រយត្ន័ខ្លួនក៏ត្រូវគ្រាប់រះចំឆ្អឹងៗដួលគ្រេងៗអស់ ជាច្រើននាក់ ។ រំពេចនោះ ពួកយោធាក៏ទាញកាំភ្លើង បាញ់រះត្រឡប់ទៅលើអ្នកទោសទាំងឡាយតបមកវិញយ៉ាងឃោរឃៅ ទាំង កណ្តាលយប់ងងឹតធ្វើឲ្យភាពចលាចលមួយរំពេច ។ រំពេចនោះ ធិតាយើងមានអារម្មណ៍ថាមានគេវាយនាងមួយត្រាកាំភ្លើងឬមួយ ដំបងយ៉ាងខ្លាំង ចំលលាដ៏ពីក្រោយ រួចហើយនាងក៏វិលមុខខ្វាល់ ដួលប្រួសធ្លាក់ចូលក្នុងរណ្តៅ លែងដឹងខ្លួនតទៅទៀត មិនដឹងថាស្ថានការណ៍បន្តទៅទៀតនោះ យ៉ាងណាខ្លះឡើយ ។

ព្យុះសង្ឃរាយ៉ាងធំមួយបានបង្ហុរមកលើពសុធា ដោយមាននាំមកនៅផ្គររន្ទះផ្ទុងផាំងគួរអោយព្រឺខ្លាច ។ និមលក៏ប្រែខ្លួនឡើងឃើញសុទ្ធតែគំនរសាកសពជុំវិញខ្លួនរបស់នាង ។ ពេលនោះ នារី មានអារម្មណ៍ថាខ្លួននាងរងាយ៉ាងខ្លាំង ស្ទើរទ្រាំមិនបាន ។ បន្ទាប់ ពីប្រមូលកម្លាំងនិងស្មារតីបានមកវិញនាងក៏ប្រវេប្រវាលូនចេញពី រណ្តៅឡើងមកខាងក្រៅ ធ្វើដំណើរទាំងតតេះតតះទាំងកណ្តាលព្យុះដ៏សាហាវ ។ និមលដើរផងលូនផង តាមតែកម្លាំងអាចធ្វើទៅបាន.. រីឯពន្លឺផ្លេកបន្ទោរភ្លែតៗចាំងជះមកលើប្រថពី បានបញ្ចាំងនូវ ទិដ្ឋភាពជុំវិញនារីហាក់បីដូចជានាងកំពុងតែយល់យល់សប្តិដូច្នោះឯង

CHANBOKEO.COM

ព្រោះនាងភ្លេចអស់ការឈឺចាប់លើស្នាមរបួសនោះអស់រលីងតែម្តង គ្រាន់តែដឹងថា នាងចង់រត់ទៅរកឪពុកម្តាយរបស់នាងវិញ ដើម្បី ជួបមុខលោកជាចុងក្រោយ ។ ពេលនោះ មាណវីក៏មិនដឹងដែរ ថា នាងត្រូវដើរ រកឪពុកម្តាយនៅទីណាទេ ក្រៅតែពីចេះតែដើរៗទៅ អោយផុតពី បរិវេណវាលពិឃាដនោះ តែប៉ុណ្ណោះ ៖

- ម៉ែ! ពុក! នៅទីណា ? សូមជួយកូនផង...!

ភ្លឺស្រាងៗ និមលបានដើរទ្រេតទ្រោតមកដល់ភូមិមួយ ឃើញ អ្នកស្រុកកំពុងស្ងួង ក៏គេចចូលភូមិ ទៅលួចខោអាវអ្នកភូមិយកមក ផ្លាស់ ហើយលើកដៃប្រណម្យស្រដីថា ៖

- អោយខ្ញុំសុំទោសដែលខ្ញុំត្រូវលួចខោអាវរបស់លោកអ្នកពេលនេះ សូមមេត្តាអភ័យទោសដល់ខ្ញុំផង ហើយសូមឲ្យលោកសុខសប្បាយ តរៀងទៅ ។

ធិតាយើងលួចបានបាយហាលមួយបង្វិច រួចហើយក៏លូនគេច ចូលព្រៃវិញ រស់នៅគ្មានក្រុមគ្មានកង រស់នៅដោយសារផ្លែឈើ ព្រៃ និងស្រូវឬពោតដែលគេដាំតាមវាល អស់ជាច្រើនអាទិត្យ រហូតដល់ពេលមួយដែលនាងទទួលជម្ងឺគ្រុនចាញ់ជាទម្ងន់ដោយការ ដេកនៅព្រៃហាលភ្លៀងហាលខ្យល់ជាយូរខែ ។ ទីបំផុត និមលក៏ ត្រូវដួលដេកនៅលើភ្លឺស្រែមួយដើបលែងរួចតែម្តង ។ សំណាងល្អ នាងបានត្រូវអ្នកភូមិសប្បុរសម្នាក់ ជួយសង្គ្រោះយកអាសារនាំទៅ ភូមិ ។ ក្រោយមកគេក៏ជួយនាងអោយបានរស់នៅមានក្រុមមានកង នឹងគេវិញ ។ ចាប់តាំងពីពេលនោះមក និមលបានលួចដូរឈ្មោះថ្មី មួយថា មិត្តដៅល ។ ដោយឃើញភាពទុរន់ទុរារបស់នាង អ្នកភូមិ នោះក៏អោយនាងធ្វើការនៅរោងចិញ្ចឹមជ្រូក ជាអ្នកដាក់បបរអោយ ជ្រូកស៊ី ។ ធិតារស់នៅលាក់ខ្លួន ព្យាបាលជម្ងឺដោយវិធីផ្សំថ្នាំឫស ឈើបុរាណ តាមដែលអ្នកភូមិគេប្រាប់ ។ មិនយូរប៉ុន្មាន ជម្ងឺគ្រុន ចាញ់របស់នាងក៏បានធូរស្រាលមកវិញ ។

ក្រោយមក និមលបានស៊ើបដំណឹងថា ម្តាយនាងនៅរស់ឯ ភូមិត្រាងដដែល ប៉ុន្តែ ប្អូនៗនឹងឪពុករបស់នាង បានចេញចល័ត គ្រប់ទីកន្លែងតាមដែលអង្គការចាត់តាំង មិនដែលបានមកភូមិវិញ ទេ ។ សព្វថ្ងៃនោះ គ្មាននរណាដឹងទេ ថាអ្នកទាំងនោះត្រូវអង្គការ ចាត់តាំងទៅខាងណា ។ និមលលួចសន្សំបានបាយក្រៀមពីរកំប៉ុង និងដំឡូងពីរបីដុំ ក៏វេចបន្លំនឹងបាច់ត្រកួនមួយទំនួលដែលនាងបេះ ពីវាលស្រែសំរាប់ដាក់រោងបាយការដ្ឋាន ។ ថ្ងៃនោះ នាងធ្វើពើជា វង្វេងផ្លូវ ខំដើរតាំងពីវាលទ្រារហូតដល់ត្រាង តាមរកម្តាយនាង

CHANBOKEO.COM

របូតដល់បានជួបដូចបំណង ។ មីងនិមលស្រវាអោបកូនយំខ្សឹក ខ្សួលអស់ជាយូរ ទំរាំមីងស្រដីចេញ សួរកូនស្រីថា ៖

- សុខសប្បាយទេ និមលកូន ?

និមលរួលដើមកនិយាយមិនចេញទេ កាលបើឃើញម្តាយនាង ស្គាំងស្គម ហើមមុខប៉ផ្លូសដោយការអត់អាហារនិងជំងឺរ៉ាំរ៉ៃ គ្មានថ្នាំព្យាបាលក្រៅពីស្មោះដើមត្របែកស្ងោរប៉ុណ្ណោះ ។ មីងមណីរស់នៅយ៉ាងកណ្តោចកណ្តែងនៅក្នុងភូមិមួយ ដែលគាត់គ្មានស្គាល់នរណា ទាំងអស់ ព្រោះសាច់ញាតិទាំងឡាយត្រូវអង្គការជន្លៀសចេញទៅ ធ្វើការកន្លែងផ្សេងៗអស់គ្រប់គ្នា ។

- នែះ ! ខ្ញុំមានដំឡូងនិងបាយក្រៀមយកមកផ្ញើម៉ែ (និមលវាចា)

- ទុកញុំាខ្លួនឯងទៅកូន! ម៉ែមានរបបជាបបរ មួយថ្ងៃពីរពេល ដែរ មិនអត់ពោកទេ ។

- បបរមួយវែក ដែលស្ទើរតែរកគ្រប់អង្ករមិនឃើញនោះ មិនអាចជួយអោយម៉ែឆាប់ជាពីជម្ងឺទេ ។ ម៉ែទុកអីវ៉ាន់នេះពិសារចុះ ព្រោះកូនអាចរកទៀតបាន ។

នៅសម័យនោះ អង្គការខ្មែរក្រហមបានចេញបញ្ជាអោយប្រើ ពាក្យម៉ែពុកតែម្យ៉ាងប៉ុណ្ណោះ សំរាប់ហៅឪពុកម្តាយ ។ នរណាដែល ហ៊ានប្រើពាក្យអ្វីផ្សេងនោះនឹងត្រូវទទួលទោសពីអង្គការ ។

- ហើយចុះពេលនេះ កូននៅឯណាដែរ (មីងមណីសួរ)

- ចាស នៅវាលទ្រា ។

- នៅវាលទ្រា ? ម៉ែឮដំណឹងពីអ្នកស្រុកមកថា ប៉ារបស់កូន កំពុងធ្វើការងារកងចល័តនៅវាលទ្រានោះដែរ ។

- អូហ៍! អញ្ចឹងកូនត្រឡប់ទៅរកគាត់វិញសិន ។

និមលរៀបរបនឹងចេញដំណើរទៅហើយ ស្រាប់តែមីងមណីឃើញកងឈ្លបម្នាក់ជិះកង់កាត់មុខផ្ទះ ។ គាត់ក៏ធ្វើសញ្ញា អោយ និមលរត់ពួននៅគុម្ពឫស្សីមួយ ។

- មិត្តមីង! ធ្វើអីច្រឹមច្រុំៗនៅក្រោយខ្ទម ?

យោធានោះសួរមីងមណីដែលកំពុងឈរញ័រខ្លួនចំប្រប់ ។

- គឺ... មីងកំពុងរកចបជីក ទៅរកបត់ដើងបន្តិច មិត្តក្មួយ ។

- អញ្ចឹងទេ ? បើអញ្ចឹងទៅចុះ តែកុំលួចជីកដំណាំក្រោយផ្ទះ មក ហូបតែម្នាក់ឯង ក្បត់អង្គការអោយសោះ ប្រយត្ន័មានទោស ។

ថាហើយ នាយយោធានោះក៏ជិះកង់ចេញទៅ ។ មីងមណីយក ដៃបបោសដើមទ្រូងបន្ធូរក្តីភិតភ័យ ។ ការពិត ពីម្សិលមិញ មាន ពូម្នាក់ត្រូវកងឈ្លបសម្លាប់ចោលម្នាក់ហើយ ព្រោះអីគាត់ឃ្លានខ្លាំង ពេក ក៏ចូលបេះត្រឡាចដែលគាត់ដាំនៅក្រោយផ្ទះ យកមកស្ងោរ បរិភោគ ទទួលពួកកងឈ្លបខ្មែរក្រហមឃើញទាន់ ក៏ចោទថាគាត់ ក្បត់អង្គការ ក្បត់សមូហភាពក្នុងភូមិ ហើយក៏បណ្តើរយកទៅ វាយសម្លាប់ចោលនៅវាលស្រែក្បែរខ្ទមគាត់នោះតែម្តងទៅ ។

- ម៉ែ! ខ្ញុំមិនអាចនៅយូរបានទេក្រែងនាំគ្រោះថ្នាក់ដល់ម៉ែ... សូម ម៉ែថែខ្លួនផង ។

- ពេលនេះ កូនគិតទៅខាងណាវិញ ?

- ទៅរកពុកនិងប្អូនៗ ។

- អញ្ចឹង ម៉ែផ្តាំទៅផង ថាម៉ែនឹកពុករបស់កូន ហើយនឹកកូនម៉ែ គ្រប់ៗគ្នា

(មីងមណីស្រដីទាំងសម្លេងរអួលអាក់បំផុត)

- ចា៎ស! បើសិនជាអាច កូននឹងវិលមករកម៉ែទៀត ។

- ថែខ្លួនណា៎កូន! ប្រយត្ន័ប្រយ័ងផង ក្រែងលោពួកយោធាចាប់ កូនធ្វើទោសទារុណ ។

- ចា៎សម៉ែ!

ក្រោយពីសំពះលាម្តាយហើយ នាងក៏ធ្វើដំណើរត្រឡប់ទៅវាល ទ្រាំវិញមុនព្រលប់ ដើម្បីទៅរកឪពុករបស់នាង ។ តាមផ្លូវ និមល បេះបានផ្លែក្រឡោមភ្លុកតាមវាលស្រែបានបួនប្រាំ យកទៅផ្ញើឪពុក របស់នាង ។ សំណាងល្អ នាងបានប្រទះឃើញនិសាទើបនឹងឡើង ពីស្ទូងជាមួយមិត្តនារីប្រាំបួននាក់នៅកណ្តាលស្រែមួយ ។ និមល ក៏នៅរង់ចាំទាល់តែជិតព្រលប់ទើបលបស្តាត់ទៅជួបប្អូន ។ កាលបើ ជួបគ្នាហើយ ទាំងពីរនាក់ក៏ប្រវាអោបគ្នាយំសសឹកដោយក្តីរលឹក ។ ពេលនោះ និសាមានជំងឺមួលឈាមធ្វើឲ្យសាច់ឈាមនាងស្លេកស្លាំង ហើមមុខហើមដៃជើងស្តូល មើលមិនយល់ទេ ។ និមលជូតទឹកភ្នែក រួចហើយក៏ហែកអីវ៉ាន់ពាក់កណ្តាលអោយប្អូន ទុកពាក់កណ្តាលផ្ញើ ឪពុក ។ ពេលនោះ និសាលើដៃចង្អុលទិសប្រាប់ថា ៖

- ពុកយើងស្នាក់នៅស្រែខាងនោះ រំលងពីរស្រែ ដល់ហើយ ។ គាត់សំរាន្តនៅក្រោមដើមឈើមួយ ជិតផ្នូរខ្មោចមួយគូ លើទួល ក្រសាំង ។

CHANBOKEO.COM

- ថៃខ្លួនណា៎និសា! បងទៅសិនហើយ មិនដឹងថ្ងៃណាយើងជួបគ្នា ទៀតទេ...

និសាឈរសម្រក់ទឹកភ្នែកមើលតាមបងស្រីរហូតបាត់ស្រមោល ទៅ ។ មួយសន្ទុះធំក្រោយមក និមលក៏បានមកដល់ទួលដើម ក្រសាំងដែលឪពុកនាងស្នាក់នៅ ។ គ្រាន់តែក្រឡេកឃើញមុខកូនស្រីភ្លាម លោកគ្រូសុធីបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល ព្រោះ លោកបែកពីនាងយូរខែហើយមិនដែលមានដំណឹងពីគ្នាទេ ។ លោកគ្រូក៏អូសដៃកូនដើរចេញទៅវាលស្រែ អង្គុយនិយាយគ្នាស្ងាត់ៗ ៖

- និមល! សុខទុក្ខយ៉ាងណាដែរកូន ?
- កូនមិនអីទេ តែនឹកបារម្ភពីពុកម៉ែនិងប្អូនៗណាស់ ។
- កូនបានជួបម៉ែហើយឬនៅ ?
- ចា៎ស ជួបហើយប៉ា ។
- ហើយ... ម៉ែរបស់កូនសុខសប្បាយទេ ?

លោកគ្រូសួរព្រោះតែក្តីបារម្ភពីប្រពន្ធ ថ្វីបើខ្លួនលោកវិញក៏បាន ដឹងរួចហើយ ថាពេលនោះ គ្មាននរណាម្នាក់សុខសប្បាយទេ គ្រាន់ តែលោកមានប្រសាសន៍អោយធូរទ្រូងតែប៉ុណ្ណោះ ។

និមលមិនទាន់បានឆ្លើយយ៉ាងណាផង ស្រាប់តែឪពុកនាងយក ដៃចាប់ក្បាលនិមលអោយបែរ ហើយក៏លាន់មាត់សួរថា ៖

- ហេតុអ្វីក្បាលរបស់កូនមានដំបៅគយៀរ អញ្ជឹង និមល ?

និមលមិនហ៊ានប្រាប់ឪពុកទេ ថាដំបៅខួបនោះ គឺជារបួសដែល នាងបានទទួល ពីត្រាកាំភ្លើងរបស់នាយកងយោធាខ្មែរក្រហមម្នាក់ នៅមាត់រណ្តៅមរណៈ ។  ការពិត ដោយការខ្វះរសជាតិអាហារ ខ្វះថ្នាំ និងអនាម័យ ដំបៅរបស់នាងកាន់តែរីកធំទៅៗរាល់ថ្ងៃ ។

- គឺក្តារផ្ទះធ្លាក់លើ ពេលអង្គការប្រើខ្ញុំឲ្យទៅជួយធើផ្ទះអ្នកស្រុក...
- អញ្ជឹង មកនេះ! ពុកលាងដំបៅអោយ ។

លោកគ្រូក៏យកជាយក្រមា ជ្រលក់ទឹកវាលស្រែថ្លាៗមកជូតលើ មុខដំបៅរបស់កូនបន្តើរៗ រួចហើយមានប្រសាសន៍ថា ៖

- សូមអោយឆាប់ជាណា៎កូនណា៎ ។

ពេលនោះ និមលដឹងហើយ ថាទឹកវាលស្រែមិនអាចលាង ដំបៅរបស់នាងអោយជាសះស្បើយបានទេ ប៉ុន្តែ នោះគ្រាន់តែជា មធ្យោបាយព្យាបាលតែម្យ៉ាង ដែលលោកអាចមានសមត្ថភាពផ្តល់ អោយកូននាគ្រានោះតែប៉ុណ្ណោះ ។ នាងរលីងរលោងទឹកភ្នែក

CHANBOKEO.COM

នឹក អាណិតឪពុកនាងណាស់ ដែលនៅតែស្រឡាញ់ថ្នាក់ថ្នមកូន មិនថា ពេលណាទេ ។ បន្តិចមក លោកគ្រូក៏យកដៃច្បូតសក់កូនស្រី ដែល ដុះរុយៗខ្លីៗ ហើយមានប្រសាសន៍លើកទឹកចិត្តនាងថា ៖

- ពេលកូនជាដំបៅ សក់នឹងដុះវិញហើយណា៎កូន ។ កូនមិនទំពែក ដូច្នេះតទៅទៀតទេ ។

និមលញញឹមទាំងទឹកភ្នែករលីងរលោង ហើយឆ្លើយថា ៖

- កូនមិនគិតទេ ពុក...ថាកូនមានមុខមាត់យ៉ាងម៉េច ។ អ្វីដែលកូន ចង់បានបំផុតនៅពេលនេះ គឺការជួបជុំរបស់ក្រុមគ្រួសារយើង ។
- ពុកក៏បន់ស្រន់ដូចគ្នាអញ្ចឹងដែរ និមល! ប៉ុន្តែ មិនដឹងថា ពុកមានសំណាងដូច្នោះដែរឬក៏យ៉ាងណាទេ ។ ប៉ុន្មានថ្ងៃនេះ ពុក មានប្រផ្នូលក្នុងចិត្ត មិនល្អទាល់តែសោះ ជាពិសេស តាំងពីមានអ្នក ស្រុកខ្លះគេលួចខ្សិបប្រាប់ពុកអោយរត់គេចខ្លួនពីទីនេះ ។ ប៉ុន្តែពុក មិនដាច់ចិត្តរត់ចោលម៉ែរបស់កូន និងកូនៗគ្រប់គ្នាទេ ។ បើពុក នៅធ្វើការម្ដុំៗនេះ ពុកនៅមានឱកាសអាចទទួលដំណឹងពីកូននិង ម៉ែរបស់កូនខ្លះៗ មិនដាច់ដំណឹងពេកទេ ថ្វីបើយើងមិនដែលបាន ជួបមុខគ្នាសោះ ក៏ដោយ ។
- ពុកកុំជឿប្រផ្នូលអី! ខ្ញុំគិតថាយើងប្រហែលជាបែកគ្នាមិនយូរទេ បន្តិចទៀត យើងជួបជុំគ្នាវិញហើយ ។

លោកគ្រូសុធី ធ្វើមុខខ្មៅ ហើយសម្លឹងមុខកូនទាំងទឹកភ្នែក រលីងរលោង ៖

- បើអាចធ្វើបាន សូមកូនជួយតាមមើលប្អូនៗផងណា៎ ។ ពុកបាន ឮដំណឹងថា និវត្ត និស្ស័យ និងនិរន្ត ត្រូវអង្គការបញ្ជូនទៅច្រូត ស្រូវនៅសំឡូតអស់ហើយ ។ ចំណែកនិសា គេស្នាក់នៅស្រែម្ខាង ខាងនោះរហូតផុតរដូវស្ទូង រួចគេនឹងបែកទៅទិសផ្សេងទៀត តាមការចាត់តាំងរបស់អង្គការ មិនដឹងថា ពេលណាបានជួបគ្នាទេ ។ ចំណែកប្អូនស្រីចិញ្ចឹមរបស់ឯង បានសំរេចចិត្តលាចាកគ្រួសារយើង ចូលធ្វើកងយោធានារីរបស់អង្គការ លែងត្រឡប់មកវិញហើយ ។ កូន! កុំភ្លេចទៅមើលម៉ែផង ។ គេមានសុខភាពទន់ខ្សោយតាំងពី ក្មេង មិនដឹងថាពេលនេះ គេអាចទ្រាំទ្រនឹងការលំបាកអត្តខាត់បាន ប៉ុនណាទេ ។ ពុកនឹកកូនៗទាំងអស់គ្រប់គ្នាហើយពុកក៏នឹកម៉ែរបស់ កូន តែពុកពុំមានលទ្ធភាព អាចលួចរត់ទៅជួបម៉ែកូនម្ដងណាទេ... ព្រោះពួកយោធាវាឃ្លាំមើលពុក ដូចភ្នែកម្ទាស់អញ្ចឹង ។

CHANBOKEO.COM

ទឹកភ្នែកជាច្រើនដំណក់ក៏ស្រក់ចុះបន្តគ្នា លើផ្ទៃមុខដ៏ជ្រីវជ្រួញ ស្គាំងស្គមស្លេកស្លាំងរបស់លោកគ្រូសុធី ។ និមលឃើញដូច្នោះ ក៏ ស្រវាចាប់ដៃឪពុកមកកាន់ ដើម្បីលួងលោមចិត្តរបស់លោក ស្រាប់ តែនាងភ្ញាក់ព្រើត ព្រោះឃើញដៃលោកញ័រដៃទទ្រើកហើយត្រជាក់ ស្រេបដូចទឹកកក ធ្វើអោយធិតានឹកពិភាល់ក្នុងចិត្តភ្លាមតែម្តង ៖

- ពុក! ពុកកំពុងមានជំងឺមែនទេ ចា៎ស ?

- គ្រាន់តែជាជម្ងឺគ្រុនចាញ់បន្តិចបន្តួចទេ កូន! ស្មោះសំបកស្តៅ ដាំយកទឹកផឹកទៅ ពុកនឹងជាវិញហើយ ។ កូនកុំបារម្ភអី ។

មែនហើយ! ការពិតលោកគ្រូសុធីមានសុខភាពត្រដាបត្រដួស ណាស់ ប៉ុន្តែលោកមិនដែលរអ៊ូត្អូញត្អែម្តងណាទេ ព្រោះលោក សង្ឃឹមថា ថ្ងៃណាមួយ លោកនឹងអាចជាសះស្បើយ ហើយអាចវិល ទៅជួបប្រពន្ធកូនរបស់លោកវិញ ។ ពេលនេះ និមលហាក់ដូចជា រន្ធត់តក់ស្លុតក្នុងចិត្តអ្វីម្ល៉េះទេ កាលបើឃើញឪពុកមានទឹកមុខខ្មៅ ជាំ រូបកាយខៀវស្គាំងស្គមខុសធម្មតា ។ បើតាមនាងគិត... ឪពុក របស់នាងប្រហែលឆ្លងមិនរួច ពីឆ្នាំនេះឡើយ ។

- និមល! កូនមានពិការភាពខាងផ្លូវកាយពិតមែន តែពុកជឿថា កូនមានស្មារតីរឹងមាំជាងគេ ក្នុងចំណោមបងប្អូនទាំង៥នាក់ ។ ចូរ កូនថែរក្សាខ្លួន រក្សាម៉ែនិងប្អូនៗផងណា៎ ពេលណាអត់ពីពុកទៅ ។ ពិតមែនតែរបបរបស់អង្គការ មានភាពសាហាវយង់ឃ្នងលើជីវិត យើងយ៉ាងណាក៏ដោយ ក៏ប៉ាជឿថា កូនស្រីរបស់ប៉ាប្រាកដជាមិន ព្រមទទួលឥទ្ធិពលនោះឡើយ! ពួកគេមានអំណាចអាចបំបែក យើងចេញពីគ្រួសារបាន អាចបង្អត់បាយយើងបាន អាចរិបអូស យកទ្រព្យសម្បត្តិរបស់យើងបាន អាចសម្លេះជីវិតរបស់យើងបាន គ្រប់វេលា ប៉ុន្តែអ្វីដែលគេមិនអាចប្លន់យកពីយើងទៅបាននោះ គឺ សេចក្តីស្រឡាញ់ ដែលយើងមានចំពោះគ្នាទៅវិញទៅមក ក្នុង គ្រួសារ ។ ម្យ៉ាងវិញទៀត ពួកគេអាចសម្លេះជីវិតរបស់យើងបាន ដោយងាយ តែគេមិនអាចសម្លាប់ឧត្តមគតិរបស់យើងបានឡើយ ។ បើសិនប៉ាត្រូវស្លាប់លាលោកនេះទៅ ឧត្តមគតិរបស់ប៉ាមិនត្រូវស្លាប់ តាមរូបប៉ាឡើយ ។ នៅគ្រាមួយនាអនាគត ឧត្តមគតិទាំងនោះនឹង រស់ឡើងវិញហើយនឹងកើនចំនួនឡើងដូចផ្សិតមិនខាន... ប៉ាទុកចិត្ត និមលជាងគេ

CHANBOKEO.COM

ថាកូននឹងក្លាយជាស្ពានមាសមួយ នាំចម្លងឧត្តមគតិ ទាំងនោះអោយទៅដល់ត្រើយយ៉ាងជោគជ័យ ក្នុងចំណោមស្ពាន
ទាំងឡាយដែលប៉ាបានសាងសង់ ទៅលើក្មេងជាច្រើនរាប់មិនអស់...

និមលយល់ប្រសាសន៍លោកភ្លាម ថាលោកកំពុងចង់មានន័យ ថាម៉េច ។ នាងក៏តបទៅវិញថា ៖

- បើសិនកូននៅមានជីវិត កូននឹងសង់ស្ពានមាសនោះមិនខាន ហើយកូននឹងនាំពុកព្រមទាំងក្រុមគ្រួសារយើង ឆ្លងទៅរកត្រើយដ៏ ភ្លឺត្រកាលទាំងអស់គ្នា ។
- អរគុណណាស់ កូនស្រី! សូមអោយកូនមានជីវិតយឺនយូរ ចាក ផុតនូវអន្តរាយទាំងពួង ។

លោកគ្រូសុធីក៏យកដៃអង្អែលក្បាលកូនថ្នមៗដោយក្តីស្រឡាញ់ បំផុត ។ បន្តិចមក និមលក៏សំពះលាឪពុកត្រឡប់ទៅវិញ ព្រោះ ពួកកងឈ្លបចេញដើរយាមច្រវាត់ច្រវែងពេញវាលច្រើនពេក ខ្លាច គេចាប់នាងនិងឪពុកវាយធ្វើបាបទៀត ៖

- និមលស្រឡាញ់ពុកណាស់ ហើយបារម្ភពីពុកជានិច្ច ។
- ពុកក៏ស្រឡាញ់កូនហើយបារម្ភពីកូនជានិច្ច... ថែខ្លួនណ៎ាកូនណ៎ា!

លោកគ្រូសុធីថើបក្បាលកូនស្រីបន្តើរៗជាចុងក្រោយ ព្រមជា មួយនឹងស្នាមញញឹម លើផ្ទៃមុខដ៏ជ្រីវជ្រួញរបស់លោក ដើម្បីជូន ដំណើរកូន ។ ឯនិមលលើកដៃបន់ទាំងទាំងភ្នែកទៅមេឃថា ៖

- សូមមេឃដ៏សក្តិសិទ្ធិជួយតាមថែរក្សាពុកឲ្យបានសុខសប្បាយផង ដើម្បីអោយឆាប់បានវិលត្រឡប់ទៅជួបនឹងម៉ែវិញ ។

ថ្វីបើទឹកភ្នែករាប់លានដំណក់ស្ទុះរមៀលចេញមក កាត់ចង្វាក់ ខ្លះក៏ដោយ លោកគ្រូសុធីនៅតែប្រឹងញញឹមផ្តល់កម្លាំងចិត្តដល់កូន ស្រី រហូតដល់នាងដើរចេញឆ្ងាយ ផុតកន្ទុយភ្នែករបស់លោកទៅ ។ ពេលនោះ និមលមិនបានត្រឡប់ទៅវាលទ្រាវិញទេ ព្រោះនាង បានរត់ចេញពីភូមិពីរបីថ្ងៃហើយ មិនដឹងថា អង្គការមានកើតការ សង្ស័យលើនាងយ៉ាងណាខ្លះឡើយ ។ បើនាងត្រឡប់ទៅវិញ តើគេ នឹងដាក់ទោសនាងយ៉ាងណាខ្លះទៅ ។ មាណវីអង្គុយលើភ្លឺស្រែ គិត ចុះគិតឡើង ក៏សំរេចចិត្តវិលទៅរកម្តាយរបស់នាងដែលរស់នៅឯ ភូមិត្រាងវិញ ។

CHANBOKEO.COM

- កូនរស់នៅជាមួយម៉ែក៏បានដែរ ចាំម៉ែរំលែកបបរដែលជារបប របស់ម៉ែចែកកូនទទួលទាន នោះយើងនឹងរស់បានទាំងអស់គ្នា ។

មីងមណីនិយាយលោមចិត្តកូន ខ្លាចកូនរត់ចេញទៅវិញ ព្រោះ គាត់គ្មានអ្វីចែកអោយកូនបរិភោគ ។

- មិនអីទេ ម៉ែ! សូមកុំភ័យអី! កូនមានមធ្យោបាយជួយខ្លួន ឯងហើយ ម៉ែមិនពិបាករំលែកបបរ របបរបស់ម៉ែអោយកូនទេ ។

និមលសំរេចចិត្តពួនលាក់ខ្លួនជាមួយម្តាយនាងស្ងាត់ៗ បណ្តោះ អាសន្នសិន សង្ឃឹមថាអាចចាកផុតពីគ្រោះថ្នាក់មួយពេល ។

ព្រហាមស្នែកឡើង...

អ្នកភូមិម្នាក់បានយកបារីមូរដៃមួយដើម មកផ្ញើមីងមណី ៖

- កូនស្រីរបស់មីង ឈ្មោះមិត្តសា ផ្ញើបារីមូរដៃនេះមកអោយមីង ដក់ព្យាបាលជំងឺ ។ គេផ្តាំខ្ញុំអោយយកមកឲ្យមីងដោយផ្ទាល់ដៃ ។

- អឺ! មីងអរគុណណាស់ក្មួយ ។

លុះអ្នកភូមិនោះចេញបាត់ មីងមណីក៏ហែកបារីនោះ បោសថ្នាំ ដក់ចេញឃើញមានចំណាររល្អិតៗសរសេរលើក្រដាស ថា ៖

- ម៉ែ! កងយោធាបានចាប់ខ្លួនប៉ាចេញទៅកាលពីយប់មិញ នៅ ពេលពាក់អាធ្រាត បាត់ទៅហើយ ព្រមជាមួយអតីតគ្រូបង្រៀនពីរ នាក់ទៀត... និសា!

ស្រាប់តែមីងមណីស្លុតចិត្តងងឹតមុខឃើង ដួលប្រូសទៅលើដី សន្លប់បាត់ស្មារតីភ្លាមមួយរំពេច ។ និមលលួចមើលពីគុម្ពឫស្សី ដែលនាងកំពុងពួនសម្ងំ ឃើញម្តាយដួលសន្លប់ ក៏ស្ទុះចេញមក អូសម្តាយទៅដាក់លើកន្ទេល ក្នុងខ្ទមកញ្ជាស់តោកយ៉ាករបស់គាត់ ភ្លាម រួចហើយនាងក៏ទាញកូនចំណារនោះមកអាន ស្រាប់តែនាង មានអារម្មណ៍ថាបេះដូងរបស់នាងលោតភិបៗស្ទើរតែធ្លាយទ្រូងមក ក្រៅ រិះតែសន្លប់បាត់ស្មារតីទៅម្នាក់ទៀតដែរ ៖

- ពុទ្ធោ ប៉ា!

និមលស្រក់ទឹកភ្នែកច្រោកដោយក្តីតក់ស្លុតរន្ធត់ក្នុងចិត្តតក្កមា ។ ពេលនោះ និមលដឹងហើយ ថាឪពុករបស់នាងនឹងត្រូវទទួលទោស ទារុណបែបណា នៅពេលដែលលោកត្រូវគេចាប់ខ្លួនយកទៅ ព្រោះ នាងធ្លាប់ហែលឆ្លងនូវទុក្ខអវិចីនោះរួចហើយ...

CHANBOKEO.COM

ពេលនោះដើមទ្រូង របស់នាងក៏ចាប់ឈឺខ្លោចៗឡើង... ទឹកភ្នែកក៏ចេះតែហូរមកដោយ ឯកឯង... ធិតាខាំធ្មេញក្រឹតៗ ដោយភាពក្តៅរអួលណែនក្នុងចិត្ត ៖

- ហេតុអ្វីមនុស្សស្លូតត្រង់ដូចប៉ា ត្រូវទទួលទារុណកម្មដូច្នេះផង ? ហេតុអ្វី ? ខ្ញុំមិនយល់ទេ! ខ្ញុំមិនយល់ទេ! ពិភពលោកនេះ ហេតុ អ្វីក៏អយុត្តិធម៌ម្ល៉េះ ?

និមលធ្លាប់ឆ្លងកាត់នូវការឈឺចាប់ ដោយទណ្ឌកម្មឃោរឃៅពី ពួកយោធាខ្មែរក្រហម យ៉ាងវេទនាមហិមា ក៏គង់នាងអាចនៅទ្រាំ ទ្របាន ។ ប៉ុន្តែពេលនេះ នាងបែរជាមានអារម្មណ៍ថា នាងទ្រាំមិន បានទេ ទ្រាំនឹកការឈឺចុកចាប់ដែលគេចាប់ឪពុកនាងទៅនោះមិន បានទេ...! ធីរយើងចង់តែស្រែក ស្រែកអោយបែកអាកាសដោយ កំហឹងឈឺចាប់ ប៉ុន្តែនាងក៏មិនអាចធ្វើទៅបានឡើយ ព្រោះនាងគ្មាន សមត្ថភាពអាចកែស្ថានការណ៍អ្វីទាំងអស់នៅក្នុងប្រទេសបាន ក្រៅ តែពីប្រឹងលេបទឹកភ្នែកដ៏ក្តៅងំនោះចូលទៅក្នុងពោះវិញ ទាំងចុក ចាប់ខ្លោចផ្សាក្នុងចិត្តតែម្យ៉ាងប៉ុណ្ណោះ ។

មួយស្របក់ក្រោយមក និមលក៏ខាំធ្មេញ ហើយយកដៃជូតទឹក ភ្នែក រួចក៏ចាប់យកសេនមកកោសខ្យល់ឲ្យម្តាយរបស់នាង ដែល កំពុងសន្លប់បាត់ស្មារតីមុខស្វាយល្អក នៅលើកន្ទេលស្លឹកត្នោតយ៉ាង កណ្តាចបំផុត... ឯកំសួលព្យុះនៅតែបន្តកំសួលក្នុងបេះដូងរបស់នារី យ៉ាងខ្លាំងក្លា មិនមានស្រាកស្រាន្តបន្តិចឡើយ...

ពីរថ្ងៃកន្លងទៅ...

និមលកំពុងអង្គុយជីកដំឡូង ស្រាប់តែឃើញគុម្ពឫស្សីរង្គើ ។ នាងក៏ស្ទុះទៅរកមើល ស្រាប់តែឃើញប្អូនរបស់នាងពីរនាក់ និរន្ត និងនិស្ស័យកំពុងពួននៅទីនោះ ។ គេទាំងពីរមានរូបរាងស្គាំងស្គម ដូចអសុភ កើតដំបៅងារពេញខ្លួន មើលមិនយល់ទេ ។ មើលទៅ ជីវិតពួកគេក៏មិនប្រសើរអ្វីជាងនាងដែរ ។

- បងនិមល! ខ្ញុំនឹកម៉ែពេក ទើបលួចរត់មកផ្ទះ ។ តើខ្ញុំអាចចេញ ទៅមើលគាត់បានទេ ? (និស្ស័យសួរ)

- កុំទាន់អី! ចាំងងឹតសិន ខ្លាចពួកយោធាឃើញ គេចាប់ប្អូនធ្វើ ទោស នាំតែឈឺខ្លួនទេ (និមលខ្សិបប្រាប់វិញ)

បន្តិចមក និមលក៏គេចមកខ្ទមវិញ ទុកអោយប្អូនទាំងពីរនៅ ពួនក្នុងគុម្ពឫស្សីនោះតទៅទៀត ។

CHANBOKEO.COM

ឯមីងមណីវិញបានក្លាយជាមនុស្សគ អង្គុយធ្មឹងៗ លែងមាន វិញ្ញាណមានស្មារតី លែងនិយាយស្តីអ្វីអស់ហើយ ។ និមលឃើញ ម្តាយនាងផ្លាស់ប្តូរដូច្នេះ ក៏ភិតភ័យរបូតយំលែងចេញដែរ ។ ដោយនាងចេញមុខញឹកញាប់ ក្បែរខ្ទមរបស់ម្តាយ និមលក៏ត្រូវកង
ឈ្លបយុវជនប្រចាំភូមិម្នាក់ ចាប់នាងបាន ៖
- នែ៎! មិត្តឯងជានរណា ? មកពីណា ?
នាយឈ្លបក្មេងនោះសួរផង លើកខ្សែត្នោងវាយនិមលផង ពេលនាងកំពុងជីកដំឡូងក្រោយផ្ទះ ដើម្បីយកទៅស្ងោរឲ្យម្តាយ ពិសា ។ និមលឈឺណាស់ តែខំឆ្លើយធ្វើមិនដឹងថា ៖
- ខ្ញុំជាអ្នកស្រុក ដើរកាត់ទីនេះទៅរកបេះត្រកួន ទទួលមីងម្នាក់ នេះទៅបេះត្រកួនដែរ ហើយក៏ដួលសន្លប់នៅឯស្រែ ទើបខ្ញុំជួយ គ្រាហ៍គាត់មកដល់ខ្ទមតោកយ៉ាករបស់គាត់នេះទៅ ។ បើ មិត្តប្អូន មានការអី សួរគាត់ទៅ ម៉េចមកវាយខ្ញុំអញ្ចឹង ?
ឃើញនាងស្រដីធ្វើហី នាយឈ្លបនោះជ្រួញចិញ្ចើមហើយស្ទុះ លើកត្នោងទៅវាយវាត់មីងមណី ដែលកំពុងសម្រាន្តបិទភ្នែក លើ កន្ទេលស្លឹកត្នោតកញ្ជាស់មួយ ៖
- ហើយមិត្តមីងឯងក៏មាយាម្ល៉េះ មិនចេះម្ចាស់ការខ្លួនឯងទេ បាន ជាហៅមនុស្សចម្លែកចូលភូមិ ដោយមិនរាយការណ៍ជូនអង្គការ ?
ត្រឹមតែវាយខ្លួននាង និមលមិនតដៃទេ សុខចិត្តខាំមាត់ធ្វើចុះ ចាញ់ តែលុះដល់ឃើញគេប្រមាថម្តាយនាងដែលកំពុងឈឺសម្រាន្ត កន្ទេល និមលអត់លែងបានតែម្តង ។ នាងក៏ស្ទុះកញ្ឆក់ត្នោងពីដៃ នាយឈ្លបជំទង់នោះយ៉ាងរហ័ស ហើយយកដងត្នោងវាយក្បាល នាយនោះវិញយ៉ាងអស់ទំហឹង ដោយកំហឹងឈឺចាប់ពេញទ្រូង ៖
- យ៉ស! ថ្លើមធំហ៊ានមើលងាយមនុស្សចាស់ផង ឬអាប្រេត ? នេះ៎ ល្មមរៀនទទួលខ្លះទៅថា អានឯងនិងអាចុងថ្នោងនេះវាធ្វើឲ្យ អោយមនុស្សក្រហាយសាច់ណាស់ ដឹងទេ ? បើមិនទាន់ដឹងទេ សាកពីរបីត្នោងនេះសិនទៅ នឹងដឹងហើយ ។
និមលទើបតែបាត់បង់ឪពុកទៅ មិនទាន់បានពីរថ្ងៃស្រួលបួល ផង ស្រាប់តែមានគេមកប៉ងយាយីម្តាយនាងនៅនឹងមុខទៀត ធ្វើ ឲ្យនាងទ្រាំលែងបាន ក៏យកដងខ្សែតីមកសំពងក្បាលនាយយុវជន យោធាខ្មែរក្រហមនោះ លាន់ភ្លូសផសៗយ៉ាងញាប់ដៃ រកតែនាយ ឈ្លបនោះតដៃវិញមិនទាន់ផង ។

CHANBOKEO.COM

ថ្វីបើនិមលពិការពិតមែន តែ និមលមានចិត្តខ្លាំងណាស់ មិនព្រមចុះចាញ់អ្វីងាយៗទេ ព្រោះនាងធ្លាប់ចាញ់មកជាយូរហើយ ពេលនេះ នាងកំពុងតែដើរដល់ ក៏រឹតមួយដែលគេហៅថាដល់ ក... តដៃវិញដោយមិនខ្លាចងាប់ ។

- អ៊ុំយ ! មិត្តឯងមិនរួចខ្លួនទេ យើងនឹងសម្លាប់នាងចោល !

នាយឈ្លបជំទង់នោះក៏លើកដៃលើកជើងវាយតបតវិញ ។

កំពុងប្រវាយតប់គ្នាទៅវិញទៅមក ស្រាប់តែពួកយោធារត់ខ្មៅមីរ ពេញផ្លូវ ស្រែកកូកហៅគ្នាចេញដំណើរទៅទិសខាងលិច យ៉ាង អាសន្នក្រៃលែង ។ នាយឈ្លបក្មេងមួយរូបនោះ ក៏ព្រលែងដៃពី និមលរួចហើយរត់ចេញទៅរហ័សដូចរន្ទះ ។ និមលក៏បែរមើល តាមពួកគេទាំងងឿងឆ្ងល់ក្នុងចិត្តតែម្នាក់ឯង ព្រោះឃើញពួកនោះសម្ដែងការភិតភ័យខុសធម្មតា ។ លុះយប់បន្តិចស្រាប់តែ មានកង យោធាក្រុមថ្មីចូលមកដល់ និយាយខ្មែរប៉ែឡាំៗ ចូលមកដល់ភូមិ ប្រកាសប្រាប់អ្នកស្រុក ថា ៖

- យើងជាកងយោធាភូមិភាគនិរតី ត្រូវអង្គការចាត់តាំងមកកាន់ កាប់ភូមិនេះ ។ ចំណែកកងយោធាភូមិភាគពាយព្យ័ កំពុងត្រូវអង្គការចាត់តាំងអោយទៅបំរើនៅកន្លែងផ្សេងទៀត ។

ពេលនោះ និមលធូរទ្រូងបន្តិច ព្រោះពួកនោះជាពួកថ្មី មិន ស្គាល់អ្នកភូមិទេ ម្ល៉ោះហើយនាងក៏បញ្ជោញប្អូនអោយមកជួបម្ដាយ នាង ដោយមិនខ្លាចអ្វីតទៅទៀត ។ ទម្រាំយោធានិងកម្មាភិបាលថ្មី ឡើងចាត់ចែង និមលនិងប្អូនបាននៅបំរើម្ដាយបានមួយរយៈដោយគ្មាននរណារករឿង ។ លុះគេដើរចុះឈ្មោះធ្វើបញ្ជីថ្មី និមលក៏ភូត តាមតែដំណើរ ។ ក្រោយមកគេក៏ចាប់ប្អូនរបស់នាងទាំងពីរអោយ
ចេញទៅធ្វើកងចល័តកុមារឈានមុខជាថ្មីម្ដងទៀត ។

សំណាងល្អ ដោយពិការភាពរបស់នាង និងដោយសារម្ដាយនាងមានជម្ងឺរ៉ាំរ៉ៃនៅលើកន្ទេលផង និមលក៏បានត្រូវក្រុមយោធាថ្មីអនុញ្ញាតិអោយនាងធ្វើការនៅភូមិ ហាន់ដើមចេក កាប់ផ្ទីរ ទទាក់ កន្ទក់ដាំបាយជ្រូក ចិញ្ចឹមជ្រូកសហករណ៏តែពីរនាក់ម្ដាយនាងទៅ ។ ក្រោយមក នាងបានដំណឹងថាពួកយោធាខ្មែក្រហមខាងភូមិភាគ ពាយព្យ
ដែលធ្លាប់កាន់កាប់ភូមិត្រាងនោះពីឆ្នាំ១៩៧៥ដល់១៩៧៧
បានត្រូវពួកយោធាបដិវត្តន៍ថ្មប្រមូលយកទៅសម្លាប់ចោលអស់គ្មាន សល់ម្នាក់ឡើយ ។

CHANBOKEO.COM

ថ្ងៃមួយ មានអ្នកស្រុកម្នាក់ដែលមានកូនប្រសារជាកងយោធា បដិវត្តន៍ខ្មែរក្រហមថ្មី បានមកលួចឱ្យបប្រាប់មីងមណីថា ៖

- អ្នកអើយ! បើអាចរត់បាន អ្នកឆាប់រត់ទៅ ព្រោះពេលនេះអង្គការកំពុងតាមបោសសំអាតស្ត្រីមេម៉ាយ និងកូនចៅក្រុមគ្រួសារណា ដែលមានឪពុកត្រូវអង្គការចាប់ខ្លួនទៅនោះហើយ ។

និមលនិងមីងមណីឮដូច្នោះ ក៏មើលមុខគ្នា ក្រោយមកក៏សំរេច ចិត្តបំបែកផ្លូវគ្នាបណ្តោះអាសន្នដើម្បីរស់ ។ មីងមណីបានចេញ ទៅរកនិសានៅឯរនាម ។ ចំណែកនិមលចេញទៅរកប្អូនទាំងបី ដែលអង្គការបញ្ជូនទៅច្រូតស្រូវ នៅខាងភ្នំសំពៅ ភ្នំក្រពើ ។

មិនទាន់បានរកគ្នាឃើញផង កងទព័វៀតណាមបានចូលវាយ លុកដល់ខេត្តបាត់ដំបង ហើយក៏បានប៉ះទង្គិចគ្នាជាមួយកងទ័ពខ្មែរ ក្រហម បង្កនូវភាពចលាចលពេញទឹកពេញដីតែម្តង ។

ooooooooooooooooooooo

oooooo

o

CHANBOKEO.COM

# វគ្គទី១៥
# ទារុណដួងចិត្ត

ពាក់កណ្ដាល ខែមករាឆ្នាំ១៩៧៩...

និមលរត់តាមរកម្ដាយនៅភូមិត្រាងសាជាថ្មី ហើយក៏បានជួប ប្អូនៗម្ដងមួយៗ ដែលវិលមករកមីងមណីនៅឯភូមិត្រាង គ្រប់គ្នា រហូតដល់ជុំគ្នាវិញ បាត់តែឪពុកនាងម្នាក់ និងប្អូនចិញ្ចឹមរបស់នាង ដែលបានស្ម័គ្រចិត្តចូលធ្វើយោធានារីខ្មែរក្រហមនោះ តែប៉ុណ្ណោះ ។ ថែមទៀត មីងមណីបានផ្លាស់ប្ដូរទៅជាលែងមានសតិ ប្រក្រតីដូចគ្រា មុនៗទៀតហើយ ។ ព្រឹកណាក៏ដូចព្រឹកណា មីងមណីតែងតែ ក្រោកឡើងពីព្រហាម លីចបកាប់ដើរយំ រត់យំសំដៅវាលស្រែ ទៅកាប់កកាយគ្រប់ផ្នូរខ្មោចអនាមិកតាមវាលទាំងឡាយនោះ ដើម្បី តាមរកអដ្ឋិធាតុរបស់លោកគ្រូសុធី ឲ្យអស់ចិត្តដែលឃើចាប់...

កាលសម័យមុននោះ ពេលមនុស្សម្នាក់ត្រូវពួកទាហានខ្មែរ ក្រហមសម្លាប់ត្រង់ណា អ្នកស្រុកគ្មានសិទ្ធិអូសសពទៅបញ្ចុះនៅ ឯណាទេ ក្រៅពីកាយដីម្ដុំនោះ កប់បន្ថែមប៉ុណ្ណោះ ។ កាលដែលគេ ចាប់លោកគ្រូសុធីទៅ ពេលនោះលោកនៅធ្វើស្រែជាមួយកងចល័ត បុរសឯវាលទ្រា ខាងជើងភូមិត្រាងនិងភូមិត្រោះ ។ ម្ល៉េះហើយ មីងមណី ក៏លីចបដើរកាយគ្រប់ផ្នូរអនាមិកទាំងឡាយ ដើម្បីតាមរក គម្រោងឆ្អឹងរបស់លោកគ្រូ ។ និមលឃើញដូច្នោះក៏ផ្ដាំនិសាអោយ ជួយមើលប្អូន ហើយរត់តាមម្ដាយពីក្រោយ រាល់ព្រឹកដែរ ។

ថ្ងៃមួយ...

នៅកណ្ដាលវាលស្រែខាងជើងភូមិត្រាង...

- ម៉ែ! ម៉ែឈប់ធ្វើដូច្នេះទៅ ។ ផ្នូរអនាមិកមានច្រើនណាស់ មិន ដឹងថា មួយណាជារបស់ពុកទេ ។ ម្យ៉ាងទៀត ពុកត្រូវគេចាប់ទៅ តាំងពីខែកក្កដាឆ្នាំ១៩៧៧ មកទល់នឹងពេលនោះ ជិតមួយឆ្នាំកន្លះ ហើយ តើម៉ែធ្វើម្ដេចនឹងចំណាំសំណាកឆ្អឹងរបស់ពុកបាន ?

និមលទម្លាប់ហៅម៉ែពុក តាមការតម្រូវរបស់អង្គការរហូតដល់ ធ្លាប់មាត់ ។ កាលបើឮកូននិយាយដូច្នោះ មីងមណីឆ្លើយថា ៖

CHANBOKEO.COM

- ម៉ែស្គាល់ពុកឯងច្បាស់ណាស់ ឃើញតែលលាដ៍ក្បាលនិងធ្មេញ ម៉ែស្គាល់ភ្លាម ។ ម៉ែពិតជាមិនអស់ចិត្តទេ បើសិនណាម៉ែរកប៉ាកូន មិនឃើញ ។

មីងមណីស្រដីផង យំខ្សឹកខ្សួលផង ។ និមលអត់ទ្រាំបញ្ឈរភ្នែកមើលម្ដាយកកាយដីយ៉ាងវេទនា កណ្ដាលថ្ងៃក្ដៅ នោះមិនបាន ក៏លើកចបជួយកាប់កាយ បន្ទាប់មកក៏ជួយកប់ទៅវិញ កាលបើដឹង ថាមិនមែនជាឪពុកនាង ។ ពេលនោះ មីងមណីបោកខ្លួននឹងភ្លឺស្រែ យំខ្សឹកខ្សួលអណ្ដឺតអណ្ដក់យ៉ាងទារុណ រៀបរាប់ថា ៖

- ប្ដីសម្លាញ់! យើងរស់នៅកម្សត់កម្រនឹងគ្នា រួមសុខរួមទុក្ខជា មួយគ្នាសព្វបែបយ៉ាង...ប៉ុន្តែ ហេតុអ្វីក៏ទេវតាដាក់ទោសយើងឲ្យ បែកគ្នាដោយមិនបានលាគ្នាមួយម៉ាត់យ៉ាងដូច្នេះ ? អូនមិនអស់ចិត្ត ទេ... អូនអស់ចិត្តទេ... អូនត្រូវតែតាមរកបងអោយឃើញ... ស្លាប់ ក្ដី រស់ក្ដី សូមឲ្យអូនបានដឹងដំណឹងពីបងផង...ណាំប្ដីសម្លាញ់...!!

និមលអង្គុយអោបម្ដាយ សម្រក់ទឹកភ្នែកទាំងក្ដុកក្ដួលរំជួលចិត្ត ព្រោះយល់ច្បាស់ថាចិត្តម្ដាយនាងឈឺចាប់ខ្លាំងយ៉ាងណា... សូម្បីតែ នាងជាកូន ក៏ឈឺ...ឈឺ...ឈឺផ្សារហួតទ្រាំមិនបានទៅហើយ ដែល ជនស្លូតត្រង់ដូចឪពុកនាងបានត្រូវគេប្រហារជីវិតដោយគ្មានទោស ពៃរ៍ ។ នេះឬរបបខ្មែរក្រហម ? នេះឬរបបខ្មែររំដោះជាតិ ? តើត្រង់ណាទៅដែលបង្ហាញថា ពួកគេរំដោះជាតិ កាលបើគេបំផ្លាញ អ្វីសព្វយ៉ាងរបស់ជាតិ បំផ្លាញសូម្បីតែប្រជាពល រដ្ឋស្លូតត្រង់របស់ ជាតិរាប់លាននាក់នោះ ?

- ម៉ែ! កាត់ចិត្តខ្លះទៅណាំម៉ែ ព្រោះនៅឯផ្ទះ មានកូនម៉ែបីបួន នាក់ទៀតកំពុងរង់ចាំម៉ែត្រឡប់ទៅរកគេវិញ ។ សូមម៉ែកុំធ្វើបាប ខ្លួនអី! (និមលអង្វរម្ដាយទាំងទឹកភ្នែក)

មួយប្រយោគនោះសក្ដិសិទ្ធិណាស់ ។ គ្រាន់តែឮកូនស្រីនិយាយ ដូច្នោះ មីងងើបមុខឡើង យកដៃជូតទឹកភ្នែក ៖

- មែនហើយ! ម៉ែភ្លេចគិតពីប្អូនៗរបស់ឯងអស់រលីង ។ តោះ ជូនម៉ែទៅផ្ទះ! ទៅដាំបាយអោយពួកគេ មិនដឹងថាគេឃ្លានយ៉ាង ណាទេ សុទ្ធតែឈឺគ្រប់គ្នាយ៉ាងនេះ ។

បន្តិចមក និមលក៏លុតជង្គង់សំពះសូមទោសម្ចាស់ផ្នូរ ជំនួស ម្ដាយរបស់នាងដែលបានកាប់កកាយផ្នូរ ។ ការពិត នាងបណ្ដោយ អោយម្ដាយធ្វើដូច្នោះ គឺដើម្បីជួយលាងជម្រះភាពទារុណនៅក្នុងចិត្ត របស់មីងមណីឲ្យបានធូរស្រាល ។ បើមិនដូច្នោះទេ

CHANBOKEO.COM

មីងមណីច្បាស់ ជាក្លាយជាជនវិកលសតិយ៉ាងធ្ងន់ធ្ងរមិនខាន ព្រោះតែការព្រាត់ ប្រាសនិរាសស្វាមី ដោយឥតដំណឹង...

ក្រោយមក និសានិងនិមលក៏សំរេចចិត្តនាំម្តាយនិងប្អូន រត់ទៅ នរាតាមរកឪពុកមាជីដូនមួយដែលជាអតីតគ្រូបង្រៀន ហើយដែល ធ្លាប់មានចំណងគ្រួសារស្និទ្ធិស្នាលនឹងមីងមណី ដើម្បីសុំឲ្យបងប្អូន ចាស់ទុំជួយសម្រាលផ្លូវចិត្តមីងយើងខ្លះៗ ។ ក្រោយពីរកឪពុកមា និងគ្រួសារគាត់ឃើញ និសាក៏នៅរក្សាម្តាយនិងប្អូន ហើយនិមលក៏ ធ្វើដំណើរតាមគេតាមឯងទៅរត់ពន្ធនៅជាយដែន ដើម្បីផ្គត់ផ្គង់ គ្រួសារ ។ នាងធ្វើដំណើរទៅមកៗរកស្បៀង ធ្វើឲ្យម្តាយនិងប្អូន តក់ៗជានិច្ច ប៉ុន្តែ ដោយហេតុថានាងពិការឆ្អឹងខ្នង មិនអាចធ្វើការ ធ្ងន់បាន នាងរកស៊ីជាឈ្មួញកណ្តាលតូចតាច លើកដាក់របស់លក់ ដូរស្រាលៗ រវាងអ្នករត់ពន្ធពីថៃចូលដីខ្មែរ និងពួកដែលមកពី ភ្នំពេញឬខេត្តដទៃទៀត ដើម្បីសន្សំកំទេចមាស កំទេចប្រាក់ដែល ជាបំណែកនៃការចំណេញនោះផ្ញើទៅផ្គត់ផ្គង់ម្តាយនិងប្អូនៗ ។ កាល ជំនាន់នោះ ប្រទេសខ្មែរមិនទាន់ចាយលុយទេ ។ គេរកស៊ីដូរញដូរ ដោយកំទេចមាសនិងកំទេចប្រាក់ យ៉ាប់យ៉ឺនជាងសម័យលង្វែកទៅ ទៀត ។

ឯការរកស៊ីរត់ពន្ធអីវ៉ាន់នោះក៏ជាការប្រថុយនឹងគ្រោះថ្នាក់បំផុត ដែរ ព្រោះនិមលត្រូវដើរលុយចំការមីនផង ចោរព្រៃផង និង ការបាញ់គ្នារវាងកងទ័ពវៀតណាម ទ័ពខ្មែរក្រហម និង ទ័ពខ្មែរ សេរីការដែលទើបនឹងកទ័ពថ្មីៗនេះផង ។ មាណវីយើងបានប្រទះ នឹងគ្រោះទារុណជាច្រើនលើកច្រើនគ្រា ប៉ុន្តែនាងមិនដែលហ៊ាន ហើបមាត់និយាយប្រាប់ ឲ្យម្តាយដឹងទេ ត្បិតម្តាយរបស់នាងមាន ជម្ងឺផ្លូវចិត្តយ៉ាងធ្ងន់ធ្ងររួចទៅហើយ ដូច្នេះគាត់ពិតជាមិនអាចទទួល បានទេនូវដំណឹងមិនល្អអ្វីៗពីនាងបន្ថែមទៀត ។ និមលក៏លាក់រឿង ជីវិតទារុណទាំងឡាយរបស់នាងតែក្នុងចិត្ត មិនឲ្យនរណាដឹងម្នាក់ ឡើយ ។ មានថ្ងៃខ្លះនិមលទៅអង្គុយយំសម្រក់ទឹកភ្នែកនៅកណ្តាល វាលស្រែតែម្នាក់ឯង... លុះយំអស់ចិត្តអស់ចង់ ធូរស្បើយចិត្តបន្តិច ហើយទើបវិលត្រឡប់ចេញ មករកស៊ីរត់ពន្ធចិញ្ចឹមម្តាយនឹងប្អូនបន្ត ទៅទៀត ។

នេះឬលទ្ធផលដ៏ប្រសើររបស់របបខ្មែរក្រហមរំដោះជាតិ ? តើ ពាក្យ "រំដោះ" មានន័យថាម៉េចពិតប្រាកដ ? ហេតុអ្វីគេរំដោះជាតិ ដោយសម្លាប់ជីវិតអ្នកស្រុកស្លូតត្រង់ បំបែកពង្រាត់ក្រុមគ្រួសារ ធ្វើ

CHIANBOKEO.COM

ទារុណកម្មលើមនុស្សដូចសត្វធាតុ បំផ្លាញសាលានិងការចេះដឹង របស់មនុស្ស បំផ្លាញមន្ទីរពេទ្យដែលជាកន្លែងរក្សាសុខភាពមនុស្ស បំផ្លាញលំនៅដែលជាជំរករបស់ពលរដ្ឋ ហើយឲ្យគេទៅរស់នៅវែង វេទនាខ្លោចផ្សាតាមភ្លឺស្រែ គ្មានមុងគ្មានខ្នើយ គ្មានបាយចំអែត ទៅវិញ ? ម្នាក់ៗត្រូវគេបង្ខំឲ្យគោរពទូលអង្គការជាអាទិទេព ប៉ុន្តែ អង្គការបែរជាប្រព្រឹត្តអំពើបាបដូចប្រេតតិរិច្ឆាន លើជីវិតប្រជាពល រដ្ឋរាប់លាននាក់ជាសំណាង... នេះឬចលនាអង្គការបដិវត្តន៍ ? ពិត ជាគួរអោយព្រឺរអារពេកក្រៃ...

និមលអង្គុយយំរាល់ថ្ងៃចំពោះសោកវេទនាដែលនាងនិងគ្រួសារ បានទទួលកន្លងមកពីរបបខ្មែរក្រហម ។ ពេលនេះ នាងមិនដឹង ទេថាឪពុកនាងស្លាប់ឬក៏រស់ ? បើស្លាប់ ស្លាប់នៅឯណា ? បើរស់ តើលោករស់នៅឯណា ? ឯម្តាយរបស់នាងក៏មានជម្ងឺផ្លូវចិត្តយ៉ាង ធ្ងន់ធ្ងរ ព្រោះមិនអាចទ្រាំទ្រនឹងវិបត្តិដ៏ទារុណ ទាំងកាយទាំងចិត្ត ពី សំណាក់របបផ្តាច់ការរបស់ខ្មែរក្រហម ។ ចំណែកប្អូនៗ ក៏មានជម្ងឺ គ្រប់គ្នាទៀត ដោយកង្វះអាហារ កង្វះសំលៀកបំពាក់ កង្វះថ្នាំសង្កូវ និងកង្វះជំរក ជ្រកតាមសំយាបផ្ទះអ្នកស្រុកសប្បុរសតែប៉ុណ្ណោះ ។ មានតែនាងម្នាក់ទេដែលរឹងប៉ឹងផ្លូវចិត្តជាងគេ ថ្វីបើនាងមានពិការ ភាពផ្លូវកាយខ្លះក៏ដោយ ។

ថ្ងៃមួយ និមលបានជួបមិត្តរួមថ្នាក់ម្នាក់ដែលធ្លាប់ធ្វើកងចល័ត នៅភូមិក្តុល ។ គេបានប្រាប់នាងថា គេបានឃើញលោកគ្រូសុធីត្រូវ យោធាខ្មែរក្រហមចងបណ្តើរនៅបាត់ដំបង ព្រមជាមួយគ្រូបង្រៀន ជាច្រើននាក់ទៀត ប៉ុន្តែមិនដឹងថាពួកនោះនាំលោកទៅណាទេ ។ ពេលនោះ និមលនឹកឆ្ងល់ក្នុងចិត្តណាស់ ថាហេតុអ្វីបានជាគេចាប់ ឪពុកនាងបណ្តើរឆ្លងតំបន់អីឆ្ងាយដល់ម្លឹង ? ក្រោយមក ក៏មានអ្នក ស្រុកខ្លះមកប្រាប់មីងមណីដោយផ្ទាល់ នូវពត៌មានដូចគ្នាទៀត ប៉ុន្តែ គ្មាននរណាដឹងឡើយថា លោកគ្រូសុធីត្រូវគេនាំទៅណា...

នៅខែតុលា១៩៧៩ និមលបានដំណឹងថានៅទល់ដែន មានអង្គ ការសហប្រជាជាតិ និងកាកបាទក្រហមអន្តរជាតិមកសង្គ្រោះជន ភៀសខ្លួនតាមទល់ដែន មានចែកថ្នាំពេទ្យ និងផ្តល់ការព្យបាលដល់ អ្នកជម្ងឺដោយមិនគិតថ្លៃ ។ និមលនឹកភ្នកចង់យកម្តាយនឹងប្អូនទៅ ទីនោះ ដើម្បីទទួលការព្យាបាល ព្រោះម្នាក់ៗសុទ្ធតែមានជំងឺគ្រុន ចាញ់ មួលឈាម ហើមសាច់ និងកើតលឿង គ្រប់ៗគ្នា ។

- ម៉ែមិនទៅទេកូន! កុំបបួលម៉ែអី! ម៉ែមិនទៅចោលពុកឯងទេ!

CHANBOKEO.COM

មីងមណីឆ្លើយទាំងទឹកភ្នែក ពេលឮនាងបបួលរត់ទៅទល់ដែន ដើម្បីរកពេទ្យព្យាបាលខ្លួន ។ រំពេចនោះ ឪពុកមាជីដូនមួយរបស់ និមលខាងម្ដាយនោះ ក៏ឃាត់នាងដែរ ៖

- កុំទៅអី  និមលអើយ! តាមផ្លូវ គ្រោះថ្នាក់ណាស់! ក្មួយឯង ហាក់ដូចជាប្រថុយជីវិតពេកទេដឹង ?

- ប៉ុន្តែ យើងអាចមានសំណាងចេញទៅប្រទេសទីបីនោះផងព្រោះ ម៉ែមានបងប្អូន ដែលរស់នៅស្រុកបារាំង តាំងជំនាន់ស្រុកសំបូរ សប្បាយនោះមកម្ល៉េះ ។ យើងប្រហែលអាចរកពួកគេឃើញ ។

- តើឯងចង់ទៅបារាំងធ្វើស្អី ? ទីនេះជាស្រុកឯងដឹងឯង ម៉េចបាន ជាមិនចង់រស់នៅទៅវិញ ? (ឪពុកមាសួរ)

- ព្រោះខ្ញុំចង់ទៅរៀនបន្ត ហើយចង់ទៅព្យាបាលខ្លួនផង ។ ខ្ញុំមិន ចង់នៅពិការ ដើរប៉ុងខ្ញើចដូច្នេះមួយជីវិតទេ ហើយខ្ញុំដឹងថា ខ្ញុំ មានប្រាជ្ញ អាចរៀនបន្តនៅមហាវិទ្យាល័យបាន ។

មែនហើយ បើនិយាយពីរឿងរៀននោះ គ្មាននរណាហ៊ានមាត់ ទេ ព្រោះនិមលរៀនពូកែណាស់ ជាពិសេសដែល ពួកគេស្ញើចជាង គេនោះគឺ និមលធ្លាប់ឈឺគេងកន្ទេលរាប់ខែហើយនៅអាចប្រឡង ជាប់មធ្យមសិក្សានិទ្ទេសល្អទៀត ។ កាលនោះសូម្បីតែសិស្សដែល មានសុខភាពល្អ ក៏សឹងមិនហ៊ានលលេងនឹងនិមលងាយៗដែរ កុំថា ដល់ទៅមានជំងឺដេកកន្ទេលទៀតនោះ ។

ដោយនិមលចង់បន្តការសិក្សាខ្លាំងពេក ហើយដោយសារនាង ទទូចថាចង់ទៅព្យាបាលខ្លួនផង មីងមណីក៏បណ្ដោយអោយនាង ធ្វើ ដំណើរចេញទៅទល់ដែនខ្មែរថៃ ដែលដេញអោយនិវត្តចេញមកជា មួយនិមលដើម្បីឲ្យបានជាគ្នា ។ អ្នកទាំងពីរបានឆ្លងកាត់គ្រោះថ្នាក់ ជាច្រើនទំរាំរត់ដល់ទល់ដែន ត្រូវខ្មែរក្រហម កៀរឡើងភ្នំឆត្រអស់ ប៉ុន្មានថ្ងៃទំរាំរត់រួចមកវិញ ។ តាមផ្លូវ គេប្រទះឃើញមនុស្សស្លាប់ ដោយជាន់មីន ហើមស្អឹងពេញព្រៃ ឃើញចោរប្លន់សម្លាប់មនុស្ស ឃើញអ្នកស្លាប់ដោយអត់បាយតាមផ្លូវ... គួរឲ្យវេទនាភ្នែកណាស់ ។ លុះមកដល់ទល់ដែន អ្នកទាំងពីរក៏បានប្រទះនឹងការបាញ់ប្រហារ រវាងទ័ពវៀតណាម ទ័ពខ្មែរក្រហម ទ័ពសេរីការ និងទ័ពថៃទៀត ហើយ ។ គេនាំគ្នារត់ពីជំរំណងសាមិត ទៅជំរំគោកឲ្យង រួចហើយ ទៅជំរំណងចាន់ បន្ទាប់មកទៅជំរំចាស់ ប៉ុន្តែនៅតែគេចមិនរួចពី

CHANBOKEO.COM

ការបាញ់ប្រហារគ្នាទាំងព្រឹកទាំងល្ងាចនោះឡើយ ។ ទីបំផុត និមល
ក៏បានរត់រកឃើញក្រុមកាកបាទក្រហមអន្តរជាតិ ដែលចុះមកជួយ
សង្គ្រោះអ្នកស្រុកតាមព្រៃទល់ដែន ។ ពេលនោះ និមលត្រូវរបួស
ដោយបំណែកគ្រាប់កាំភ្លើងចំក្បាលជង្គង់ និងភ្លៅដែលជាហេតុធ្វើ ឲ្យនាងពិបាកធ្វើដំណើរណាស់ ។
លុះដល់ឡានកាកបាទក្រហម ស្រាប់តែនិវត្តន៍ចិត្ត មិនព្រមឡើងឡានកាកបាទក្រហមទៅជាមួយ
បងស្រីទេ ។ គេបែរជារត់ថយក្រោយត្រឡប់ទៅវិញ ហើយស្រែក ផ្តាំពីចម្ងាយមកថា ៖
- ខ្ញុំមិនទៅចោលម៉ែទេ ។ ខ្ញុំជាកូនប្រុស ត្រូវតែត្រឡប់ទៅជួយ
មើលម៉ែ ពេលបងមិននៅ ។

និមលអាណិតប្អូនណាស់ មិនចង់អោយគេដើរកាត់ព្រៃត្រឡប់ ទៅស្រុកវិញតែម្នាក់ឯងទេ
ប៉ុន្តែឃាត់មិនជាប់ ។ នាងក៏ស្រវាលូក
យកកញ្ចប់កំទេចមាសដែលនាងមានជាប់នឹងខ្លួនទាំងប៉ុន្មាន សំរាប់ ជាទុនរកស៊ីរត់ពន្ធនោះ
បោះអោយប្អូនប្រុសនាងទាំងអស់ ៖
- នេះ! ប្អូនយកទុកប្រើការទៅ! ចាំបងផ្តល់ដំណឹងទៅប្អូនតាម
ក្រោយពេលបងទៅដល់ជំរំអង្គការសហប្រជាជាតិ ។

រួចហើយ និមលក៏ស្ទុះឡើងរថយន្តកាកបាទក្រហម ចេញ ដំណើរទៅយ៉ាងរហ័ស
ព្រោះគ្រាប់កាំភ្លើងវាសង្ហើញជីវិតមនុស្ស តាមព្រៃខ្លាំងពេក ។ តាមផ្លូវ
និមលអង្គុយសម្រក់ទឹកភ្នែករហូត ព្រោ មិនដឹងថា នាងសម្រេចចិត្តនោះខុសឬត្រូវទេ ។
ការពិតប្អូន ប្រុសរបស់នាងទើបតែមានអាយុ១៣ឆ្នាំ មិនដឹងថាគេ មានសតិ ប្រាជ្ញគ្រប់គ្រាន់
នឹងរក្សាខ្លួនអោយទៅដល់ស្រុកវិញបាន ដោយ សុវត្ថិភាពឬក៏យ៉ាងណា ?
និមលមិនចង់រត់ចោលម្តាយនិងប្អូនៗ ឡើយព្រោះគាត់ក៏កំពុងត្រូវការនាង
អោយជួយជ្រោមជ្រែងទំនុក បំរុងគ្រួសារនៅឯស្រុកដែរ ។ ប៉ុន្តែ បើនាងមិនប្រថុយប្រថាន
នោះក៏មិនអាចជួយម្តាយនិងប្អូនបានដូចគ្នា ព្រោះម្នាក់ៗក្នុងគ្រួសារ
សុទ្ធតែជាអ្នកជម្ងឺរ៉ាំរ៉ៃធ្វើអ្វីមិនកើត ហើយគ្រួសារនាងក៏ក្រីក្រគ្មាន ទុនអ្វីនឹងចិញ្ចឹមជីវិតទេ
ក្រៅពីការរកស៊ីតក់ៗដោយកម្លាំងរៀង រាល់ថ្ងៃ បានត្រឹមម៉ាលាបក្រពះនោះប៉ុណ្ណោះ ។ ពេលនេះ
បើសិន នាងអាចមានលទ្ធភាពចេញទៅរស់នៅប្រទេសទីបី នោះនាងនឹង
អាចប្រឹងរកលុយផ្ញើម្តាយអោយបានច្រើនបំផុត ឬក៏អាចធានាយក
ម្តាយចេញទៅព្យាបាលជម្ងឺរបស់គាត់ផង ។

CHANBOKEO.COM

ជំរំខាវអ៊ីដាង ខែធ្នូ ១៩៧៩....

ពេលស្នាក់នៅក្នុងជំរំជនភៀសខ្លួន ដែលគ្រាន់តែជាវាលស្មៅ វាលព្រៃចគ្មានអ្វីទាំងអស់ និមលបានទៅជួបសមាជិកអង្គការយូអិន សុំការធ្វើជាអ្នកបកប្រែ ។ ដោយសារនាងមានរបួសផង និមលត្រូវ ចូលទៅរក្សាជម្ងឺខ្លួនឯងរាល់ថ្ងៃ ហើយចូលធ្វើការនៅរោងព្យាបាល ដែលមានតែដំបូលតតជញ្ជាំង ដើម្បីជួយបកប្រែឲ្យអង្គការយូអិន រាល់ថ្ងៃដែរ ។ ពេលនោះ នាងបានជួបនឹងជនជាតិអាមេរិកាំងម្នាក់ ដែលស្មគ្រ័ចិត្តមកធ្វើការតាមជំរំ ។ លោកមានប្រសាសន៍ប្រាប់ និមលថា បើនិមលចង់ទៅព្យាបាលជម្ងឺរបស់នាងនៅអាមេរិក នាង ត្រូវដាក់ពាក្យស្នើទៅទូតអាមេរិកាំងនៅបាំងកក ដើម្បីឲ្យគេហៅ សម្ភាសន៍ ។ បន្ទាប់មក លោកក៏នាំនាងទៅបង្ហាញប្រអប់កាកបាទ ក្រហមដែលនាងអាចផ្ញើសំបុត្រដោយមិនបាច់បង់ថ្លៃតែម រួចហើយ សប្បុរសជននោះ ក៏ត្រឡប់ទៅអាមេរិកវិញបាត់ទៅ ។

និមលក៏សរសេរសំបុត្រមួយច្បាប់ ដាក់ផ្ញើទៅទូតអាមេរិកាំង ។ សំណាងអណ្តែតរបស់និមល គ្រាន់តែនាងផ្ញើសំបុត្រមិនទាន់បាន ១០ថ្ងៃស្រួលបួលផង ស្រាប់តែមានគេមកតាមហៅនាងអោយទៅ សម្ភាសន៍ជាមួយទូតអាមេរិកាំងភ្លាមៗដែរ ។ ដោយសារការចេះ ដឹងជ្រៅជ្រះផ្នែកភាសាអង់គ្លេស និងដោយសារប្រវត្តិរបស់នាង យ៉ាងទារុណក្នុងរបបខ្មែរក្រហមដែលបន្សល់ស្លាកស្នាមរបួសលើរូប កាយរបស់នាង បញ្ជាក់ដោយសំណៅឯកសារពេទ្យកាកបាទក្រហម ជាភស្តុតាងផង និមលក៏បានទទួលការអនុញ្ញាតឲ្យទៅព្យាបាលខ្លួន នៅអាមេរិក យ៉ាងរហ័សទាន់ចិត្ត ឥតបង្អង់ឡើយ ។

ជាងពីរឆ្នាំកន្លងទៅ...

ភូមិនរា បាត់ដំបង ឆ្នាំ ១៩៨២...

និស្ស័យកំពុងអង្គុយកោសខ្យល់ អោយមីងមណីនៅសំយាបកុដិ ចាស់មួយនៅវត្តបាឡាត់ ដែលជាជំរកលំនៅរបស់មីងមណីនិងកូន តាំងពីនិមលបែកពីគាត់ទៅ ។ ព្រលប់មួយនោះ មានបុរសចំណាស់ ម្នាក់ជាអតិតគ្រូបង្រៀននៅវិទ្យាល័យអ៊ាបឃុត បានជិះម៉ូតូមកដល់ មុខកុដិលោក សួររកមីងមណី ។ មីងក៏ក្រោកទទួលបុរសនោះ ភ្លាម ។ ការពិត បុរសនោះធ្វើការជាចៅហ្វាយខែត្របាត់ដំបង បាន លួចមកជួបមីងមណីស្ងាត់ៗ ដោយមានហុចសំបុត្រមួយអោយ ទៅមីងផង រួចហើយលួចខ្សិបប្រាប់គាត់ថា ៖

CHANBOKEO.COM

- សូមអ្នកបងកុំប្រាប់នរណាអោយសោះ ថាខ្ញុំយកសំបុត្រនេះមក អោយក្រែងត្រូវទទួលទោសពីអង្គការទាំងអស់គ្នា ។

មានប្រសាសន៍រួចហើយ លោកក៏ចេញដំណើរទៅវិញយ៉ាង ប្រញិបប្រញាប់ហាក់ដូចជាមិនចង់អោយនរណាឃើញថា លោក យកអ្វីមកផ្ញើមីងមណីទេ ។ លុះបុរសនោះចេញទៅបាត់ មីងមណីក៏ ទាញសំបុត្រនោះមកអាន ស្រាប់តែឃើញត្រាតែមសហរដ្ឋអាមេរិក នៅលើស្រោម ៖

- និស្ស័យ! ទៅដើរហៅបងប្អូនមកកូន ។ ម៉ែមានការនិយាយជា មួយទាំងអស់គ្នា ។

និស្ស័យក៏ពិភាល់ចង់ដឹងថា តើសំបុត្រនោះនិយាយពីអ្វីខ្លះ ។ នាងក៏ស្ទុះរឹងតាមរកបងប្អូនភ្លាម ។ ចៃដន្យ និវត្តមិនបាននៅផ្ទះ ទេ ព្រោះគេចេញរកស៊ីនៅទល់ដែន តាំងពីនិមលចាកចេញពីគេ ទៅម្ល៉េះ ។ យូរៗទើបនិវត្តត្រឡប់មកផ្ទះម្តង ។ និស្ស័យនិងនិរន្ត កំពុងនៅរៀនបឋមសិក្សា ។ ចំណែកនិសាបានឈប់លក់នំបញ្ចុក ទៅចូលធ្វើគ្រូនៅសាលាបឋមសិក្សាវត្តគរ ។ បន្ទាប់ពីជួបជុំគ្នាហើយ មីងមណីក៏បិទទ្វារ អានសំបុត្រខ្សិបៗចែកកូនៗស្តាប់ ៖

- ជំរាបម៉ែ និងប្អូនៗ! ខ្ញុំបានមករស់នៅអាមេរិកដោយសុខ សប្បាយហើយបានចូលមន្ទីរពេទ្យព្យាបាលខ្លួនដែរ ។ ពេលនេះ ខ្ញុំបានចូលរៀននៅឆ្នាំទីពីរក្នុងមហាវិទ្យាល័យ... ខ្ញុំនឹកម៉ែនិងប្អូន ណាស់... បានសរសេរសំបុត្រជាច្រើន ផ្ញើតាមមិត្តស្គាល់គ្នាតាមជំរំ ផង ផ្ញើតាមប្រៃសណីយ៍ផង ។ ខ្ញុំសរសេរផ្ញើមួយអាទិត្យមួយច្បាប់ តាំងពីមកដល់អាមេរិក សង្ឃឹមថាម៉ែនឹងបានទទួលសំបុត្រណាមួយ ខាន បើមិនតាមប៉ុស្តិ៍ក៏តាមរយៈមិត្តភក្តិនៅជំរំដែរ ។ សូមម៉ែឲ្យ ប្អូនៗទាំងអស់ទន្ទេញអាសយដ្ឋានរបស់កូនឲ្យចាំមាត់ ។ និមល!

ថ្វីបើសំបុត្រនោះសរសេរយ៉ាងខ្លី ប៉ុន្តែមានន័យធំធេងណាស់ សំរាប់មីងមណីនិងកូនចៅ ។ មីងត្រេកអរពេករហូតដល់អង្គុយ ស្រក់ទឹកភ្នែក លែងខ្មាស់អៀននរណាទៅហើយ ព្រោះគាត់មិនដែលមានសង្ឃឹមទេ ថានឹងបានដំណឹងពីនិមលកូនស្រីរបស់គាត់ ។ ពេលនេះ ជីវិតរបស់មីងមិនខុសដើមរុក្ខជាតិដែលកំពុងត្រូវទឹក ភ្លៀងឡើងស្រស់ញញឹមវិញនោះឡើយ ។

ចំណែកប្អូនៗរបស់និមលវិញ ក៏មិនខុសពីម្តាយរបស់គេដែរ ។ ពេលនោះគេស្រម័យនឹកទៅដល់គ្រាមួយដែលពួកគេនឹងបងស្រី បានជួបជុំគ្នាវិញសាជាថ្មី ។ ថ្វីបើពេលនោះ គេមិនបានទទួលអ្វី សោះពីបងស្រីក្រៅពីសំបុត្រដ៏ខ្លីមួយច្បាប់នោះ ប៉ុន្តែ ម្នាក់ៗមាន

CHANBOKEO.COM

អារម្មណ៍រីករាយរំភើប ហាក់បីដូចជាខ្លួនជីកបានកំណប់មហាសាល មួយអញ្ចឹង ។ ម្នាក់ៗក៏មានកម្លាំងចិត្តមកវិញយ៉ាងខ្លាំងក្លា ដើម្បី តស៊ូនឹងជីវិតបន្តទៅទៀត ។

នៅសម័យនោះ ការមានទំនាក់ទំនងជាមួយសាច់ញាតិដែល នៅប្រទេសទីបី មានការលំបាកហើយរអាក់រអួលណាស់ ។ ម្យ៉ាង ទៀត រដ្ឋាភិបាលកំពុងស្កាត់មិនអោយប្រជាជនរត់ចេញពីប្រទេស ផង ម្ល៉ោះហើយ គ្មាននរណាចង់អោយនរណាដឹងទេ ថាខ្លួនមាន សាច់ញាតិនៅប្រទេសក្រៅ ព្រោះខ្លាចត្រូវរដ្ឋាភិបាលដាក់ទោស ។ មីងមណីក៏រស់នៅស្ងាត់ស្ងៀម ស្ងប់ចិត្តមកវិញ តាំងពីដឹងថា កូនស្រីច្បងរបស់គាត់បានសុខសប្បាយ ថ្វីបើគាត់នៅតែទន្ទឹងរង់ចាំ ដំណឹងពីលោកគ្រូសុធីជាស្វាមី យ៉ាងផ្សាភ្នែក ខ្លោចដួងចិត្តយ៉ាង ណាក៏ដោយ ។

ការពិត ជាងពីរឆ្នាំកន្លងទៅនេះ មីងមណីមានជម្ងឺចិត្តវិបត្តិ កាន់តែធ្ងន់ធ្ងរឡើងដោយការបាត់ដំណឹងពីកូនស្រី ។ ថ្វីបើបានដឹងពី និវត្តមកហើយថា និមលបានទទួលការសង្គ្រោះ ពីក្រុមកាកបាទ ក្រហមអន្តរជាតិទៅហើយក្តី ក៏មីងមណីនៅតែបារម្ភ ព្រោះមិនដឹង ថានាងទៅនៅជំរំណា សុខទុក្ខយ៉ាងណា ឈឺឬជា ឬក៏បានចេញទៅ ប្រទេសទីបី... ឯជីវិតមីងមណីនិងកូននៅស្រុកខ្មែរ ក៏មិនមានអ្វី គាប់ប្រសើរដែរ តាំងពីនិមលចាកចេញពីក្រុមគ្រួសារទៅ ។

នៅចំពោះព្រះភក្ត្រ័ព្រះពុទ្ធអង្គ មីងមណីអុជធូបបន់ស្រន់តែ ម្នាក់ឯងស្ងាត់ៗ ថា ៖

- សូមវត្ថុសក្តិសិទ្ធិទាំងឡាយជួយតាមថែរក្សា និមលកូនរបស់ម៉ែ អោយជួបតែសេចក្តីសុខនិងជោគជ័យគ្រប់យ៉ាង ហើយសូមអោយ យើងឆាប់បានជួបជុំគ្នាវិញផង ។

*oooooooooooooooooo*

*ooooo*

*o*

CHANBOKEO.COM

# វគ្គទី១៦
# ម្ចាស់ក្រាំងមាស
# និង ម្ចាស់ស្ពានមាស

ក្រុងភ្នំពេញ ខែធ្នូ ឆ្នាំ២០០៧...

យន្តហោះបន្ទាបខ្លួនចុះចតលើដីភ្នំពេញ ។ អ្នកគ្រូនិមលដើរ ចេញពីចំណតយន្តហោះ ដោយបេះដូងលោតកញ្ជ្រោលយ៉ាងចម្លែក ឥតឧបមា ។ នៅខាងក្រៅ ហ្វូងមនុស្សខៀវខ្វាកំពុងឈរអើតអើម ងកកចំហមាត់ រង់ចាំដំណើរភ្ញៀវដែលទើបមកដល់ ។ អ្នកគ្រូយើង ដើរកាន់ដៃដូនចាស់ម្នាក់ចេញមក ព្រមជាមួយស្វាមីនិងកូនស្រី ជំទង់មួយរូប ស្រាប់តែប្រទះឃើញ ហ្វូងអ្នកស្រុកលើកបដាមួយ ដែលសរសេរថា ៖

- សូមស្វាគមន៍ម្ចាស់ក្រាំងមាស!!

អ្នកគ្រូយើងភ្ញាក់ព្រើត មិនដឹងថាហេតុអ្វីក៏មានមនុស្សមក ទទួលក្រុមគ្រួសារអ្នកគ្រូឡើងកុះករដល់ម្លឹង ? រំពេចនោះ នារីម្នាក់ លើកកម្រងផ្កាម្លិះមកបំពាក់ជូនអ្នកគ្រូហើយស្រដីថា ៖

- ខ្ញុំឈ្មោះផលា ជាអ្នកដែលអានសៀវភៅរបស់អ្នកគ្រូគ្រប់ក្បាល ទាំងអស់ដែលបានចេញផ្សាយនៅស្រុកយើង ជាពិសេសសៀវភៅ ដែលមានចំណងជើងថា ក្រាំងមាស ។ សៀវភៅមួយក្បាលនោះ មានតម្លៃសំរាប់ខ្ញុំបំផុត ក្នុងចំណោមសៀវភៅទាំងឡាយឯទៀត ដែលអ្នកគ្រូបោះពុម្ពផ្សាយ ។

រួចហើយនាងក៏លើកដៃប្រណម្យឡើងសំពះ ថែមទាំងវាចាថា៖

- បើកុំតែបានការណែនាំនៅក្នុងសៀវភៅរបស់អ្នកគ្រូ ម្ល៉េះសមខ្ញុំ រកពន្លឺជីវិតមិនឃើញនៅថ្ងៃនេះទេ ។ ពេលនេះ ខ្ញុំបានរកឃើញ រស្មីជីវិតថ្មី លើផ្លូវជីវិតថ្មីមួយដែលប្រកបដោយជោគជ័យសព្វយ៉ាង ទើបមកសុំអរគុណអ្នកគ្រូដោយផ្ទាល់ ចំពោះការដែលអ្នកគ្រូបាន សរសេរបោះពុម្ពសៀវភៅទាំងឡាយនោះ ផ្សាយដល់កូនយើងនៅ ស្រុកខ្មែរបានអាននិងបានទទួលការចេះដឹងយ៉ាងប្រពៃ ។

អ្នកគ្រូរំភើបចិត្តណាស់ កាលបើបានទទួលនូវការស្វាគមន៍ដ៏កក់ ក្តៅពីនិស្សិតនារីមួយរូបនោះ ។ ការពិត អ្នកគ្រូយើងមានវ័យជាង

CHANBOKEO.COM

ហាសិបហើយប៉ុន្តែនៅរក្សាភាពរឹងប៉ឹងក្លាហានរហ័សរហួនមិនចាញ់
ក្មេងៗក្នុងវ័យជាងម្ភៃនោះឡើយ ។ បែរមើលទៅដូនចាស់ ដែល ធ្វើដំណើរមកជាមួយវិញនោះ
ក៏មិនមែនជានរណាក្រៅពីម្តាយរបស់ អ្នកគ្រូនិមលឈ្មោះលោកយាយមណីនោះឡើយ ។ ពេលនេះ
លោក យាយមានវ័យចិតសិបប្លាយហើយ ហើយក៏មានរូបកាយទ្រុឌទ្រោម
តាមវ័យរបស់លោកដែរ ។ ប៉ុន្តែដោយសារកម្លាំងចិត្តមុតមាំ លោក
យាយក៏ធ្វើដំណើរពីអាមេរិកមកដល់កម្ពុជាដោយសុវត្ថិភាព ។

រំពេចនោះ ហ្វូងមនុស្សក៏ស្ទុះចោមរោមបំពាក់បាច់ផ្កាដល់អ្នក
គ្រូនិមលនិងក្រុមគ្រួសារព្រមទាំងបាចផ្កាព្រោងព្រាត ព្រមជាមួយ ស្នូរទះដៃយ៉ាងរំពងអឺងកង ។
យុវជនម្នាក់ឡើងប្រកាសថា ៖

- យើងទាំងអស់ជាសិស្សនិស្សិត ជាកម្មករ ជាអ្នកស្រុកសាមញ្ញ
ដែលបានអានសៀវភៅទាំងឡាយរបស់អ្នកគ្រូគ្រប់ៗគ្នា ។ ថ្ងៃនេះ
ពួកយើងសូមចូលខ្លួនមកអរគុណអ្នកគ្រូដោយផ្ទាល់ និងសូមផ្តល់នូវ
ការគាំទ្រស្នាដៃរបស់អ្នកគ្រូតទៅទៀត ព្រោះដោយសារស្នាដៃទាំង នោះ
យើងក៏បានត្រងយកនូវគំនិតល្អៗដែលមនុស្សសាមញ្ញធម្មតា អាចទទួលយកបាន
ហើយអាចយកមកអនុវត្តន៏ក្នុងការរស់នៅ ឲ្យ ជីវិតបានជួបប្រទះនូវភាពភ្លឺត្រកាល ។
សៀវភៅទាំងនោះគឺជា កម្លាំងចិត្តយ៉ាងខ្លាំងក្លាសំរាប់ជនក្រីក្រនិងជនសាមញ្ញ ដូចពួកយើង
ទាំងឡាយនេះ និងជាកត្តាជំរុញឲ្យយើងខំប្រឹងរៀនសូត្រ ខំប្រឹង ប្រព្រឹត្តអំពើល្អ
ហើយផ្សព្វផ្សាយនូវអំពើល្អជាបន្តទៅទៀត ។

ស្នូរទះដៃក៏លាន់ឡើងសាជាថ្មី ។ អ្នកគ្រូយើងរំភើបចិត្តរហូត ដល់ស្រក់ទឹកភ្នែកមិនដឹងខ្លួន
៖

- អរគុណប្អូនៗណាស់ដែលបានមកលើកទឹកចិត្តមីងនៅពេលនេះ ! ការពិត
អ្នកដែលជាម្ចាស់សៀវភៅពិតប្រាកដនោះ គឺជាអ្នកផ្សេង ម្នាក់ទៀត មិនមែនជារូបមីងទេ ។
រូបមីងគ្រាន់តែជាលេខា កត់ ត្រាធ្វើការជូនលោកតែប៉ុណ្ណោះ ។

គ្រាន់តែឮប្រយោគនោះ មនុស្សម្នាមួយហ្វូងធំនោះ ក៏ភ្ញាក់ ក្រញាង ស្ងាត់មាត់ច្រៀបតែម្តង
ព្រោះមិនយល់សោះថាប្រសាសន៍ របស់អ្នកគ្រូមានន័យថាយ៉ាងម៉េចឡើយ ។ អ្នកគ្រូនិមលឃើញ
ដូច្នោះ ក៏មានប្រសាសន៍បន្តថា ៖

CHANBOKEO.COM

- បើអ្នកទាំងអស់គ្នាចង់ស្គាល់ សូមអ្នកទាំងអស់តាមខ្ញុំមក ព្រោះខ្ញុំបំរុងទៅគោរពលោកដល់កន្លែងហើយ ។

ទាំងអស់គ្នាពិភាល់ក្នុងចិត្តណាស់ ថាតើម្ចាស់ក្រាំងមាសពិត ប្រាកដនោះជានរណា ។ មិនយូរប៉ុន្មាន ពួកគេក៏នាំគ្នាឡើងជិះកង់ ជិះម៉ូតូ ជិះឡានធ្វើដំណើរហែហមតាមពីក្រោយរថយន្តរបស់អ្នកគ្រូ និមល ចេញទៅយ៉ាងអ៊ូអរគគ្រឹកគគ្រេង ។

មកដល់មុខមណ្ឌល ស-២១ (គុកទួលស្លែង) អ្នកគ្រូក៏បញ្ជាអោយគេឈប់ចតរថយន្តនៅទីនោះ ។ ពពួកហ្វូងក្រុមនិស្សិតនិងអ្នកដែលចង់តាមដានស្ថានការណ៍ក៏បានមកដល់បន្តកន្ទុយគ្នា ។ អ្នកគ្រូក៏ដើរទៅឈរនៅចំកណ្តាលហ្វូងមនុស្ស ហើយក៏ប្រកាសថា ៖

- ម្ចាស់សៀវភៅក្រាំងមាសពិតប្រាកដនោះ បានត្រូវទទួលទោសទារុណនៅទីនេះដោយស្នាដៃខ្មែរក្រហម នៅឆ្នាំ១៩៧៧ ។ ការពិតលោកគ្រាន់តែជាជនសាមញ្ញមួយរូប ដែលមិនព្រមកាន់អាវុធដំបង ម្តងណាឡើយក្នុងជីវិត ប៉ុន្តែខ្មែរក្រហមបែរជាខ្លាចរអារ... ខ្លាច សូម្បីតែទុកជីវិតអោយលោកក៏មិនហ៊ាន ព្រោះលោកជាមនុស្សមាន សតិប្រាជ្ញនិងការចេះដឹងឈ្លាសវៃ អាចដឹកនាំជនល្ងិតល្ងង់ឲ្យឈានទៅការមានចំណេះខ្ពង់ខ្ពស់និងអនាគតឧត្តុង្គឧត្តម ។ ចៃដន្យ ពួកខ្មែរក្រហមសម្លាប់បានតែជីវិតរបស់លោកប៉ុណ្ណោះ ប៉ុន្តែពួកគេគ្មានសមត្ថភាពអូសយកការចេះដឹង និងសតិប្រាជ្ញរបស់លោកទៅណា បានឡើយ ។ ពេលនេះ លោកក៏មានជីវិតរស់ឡើងវិញហើយ នៅក្នុងបេះដូងកូនខ្មែរជំនាន់ក្រោយជាច្រើន តាមរយៈសៀវភៅ ក្រាំងមាស ដែលមានរូបខ្ញុំជាលេខាបានកត់ត្រាទុកជូនលោក ហើយបានយកមកបោះពុម្ពផ្សាយចែកចាយជូនខ្មែរអានពេញផ្ទៃប្រទេស!
លោកក៏នៅមានសំណៅក្រាំងមាសជាច្រើនទៀត ដែលនឹងចេញ ផ្សាយជូនបងប្អូនអានគ្រប់គ្នាអានរៀងរាល់ខែ ក្នុងមួយខែមួយ សំណៅ រហូតដល់អស់ពាក្យបណ្តាំរបស់លោក ។ ពេលនេះ សូមអញ្ជើញអ្នកទាំងអស់ ដែលមានមោទនភាពចំពោះសៀវភៅក្រាំង មាស ចូលរួមជាមួយនាងខ្ញុំធ្វើការស្មឹងស្មាធមួយនាទី ដើម្បី គោរពដល់វិញ្ញាណក្ខន្ធ័ និងស្នាដៃរបស់លោក!

ទាំងអស់គ្នាក៏សង្រួមឥរិយាបថគោរពតាមភ្លាម ។ បន្តិចមក អ្នកគ្រូនិមលបានយកគម្រូសញ្ញាបត្រអនុបណ្ឌិត មួយសន្លឹក ដែល មានផ្តិតឈ្មោះ

CHANBOKEO.COM

លោកគ្រូសុធីយ៉ាងក្រឡៅ ទៅដាក់លើថាសសមួយ ហើយក៏ទាញដៃកកេះកេះ
ដុតក្រដាសនោះឡើង  ព្រមទាំងមាន
ប្រសាសន៍ថា ៖
- ថ្ងៃនេះ កូនសូមផ្ញើសញ្ញាបត្រនេះជូនចំពោះលោកប៉ាសុធី ឯ បរលោក
សូមលោកប៉ាទទួលយកពីកូនផងចុះ !

ភ្លាមនោះ ស្វាមីអ្នកគ្រូនិមលបាននិមន្តព្រះសង្ឃប្រាំពីរអង្គ មកដល់មុខមន្ទីរ ស-២១ នោះ ហើយបានធ្វើពិធីសូធ្យបង្សុកូល ដោយមានការចូលរួមពីសិស្សនិស្សិត និងអ្នកស្រុកសាមញ្ញយ៉ាងគគ្រឹកគគ្រេង ។ លោកយាយមណីឈរស្មឹងស្មាធស្ងៀមស្ងាត់បញ្ជូនអារម្មណ៍ផ្ញើទៅលោកគ្រូសុធីជាស្វាមីនៅសុគតិភព ៖
- ប្ដីសម្លាញ់! ជាង២០ឆ្នាំដែលយើងរួមរស់ជាមួយគ្នា គឺជាពេលវេលាដ៏មានតម្លៃបំផុតសំរាប់គ្រួសារយើងព្រោះខ្ញុំនិងកូនបានទទួលនូវសេចក្ដីសុខនិងសុភមង្គលពេញលក្ខណ: ។ ថ្វីបើយើងមិនមែន ជាអភិជនតែជីវិតយើងបរិបូណ៌ទៅដោយសេចក្ដីស្រឡាញ់ និង ភាពកក់ក្ដៅជាទីបំផុត ។ ពេលនេះថ្វីបើខ្ញុំនៅតែមានការឈឺចាប់ ចំពោះទារុណជីវិត ដែលគ្រួសារយើងបានទទួលពីរបបខ្មែរក្រហមក៏ដោយ ក៏អារម្មណ៍របស់ខ្ញុំបានស្ងប់វិញខ្លះៗហើយ កាលបើខ្ញុំបានដឹងថាបងបានទទួលមរណភាពនៅទីណាពិតប្រាកដ ។ ថ្ងៃនេះខ្ញុំនិងកូនសូមធ្វើបុណ្យឧទ្ទិសជូនដល់វិញ្ញាណក្ខ័ន្ធរបស់បង សូមបងទទួល យកនូវកុសលទាំងនេះកុំបីខាន ។

នៅថ្ងៃបន្ទាប់មក រូបភាពអ្នកគ្រូនិមលនិងមិត្តអ្នកអានទាំងឡាយបានចុះនៅទំព័រទីមួយនៃកាសែតជាតិខ្មែរមួយ ក្នុងអត្ថបទ ដែលមានចំណងជើងថា ៖
- ម្ចាស់ក្រាំងមាសពិតប្រាកដ បានរកឃើញហើយ !

នៅថ្ងៃដដែលនោះ អ្នកគ្រូនិមលក៏បានឡើងសម្ភាសន៍នៅ ទូរទស្សន៍ជាតិអំពីសៀវភៅក្រាំងមាស ដែលអ្នកគ្រូបានបោះពុម្ព ផ្សាយព្រមជាមួយសំណៅជាច្រើនទៀត ។ នៅឆ្នាំ២០០៦សៀវភៅ ក្រាំងមាស បានទទួលប្រិយភាពយ៉ាងគ្រាំគ្រេងពីសំណាក់មិត្តអ្នក អានរហូតដល់ត្រូវបោះពុម្ពផ្សាយជាច្រើនដងក្នុងឆ្នាំដដែលនោះ ។ អ្នកគ្រូមានប្រសាសន៍ ថា ៖
- ជីវិតមនុស្សអាចស្លាប់បាននៅគ្រប់វេលាទាំងអស់ ប៉ុន្តែឧត្ដមគតិ

CHANBOKEO.COM

របស់គេវិញនឹងមានជីវិតអមតៈ ។ ពេលនេះ ថ្វីបើម្ចាស់ក្រាំងមាស បានធ្វើមរណកាលទៅហើយក្តី ប៉ុន្តែគំនិតអប់រំល្អៗដែលលោកបាន ចែកចាយទៅកូនចៅ និងក្មេងៗទាំងឡាយ ដែលជាសិស្សរបស់ លោក នៅតែមានជីវិតនិរន្តន៍រហូតតទៅ ។ ហើយក្រាំងមាសរបស់ លោកនឹងក្លាយជាសំណៅប្រវត្តិសាវតារ កត់ត្រាឧត្តមគតិរបស់ លោកក្នុងការអប់រំខ្លួន អប់រំកូនចៅ និងអប់រំក្មេងទូទៅ ឲ្យស្គាល់ នូវតម្លៃនៃការសិក្សា តម្លៃសីលធម៌ ការដោះស្រាយបញ្ហាក្នុង គ្រួសារឬក្នុងសង្គម ដោយសតិប្រាជ្ញ ចៀសវាងការប្រើហឹង្សា ចំពោះគ្នា ការរៀនពន្លត់កំហឹងក្នុងចិត្ត ការមានអាធ្យាស្រ័យចំពោះ គ្នា ការរក្សាសន្តិសុខសង្គមដោយរក្សាសន្តិសុខក្នុងគ្រួសារ ការរក្សា សន្តិសុខគ្រួសារដោយរក្សាលំនឹងក្នុងចិត្តបុគ្គល... ជាដើម ។ ជា ពិសេសក្រាំងមាសមួយនេះ នឹងក្លាយជាប្រភពកម្លាំងចិត្តដល់អ្នក រងគ្រោះនិងអ្នកក្រីក្រទាំងឡាយ មិនអោយលះបង់សេចក្តីសង្ឃឹម ក្នុងជីវិតរបស់គេឡើយ ។

អ្នកគ្រូនិមលនិងស្វាមីបាននាំលោកយាយមណីទៅជួបអ្នកស្រុក នៅភូមិត្រាងទាំងឡាយដែលធ្លាប់បានធ្វើអំពើល្អមកលើក្រុមគ្រួសារ របស់នាងកាលពីសម័យខ្មែរក្រហម ហើយបានចែកអំណោយដល់ ចាស់ៗទាំងនោះ ដើម្បីជាសគុណលើកកម្លាំងចិត្ត ព្រមទាំងបានធ្វើ បុណ្យជុំគ្នាទៀតផង ។

នៅកណ្តាលវាលស្រែមួយដែលនិមលចំណាំបានថា ជាកន្លែង ដែលនាងបានជួបឪពុកនាងជាចុងក្រោយ ធិតាបានរៀបចំអាសនៈ សែនព្រេនយ៉ាងសមរម្យ ដោយមានការចូលរួមពីស្វាមីនិងកូន លោកយាយមណី និងញាតិទាំងឡាយពីភូមិត្រាង ដើម្បីរំលឹកនូវ សេចក្តីស្រឡាញ់ និងការថ្នាក់ថ្នមរបស់ឪពុកចំពោះនាង ជាចុង ក្រោយមុនពេលដែលលោកបែកពីនាងរហូតទៅ ។

- ប៉ា! ថ្ងៃនេះ កូនបានធ្វើនូវអ្វីដែលប៉ាចង់អោយកូនធ្វើ រួចក៏ បានទទួលជោគជ័យយ៉ាងធំធេងមហិមា ។ ពេលនេះ កូនមកជំរាប ដំណឹងជូនលោកប៉ាថាបំណងប្រាថ្នារបស់ប៉ាមានរូបរាងហើយ ហើយ នឹងមានជីវិតរហូតជានិរន្តន៍តទៅ ។ សៀវភៅក្រាំងមាស និង សំណេរសិក្សាទាំងឡាយ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ដែល កូនបានសរសេរនិពន្ធដោយខ្លួនឯង បានត្រូវគេទទួលស្គាល់ គ្រប់ទី កន្លែង ទាំងនៅអាមេរិក ទាំងនៅកម្ពុជា ។ ទាំងនោះជាគំនិត ជាស្នាដៃរបស់ប៉ាទាំងអស់ ហើយកូនក៏បានក្លាយជាស្ពានមាស នាំ

CHANBOKEO.COM

ចម្លងគំនិតរបស់ប៉ាបានដល់ត្រើយ ដូចដែលប៉ាធ្លាប់គិតប្រាថ្នា នោះ ហើយ ។ ហេតុដូច្នេះ សូមប៉ាទទួលយកនូវជោគជ័យទាំងឡាយ នោះ ពីកូនស្រីរបស់ប៉ា កុំបីខាន ។

ទាំងអស់គ្នាក៏វន្ទាប្រណាម្យគោរពលោកជាចុងក្រោយ...

នៅវិទ្យាល័យអ៊ាបយុតនេតយ៉ង់ ក្រុងបាត់ដំបង...

អ្នកគ្រូនិមលនិងលោកយាយមណី បានទទួលការស្វាគមន៍យ៉ាង កក់ក្ដៅពីលោកគ្រូអ្នកគ្រូជាច្រើន មានខ្លះធ្លាប់ជាអតិតសិស្សរបស់ លោកគ្រូសុធីកាលពីសម័យមុនទៀតផង ។ បន្ថែមពីលើនោះទៅ ទៀត អ្នកគ្រូនិមលនិងក្រុមគ្រួសារក៏បានទទួលនូវការស្វាគមន៍ពី សិស្សនិស្សិតជាច្រើន ដែលបានអានសៀវភៅក្រាំងមាស និង សំណៅអត្ថបទសិក្សាដែលអ្នកគ្រូនិមលបានបោះពុម្ពផ្សាយ ។ ពួក គេបានចូលរួមធ្វើពិធីបុណ្យមួយ ដែលប្រារព្ធឡើង ដើម្បីឧទ្ទិសដល់ វិញ្ញាណក្ខន្ធ័ និងស្នាដៃបង្រៀនសិស្សរបស់លោកគ្រូសុធីដ៏ល្បី ល្បាញពីអតីតកាល ។ ក្រោយពីចប់ពិធីបុណ្យ អ្នកគ្រូនិមលបាន ដើរទៅជិតបុរសម្នាក់ឈ្មោះហុង ជាមិត្តពីកុមារភាព សព្វថ្ងៃធ្វើការ ជាសាស្ត្រាចារ្យដ៏ល្បីមួយរូប រួចអ្នកគ្រូមានប្រសាសន៍ថា ៖

- សូមអរគុណណាស់ មិត្តសម្លាញ់ ដែលបានជួយកែអក្ខរាវិរុទ្ធក្នុង សំណេរទាំងឡាយ ដើម្បីបោះពុម្ពផ្សាយសៀវភៅក្រាំងមាស ផ្សព្វ ផ្សាយពេញផ្ទៃប្រទេស ។ ពេលនេះ ខ្ញុំបានក្លាយជាស្ពានមាស ហើយមិត្តក៏ជាបង្កាន់ដៃស្ពាន ជួយចម្លងឧត្ដមគតិរបស់ឪពុកខ្ញុំឲ្យ បានដល់ត្រើយដូចបំណងរបស់លោកយ៉ាងជោគជ័យហើយ ហើយ ខ្ញុំក៏សូមអរគុណមិត្តបំផុតដែលបានជួយស្រាវជ្រាវរកឃើញឯកសារ ទាក់ទងទៅនឹងឪពុករបស់ខ្ញុំនៅគុកទួលស្លែង ។ សំណៅទាំងនោះ បានធ្វើឲ្យម្ដាយរបស់ខ្ញុំ បានកាត់ចិត្តវិញបានហើយ កាលបើលោក បានដឹងជាក់ច្បាស់ថា ឪពុករបស់ខ្ញុំបានស្លាប់ដោយរបៀបណា នៅ ទីណា ។ ពេលនេះ សំណោកទារុណដួងចិត្តរបស់ម្ដាយខ្ញុំ ដោយ ការទន្ទឹងដំណឹងពីស្វាមីទាំងបេះដូងខ្លោចផ្សាវេទនានោះ ត្រូវបិទ ទំព័រនៅថ្ងៃនេះហើយ ។ ចាប់ពីពេលនេះតទៅ ម្ដាយរបស់ខ្ញុំនឹង ទទួលភាពស្ងប់ស្ងៀមក្នុងអារម្មណ៍ ចាកផុតនូវចិត្តវិបត្តិដ៏សែន ងងឹតនោះហើយ ហើយវិលមកទទួលយកជីវិតប្រក្រតីវិញ ដើម្បី ក្លាយជាម្លប់ដ៏ត្រជាក់ដល់កូនចៅរបស់លោកគ្រប់ៗគ្នា ។

CHANBOKEO.COM

# ចប់

CHANBOKEO.COM